# សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី

# ភាគ ៣

រៀបរៀងដោយ
ក្រុមការងារនៃគ្រូបណ្តុះបណ្តាល
នៅសាលាគ្រូមិនចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ការកែសម្រួលលើការបោះពុម្ពលើកទី ១
រាជធានីភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧





ឈ្មោះឯកសារ

ប្រភេទឯកសារ

តាមស្ថាប័ន

ស្វែងរក

សូមចូលទៅកាន់គេហទំព័រក្រសួងយុត្តិធម៌
**ww.moj.gov.kh**
សម្រាប់ការស្រាវជ្រាវក្នុងវិស័យយុត្តិធម៌
១.បណ្ណាល័យវិស័យយុត្តិធម៌
២.ឯកសារច្បាប់និងបទប្បញ្ញត្តិ
៣.ស្វែងរកពាក្យគន្លឹះក្នុងច្បាប់និងបទប្បញ្ញត្តិ
ដែលកំពុងធ្វើបច្ចុប្បន្នភាពជារៀងរាល់ថ្ងៃ
សូមអរគុណ!

www.moj.gov.kh

បណ្ណាល័យ



# សេចក្តីពន្យល់
# ក្រមរដ្ឋប្បវេណី

## ភាគ ៣

រៀបរៀងដោយ

**ក្រុមការងារនៃគ្រូបង្គោល**
**នៅសាលាភូមិន្ទចៅក្រម**

ការកែសម្រួលលើការបោះពុម្ពលើកទី ១

រាជធានីភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧

បោះពុម្ពនៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍវិស័យច្បាប់ និង តុលាការ
របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ឆ្នាំ ២០១៧

សិទ្ធិអ្នកនិពន្ធ © រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ឆ្នាំ២០១៧
ISBN-13:978-99963-26-12-7

# បុព្វកថា

សៀវភៅនេះត្រូវបានចងក្រងឡើងតាមផ្នែកនៃ "**ក្រមរដ្ឋប្បវេណី**" ហើយនេះ គឺជាសៀវភៅភាគទី៣ ដែលគ្របដណ្តប់លើ ***មូលដ្ឋាននៃញាតិ និង សន្តតិកម្ម*** ។

សៀវភៅនេះ  ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទថៅក្រម  ដោយមានការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD)។

សមាជិកក្រុមការងារដែលបានធ្វើការរៀបរៀងសៀវភៅ "**ក្រមរដ្ឋប្បវេណី**" មានដូចខាងក្រោម៖

| | | |
|---|---|---|
| លោក **អ៊ិន វ៉ានវិបុល** | លោកស្រី **ចាំង ស៊ីណាត** | លោកស្រី **សែម សក្តិភូឡា** |
| លោក **សេង នាង** | លោក **ម្លង់ សំណាង** | លោក **តាំង ស៊ុនឡាយ** |
| លោក **យូ ប៊ុនណា** | លោក **ខួន រតនា** | លោក **គង់ តារាឆាត** |
| លោក **ម៉ុង មុនីសោភា** | លោក **ហួត ហ៊ាង** | លោក **ជា សុខហៀង** |
| លោក **ហេង សុខណា** | លោកស្រី **យ៉េត ម៉ូលីន** | លោក **ខួន វុទ្ធី** |
| លោកស្រី **ថ្លាង ផាណែត** | លោកស្រី **ស្រ៊ុន ឈន់វលក្ខណ៍** | លោកស្រី **ស៊ី លីនណា** |
| លោក **កេត សុជាតិ** | លោក **ច័ន្ទ រង្សី** | លោកស្រី **ខៀវ សុខា** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណារ័ត្ន** | លោក **ហេង ចន្ទស៊ីបូរិន** |
| លោក **ឆៃ វីរៈ** | លោក **អ៊ី ឋាវរៈ** | លោក **កេង សុម៉ារិទ្ធ** |
| លោក **ឈុន ច័ន្ទសីហា** | លោក **យាប់ មេត្តា** | លោក **ឆៃ វិវឌ្ឍនៈ** |
| លោកស្រី **វ៉ា សត្ថា** | លោក **សំម ឫទ្ធីវាសនា** | |

សមាជិកក្រុមការងារដែលបានរួមចំណែកក្នុងការកែសម្រួល  និង  បំពេញបន្ថែមឲ្យគ្រប់ជ្រុងជ្រោយចំពោះចំណុចសារធាតុ និង ផ្នែករដ្ឋបាលមានដូចខាងក្រោម៖

| | | |
|---|---|---|
| ឯកឧត្តម **ប៊ុន យ៉េណារិន** | ឯកឧត្តម **ម្លង់ សំណាង** | លោក **សេង នាង** |
| លោក **តាំង ស៊ុនឡាយ** | លោកស្រី **ចាំង ស៊ីណាត** | លោកស្រី **សែម សក្តិភូឡា** |
| លោក **ឆាន់ ស៊ីណា** | លោក **ចាយ ច័ន្ទតារាវណ្ណា** | លោក **យាប់ មេត្តា** |
| លោក **ខួន រតនា** | លោក **គង់ តារាឆាត** | លោក **ខួន វុទ្ធី** |
| លោក **សំម ឫទ្ធីវាសនា** | លោក **ញឹម ពិសាល** | លោក **ហេង សុខណា** |
| លោកស្រី **ថ្លាង ផាណែត** | លោកស្រី **រស់ បូផាណា** | លោកស្រី **ស៊ី លីនណា** |
| លោក **កេត សុជាតិ** | លោកស្រី **វ៉ា សត្ថា** | លោក **ឆៃ វិវឌ្ឍនៈ** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណារ័ត្ន** | លោក **ហេង ចន្ទស៊ីបូរិន** |
| លោក **ឆៃ វីរៈ** | លោក **អ៊ី ឋាវរៈ** | លោកស្រី **សុខ ឆវ័ន្ត** |
| លោក **ឈុន ច័ន្ទសីហា** | លោកស្រី **សែម សែងទេវៃ** | លោក **ណាយ សំអុល** |

និងលោក **ហាម គីរម្យ**

☆**កំណាត់សម្គាល់៖**

សៀវភៅ "**សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី**" ភាគ៣នេះ គឺជាការកែសម្រួលចំពោះសៀវភៅ "**ក្រមរដ្ឋប្បវេណី**" ភាគ៦នៃគម្រោង RSJP ក្នុងឆ្នាំ២០១២នៃកិច្ចសហប្រតិបត្តិការដំណាក់កាលទី២។

ខ្លឹមសារនៃសៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទចៅក្រម និង មិនបានឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

ការបោះពុម្ពលើកទី១នៃសៀវភៅនេះ ត្រូវបានធ្វើឡើងនៅក្នុងខែមីនា ឆ្នាំ២០១២។

ការកែសម្រួលលើការបោះពុម្ពលើកទី១នេះ មិនបានផ្លាស់ប្តូរចំណុចសារធាតុសំខាន់ៗនៃខ្លឹមសារដើមឡើយ។ ប៉ុន្តែ កំហុសអក្ខរាវិរុទ្ធជាក់ស្តែងនៅក្នុងការបោះពុម្ពលើកទី១នោះ ត្រូវបានកែតម្រូវ។ ទន្ទឹមនឹងនេះ លំដាប់លំដោយនៃជំពូកមួយចំនួនក៏ត្រូវបានផ្លាស់ប្តូរផងដែរ។ ម្យ៉ាងវិញទៀត ការកែសម្រួលនេះត្រូវបានប្រមូលផ្តុំបោះពុម្ពសាជាថ្មី ជា៣ភាគ ដើម្បីជាការងាយស្រួលដល់មិត្តអ្នកអានដោយសារតែការបោះពុម្ពលើកទី១ ត្រូវបានធ្វើឡើងជា៦ ភាគ។

សមាជិកក្រុមការងារទាំងអស់សង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះអាចនឹងជួយដល់មិត្តអ្នកអានឲ្យយល់ដឹងច្បាស់ និង ងាយសិក្សាអំពីមូលដ្ឋាននៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។

សៀវភៅ "សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី" ភាគ១ និង ភាគ២ ត្រូវបានកែសម្រួល និង បោះពុម្ពម្តងទៀតនៅខែមេសា ឆ្នាំ២០១៣។

ការកែសម្រួលលើការបោះពុម្ពលើកទី១ ដែលជាសៀវភៅ "**សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី**" ភាគ៣ នេះ ត្រូវបានបោះពុម្ពនៅក្នុងខែមីនា ឆ្នាំ២០១៧។

សៀវភៅនេះត្រូវបានកែសម្រួល និង បំពេញបន្ថែមឲ្យគ្រប់ជ្រុងជ្រោយដោយសមាជិកក្រុមការងារដែលបានរៀបរាប់ខាងលើ។ ទន្ទឹមនឹងនេះ សៀវភៅនេះក៏ត្រូវបានចូលរួមត្រួតពិនិត្យបន្ថែមយ៉ាងល្អិតល្អន់ដោយជំនាញការ JICA ចំនួន ៣រូប គឺលោក HARA Masanori លោក SHIMANUKI Masao និង លោក UCHIYAMA Jun ជាមួយនឹងការសម្របសម្រួលពីអ្នកសម្របសម្រួលគម្រោង គឺលោកស្រី KAWAKUCHI Yuko និង សហការី ២រូបជាជំនួយការផ្នែកច្បាប់ គឺលោក ៣ៀ វិសាល និង លោក ហួច ម៉េងហួរ ។

ចំពោះមិត្តអ្នកអាន

សៀវភៅនេះ ត្រូវបានចងក្រងឡើងទៅតាមផ្នែកនីមួយៗនៃក្រមរដ្ឋប្បវេណីដែលរួមមានទាំងអស់ចំនួន ៣ (បី) ភាគ។ ភាគទី១ និយាយអំពី ***មូលដ្ឋាននៃបទប្បញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស*** និង ***កាតព្វកិច្ច*** ភាគទី២ និយាយអំពី ***មូលដ្ឋាននៃកិច្ចសន្យាសំខាន់ៗ កាតព្វកិច្ចដែលកំណត់ដោយច្បាប់*** និង ***ការធានាកាតព្វកិច្ច*** និង ភាគទី៣ និយាយអំពី ***មូលដ្ឋាននៃញាតិ*** និង ***សន្តតិកម្ម*** ។

ខ្លឹមសារឯកសារមេរៀននៅក្នុងសៀវភៅ "**សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី**" ភាគទី៣នេះ ត្រូវបានបង្កើតឡើងដោយសមាជិក សមាជិកានៃក្រុមការងារដែលរួមមានគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង ត្រូវបានពិនិត្យកែសម្រួលបន្ថែមឲ្យគ្រប់ជ្រុងជ្រោយឡើងវិញដោយសមាជិកក្រុមការងារដែលជាគ្រូបណ្តុះបណ្តាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយមានការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

រាល់សិទ្ធិអ្នកនិពន្ធទាំងអស់ដែលពាក់ព័ន្ធនឹងសៀវភៅទាំងនេះ គឺជាកម្មសិទ្ធិរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

គ្មានផ្នែកណាមួយនៃឯកសារ ដែលទទួលបានការការពារដោយសេចក្តីជូនដំណឹងអំពីសិទ្ធិអ្នកនិពន្ធនេះ អាចត្រូវបានបោះពុម្ពឡើងវិញ ឬ ប្រើប្រាស់ក្នុងទម្រង់ណាមួយ ឬ តាមមធ្យោបាយផ្សេងៗ តាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬ តាមរយៈម៉ាស៊ីន រួមបញ្ចូលទាំងការថតចម្លង ការកត់ត្រាទុក ឬ ដោយប្រព័ន្ធរក្សាទុក និង ប្រព័ន្ធទទួលពត៌មានផ្សេងណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធក្នុងគោលបំណងពាណិជ្ជកម្ម ឬ ការចំណាយផលប្រយោជន៍ហិរញ្ញវត្ថុបានឡើយ។ ករណីលើកលែងគឺ សម្រាប់តែគោលបំណងស្រាវជ្រាវ បង្រៀន សិក្ខាសាលា ការសិក្សាឯកជន ឬ សម្រាប់គោលបំណងការងារ ជាងនេះទៅទៀត សៀវភៅទាំងនេះ គឺមិនមែនសម្រាប់លក់ទេ។

ការសាកសួរទាំងឡាយ ទាក់ទងនឹងការផលិតឡើងវិញនៅក្រៅពីលក្ខខណ្ឌខាងលើ អាចទំនាក់ទំនងតាមរយៈអ៊ីម៉ែល ៖ **admin@rajp.gov.kh** ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបង្ហាញពីការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការដ៏ជោគជ័យរបស់សមាជិក សមាជិកាក្រុមការងារដែលរួមមាន គ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង សមាជិក សមាជិកាក្រុមការងារដែលជាគ្រូបណ្តុះបណ្តាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ជាមួយនិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងក្លាយជាប្រទីបថ្មីមួយបន្ថែមសម្រាប់ជាជំនួយដល់ការយល់ដឹង ការសិក្សាស្រាវជ្រាវ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ ការអនុវត្ត ក៏ដូចជាការតាក់តែងច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗនាពេលអនាគត។

ភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

ប្រធានទីប្រឹក្សាផ្នែកច្បាប់
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ

Tsuji Yasuhiko

ប្រធាន
រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

បណ្ឌិតរដ្ឋ **ឈន ព្រលឹង**

# មាតិកា

**ទំព័រ**

**ជំពូកទី៨ ញាតិ** ........ 1
**ផ្នែកទី១ និយមន័យនៃញាតិ** ........ 1
១. ញាតិមានបី ប្រភេទ ........ 1
២. ទំហំនៃញាតិ ........ 1
២.១. វិធីគណនាថ្នាក់ញាតិ ........ 1
២.២.ទំហំញាតិ ........ 2
២.៣. ពាក្យពេចន៍ ........ 2
៣. ការកើតមានឡើង និង ការរលត់នូវទំនាក់ទំនងញាតិភាព ........ 2
៣.១. ការកើតមានឡើង និងការរលត់នូវទំនាក់ទំនងញាតិដោយការសុំកូន ........ 2
៣.២ ការរលត់ទំនាក់ទំនងញាតិពន្ធ ........ 3
**ផ្នែកទី២ កំដាប់ពាក្យ** ........ 4
១. អត្ថន័យ និង លក្ខខណ្ឌនៃការបង្កើត ........ 4
២. អានុភាព ........ 4
៣. អំឡុងពេលនៃការទាមទារ ........ 5
**ផ្នែកទី ៣ ឪពុកម្តាយ និង កូន** ........ 6
១. ឪពុកម្តាយ និង កូន ........ 6
២. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត ........ 6
២.១. បទប្បញ្ញត្តិទូទៅ ........ 7
២.២. ការសម្រេចអំពីបុត្តភាព ........ 7
២.២.១. មាតុភាព ........ 7
២.២.២. បិតុភាព ........ 7
២.២.៣. ការបដិសេធបិតុភាព ........ 8
២.២.៤. កថាភាគទី៣ ការទទួលស្គាល់បិតុភាព ........ 9
២.២.៤.១. ការទទួលស្គាល់ដោយស្ម័គ្រចិត្ត (មាត្រា ៩៩៣) ........ 9
២.២.៤.២. បណ្តឹងទាមទារឱ្យទទួលស្គាល់ ........ 10
២.២.៤.៣. បណ្តឹងទាមទារបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព (ការបដិសេធបិតុភាព) ........ 10
២.២.៤.៥. បណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព ........ 10
៣. សុំកូន ........ 11
៣.១. អត្ថន័យនៃរបបសុំកូន ........ 11
៣.២. សុំកូនធម្មតា ........ 12
៣.២.១. លក្ខខណ្ឌដើម្បីបង្កើតសុំកូនធម្មតា ........ 12
៣.២.១.១. លក្ខខណ្ឌទំរង់ ........ 12
៣.២.១.២. លក្ខខណ្ឌជាសារធាតុ ........ 12

៣.២.២. អានុភាពនៃស្មុំកូនធម្មតា ( មាត្រា ១០២៦, មាត្រា ១០២៧) ........................ 13
៣.២.២.១. អានុភាពនៃស្មុំកូនធម្មតា.......................................................................... 13
៣.២.២.២. អានុភាពនៃស្មុំកូនធម្មតាដែលមានវិការៈ ....................................................... 14
៣.២.៣. ការលុបចោលស្មុំកូនធម្មតា ........................................................................ 14
៣.២.៣.១. លក្ខខណ្ឌនៃការកាត់កាល់តាមការព្រមព្រៀង................................................. 14
៣.២.៣.២. លក្ខខណ្ឌនៃការកាត់កាល់តាមផ្លូវតុលាការ ...................................................... 15
៣.២.៣.៣. អានុភាពនៃការកាត់កាល់ ( មាត្រា ១០៣២) ................................................... 15
៣.៣. ស្មុំកូនពេញលេញ ......................................................................................... 15
៣.៣.១. លក្ខខណ្ឌដើម្បីស្មុំកូនពេញលេញ.................................................................... 16
៣.៣.១.១. លក្ខខណ្ឌទំរង់............................................................................................ 16
៣.៣.១.២. លក្ខខណ្ឌជាសារធាតុ.................................................................................. 16
៣.៣.២. អានុភាពនៃស្មុំកូនពេញលេញ ...................................................................... 17
៣.៣.២.១. អានុភាពនៃស្មុំកូនពេញលេញ ..................................................................... 17
៣.៣.២.២. អានុភាពនៃស្មុំកូនពេញលេញ ដែលមានវិការៈ.............................................. 17
៣.៣.៣. ការរំលាយស្មុំកូនពេញលេញ ........................................................................ 18
**ផ្នែកទី៤ ការលែងលះ**.................................................................................................. 19
១. សេចក្តីផ្តើម ................................................................................................... 19
២. ការលែងលះ មានពីរប្រភេទ ............................................................................... 19
២.១. ការលែងលះ ( ករណីមានការព្រមព្រៀង)............................................................... 19
២.២. ការលែងលះ ( ករណីគ្មានការព្រមព្រៀង) ............................................................. 19
២.២.១. មូលហេតុនៃការលែងលះ ................................................................................ 19
២.២.២. មូលហេតុរាំងការលែងលះ............................................................................... 20
២.២.៣. ការបែងចែកទ្រព្យសម្បត្តិ.............................................................................. 22
២.២.៣.១. តួនាទីនៅក្នុងបណ្តឹងសុំលែងលះ.................................................................. 22
២.២.៣.២. គោលការណ៍សមាមាត្រនៃចំណែក និង ករណីពិសេស.......................................... 22
២.២.៣.៣. វិធីបែងចែក .............................................................................................. 23
២.២.៣.៤. ទ្រព្យសម្បត្តិរួម......................................................................................... 23
២.២.៤. អំពីអំណាចមេបាលើកូន................................................................................. 23
៣. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ................................................ 25
៣.១. អ្វីទៅជាការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ? ...................... 25
៣.២.ទំនាក់ទំនងរវាងការទទួលខុសត្រូវសោហ៊ុយចំណាយ ............................................
ក្នុងពេលអាពាហ៍ពិពាហនឹងរឿងក្តីសុំលែងលះ......................................................... 26
៣.៣. វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ........ 26
៤. អនីតិសង្វាស ..................................................................................................... 27
សេចក្តីផ្តើម.............................................................................................................. 27

៩.១. អ្វីទៅជាអនីតិសង្វាស? ........ 28
៩.២. មូលហេតុនាំអោយកើតមានអនីតិសង្វាស........ 28
៩.៣. ការបង្កើតអនីតិសង្វាស........ 29
៩.៤. ការអនុវត្តមាត្រាស្រដៀងស្តីពីប្តីប្រពន្ធអនីតិសង្វាស ........
នៅក្នុងក្រមរដ្ឋប្បវេណី (អានុភាពនៃអនីតិសង្វាស) ........ 29
៩.៤.១. លក្ខណៈទូទៅ........ 29
៩.៤.២. មាត្រាពាក់ព័ន្ធដែលអាចយកមកអនុវត្តបាន ........ 30
៩.៤.៣. មាត្រាដែលមិនត្រូវយកមកអនុវត្ត ........ 31
៩.៤.៤. ការរំលាយអនីតិសង្វាស ........ 32
**ផ្នែកទី ៥ អាហារកាតព្វកិច្ច**........ 34
១. សេចក្តីផ្តើម........ 34
២.សញ្ញាណនៃអាហារកាតព្វកិច្ច........ 35
២.១. អាហារកាតព្វកិច្ច ........ 35
២.២. លក្ខខណ្ឌនៃការអនុវត្តការផ្តត់ផ្គង់អាហារកាតព្វកិច្ច........ 35
២.៣. ចរិកលក្ខណៈនៃអាហារកាតព្វកិច្ច ........ 35
៣.ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច........ 36
៣.១. សិទ្ធិទាមទារអាហារកាតព្វកិច្ច........ 38
៣.២. ការទាមទារអាហារកាតព្វកិច្ចរបស់អតីតសហព័ទ្ធ........ 39
៤. ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច........ 39
៥. កម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ........ 43
៥.១. ការពិភាក្សារវាងជនមានករណីយកិច្ចផ្គត់ផ្គង់ និងជនមានសិទ្ធិទាមទារ ........ 43
៥.២. ការកែប្រែ ផ្លាស់ប្តូរ ឬលុបចោលការផ្គត់ផ្គង់អាហារកាតព្វកិច្ច........ 44
៥.៣. ការបញ្ចប់ការផ្គត់ផ្គង់អាហារកាតព្វកិច្ច........ 44
៦. ការគណនារកចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច........ 45
៦.១. មូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច........ 45
៧. ទណ្ឌកម្មនៃការមិនផ្គត់ផ្គង់អាហារកាតព្វកិច្ច ........ 46
**ជំពូកទី ៩ សន្តតិកម្ម**........ 47
**ផ្នែកទី ១ មតកសាសន៍**........ 47
១. អត្ថន័យ និង លក្ខណៈនៃមតកសាសន៍........ 47
១.១. និយមន័យ........ 47
១.២. លក្ខណៈនៃមតកសាសន៍ ........ 47
២. សមត្ថភាពក្នុងការធ្វើមតកសាសន៍ ........ 48
៣. វិធីធ្វើមតកសាសន៍ ........ 50
៣.១. គោលគំនិត........ 50
៣.២. ប្រភេទនៃទម្រង់មតកសាសន៍........ 50
៣.២.១. វិធីធម្មតា........ 51

៣.២.១.១. មតកសាសន៍ដោយលិខិតយថាភូត (មាត្រា ១១៧៣) 51
៣.២.១.២. មតកសាសន៍ដោយលិខិតឯកជន (មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណី) 52
៣.២.១.៣. មតកសាសន៍ដោយលិខិតសំងាត់ (មាត្រា ១១៧៥) 52
៣.២.២. វិធីពិសេស 53
៣.២.២.១ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត 53
៣.២.២.២ មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ (មាត្រា ១១៧៨) 54
៣.២.៣. មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ 54
៣.២.៤. មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស 55
៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ 55
៥. ការលុបចោលនូវមតកសាសន៍ 56
៥.១. ការលុបចោលដោយមតកសាសន៍ ( មាត្រា ១១៨៩ កថាខណ្ឌទី ១) 56
៥.២. ការលុបចោលដែលច្បាប់កំណត់ 57
៥.៣. ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើការ:
ក្នុងការបង្ហាញឆន្ទៈ 58
៦. អានុភាពនៃមតកសាសន៍ 59
៦.១. អានុភាពនៃមតកសាសន៍ 59
៦.២. មោឃភាព និង ការលុបចោលនូវមតកសាសន៍ 59
៧. អច្ច័យទាន 60
៧.១. លក្ខណៈទូទៅ 60
៧.២. អច្ច័យលាភី 60
៧.៣. ការបោះបង់ ឬ ការទទួលស្គាល់នូវអច្ច័យទាន 61
៧.៤. អច្ច័យទានដែលភ្ជាប់បន្ទុក 62
៧.៤.១. ការទទួលខុសត្រូវរបស់អច្ច័យលាភី (មាត្រា ១២១១) 62
៧.៤.២. ករណីតម្លៃនៃកម្មវត្ថុត្រូវបានកាត់បន្ថយ 62
៧.៤.៣. ករណីអច្ច័យលាភីមិនបានអនុវត្តករណីយកិច្ច 63
៨. ការអនុវត្តមតកសាសន៍ 63
៨.១. អត្ថន័យនៃការអនុវត្តមតកសាសន៍ 63
៨.២. ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍ (មាត្រា ១២១៣) 64
៨.២.១. គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ 64
៨.២.២. នីតិវិធីសំខាន់ដែលត្រូវគោរពតាមមុនពេលឡើងតុលាការ 64
៨.២.៣. នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ 65
៨.២.៣.១. សមត្ថកិច្ច 65
៨.២.៣.២. ការកោះហៅសន្តតិជន ជាអាទិ៍ 65
៨.២.៣.៣. កាលបរិច្ឆេទនៃការពិនិត្យបញ្ជាក់ 66
៨.៣. អ្នកប្រតិបត្តិមតកសាសន៍ 66
៨.៣.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ 66

៨.៣.២. ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍ ... 67
៨.៣.៣. ការដាក់កម្រិតលើការទទួលស្គាល់ជនប្រតិបត្តិមតកសាសន៍ ... 68
៨.៣.៤. មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍ ... 68
៨.៣.៤.១ ការចាប់ផ្តើមបំពេញមុខងារ ... 69
៨.៣.៤.២ ការអនុវត្តមតកសាសន៍ ... 69
៨.៣.៤.៣. ការកម្រិតនូវសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់សន្តតិជន ... 70
៨.៣.៤.៤. ឋានៈ សិទ្ធិជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បន្ត ការផ្តល់កម្រៃ ជាអាទិ៍ .. 70
**ផ្នែកទី២ ការបែងចែកមត៌ក** ... 72
៩. ការបែងចែកមតិក ... 72
៩.១. ករណីមានភាពចាំបាច់ក្នុងការបែងចែកមតិក ... 72
៩.២. ការគ្រប់គ្រងមតិកមុននឹងធ្វើការបែងចែក ... 73
៩.៣. របៀបនៃការបែងចែកមតិក ... 74
៩.៤. វត្ថុសម្រាប់ជំនឿសាសនា ចេតិយ និងចលនវត្ថុ ...
ដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន ... 75
៩.៥. កាតព្វកិច្ច ... 75
៩.៦. ចំនុចគួរពិចារណា ... 76
៩.៧. ទម្រង់នៃការបែងចែកមតិកតាមការព្រមព្រៀង ... 76
**ផ្នែកទី៣ ភាគបម្រុង** ... 77
១. អ្នកមានសិទ្ធិលើភាគបម្រុង និង ចំណែកនៃភាគបម្រុង ... 77
២. ការគណនារកចំណែកនៃភាគបម្រុង ... 78
៣. ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ... 80
ក. ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ... 80
ខ. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយ ... 82
គ. លំដាប់នៃការកាត់បន្ថយ ... 86
៤. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ... 93
**ផ្នែកទី៤ ការយល់ព្រមទាំងស្រុង ការបោះបង់ និង ការយល់ព្រមដោយមានកម្រិត** ... 94
១. លក្ខណៈទូទៅ ... 94
២. ការយល់ព្រមទាំងស្រុង ... 94
៣.ការបោះបង់សន្តតិកម្ម ... 95
៣.១. គោលបំណង ... 95
៣.២. របៀបនៃការបោះបង់សន្តតិកម្ម ... 96
៣.២.១. ការដាក់ពាក្យសុំ ... 96
៣.២.២. ករណីដែលសន្តតិជនជាអនីតិជន ឬ ...
ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ... 96
៣.២.៣. ករណីដែលសន្តតិជនជាជនដែលស្ថិតក្រោមហិតូបត្ថម្ភ ... 97
៣.៣. ការដាក់កម្រិតរយៈពេលដាក់ពាក្យសុំ ... 97

៣.៣.១. វិធានទូទៅ ..... 97
៣.៣.២. ករណីសន្តតិជនទទួលមរណភាពដោយមិនបានយល់ព្រម ឬ បោះបង់ ..... 98
៣.៣.៣. ករណីដែលសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ..... 98
៣.៣.៤. ករណីដែលសន្តតិជនមិនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ច ..... 98
៣.៣.៥. ការពន្យារពេលគិតពិចារណា ..... 99
៣.៤. អានុភាព ..... 99
៣.៤.១. ដីកាសម្រេច ..... 99
៣.៤.២. អានុភាពនៃការបោះបង់សន្តតិកម្ម ..... 100
៣.៥. ការបោះបង់ និង ការគ្រប់គ្រងមត៌ក ..... 100
៤. ការយល់ព្រមដោយមានកម្រិត ..... 101
៤.១. គោលបំណង ..... 101
៤.២. វិធីក្នុងការយល់ព្រមដោយមានកម្រិត ..... 101
៤.២.១. ការដាក់ពាក្យសុំ ..... 101
៤.២.២. ករណីដែលសន្តតិជនជាអនីតិជន ឬ .....
ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ..... 102
៤.២.៣. ករណីដែលសន្តតិជនជាជនស្ថិតក្រោមហិតូបត្ថម្ភ ..... 102
៤.៣. ការកំណត់ពេលវេលានៃការដាក់ពាក្យសុំ ..... 102
៤.៤. អានុភាព ..... 102
៤.៤.១. ដីកាសម្រេច ..... 102
៤.៤.២. អានុភាពនៃការយល់ព្រមដោយមានកម្រិត ..... 103
**ផ្នែកទី៥ អវត្តមាននៃសន្តតិជន** ..... 104
១. គោលគំនិតទូទៅ ..... 104
២. លំហូរនៃនិតិវិធី ..... 105
៣. នីតិវិធី ..... 106
៣.១. មរណភាពនៃមតកជន ..... 106
៣.២. ការតែងតាំងអ្នកគ្រប់គ្រង ..... 106
៣.៣. ការជូនដំណឹងលើកទី ១ ដោយតុលាការះ ..... 107
៣.៤. ការជូនដំណឹងលើកទី ២ ដោយអ្នកគ្រប់គ្រងះ ..... 107
៣.៥. ការដកចេញពីការជម្រះ ..... 107
៣.៦. ការជម្រះ ..... 108
៣.៧. ការជូនដំណឹងលើកទី ៣ ដោយតុលាការះ ..... 108
៣.៨. ការរលត់សិទ្ធិ (មាត្រា១២៩៨) ..... 109
៣.៩. ការចែកមត៌កទៅឲ្យជនដែលមាននិស្ស័យពិសេស ..... 109
**ជំពូក ១០ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល**
**និងច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង** ..... 111
១. ទំនាក់ទំនងជាមួយនឹងក្រមនីតិវិធីរដ្ឋប្បវេណី ..... 111

ក. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 111
ខ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 111
២. វិសាលភាពនៃការអនុវត្ត ..... 112
ក. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 112
ខ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 112
៣. ការប្រៀបធៀប ..... 113
៣.១. តើអនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ .....
អាចធ្វើសកម្មភាពបណ្តឹងបានដែរឬទេ? ..... 113
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 113
ខ. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 113
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 113
៣.២. ការច្រានចោលនូវមធ្យោបាយតទល់ .....
និងការពារខ្លួនសម្រាប់ការដាក់ទៅតុលាការយឺតយ៉ាវ ..... 114
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 114
ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 114
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 114
៣.៣. តើតុលាការអាចចេញសាលក្រម ..... 114
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 114
ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 115
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 115
៣.៤. ការត្រួតពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់តុលាការ ..... 115
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 115
ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 115
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 115
៣.៥. តើតុលាការត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ដែរឬទេ? ..... 115
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 115
ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 116
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 116
៣.៦. ការផ្សះផ្សារលើបណ្តឹង ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារ ..... 116
ក. ក្រមនីតិវិធីរដ្ឋប្បវេណី ..... 116
ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ..... 116
គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ..... 116
៤. ករណីសិក្សា ..... 116
៤.១. ការលែងលះ ..... 116
៤.២. ការបែងចែកមតិក ..... 119
៤.៣. ការរំលាយស៊ុំកូនធម្មតា ..... 120

# ជំពូកទី ៨
# ញាតិ
## ផ្នែកទី ១
## និយមន័យនៃញាតិ

**១. ញាតិមាន បី ប្រភេទ**

ញាតិលោហិត ត្រូវបានបែងចែកជាបី គឺមានដូចជា ៖

- ញាតិលោហិតធម្មតា ៖ គឺជាទំនាក់ទំនងញាតិលោហិតផ្ទាល់ និង ទំនាក់ទំនងសាខាញាតិលោហិត ឧទាហរណ៍ ៖ រវាងឪពុកម្ដាយ និង កូនបង្កើត, រវាងបងប្អូនបង្កើត។

- ញាតិលោហិតដែលច្បាប់កំណត់ ៖ ញាតិលោហិតដែលកំណត់ដោយច្បាប់ អោយមានទំនាក់ទំនងដូច ញាតិលោហិតដែរ ឧទាហរណ៍ ៖ ទំនាក់ទំនងកូនស្មុំ និង ឪពុកម្ដាយចិញ្ចឹម, ទំនាក់ទំនងរវាងកូនស្មុំ និង កូនរបស់ឪពុកម្ដាយចិញ្ចឹម។

- ញាតិពន្ធ ៖ ជាទំនាក់ទំនងកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ ។

ឧទាហរណ៍ ៖ ញាតិខាងប្រពន្ធ គឺជា ញាតិពន្ធរបស់ប្ដី។

**២. ទំហំនៃញាតិ**

ដោយសារញាតិទាំងមូល វាមានលក្ខណៈទូលាយ និងមានទំហំធំ ដូច្នេះទើបក្រមរដ្ឋប្បវេណី បានកំណត់ យកតែមួយផ្នែកនៃញាតិ ដែលមានទំនាក់ទំនងជិតស្និតប៉ុណ្ណោះ តាម **មាត្រា ៩៣៨** នៃក្រមរដ្ឋប្បវេណី បុគ្គលដែលបានកំណត់ជាញាតិ មានដូចជា:

- ញាតិលោហិត ៦ ថ្នាក់
- ញាតិពន្ធ ៣ ថ្នាក់
- សហព័ទ្ធ

**២.១ វិធីគណនាថ្នាក់ញាតិ**

**ក.** ការគណនាថ្នាក់ញាតិផ្ទាល់ ៖ ថ្នាក់ញាតិត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ។

**ខ.** ការគណនាថ្នាក់សាខាញាតិ ៖ ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិត ចាប់ពីជននោះ ឬ សហាព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត។

### ២.២ ទំហំញាតិ

យោងតាមមាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណី បុគ្គល ដែលបានកំណត់ជាញាតិ គឺ៖

- ញាតិលោហិត ៦ ថ្នាក់
- ញាតិពន្ធ ៣ ថ្នាក់
- សហាព័ទ្ធ

### ២.៣ ពាក្យពេចន៍

**ក.** ញាតិផ្ទាល់ ៖ គឺជាញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុកម្ដាយ និងកូន។

**ខ.** សាខាញាតិ ៖ ញាតិដែលមានបុព្វជនរួមគ្នា ដូចជាបងប្អូនបង្កើត បងប្អូនជីដូនមួយ ឬ បងប្អូនជីទួត មួយ។

**គ.** បុព្វញាតិ ៖ ជនដែលស្ថិតក្នុងលំដាប់ថ្នាក់ញាតិខ្ពស់ជាងខ្លួន។

**ឃ.** បច្ឆាញាតិ ៖ ញាតិក្រោយ ឬ ជនដែលកើតពីជនមួយពួកទៀត។

**ង.** ញាតិពន្ធ ៖ ចំណងគតិយុត្តរវាងសហាព័ទ្ធម្ខាង និងញាតិលោហិត របស់សហាព័ទ្ធម្ខាងទៀត ដូចជា ឪពុក ម្ដាយក្មេក និង កូនប្រសារ។

## ៣. ការកើតមានឡើង និង ការរលត់នូវទំនាក់ទំនងញាតិភាព

### ៣.១ ការកើតមានឡើង និងការរលត់នូវទំនាក់ទំនងញាតិដោយការសុំកូន

ទំនាក់ទំនងចំពោះការសុំកូន មិនមានទំនាក់ទំនងទៅដល់ញាតិដទៃផ្សេងទៀតរបស់កូនដែលត្រូវបានសុំទេ ប៉ុន្តែ វានាំអោយមានទំនាក់ទំនងចំពោះញាតិដោយចំណងអាពាហ៍ពិពាហ៍ និងកូនចៅរបស់អ្នកសុំកូន។

ដោយសារកូនសុំ មានទំនាក់ទំនងញាតិដូចកូនបង្កើត ដូច្នេះហើយនាំអោយកូនសុំ ក៏មានឋានៈស្មើរនឹងកូន បង្កើតដែរ (មាត្រា ៩៤០នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែទំនាក់ទំនងនេះវាត្រូវរលត់ទៅវិញ បើកូនចិញ្ចឹមនោះ ត្រូវបានកាត់កាលចោល ឬ លែងទទួលស្គាល់ តាមមាត្រា ៩៤២នៃក្រមរដ្ឋប្បវេណី។

ផ្ទុយទៅវិញបើកូនសុំ មានប្រពន្ធកូន ក្រោយការសុំ នោះទំនាក់ទំនងញាតិដោយការសុំ មានតែចំពោះបុគ្គលដែលបានសុំប៉ុណ្ណោះ។

**៣.២ ការរលត់ទំនាក់ទំនងញាតិពន្ធ**

- តាមរយៈការលែងលះ មាត្រា៩៨១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ៖ ពេលសហព័ទ្ធត្រូវបានលែងលះ ឬ ផ្តាច់ចំណងអាពាហ៍ពិពាហ៍ ទំនាក់ទំនងញាតិពន្ធ ក៏ត្រូវរលាយដែរ ព្រោះទំនាក់ទំនងនេះ កើតឡើងដោយសារចំណង អាពាហ៍ ពិពាហ៍ ដូច្នេះបើចំណងអាពាហ៍ពិពាហ៍ ត្រូវរលាយ នាំអោយទំនាក់ទំនងក៏ត្រូវរលាយដែរ។

- តាមរយៈសហព័ទ្ធម្ខាងស្លាប់ មាត្រា៩៨១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ៖ ករណីសហព័ទ្ធម្ខាងស្លាប់ ហើយសហព័ទ្ធ ម្ខាងទៀតនៅរស់មិនទាន់រៀបអាពាហ៍ពិពាហ៍ថ្មី នោះទំនាក់ទំនងរវាងញាតិពន្ធ ក៏មិនទាន់រលាយដែរ ប៉ុន្តែសហព័ទ្ធ ម្ខាងទៀតនៅរស់ ក៏អាចដាក់ពាក្យស្នើរសុំឲ្យបញ្ចប់ចំណងញាតិពន្ធបានដែរ ដោយមិនចាំបាច់រៀបអាពាហ៍ពិពាហ៍ថ្មី។

# ផ្នែកទី ២
# កំជាប់ពាក្យ

តាមទំនៀមទំលាប់ប្រទេសជាច្រើន ក៏ដូចជាប្រទេសកម្ពុជា មុនឈានដល់ការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គឺតែងតែឆ្លងកាត់ពិធីកំជាប់ពាក្យ នៅក្នុងករណីជាច្រើន។

ទោះបីជាក្រមរដ្ឋប្បវេណី មិនបានតំរូវឲ្យមានកំជាប់ពាក្យនៅមុនការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ដោយ ក៏វាត្រូវមានអានុភាពតាមផ្លូវច្បាប់ នៅពេលដែលកំជាប់ពាក្យនោះ ត្រូវបានធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

## ១. អត្ថន័យ និង ល័ក្ខខ័ណ្ឌនៃការបង្កើត

មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី បានចែងថា គឺជាសេចក្តីសន្យារវាងបុរស "កំជាប់ពាក្យ" ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ។ តាម និង នារី ន័យនៃមាត្រានេះ បុរស និង នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចបង្ហាញឆន្ទៈដោយសេរីក្នុងការបង្កើតកំជាប់ពាក្យ ហើយបើគ្រាន់តែមានសេចក្តីសន្យារវាងបុរស និង នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលខាងមុខ វា មិនគ្រប់គ្រាន់នៅឡើយទេ។ ដើម្បីឲ្យកំជាប់ពាក្យមានសុពលភាពនោះ វាចាំបាច់ត្រូវមានធ្វើពិធីកំជាប់ពាក្យតាមប្រពៃណីបន្ថែមទៀត។

## ២. អានុភាព

ជាទំលាប់ នៅពេលមានពិធីកំជាប់ពាក្យ គឺតែងតែមានការជូនជាជំនូន អាចភាគីខាងប្រុសជាអ្នកជូន ឬក៏ អាចភាគីខាងស្រីជាអ្នកជូនដែរ។ ជំនូននៅទីនេះ អាចជាប្រាក់កាស និង ជាទ្រព្យផ្សេងៗ។ កំជាប់ពាក្យ ត្រូវបានបង្កើត ក៏ប៉ុន្តែដោយសារហេតុផលអ្វីមួយ ធ្វើអោយកំជាប់ពាក្យត្រូវរលាយទៅវិញ តើការរលាយនៃកំជាប់ពាក្យ នេះ មានអានុភាពយ៉ាងណាដែរ ចំពោះគូភាគី?

**ក.** ភាគីអាចទាមទារឲ្យសងជំនូន៖ ភាគី ដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយការសង្ឃឹមថា ខ្លួននឹងបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែកំជាប់ពាក្យត្រូវបានរលាយទៅវិញ ភាគីនោះ អាចទាមទារអោយភាគីម្ខាងទៀត សងជំនូនមកវិញបាន(មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី)។ តាមខ្លឹមសារនៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីនេះ ទោះបីជាភាគី ដែលលើកជំនូនមានកំហុស ឬ គ្មានកំហុសក្នុងការរលាយកំជាប់ពាក្យក៏ដោយ ក៏ ភាគីនោះអាចទាមទារអោយភាគីម្ខាងទៀតសងជំនូនមកវិញបានដែរ។

**ខ.** ភាគី អាចទាមទារឲ្យសងសំណងនៃការខូចខាត៖ កំជាប់ពាក្យ គឺជាដំណើរការសង្គម ដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វីដែល គ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ហេតុដូចនេះ បើចេះតែឲ្យភាគីអាចរំលាយកំជាប់ពាក្យបាន ដោយសេរី ទោះបីជាភាគីដែលសុំរំលាយ មានកំហុស នោះវាអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និង ទំនៀមទំលាប់ល្អរបស់សង្គម ដូចនេះ ទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តិ មាត្រា ៩៤៦ នៃក្រមរដ្ឋ ប្បវេណី ដែលដាក់កំរិតចំពោះភាគីដែលមានកំហុសក្នុងការរំលាយកំជាប់ពាក្យ ត្រូវទទួលខុសត្រូវ ចំពោះសំណងនៃការខូចខាត។ វាមានន័យថាបើភាគីម្ខាងបដិសេធកំជាប់ពាក្យដោយគ្មានមូល ហេតុត្រឹមត្រូវ ភាគីម្ខាងទៀតនៃកំជាប់ពាក្យ អាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការបដិសេធ ចោលនោះបាន ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល។

**៣. អំឡុងពេលនៃការទាមទារ**

ការទាមទារអោយសងជំនួន (មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី) និង ការទាមទារសំណងនៃ ការខូចខាត (មាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី) អ្នកដែលមានបំណងទាមទារ ត្រូវដាក់ពាក្យបណ្តឹង ទៅតុលាការ ក្នុងអំឡុងពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃកំជាប់ពាក្យបានរលាយ។

ករណីសិក្សា៖

ក បានភ្ជាប់ពាក្យជាមួយ ខ ដោយ ក បានជូនឡានម៉ាកកាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លារ ជាជំនូនក្នុងពិធីកំជាប់ពាក្យនោះ។ បន្ទាប់ពីកំជាប់ពាក្យបានរយៈពេល ១ខែ ស្រាប់តែ ខ ដឹងថា ក មានប្រពន្ធហើយ ខ និង ក ក៏មានការឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងរហូតព្រម ព្រៀងគ្នារំលាយកំជាប់ពាក្យ។ ក្រោយពីរលាយកំជាប់ ពាក្យ ក ក៏ដាក់ពាក្យបណ្តឹងទៅតុលាការ ទាមទារជំនូន (ឡានម៉ាកកាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លារ) ពី ខ មកវិញ ហើយ ខ ក៏បាន ដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតពី ក ដែរ។ តើ ក អាចទាមទារជំនូនបាន ដែរ ឬ ទេ? ហើយតើ ខ អាចទាមទារសំណងការខូចខាតបានដែរ ឬ ទេ?

ចំលើយ៖

តាមមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី នៅពេលកំជាប់ពាក្យបានរលាយ ក អាចប្តឹងទាមទារ ឡានម៉ាក កាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លារ ពី ខ បាន។

តាមមាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី នៅពេលកំជាប់ពាក្យបានរលាយ ខ អាចប្តឹងទាមទារ សំណងការខូចខាតពី ក បាន។

# ផ្នែកទី ៣
# ឪពុកម្តាយ និង កូន

ទំនាក់ទំនងឪពុកម្តាយ និងកូន គឺជាទំនាក់ទំនងរវាងមនុស្សប្រុស និង មនុស្សស្រីនៅក្នុងគ្រួសារ ដែលជាកោសិកាតូចៗនៅក្នុងសង្គម ។

**១. ឪពុកម្តាយ និង កូន**

ទំនាក់ទំនងឪពុកម្តាយ និង កូននេះត្រូវបានបែងចែកជាពីរប្រភេទ គឺៈ

**ក.** ទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និង កូនបង្កើត

**ខ.** ទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និង កូនសុំ

**២. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត**

ជាសត្យានុម័ត ដើម្បីមានកូនបានលុះត្រាតែមានឪពុក និងម្តាយ ជាអ្នកបង្កើតកូន ទើបកូននោះអាចកើតមានរូបរាងឡើងបាន ។

តើអ្នកណាជាឪពុកម្តាយរបស់កូន ? តើត្រូវកំណត់ដោយផ្អែកលើអង្គហេតុអ្វីខ្លះ ?

ឪពុកម្តាយរបស់កូន គឺជាបុរស និង ស្ត្រីដែលបានបង្កើតកូន។ ចំពោះម្តាយ មានភាពងាយស្រួលក្នុងការកំណត់ ព្រោះម្តាយ គឺជាអ្នកបង្កើតកូនដោយផ្ទាល់ ឯឪពុកវិញ មានភាពលំបាកជាងម្តាយក្នុងការកំណត់ភាពជាឪពុកនេះ ព្រោះឪពុកមិនមែនជាអ្នកបង្កើតកូនដោយផ្ទាល់នោះទេ ដូច្នេះ ក្រមរដ្ឋប្បវេណីកំណត់អំពីទំនាក់ទំនង ឪពុក និង កូន ដោយផ្អែកលើទំនាក់ទំនងម្តាយ និង កូន ឬ ដោយផ្អែកលើការទទួលស្គាល់ពីបុរសនេះ។

ល័ក្ខខ័ណ្ឌ និង អង្គហេតុដែលអាចកំណត់ពីភាពជាឪពុកបានៈ

**ក.** ជាដំបូង គេត្រូវពិនិត្យមើលពីទំនាក់ទំនងរវាងម្តាយ និង កូនសិន បន្ទាប់មកទើបគេពិនិត្យពីទំនាក់ទំនងរបស់បុរសជាមួយស្ត្រីដែលជាម្តាយនោះ រួចទើបអាចកំណត់ និង សន្មតបានថាបុរសនោះ ជាឪពុករបស់កូននោះ។

**ខ.** មានការទទួលស្គាល់ពីបុរសដែលជាឪពុកដោយផ្ទាល់ ហើយនិងមានការយល់ព្រមពីស្ត្រីជាម្តាយផងដែរ ទើបអាចកំណត់ និង សន្មតបានថាបុរសនោះគឺជាឪពុករបស់កូន។

## ២.១ បទប្បញ្ញត្តិទូទៅ

### ការសុំចុះសំបុត្រកំណើត

ក្រមរដ្ឋប្បវេណី មាត្រា ៩៨៥ បានចែងថា ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះសំបុត្រកំណើតរបស់កូន នៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃដែលកូននោះកើត។ ប្រសិនបើឪពុក ឬ ម្តាយ មិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូន ត្រូវសុំចុះសំបុត្រកំណើតរបស់កូននោះ ឲ្យបានឆាប់រហ័ស ។

ក្នុងករណីដែលឪពុកម្តាយធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី ១ ខាងលើដោយគ្មានមូលហេតុត្រឹមត្រូវ ពួកគាត់នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០,០០០៛ (មួយម៉ឺន រៀល)។

## ២.២ ការសម្រេចអំពីបុត្តភាព

### ២.២.១ មាតុភាព

ក្រមរដ្ឋប្បវេណីមាត្រា ៩៨៧ បានចែងថា ស្រ្តី ដែលបានសម្រាលកូន គឺជាម្តាយរបស់កូន។ ក្នុងស្មារតីនៃមាត្រានេះ ចង់បញ្ជាក់អំពីភាពច្បាស់លាស់មួយ ដែលមិនអាចប្រកែកបាន ហើយមានលក្ខណៈសមហេតុផលបំផុត ដូច្នេះ អង្គហេតុមួយដែលស្ត្រីជាម្តាយបានសម្រាលកូន គឺកូននោះឯងត្រូវតែជាកូនរបស់ស្ត្រីនោះ។ ហើយម៉្យាងទៀត ចំពោះអង្គហេតុសម្រាលកូននេះ មិនត្រឹមតែអាចកំណត់អំពីចំណងមាតុភាពដែលកើតដំណាលពេល និង ចំណងបុត្តភាពនោះទេ អាចឲ្យគេនឹកឃើញពីចំណងបិតុភាពផងដែរ ចំពោះបុរសដែលមានទំនាក់ទំនងនឹងម្តាយនោះ។

ការកំណត់ក្នុងមាត្រានេះដែលលើកពីអង្គហេតុសម្រាលកូនក្នុងការសន្មតអំពីមាតុភាព អាចនឹងមានបញ្ហានាពេលអនាគតផងដែរ ប្រសិនបើការសម្រាលកូនតាមបែបសិប្បនិម្មិតបង្កើតឡើងតាមរយៈបច្ចេកវិទ្យា ដោយបុរស និង ស្ត្រី បានព្រមព្រៀងយកមេជីវិតរបស់ខ្លួនឲ្យទៅស្ត្រីផ្សេងជាអ្នកពរពោះជំនួស ដូច្នេះគឺវាផ្ទុយនឹងមាត្រានេះដែលនិយាយអំពីការសន្មតមាតុភាព។ ក៏ប៉ុន្តែ បញ្ហានេះយើងនឹងមិនធ្វើការបកស្រាយលម្អិតឡើយ ដោយសារតែប្រទេសខ្លះបដិសេធមិនឲ្យមានការសម្រាលកូនតាមបែបសិប្បនិម្មិតនេះ ហើយស្ថានភាពនៅប្រទេសកម្ពុជាក៏មិនទាន់មាន និង ក៏មិនមែនជាបញ្ហាចំពោះមុខដែរ ។

### ២.២.២ បិតុភាព

ក្រមរដ្ឋប្បវេណីមាត្រា ៩៨៨ បានចែងថាៈ

**១.** ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។

**២**. កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាមានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។

**៣**. ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានបង្កើតកូន ផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និង ទី២ ខាងលើនេះទេ ត្រូវសន្មតថាកូនជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ ។

កថាខណ្ឌទី១ នៃមាត្រានេះ ចែងអំពីការមានគភ៌របស់ប្រពន្ធ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្ដី ។

មូលហេតុដែលកំណត់ដូច្នេះ គឺមានន័យថា ដោយសារតែប្ដី និង ប្រពន្ធ បានធ្វើការរួមរស់នៅជាមួយគ្នា ដែលប្ដី និង ប្រពន្ធនោះបានរួមរក្សគ្នាក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ។

ដោយផ្អែកលើគោលការណ៍នេះទើបប្រើពាក្យ ប៉ុន្តែប "សន្មត" ើមានករណីដែលឪពុកមានការអះអាងផ្សេងដែលបង្ហាញថាខ្លួនមិនមែនជាឪពុក បុរសនោះអាចដាក់ពាក្យសុំបដិសេធបិតុភាពទៅតុលាការបានដោយផ្អែកលើ ការបដិសេធបិតុភាពក្នុងមាត្រា ៩៨៩ នៃក្រមរដ្ឋប្បវេណីបាន ។

ឧទាហរណ៍ ៖ ឆ្នាំ ១៩៤៦ **ក** និង **ខ** រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា

១៩៤៩ **ក** និង **ខ** បានរស់នៅបែកគ្នា

១៩៥០ **ខ** និង **គ** មានទំនាក់ទំនងផ្លូវភេទជាមួយគ្នា

១៩៥១ **ខ** បង្កើតបានកូន **ឃ** ម្នាក់

១៩៥២ **ក** និង **ខ** បានលែងលះគ្នា

នៅក្នុងករណីនេះ ទោះបី **ក** និង **ខ** បានរស់នៅបែកគ្នាក៏ដោយ ហើយ ទោះបីជាឈាមរបស់ **ក** និង **ឃ** ខុសគ្នាក៏ដោយ តើលោក លោកស្រី គួរសន្មតដោយផ្អែកលើមាត្រា ៩៨៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ថា **ក** ជាឪពុករបស់ **ឃ** បានដែរឬទេ ?

## ២.២.៣ ការបដិសេធបិតុភាព

- ការបដិសេធបិតុភាពមានចែងក្នុងមាត្រា ៩៨៩
- វិធីបដិសេធបិតុភាពមានចែងក្នុងមាត្រា ៩៩០,៩៩១
- អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពមាត្រា ៩៩០ កថាខណ្ឌទី១ និង មាត្រា ៩៩១ កថាខណ្ឌទី ៣
- អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាពមាត្រា ៩៩២

### ២.២.៤ កថាភាគទី៣ ការទទួលស្គាល់បិតុភាព

#### ២.២.៤.១ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត (មាត្រា ៩៩៣)

ឪពុករបស់កូន អាចទទួលស្គាល់កូននោះបាន។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

ក្នុងស្មារតីមាត្រា ៩៩៣នេះ ការទទួលស្គាល់ដោយស្ម័គ្រចិត្តអាចធ្វើបាន ប៉ុន្តែមិនអាចធ្វើបានឡើយ ក្នុងករណីដែលកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ដោយយោងតាមមាត្រា ៩៩៨ កថាខណ្ឌទី ១។

មានន័យថា ការទទួលស្គាល់នេះ ទោះបីជាធ្វើឡើងដោយឪពុកបង្កើតរបស់កូននោះក៏ដោយ ក៏មិនអាចធ្វើបានដែរ។

ឧទាហរណ៍ ៖ **ក** ត្រូវបានសន្មតថាជាឪពុករបស់ **ឃ** ដែលមាន **ខ** ជាម្តាយ។ ក្រោយមក **គ** បានអះអាងថា ខ្លួនជាឪពុករបស់ **ឃ** ហើយមានបំណងចង់ទទួលស្គាល់កូននោះ។

ករណីនេះអាច៖

**ឃ** អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ **ក** បាន

**ខ** អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ **ក** បាន

ប៉ុន្តែ **គ** មិនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ **ក** បានទេ ប្រសិនបើ **ឃ** និង **ខ** មិនដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ **ក** ។

**ស្តីពីការទទួលស្គាល់កូន**

**ក.** កូនជាអនីតិជន៖ ឪពុកអាចទទួលស្គាល់កូនជាអនីតិជនបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកណាឡើយ។(មាត្រា ៩៩៥ កថាខណ្ឌទី១)

**ខ.** ទារកនៅក្នុងគភ៌៖ ឪពុកអាចទទួលស្គាល់ទារកនៅក្នុងគភ៌ថាជាកូនបាន លុះត្រាតែមានការយល់ព្រមពីម្តាយរបស់កូននោះ ។(មាត្រា ៩៩៥ កថាខណ្ឌទី២)

**គ.** កូនជានីតិជន៖ ឪពុកអាចទទួលស្គាល់កូនជា អានីតិជនបាន លុះត្រាតែមានការយល់ព្រមពីកូននោះ។ (មាត្រា ៩៩៦ កថាខណ្ឌទី១)

នីតិវិធី និង ទម្រង់នៃការទទួលស្គាល់កូនមានចែងក្នុងមាត្រា ៩៩៧ កថាខណ្ឌទី១ ដែលបានបញ្ញត្តិថា៖

**ក.** ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្រ្តីអត្រានុកូលដ្ឋាន។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍បានដែរ ។

**ខ.** ការយល់ព្រមរបស់ម្ដាយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបានដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ។

អានុភាពនៃការទទួលស្គាល់កូនមានចែងក្នុងមាត្រា៖

- មាត្រា ៩៩៨ អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើត និងការទទួលស្គាល់

- មាត្រា ៩៩៩ អានុភាពប្រតិសកម្មនៃការទទួលស្គាល់

- មាត្រា ១០០០ ការហាមឃាត់មិនឲ្យដកការទទួលស្គាល់ចេញ

(ន័យក្នុងមាត្រា ១០០០ នេះប្រើបានត្រឹមតែអាជ្ញាធរប៉ុណ្ណោះ គឺឪពុកដែលបានទទួលស្គាល់កូនហើយ មិនអាចដកការទទួលស្គាល់នោះបានទេ តែបើឪពុកនោះដាក់ពាក្យបណ្ដឹងទៅតុលាការនោះអាចដកការទទួលស្គាល់នោះបាន ប្រសិនបើមានមូលហេតុ និងភស្តុតាង។

**២.២.៤.២ បណ្ដឹងទាមទារឲ្យទទួលស្គាល់**

ការទទួលស្គាល់ដោយបង្ខំអាចធ្វើបានដោយមានចែងក្នុងមាត្រា១០០១នៃក្រមរដ្ឋប្បវេណី។

**២.២.៤.៣ បណ្ដឹងទាមទារបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព (ការបដិសេធបិតុភាព)**

អ្នកដែលមានសិទ្ធិដាក់ពាក្យបណ្ដឹង មានដូចខាងក្រោម៖

- កូន (មាត្រា ១០០២ កថាខណ្ឌទី ១)

- ឪពុក (មាត្រា ១០០២ កថាខណ្ឌទី ២)

- ម្ដាយ (មាត្រា ១០០២ កថាខណ្ឌទី ៣)

មានករណី ០៣ យ៉ាង ដែលមិនអាចដាក់ពាក្យបណ្ដឹងបានមានចែងក្នុងមាត្រា ១០០២ កថាខណ្ឌទី ៤ គឺ៖

- ឪពុក ឬ ម្ដាយដែលបានទទួលស្គាល់កូនរួចហើយដោយចេតនា

- ឪពុក ឬ ម្ដាយដែលមានកំហុសធ្ងន់ធ្ងរ ដែលបានចុះឈ្មោះរួចហើយក្នុងសៀវភៅកំណើតរបស់កូន

- អំឡុងពេល ២០ ឆ្នាំ បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអនុភាពនៃការទទួលស្គាល់កូនបានកើតឡើង។

**២.២.៤.៥ បណ្ដឹងទាមទារឲ្យបញ្ជាក់អត្ថិភាពនៃមាតុភាព**

មានចែងក្នុងមាត្រា ១០០៤ និង ១០០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- កូនអាចដាក់ពាក្យបណ្ដឹងបានតាមមាត្រា ១០០៤

- ម្ដាយអាចដាក់ពាក្យបណ្ដឹងបានតាមមាត្រា ១០០៥

អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព មានចែងក្នុងមាត្រា ១០០៦ ដែលអានុភាពនេះ មានទំនាក់ទំនងសំខាន់ចំពោះសន្តិកម្ម។

## ៣. សុំកូន

### ៣.១ អត្ថន័យនៃរបបសុំកូន

របបសុំកូន គឺជារបបទទួលស្គាល់ឲ្យជនដែលគ្មានទំនាក់ទំនងសាច់ញាតិ បង្កើតនូវទំនាក់ទំនងជាឪពុក ម្ដាយ និង កូន ដូចឪពុកម្ដាយនិងកូនបង្កើតដែរ។

គោលបំណងនៃរបបសុំកូន គឺះ

**ក.** អ្នកដែលគ្មានអ្នកណាស្នង អាចរកអ្នកស្នងបានតាមរយៈសុំកូន (ឲ្យស្នងអាជីវកម្ម)

**ខ.** គ្រួសារ សន្តតិកម្ម ទ្រព្យសម្បត្តិ ជាអាទិ៍។

**គ.** ចំពោះអ្នកដែលគ្មានកូន អាចរកកូនបាន (ដើម្បីឲ្យកូនផ្គត់ផ្គង់អាហារកិច្ច នៅពេលដែលខ្លួនចាស់ ជាអាទិ៍)

**ឃ.** រកឪពុកម្ដាយសំរាប់កុមារកំព្រា

ចំពោះចំណុច ក និង ខ គឺជា" សុំកូនសំរាប់ឪពុកម្ដាយ" ឬ "សុំកូនសំរាប់ស្នងគ្រួសារ" រីឯចំណុច គ និង ឃ វិញ គឺជា"សុំកូនសំរាប់កូន" ។

នៅកម្ពុជា ក្រមរដ្ឋប្បវេណី មានចែងអំពីរបបសុំកូនពីរ គឺសុំកូនពេញលេញ (ពីមាត្រា ១០០៧ ទៅ) និង សុំកូនធម្មតា (ពីមាត្រា ១០២០ ទៅ)។ សុំកូនធម្មតា គឺជារបបសុំកូន ក្នុងគោលបំណង ក្នុងគោលបំណង សុំកូនដើម្បីស្នងមតិកគ្រួសារ និង សុំកូនដើម្បីឪពុកម្ដាយ។ រីឯសុំកូនគឺសុំកូនដើម្បីកូន។ ក្នុងករណីដែលមានទំនាក់ទំនងដូចឪពុក ម្ដាយ និង កូនបង្កើតតាមរយៈសុំកូន ទំនាក់ទំនងគតិយុត្តិរវាង ឪពុក ម្ដាយ និង កូន ត្រូវបានបង្កើតឡើងរវាងកូនសុំ និង ឪពុក ម្ដាយចិញ្ចឹមនោះ។ ទស្សនៈស្ដីពីទំនាក់ទំនងរវាង ឪពុកម្ដាយ និង កូនសុំ មានពីរបែប គឺ ១. ទំនាក់ទំនងឪពុកម្ដាយ និង កូនបង្កើត មានអត្ថិភាពតាមផ្លូវច្បាប់ ២. ទំនាក់ទំនងឪពុកម្ដាយ និង កូនបង្កើត ត្រូវរលត់តាមផ្លូវច្បាប់។

របបសុំកូនពេញលេញក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គឺមានគោលគំនិតបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ដូចឪពុកម្ដាយ និង កូនបង្កើតដែរ ហេតុនេះហើយពេលដែលបានសុំកូនទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន បង្កើត ត្រូវរលត់តាមផ្លូវច្បាប់ (មាត្រា ១០១៤)។

### ៣.២ សុំកូនធម្មតា

សុំកូនធម្មតា អាចបង្កើតឡើងតាមរយៈកិច្ចសន្យារវាងភាគីទាំងសងខាង ក្នុងគោលបំណងបង្កើតនូវអានុភាពដូចគ្នានឹងរវាងឪពុកម្ដាយ និង កូនបង្កើតធម្មជាតិ។

ខ្លឹមសារនេះ គឺជាខ្លឹមសារដែលច្បាប់កំណត់ ដូច្នេះមិនអាចដាក់លក្ខខណ្ឌ ឬ កំណត់អំឡុងពេលបានឡើយ។ ម្យ៉ាងទៀត មិនអនុញ្ញាតឲ្យបង្កើតប្រការពិសេសដែលផ្ទុយនឹងអ្វីដែលច្បាប់កំណត់ទេ (ឧទាហរណ៍ ប្រការពិសេសដែលមានខ្លឹមសារ តែមិនផ្តល់សិទ្ធិសន្តតិ ផ្តល់អាហារកិច្ច-កម្ម)។

### ៣.២.១ លក្ខខណ្ឌដើម្បីបង្កើតសុំកូនធម្មតា

ដើម្បីសុំកូនធម្មតា ត្រូវស្របនឹងលក្ខខណ្ឌទម្រង់ (ការដាក់ពាក្យសុំទៅតុលាការ និង ដីកាសម្រេចរបស់តុលាការ) ផង និង លក្ខខណ្ឌជាសារធាតុ (លក្ខខណ្ឌដើម្បីឲ្យតុលាការ ចេញដីកាសម្រេចបង្កើតសុំកូននោះ) ផង។

#### ៣.២.១.១ លក្ខខណ្ឌទំរង់

ដើម្បីបង្កើតសុំកូនធម្មតា ត្រូវដាក់ពាក្យសុំទៅតុលាការ (មាត្រា ១០២០) ហើយតុលាការនឹងចេញដីកាសម្រេច (មាត្រា ១០២៣ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១ និង ទី ២, តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ៩) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

មានន័យថា អ្នកដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម និង អ្នកដែលនឹងក្លាយទៅជាកូនសុំត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីបង្កើតសុំកូនធម្មតា ហើយតុលាការនឹងចេញដីកាសម្រេចឲ្យបង្កើតសុំកូន។ ពេលនោះ សុំកូនធម្មតាក៏ត្រូវបានបង្កើតឡើង។

#### ៣.២.១.២ លក្ខខណ្ឌជាសារធាតុ

ប្រសិនជាការដាក់ពាក្យសុំកូនធម្មតាមិនស្របទៅនឹងលក្ខខណ្ឌដូចខាងក្រោមនេះទេ តុលាការ នឹងមិនអនុញ្ញាតឲ្យបង្កើតទេ។

**ក.** ទាល់តែភាគីទាំងសង មានឆន្ទៈសុំកូន (មាត្រា ១០២៣)

ចាំបាច់ត្រូវមានឆន្ទៈសុំកូនពិតប្រាកដ ក្នុងការបង្កើតសុំកូនរវាងភាគីទាំងសង។

ក្នុងករណីដែលមានការប្រើសិទ្ធិដោយបំពាន ក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ (រវាងអ្នកមានភេទខុសគ្នា ឬ រវាងអ្នកមានភេទដូចគ្នា) តុលាការមិនអនុញ្ញាតឲ្យបង្កើសុំកូនឡើយ។

**ខ.** អ្នកដែលនឹងក្លាយទៅជាឪពុកម្តាយ ត្រូវមានអាយុ ២៥ឆ្នាំ ឡើងទៅ (មាត្រា ១០២០ កថាខណ្ឌទី ១)

**គ.** អ្នកដែលនឹងក្លាយទៅជាកូនសុំ មិនត្រូវជាបុព្វញាតិ ឬក៏មានអាយុច្រើនជាងអ្នកដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមបានឡើយ (មាត្រា ១០២០ កថាខណ្ឌទី ១)

**ឃ.** ស្មុំកូនដោយអ្នកដែលមានសហព័ទ្ធ (មាត្រា ១០២១, មាត្រា ១០២២)

ជនដែលមានសហព័ទ្ធ ដើម្បីស្មុំកូនដែលជាអនីតិជន ត្រូវដាក់ពាក្យស្មុំកូនជាមួយសហព័ទ្ធ (មាត្រា ១០២១)

ជនដែលមានសហព័ទ្ធ ដើម្បីស្មុំកូនធម្មតា ត្រូវមានការយល់ព្រមពីសហព័ទ្ធ (មាត្រា ១០២២)

នេះ គឺដោយសារតែ តាមរយៈស្មុំកូននេះអាចមានឥទ្ធិពលទៅលើជីវភាពរស់នៅ ជាក់ស្តែង ដូចជា សន្តតិកម្ម អាហារកិច្ច ត្រកូល ជាដើម។

**ង.** ស្មុំកូនដែលកូននោះជាអនីតិជន (មាត្រា ១០២៤)

បើសិនជាអ្នកដែលនឹងក្លាយទៅជាកូនសុំជាអនីតិជន តុលាការទទួលស្គាល់នូវស្មុំកូននេះ តែក្នុងករណីដែលមានភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍របស់អនីតិជននេះប៉ុណ្ណោះ។

បើសិនជាអ្នកដែលនឹងក្លាយជាកូនសុំមានអាយុ ១៥ ឆ្នាំ ឬក៏បើសិនជាអ្នកនោះអាចបង្ហាញ ឆន្ទៈបាន តុលាការត្រូវសួរមតិរបស់អ្នកនោះ។

**ច.** ស្មុំកូនរវាងអ្នកអាណាព្យាបាល និង អ្នកនៅក្រោមអាណាព្យាបាល (មាត្រា ១០២៥)

តុលាការអាចទទួលស្គាល់បាន តែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិប៉ុណ្ណោះ។

### ៣.២.២ អានុភាពនៃស្មុំកូនធម្មតា ( មាត្រា ១០២៦ និង មាត្រា ១០២៧)

#### ៣.២.២.១ អានុភាពនៃស្មុំកូនធម្មតា

ទោះបីជាបានបង្កើតស្មុំកូនក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតត្រូវបន្តនូវអត្ថិភាពដដែល (មាត្រា ១០២៦)។ ស្តីពីសន្តតិកម្ម អ្នកទាំងពីរនៅតែមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមកដែរ ហើយត្រូវមានបន្ទុកនូវសិទ្ធិ និង កាតព្វកិច្ចអាហារកិច្ចទៅវិញទៅមក។

ស្តីពីទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹមវិញ បើសិនជាបានបង្កើតស្មុំកូនធម្មតាទៅ កូនសុំនោះនឹងមានឋានៈបុគ្គលដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ ហើយនឹងមានសិទ្ធិ និង កាតព្វកិច្ចពាក់ព័ន្ធនឹងឪពុកម្តាយដូចគ្នានឹងកូនបង្កើតដែរ (មាត្រា ១០២៧ កថាខណ្ឌទី ១ មាត្រា ១០១៥ កថាខណ្ឌទី ១)។ ម៉្យាងទៀត កូនសុំនោះអាចយកត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ឬក៏អាចទុកត្រកូលចាស់ដដែលក៏បាន។

បើសិនជាបានបង្កើតស្មុំកូនធម្មតាហើយ ត្រូវសរសេរអំពីស្មុំកូនធម្មតានៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូននោះ (មាត្រា ១០៣៣)។

**ឧទាហរណ៍**

ក្នុងករណី ដែលកូនបង្កើត A របស់ឪពុកម្តាយបង្កើត A1 និង A2 បានក្លាយជាកូនសុំតាមរយៈស្មុំកូនធម្មតារបស់ឪពុកម្តាយចិញ្ចឹម B1 និង B2។

A នឹងមានទំនាក់ទំនងជាសាច់ញាតិនឹង A1 និង A2 ដដែលផង ហើយនឹងមានឋានៈ ដូចជាកូនបង្កើតនឹង B1 និង B2 ផង។ ដូច្នេះ A នឹងមានទំនាក់ទំនងសន្តតិកម្ម និង អាហារកិច្ចទៅវិញទៅមកជាមួយនឹង A1 និង A2 ផង និង B1 B2 ផង។

ម្យ៉ាងទៀត តាមរយៈស្មុំកូននេះ ក្រៅពីទំនាក់ទំនងញាតិលោហិតនឹង A1 A2 កូនបង្កើត A ក៏មានទំនាក់ទំនងញាតិលោហិតនឹង B1 B2 ដែរ គឺ "B1 គឺជាឪពុករបស់ A" "B2 គឺជាម្តាយរបស់ A" "A គឺជាកូនបង្កើតរបស់ B1 B2 " (មាត្រា ៩៨០)។ ផ្ទុយទៅវិញ រវាង B1 B2 និង A1 A2 គ្មានទំនាក់ទំនងជាញាតិភាពទេ (ការបកស្រាយផ្ទុយនឹងមាត្រា ៩៨០)។

### ៣.២.២.២ អានុភាពនៃស្មុំកូនធម្មតាដែលមានវិការៈ

ទោះបីជាមានវិការៈក្នុងការដាក់ពាក្យស្មុំកូនក៏ដោយ (ឧទាហរណ៍ មានការភាន់ច្រឡំជាដើម) បើសិនជាតុលាការបានចេញដីកាសម្រេចឲ្យបង្កើតស្មុំកូនធម្មតា ហើយដីកាសម្រេចនោះបានចូលជាស្ថាពរ អានុភាពនៃស្មុំកូនត្រូវកើតមានឡើង។

ក៏ប៉ុន្តែ បើសិនជាមាននីតិវិធីជំនុំជំរះសាជាថ្មី ហើយតុលាការបានលុបចោលនូវដីកាសម្រេចនោះ ដោយផ្អែកលើ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣១៧ កថាខណ្ឌទី ១) ជាដើម អានុភាពនៃស្មុំកូននោះត្រូវរលត់។

### ៣.២.៣ ការលុបចោលស្មុំកូនធម្មតា

ស្មុំកូនធម្មតា នឹងត្រូវរលត់តាមរយៈការកាត់កាល់។

អាចមានករណីកាត់កាល់តាមការព្រមព្រៀងរវាងភាគី (មាត្រា ១០២៨) និង ការកាត់កាល់តាមផ្លូវតុលាការ តាមរយៈបណ្តឹង (មាត្រា ១០៣១)។

### ៣.២.៣.១ ល័ក្ខខ័ណ្ឌនៃការកាត់កាល់តាមការព្រមព្រៀង

ការកាត់កាល់តាមការព្រមព្រៀង គឺជាការកាត់កាល់ដែលភាគីទាំងសងខាង (ឪពុកម្តាយចិញ្ចឹម និង កូនសុំ) បានព្រមព្រៀង ហើយបានដាក់ពាក្យសុំទៅតុលាការ ហើយតុលាការបានធ្វើការ វិនិច្ឆ័យឲ្យកាត់កាល់ (មាត្រា ១០៣០, ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១ និង ទី ២ តារាង ឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

ក្នុងករណីដែលបានពិនិត្យទៅឃើញថា ភាគីទាំងសងខាងមានឆន្ទៈពិតប្រាកដចង់រំលាយចោលនូវទំនាក់ទំនងជាឪពុកម្តាយចិញ្ចឹម និង កូនសុំ តុលាការត្រូវសម្រេចឲ្យកាត់កាល់។

**៣.២.៣.២ ល័ក្ខខ័ណ្ឌនៃការកាត់កាល់តាមផ្លូវតុលាការ**

ការកាត់កាល់តាមផ្លូវតុលាការ គឺជាការកាត់កាល់ដែលពុំមានការព្រមព្រៀងរវាងភាគី ស្តីពីការកាត់កាល់ ហើយភាគីណាម្ខាងបានដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់ភាគីម្ខាងទៀត ហើយតុលាការបានចេញសាលក្រមកាត់កាល់។

ការកាត់កាល់នេះ គឺជាការកាត់កាល់ដោយបង្ខំចំពោះភាគីម្ខាងទៀត ដែលគ្មានបំណងចង់កាត់កាល់ ដូច្នេះទាល់តែមានមូលហេតុធ្ងន់ធ្ងរ ទើបអាចទទួលស្គាល់បាន។ ក្រមរដ្ឋប្បវេណី មានចែងអំពីមូលហេតុនៃការកាត់កាល់នេះនៅក្នុងមាត្រា ១០៣១ កថាខណ្ឌទី ១ ដូចតទៅ៖

**ក.** ករណីដែលមានការបោះបង់ដោយទុច្ចរិត

**ខ.** ករណីដែលមិនដឹងថា នៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេលមួយឆ្នាំឡើងទៅ

**គ.** ករណីដែលមានហេតុធ្ងន់ធ្ងរផ្សេងទៀតដែលធ្វើអោយពិបាកក្នុងការបន្តសុំកូន

ម្យ៉ាងទៀត បណ្តឹងទាមទារនូវការកាត់កាល់ គឺជាបណ្តឹងដែលត្រូវអនុវត្តតាមច្បាប់នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៣ ចំណុច ឈ.) ហេតុនេះហើយ នីតិវិធីនៃបណ្តឹងនេះ មានភាពខុសគ្នាបន្តិចនឹងនីតិវិធីបណ្តឹងធម្មតា ដូចជាការកែសំរួលនូវគោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ) ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ដែលមិនធ្វើជាសាធារណៈជាដើម។

**៣.២.៣.៣ អានុភាពនៃការកាត់កាល់ ( មាត្រា ១០៣២)**

ក្នុងករណីដែលបានកាត់កាល់ដោយការព្រមព្រៀង ឬ បានកាត់កាល់តាមផ្លូវតុលាការ អានុភាពនៃសុំកូន ត្រូវបានបញ្ចប់ឆ្ពោះទៅអនាគត តាមរយៈការកាត់កាល់នេះ។

កូនសុំអាចប្រើត្រកូលរបស់ខ្លួនដែលមានមុនពេលសុំកូនក៏បាន ឬក៏ប្រើត្រកូលដែលមានក្រោយពេលសុំកូនក៏បាន។

**៣.៣ សុំកូនពេញលេញ**

សុំកូនពេញលេញ គឺជារបបសម្រាប់ផ្តល់នូវគ្រួសារសុខដុមរមនាមួយ ចំពោះកុមារអភ័ព្វក្នុងគោលបំណងចិញ្ចឹមកូននោះឲ្យមានសុខភាពល្អ ហើយដែលជារបបមួយប្រហាក់ប្រហែលនឹងឪពុកម្តាយបង្កើតជាងសុំកូនធម្មតា។

### ៣.៣.១ ល័ក្ខខ័ណ្ឌដើម្បីសុំកូនពេញលេញ

សុំកូនពេញលេញត្រូវស្របនឹងល័ក្ខខ័ណ្ឌទំរង់ (ដាក់ពាក្យសុំទៅតុលាការ ហើយបានទទួលនូវដីកាសម្រេចពីតុលាការ) ព្រមទាំងល័ក្ខខ័ណ្ឌជាសារធាតុ (ល័ក្ខខ័ណ្ឌដែលចាំបាច់ដើម្បីឲ្យតុលាការចេញដីកាសម្រេច) ដូចសុំកូនធម្មតាដែរ។

#### ៣.៣.១.១ ល័ក្ខខ័ណ្ឌទំរង់

បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយ ត្រូវដាក់ពាក្យសុំបង្កើតសុំកូនពេញលេញទៅតុលាការ (មាត្រា ១០០៧) ហើយតុលាការនឹងចេញដីកាសម្រេចបង្កើតសុំកូននោះ (មាត្រា ១០១២, ច្បាប់ស្តីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១ តារាងឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៧ នៃច្បាប់ដដែលនេះ)។

#### ៣.៣.១.២ ល័ក្ខខ័ណ្ឌជាសារធាតុ

ដើម្បីសម្រេចបង្កើតសុំកូន តុលាការត្រូវពិនិត្យមើលថាតើស្របនឹងល័ក្ខខ័ណ្ឌខាងក្រោមនេះ ឬទេ។ នេះគឺខុសនឹងសុំកូនធម្មតា ដោយសារតែត្រូវផ្តាច់នូវទំនាក់ទំនងរវាងកូនបង្កើត និងឪពុក ម្តាយបង្កើត ជាអាទិ៍ ដែលជាអានុភាពមួយដ៏ធ្ងន់ធ្ងរ ម្ល៉ោះហើយចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌតឹងរឹង

ណាស់។

**ក.** សុំកូនដោយសហការរវាងប្តីប្រពន្ធ (មាត្រា ១០០៨)

ជាគោលការណ៍ បុគ្គលដែលនឹងក្លាយជាឪពុកឬម្តាយចិញ្ចឹម ត្រូវតែមានសហព័ទ្ធ ហើយប្តីប្រពន្ធត្រូវសហការគ្នាដើម្បីក្លាយទៅជាឪពុកម្តាយចិញ្ចឹម។

នេះគឺដោយសារតែ របបសុំកូនពេញលេញនេះមានគោលគំនិតផ្តល់នូវគ្រួសារមួយដែលមានឪម្តាយទាំងពីរ ហើយមានស្ថេរភាពដល់កុមារអភ័ព្វ។

**ខ.** អាយុរបស់ឪពុកម្តាយចិញ្ចឹម និង កូនសុំ (មាត្រា ១០០៩ និង មាត្រា ១០១០)

ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ឆ្នាំ។

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ។

នេះ គឺដើម្បីធ្វើអោយទំនាក់ទំនងដូចគ្នានឹងឪពុកម្តាយ និង កូនបង្កើត ម្ល៉ោះហើយបានជាតំរូវអោយមានគំលាតអាយុដូចឪពុកម្តាយ និង កូនបង្កើតដែរ។ ម្យ៉ាងទៀត ទាល់តែកូនសុំនោះនៅតូចទើបអាចបង្កើតជាទំនាក់ទំនងរវាងឪពុកម្តាយ និង កូនសុំ ដូចឪពុកម្តាយ និង កូនបង្កើតដែរ។

**គ.** ការយល់ព្រមរបស់ឪពុកម្តាយ (មាត្រា ១០១១)

ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសំរាប់អនីតិជនរបស់កុមារដែលនឹងក្លាយជាកូនសុំនោះ។

នេះ គឺដោយសារតែបើសិនជាបានបង្កើតស្មុំកូនពេញលេញទៅ ទំនាក់ទំនងរវាងឪពុកម្ដាយ និង កូនបង្កើត ឬ ញាតិនោះនឹងត្រូវរលត់។

**ឃ.** ភាពចាំបាច់នៃស្មុំកូន (មាត្រា ១០១២)

ស្មុំកូនពេញលេញ អាចបង្កើតឡើងបានទាល់តែជាករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុង ការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀតដែលចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ។

**ង.** អំឡុងពេលសាកល្បងចិញ្ចឹម (មាត្រា ១០១៣)

ស្ដីពីការស្មុំកូនពេញលេញ ត្រូវធ្វើការវិនិច្ឆ័យយ៉ាងប្រុងប្រយ័ត្ន ហេតុនេះហើយ ជាគោលការណ៍ តុលាការត្រូវត្រួតពិនិត្យមើលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និង កូនសុំនោះ ក្នុងអំឡុងពេលយ៉ាងតិច ៦ខែ ហើយវិនិច្ឆ័យនូវការស្មុំកូននោះដោយពិចារណាដល់ស្ថានភាពនោះ។

### ៣.៣.២ អានុភាពនៃស្មុំកូនពេញលេញ

#### ៣.៣.២.១ អានុភាពនៃស្មុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះត្រូវបញ្ចប់ដោយស្មុំកូនពេញលេញ (មាត្រា ១០១៤)។

រវាងកូនសុំពេញលេញ និង ឪពុកម្ដាយចិញ្ចឹម កូនសុំនេះត្រូវទទួលឋានៈដូចគ្នាទៅនឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនោះដែរ (មាត្រា ១០១៥)។

ស្ដីពីត្រកូល កូនសុំអាចប្រើនាមត្រកូលមុនស្មុំកូនក៏បាន នាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន។

កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម។

ពេលណាបានបង្កើតស្មុំកូនពេញលេញហើយ ត្រូវចុះបញ្ជីកំណើតរបស់កូនសុំជាថ្មី។ ក៏ប៉ុន្តែនៅក្នុងសំបុត្រកំណើត មិនត្រូវសរសេរចំណុចស្ដីពីស្មុំកូនទេ (មាត្រា ១០១៨)។

ក្នុងករណីដែលកូនសុំពេញលេញដែលបានក្លាយជានីតិជនចង់ដឹងអំពីកំណើតរបស់ខ្លួន កូននោះអាចទាមទារឲ្យបង្ហាញព័ត៌មាននោះ តាមរយៈតុលាការបាន (មាត្រា ១០១៩)។ នៅក្នុងករណីនេះ ត្រូវធ្វើតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង (ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង មាត្រា ៣ កថាខណ្ឌទី ១ តារាងឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៨)។

#### ៣.៣.២.២ អានុភាពនៃស្មុំកូនពេញលេញ ដែលមានវិការៈ

ត្រូវគិតដូចគ្នានឹងស្មុំកូនធម្មតា ដែលមានវិការៈដែរ។

### ៣.៣.៣ ការរំលាយសុំកូនពេញលេញ

ដោយសារតែសុំកូនពេញលេញជាការបង្កើតទំនាក់ទំនងឪពុកម្តាយចិញ្ចឹម និង កូនតែមួយគត់ ដូចទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើតដែរ ហេតុនេះហើយ ជាគោលការណ៍ មិនអនុញ្ញាតឲ្យកាត់កាល់បានឡើយ។ ក៏ប៉ុន្តែផ្ទុយទៅវិញ មិនត្រូវទុកបន្តនូវសុំកូនរហូតដល់ពេលមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់កូនសុំទេ។ ដូច្នេះហើយ មានតែករណីដែលមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម ជាអាទិ៍ ទើបមានការទទួលស្គាល់នូវការកាត់កាល់តាមរយៈបណ្តឹង (មាត្រា ១០១៦, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៣ ចំណុច ជ)។

ក្នុងករណីដែលមានការទទួលស្គាល់នូវការកាត់កាល់ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះដែលត្រូវបានបញ្ចប់ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ (មាត្រា ១០១៧)។

# ផ្នែកទី ៤
# ការលែងលះ

## ១. សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយ ដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតា អោយ តែសំណើ និងស្ទីការត្រូវគ្នា គឺកិច្ចសន្យាត្រូវបានបង្កើតឡើង ថាតើធ្វើជាលាយលក្ខណ៍អក្សរ ឬមិនធ្វើជាលាយ លក្ខណ៍អក្សរក៏ដោយ ក៏ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឲ្យប្រិតប្រៀងបំផុត និងត្រូវគោរព តាម មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី មានន័យថា កិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើសំណើសុំរៀបអាពាហ៍ពិពាហ៍ ត្រូវគ្នាជាមួយនឹងស្ទីការរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ហើយបើ មិនគោរពតាម ល័ក្ខខ័ណ្ឌនៃមាត្រា ៩៥៥ ទេ កិច្ចសន្យាអាពាហ៍ពិពាហ៍ មិនត្រូវបានបង្កើតឡើយ។

ការលែងលះ គឺជាការរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍នេះ។

## ២. ការលែងលះ មានពីរប្រភេទ

### ២.១ ការលែងលះ ( ករណីមានការព្រមព្រៀង)

ប្រសិនបើគូភាគី (ប្តីប្រពន្ធ) ព្រមព្រៀងគ្នាថា ពួកគេ មិនអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន បញ្ញត្តិ មាត្រា ៩៧៩ អនុញ្ញាតអោយភាគីអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ហើយបើតុលាការ រកឃើញថា ភាគី មានឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដ ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ តុលាការ ត្រូវតែសម្រេចឲ្យភាគីលែង លះគ្នាតាមដីកាសម្រេចលែងលះ (មាត្រា ៣-២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង)។ ការលែងលះ នាំឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវទំនាក់ទំនងឋានៈបុគ្គល ដូចនេះទោះ ជាមានការព្រមព្រៀងគ្នា រវាងភាគីក្នុងការលែងលះ ភាគី មិនអាចបង្កើតកិច្ចសន្យាលែងលះក្រៅផ្លូវតុលាការ ឬគ្រាន់តែប្រើវិធីដាក់លិខិត ជូនដំណឹងទៅសាលាឃុំ-សង្កាត់បានទេ ចាំបាច់ត្រូវតែ មានសេចក្តីសម្រេចរបស់តុលាការ ទើបការលែងលះ មាន អានុភាពតាមផ្លូវច្បាប់ ។

### ២.២ ការលែងលះ ( ករណីគ្មានការព្រមព្រៀង)

#### ២.២.១ មូលហេតុនៃការលែងលះ

ប្រសិនបើភាគី មិនមានឆន្ទៈព្រមព្រៀងគ្នាលែងលះទេ នៅពេលដែល មានបណ្តឹងចូលមកតុលាការ  តុលាការ ត្រូវតែស្វែងរកមូលហេតុ ដែលនាំឲ្យភាគីលែងលះតាមផ្លូវច្បាប់បាន។ មូលហេតុទាំងនោះ គឺមានកំណត់ នៅក្នុងមាត្រា ៩៧៨៖

**ក.** ករណីប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ៖ យុត្តិសាស្ត្រប្រទេសជប៉ុន បាន ឲ្យនិយមថាគឺជាការមានចំណាងផ្លូវភេទនឹងបុគ្គលផ្សេង ក្រៅពីសហព័ទ្ធ។ និយមន័យនៃ "អំពើផិត ក្បត់" ន័យនៃច្បាប់ស្តីពីឯកពន្ធភាព នៅ យុត្តិសាស្ត្រប្រទេសជប៉ុននេះ គឺមានន័យដូចនិយមន័យនៃមាត្រា ៧ ប្រទេសកម្ពុជាដែរ គឺជាការរួម សវនកិច្ចរវាងបុរស ដែលមានចំណាងអាពាហ៍ពិពាហ៍ "អំពើផិតក្បត់" ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសវនកិច្ចរវាងស្ត្រី ដែលមាន ចំណាងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។

**ខ.** ករណីមានការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ

**គ.** ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ០១ ឆ្នាំ

**ឃ.** ករណីសហព័ទ្ធ បានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃ អាពាហ៍ពិពាហ៍មិនចាត់ចូលនៅក្នុងករណី ៖ ការរស់នៅឆ្ងាយដោយសារការងារនេះទេ ។

**ង.** ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ ត្រូវបានបែកបាក់ ឬ ករណីផ្សេងទៀត ដែលគ្មានសង្ឃឹមថា នឹង អាចបដិទានឡើងវិញបាន៖ បញ្ញត្តិចំណុចនេះមានលក្ខណៈទូលាយ និយាយ គឺ ស្ថានភាពនោះ "ឃ" ដល់ "ក" រួមទោះបីជាមូលហេតុទាំងឡាយ ដែល មិនចូលក្នុងចំណុចចាប់ពីនេះ។ តុលាការ គប្បីត្រូវពិចារណាដល់ស្ថានភាព "ង" អាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុច នានា ដូចជា សកម្មភាព និង អាកប្បកិរិយារបស់អ្នកទាំងពីរក្នុងអំឡុង អាពាហ៍ពិពាហ៍(វាយដំ ធ្វើទុកបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ ញាតិរបស់សហព័ទ្ធ, មាន ចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ), ឆន្ទៈចង់បន្តចំណងអាពាហ៍ពិពាហ៍ឬទេ, ស្ថានភាពសុខភាព (អពលានុភាពនៃលឹង្គ) ស្ថានភាពសេដ្ឋកិច្ច ជាអាទិ៍ ។

មានករណីជាច្រើន ដែលបានបំពេញល័ក្ខខ័ណ្ឌពីចំណុច ជាញឹកញាប់ក៏ត្រូវ "ឃ" ដល់ "ក" បានចាត់ចូលទៅ ក្នុងចំណុច ផងដែរ ហើយក៏អាចមានករណីជាច្រើនី ដែលមិនស្របនឹងចំណុច "ង" " តែស្របនឹងចំណុច "ឃ" ដល់ "ក"ង។"

## ២.២.២ មូលហេតុរារាំងការលែងលះ

ជាគោលការណ៍ អោយតែមានមូលហេតុ ដូចមានលើកឡើងខាងលើ ចាប់ពីចំណុច "ក" នោះ ការលែងលះ ត្រូវបានទទួលស្គាល់។ ក៏ប៉ុន្តែ ការលែងលះនេះ អាចមានផលប៉ះ "ង" ដល់ ពាល់ធ្ងន់ធ្ងរ ដល់សហព័ទ្ធ និង កូន ដូចនេះ ដើម្បីទប់ស្កាត់ការលែងលះតាមទំនើងចិត្តដែលជាផលប៉ះពាល់ធ្ងន់ធ្ងរដល់សហព័ទ្ធ និង កូន តុលាការ អាច ច្រានចោលការលែងលះ ដោយផ្អែកលើមាត្រា ៩៧៨ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណី។ នៅត្រង់ ចំណុចនេះ កត្តាផ្លូវចិត្ត កត្តា

សង្គម កត្តាសេដ្ឋកិច្ច គឺត្រូវបានយកមកពិចារណាទាំងអស់ ហើយ អំឡុងពេលដែលរស់នៅបែកគ្នា ក៏ត្រូវយកមកពិចារណាផងដែរ។

**ករណីយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន**

សាលដីកាតុលាការកំពូលប្រទេសជប៉ុន នៅថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ១៩៩០៖

ប្ដី មានអាយុ ៥២ ឆ្នាំ ប្រពន្ធអាយុ ៥៥ ឆ្នាំ កូនប្រុសច្បងអាយុ ២៩ ឆ្នាំ កូនប្រុសទី ២ អាយុ ២៥ ឆ្នាំ ក្រោយរៀបអាពាហ៍ពិពាហ៍ បាន ២៣ ឆ្នាំ ប្ដី បានចេញពីផ្ទះទៅនៅជាមួយស្រីផ្សេង។ បន្ទាប់ពីនោះ ក៏បែកពីនារី នោះ តែមិនបានមករស់នៅជាមួយប្រពន្ធវិញទេ ហើយរយៈពេលដែលរស់នៅបែកគ្នានោះ គឺ ០៨ ឆ្នាំ។ ក្រោយពី បានរស់នៅបែកគ្នា ប្ដី បានផ្ញើប្រាក់ផ្គត់ផ្គង់ជីវភាពប្រពន្ធរហូតមក ហើយចំនួនប្រាក់នោះ មានច្រើនគួរសមដែរ។ ប្ដី បានដាក់ពាក្យបណ្ដឹងសុំលែងលះគ្នា រីឯកូន យល់ឃើញថា ចង់លែងលះ ឬ ទេនោះ គឺជាឆន្ទៈរបស់ម្ដាយគេ។ ម្យ៉ាង ទៀត ប្ដី បានបង្ហាញឆន្ទៈថា ស្ដីពីការបែកចែកទ្រព្យសម្បត្តិ ពេលលែងលះគ្នា ត្រូវលក់ផ្ទះ និង ដី ដែលប្រពន្ធ កំពុង រស់នៅ ហើយដែលជាកម្មសិទ្ធិរបស់ប្ដីនោះ ហើយទូទាត់នៅពន្ធដា ព្រមទាំងចំណាយផ្សេង ៗ លើការលក់ នៅសល់ ប៉ុន្មានចែកជាពីរ ខាងប្ដីយកពាក់កណ្ដាល ខាងប្រពន្ធយកពាក់កណ្ដាល។ រីឯបំណុលនៅសល់ ហើយជាប់ហ៊ីប៉ូតែក លើអចលនវត្ថុនោះ ខាងប្ដីជាអ្នករ៉ាប់រង ហើយគាត់ នឹងទូទាត់ពីប្រាក់ ដែលគាត់បានទទួលពីការបែងចែកនោះ ។

**"សេចក្ដីសម្រេចបញ្ចប់"**

សាលដីកាដើម បានច្រានចោលនូវការទាមទារ។ តុលាការកំពូល បានបដិសេធចោលនូវសាលដីកាដើម ហើយ បញ្ជូនត្រឡប់ទៅវិញ។

..........ក្នុងការវិនិច្ឆ័យអំពីការលែងលះគ្នា ត្រូវពិចារណាដល់អាយុរបស់ប្ដីប្រពន្ធ ដោយ ប្រៀបធៀបអំឡុងពេល ដែលរស់នៅបែកគ្នា និង អំឡុងពេលដែលរស់នៅជាមួយគ្នាដើម្បីមើលថា តើអំឡុងពេលដែលរស់នៅបែកគ្នា នោះ វែងគួរសម ឬ ទេ។ តាមគោលគំនិតនេះ គឺត្រូវពិចារណាដល់ការប្រែប្រួល ស្ថានភាពផ្សេងៗ រួមទាំងអត្ថន័យ និង ការវាយតម្លៃក្នុងសង្គម (សង្គមអាចទទួលបាន ឬ ទេ) ក្រោយការរស់នៅបែកគ្នាផងដែរ។ ហើយពេល ធ្វើការ វិនិច្ឆ័យ អំពីការទាមទារសុំលែងលះគ្នា ដោយពិចារណាអំពីគោលការណ៍សុចរិត និង ស្មោះត្រង់ ក៏ត្រូវពិចារណាអំពី ឥទ្ធិពលនៃបញ្ហានានា ដែលកើតមានឡើង ក្នុងអំឡុងពេលកកន្លងមកនោះដែរ ។

...........ហេតុនេះហើយពេលពិចារណាថា តើអំឡុងពេលដែលរស់នៅបែកគ្នានោះ វែង ឬ ខ្លី មិនមែនគ្រាន់តែ ប្រៀបធៀបនឹងរយៈពេល ឬអាយុប៉ុណ្ណោះទេ គឺត្រូវពិចារណា ដល់ការប្រែប្រួលនៃស្ថានភាពទាំងនេះផងដែរ

.............អំឡុងពេលដែលរស់នៅបែកគ្នារវាងដើមបណ្តឹងសារទុក្ខ និង ចុងចម្លើយបណ្តឹងសារទុក្ខ មាន ០៨ ឆ្នាំ ហើយ ក្រោយពេលរស់នៅបែកគ្នា ប្តី បានផ្ញើប្រាក់ទៅអោយប្រពន្ធសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅគួរសមដែរ ម៉្យាង ទៀត ប្តី បានផ្តាច់ទំនាក់ទំនងនឹងស្ត្រីនោះ ក្រោយពីបានរស់នៅបែកគ្នា។ លើសពីនេះ ក្នុងការទាមទារសុំលែងលះ គ្នានេះ ដើមបណ្តឹង បានបង្ហាញឆន្ទៈទូទាត់ទ្រព្យទៅអោយ ចុងចម្លើយបណ្តឹងសារទុក្ខ ដែលអាចទទួលស្គាល់ថា សមរម្យបាន។ រីឯចុងចម្លើយនៃបណ្តឹងសារទុក្ខវិញ ចង់បន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែក្រោយពី រស់នៅបែក គ្នាប្រហែល ៥ ឆ្នាំ គាត់ បានដាក់ពាក្យបណ្តឹងសុំនូវការចាត់ចែងជាបណ្តោះអាសន្ន មិនឲ្យចាត់ចែងអចលនវត្ថុដែល ជាកម្មសិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ។ ក្រៅពីនេះ កូនដែលមានវ័យជានីតិជនហើយនោះមានឆន្ទៈថា ការលែងលះ ឬ មិនលែងលះនោះ សំខាន់គឺឆន្ទៈរបស់ចុងចម្លើយនៃបណ្តឹងសាទុក្ខ។ ហេតុនេះហើយ បើសិនជាពុំមានបញ្ហាអ្វី ពិសេសទៀតទេ អំឡុងពេលនៃការរស់នៅបែកគ្នា និង ការប្រែប្រួលនៃស្ថានភាពផ្សេងៗ របស់ភាគី ទាំងសងខាង គប្បីពិចារណាដល់ការប្រែប្រួលនៃការវាយតម្លៃរបស់សង្គមផងដែរ ។

### ២.២.៣ ការបែងចែកទ្រព្យសម្បត្តិ

#### ២.២.៣.១ តួនាទីនៅក្នុងបណ្តឹងសុំលែងលះ

នៅក្នុងរឿងលែងលះ ភាគច្រើនតែងមានបណ្តឹងសុំបែងចែកទ្រព្យសម្បត្តិជាមួយនឹងបណ្តឹងសុំលែងលះ ផងដែរ (មាត្រា៩៨០នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ តុលាការត្រូវសម្រេចពីការបែងចែកទ្រព្យឲ្យភាគី ប៉ុន្តែ ត្រូវពិនិត្យឲ្យបានច្បាស់ថា ភាគីបានដាក់ពាក្យសុំបែងចែកទ្រព្យដែរឬទេ ពីព្រោះបើគ្មានពាក្យសុំ តុលាការមិនអាច វិនិច្ឆ័យអំពីការបែងចែកទ្រព្យបានឡើយ។ មានករណីខ្លះ គូភាគីប្តឹងសុំបែងចែកទ្រព្យក្រោយពេលលែងលះ ហើយអនុវត្តនីតិវិធីនៃរឿងក្តីមិនមែនជាបណ្តឹង។

នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឲ្យផ្តល់តារកាលិកជាប្រាក់ ការបណ្តេញចេញហើយឲ្យប្រគល់ អចលនវត្ថុ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ជាដើម។

#### ២.២.៣.២ គោលការណ៍សមាមាត្រនៃចំណែក និង ករណីពិសេស

ការបែងចែកទ្រព្យនៅពេលមានបណ្តឹងសុំលែងលះ ត្រូវផ្អែកលើមាត្រា ៩៨០ ។ គេហកិច្ចត្រូវចាត់ទុកថា មានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

មាត្រានេះ បានបង្ហាញឲ្យអនុវត្តតាមវិធីដូចខាងក្រោមៈ

**១.** ការបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

**២.** ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដូចខាងក្រោមៈ

- សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ដូចបានកំណត់នៅក្នុងមាត្រា ៩៧២។

- ជាគោលការណ៍ ទ្រព្យសម្បត្តិរួម ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ។

- ក្នុងករណីពិសេស និង មានការទាមទាររបស់ប្តី ឬ ប្រពន្ធណាមួយ តុលាការ ក៏អាចបែងចែកទ្រព្យ សម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃ ទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហាពិពាហ៍ កម្រិតជីវភាពរស់នៅ នៅក្នុងពេលមាន ចំណងអាពាហាពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី នីមួយៗ និង ផលប្រយោជនរបស់កូន ជាអាទិ៍។

### ២.២.៣.៣ វិធីបែងចែក

ដើម្បីឲ្យសាលក្រម អាចយកទៅអនុវត្តបាន តុលាការ ត្រូវកំណត់វិធីបែងចែកឲ្យបានច្បាស់នៅក្នុងសេចក្តី សម្រេច។ មានវិធី ៣ យ៉ាង៖

**១.** ការបែងចែកវត្ថុជាក់ស្តែង៖ ជាវិធីយកទ្រព្យមកបែងចែក តាមការជាក់ស្តែង

**២.** ការបែងចែកជាតម្លៃថ្នូរ៖ ជាវិធីបែងចែកដោយប្រគល់វត្ថុ ឲ្យភាគីម្ខាងគ្រប់គ្រង ហើយឲ្យអ្នកដែល ទទួលលទ្ធកម្មនោះ បង់ជាតម្លៃថ្នូរដែលស្មើនឹងចំណែករបស់ភាគីម្ខាងទៀត។

**៣.** ការបែងចែកដោយប្តូរជាប្រាក់៖ ជាវិធីបែងចែកប្រាក់ ដែលបានមកពីការលក់ដោយបង្ខំ

### ២.២.៣.៤ ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសង ឬ តែម្ខាង ទទួលបាននៅក្នុងអំឡុង ពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងចំណុច **ខ** និង **គ** នៃមាត្រា ៩៧២ (ទ្រព្យ សម្បត្តិដោយឡែក)។

### ២.២.៤ អំពីអំណាចមេបាលើកូន

សហព័ទ្ធដែលមានកូនជាអនីតិជន មានអំណាចមេបាទៅលើកូននោះ និង ប្រើប្រាស់អំណាចនេះ ដោយ សហការគ្នា (មាត្រា ១០៣៦)។ អ្នកដែលមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ចត្រូវបីបាច់រក្សារូបកាយ របស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ (មាត្រា ១០៣៥)។

នៅពេលដែលមានការលែងលះគ្នា ឪពុកម្តាយដែលលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជា អ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ (មាត្រា ១០៣៧ កថាខណ្ឌទី១)។

ក្នុងករណីដែលឪពុកម្ដាយ បានលែងលះគ្នានៅមុនកំណើតរបស់កូន ម្ដាយ គឺជាអ្នកមានអំណាចមេបា ចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាច មេបា តាមការពិភាក្សារបស់ឪពុកម្ដាយបាន (មាត្រា ១០៣៧ កថាខណ្ឌទី ២)។

ប្រសិនបើភាគី មិនអាចពិភាក្សាអំពីការប្រគល់អំណាចមេបាលើកូនបានទេ ហើយមានការទាមទារធ្វើជា អ្នកមានអំណាចមេបារៀងៗ ខ្លួន នោះ តុលាការ ត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផល ប្រយោជន៍របស់កូននោះ (មាត្រា ១០៣៧ កថាខណ្ឌទី៣)។

ក្នុងករណីដែលការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នារួចហើយ តុលាការអាចផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបាតាមការទាមទាររបស់ញាតិនៅក្នុងបួនថ្នាក់របស់កូនបាន ប្រសិនបើ ទទួលស្គាល់ថា ចាំបាច់ដើម្បីផលប្រយោជន៍របស់កូន (មាត្រា ១០៣៩)។

ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង ជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (មាត្រា ១០៤០ កថាខណ្ឌទី១)។

ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាលើកូន អាចទាមទារឲ្យអ្នកដែលមានអំណាចមេបារាយការណ៍ អំពីស្ថានភាពរបស់កូននោះបាន។ ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ត្រូវកំណត់តាមការពិភាក្សា រវាងឪពុកម្ដាយ ប៉ុន្តែបើការពិភាក្សាមិនបានសម្រេចទេ ឬ ពុំអាចធ្វើការពិភាក្សាបានទេ តុលាការ អាចសម្រេច សេចក្ដីជំនួសការពិភាក្សាតាមការទាមទាររបស់ឪពុក ឬ ម្ដាយបាន។ ញាតិបួនថ្នាក់របស់កូន អាចទាមទារអោយ រាយការណ៍អំពីស្ថានភាពរបស់កូន ចំពោះអ្នកមានអំណាចមេបាបាន (មាត្រា ១០៤១)។

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន (មាត្រា ១០៤៣)។

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន (មាត្រា ១០៤៥)។

ឪពុក ឬ ម្ដាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើ បានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការ អាចប្រកាសព្យួរ ឬ ដក ហូតអំណាចមេបាតាមការទាមទាររបស់ញាតិបួនថ្នាក់របស់កូន មេឃុំ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈ សម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន (មាត្រា ១០៤៨)។

ប្រសិនបើការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបាបានបញ្ចប់ហើយ តុលាការ អាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមាន

អំណាចមេបា តាមការទាមទារ របស់សាមីជន ដែលបានទទួលការប្រកាសព្យូរ ឬ ការដកហូត អំណាចមេបា ឬ ញាតិក្នុងបួនថ្នាក់របស់ជននោះបាន (មាត្រា ១០៤៩)។

បើមានមូលហេតុដែលមិនអាចជៀសវាងបាន ឪពុក ឬ ម្ដាយដែលអនុវត្តអំណាចមេបា អាចលាឈប់ ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ។ ប៉ុន្តែបើ មូលហេតុ ដែលបានកំណត់ ខាងលើត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្ដាយ ដែលបានលាឈប់ពីការ ធ្វើជាអ្នកមានអំណាចមេបា អាចទទួល បដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការ អនុញ្ញាតពីតុលាការ (មាត្រា ១០៥០)។

ក្នុងករណីដែលឪពុកម្ដាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុង ស្ថានភាពដែល ពុំមានអ្នកមានអំណាចមេបាដោយសារអ្នកនោះ ត្រូវបានប្រកាសការព្យូរ ឬ ការដក ហូតអំណាចមេបា ឬ បានលា ឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការ អាចយកឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នក មានអំណាចមេបារបស់កូនបាន។ ក្នុងករណីចាំបាច់ ញាតិក្នុងបួនថ្នាក់របស់កូន អាចទាមទារឲ្យធ្វើការប្រកាសដូច ខាងលើបាន។ នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្ដាយដែលធ្វើជាអ្នកមានអំណាចមេបារបស់កូនតាមការ ពិភាក្សា បានទទួល មរណភាព ប្រសិនបើកូន ពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្ដាយ ដែលពុំបានធ្វើជាអ្នក មានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា (មាត្រា ១០៥១)។

## ៣. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

### ៣.១ អ្វីទៅជាការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ?

ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយ ពិចារណាទៅលើ ទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត (មាត្រា ៩៧១)។ វាមាន ន័យថាប្ដីប្រពន្ធ ត្រូវមាន ករណីយកិច្ចទទួលខុសត្រូវនូវសោហ៊ុយចំណាយ ដើម្បីថែទាំជីវភាពរួមនៃ អាពាហ៍ពិពាហ៍ ដោយតម្រូវឲ្យប្ដីប្រពន្ធ ចែករំលែកនូវការទទួលខុសត្រូវសោហ៊ុយជីវភាពរួមនៃ អាពាហ៍ពិពាហ៍ ទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈ ក្នុងសង្គម និងមុខរបររបស់ប្ដីប្រពន្ធជា ដើម។ ការទទួលខុសត្រូវនូវសោហ៊ុយ ចំណាយដើម្បីថែទាំជីវភាពរួមនៃ អាពាហ៍ពិពាហ៍ មិនសំដៅ លើត្រឹមតែការចំណាយសម្រាប់សំលៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ ថ្លៃព្យាបាល ប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងការចំណាយលើការសិក្សា និង ថែទាំកូនផងដែរ ។ មិនតែប៉ុណ្ណោះ ក្រោយពេលប្ដី ប្រពន្ធ រស់នៅបែកគ្នាក៏ដោយ ក៏ប្ដីប្រពន្ធ ត្រូវតែបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកនេះផងដែរ ប្រសិនបើ ពួកគេ មិនទាន់លែងលះនឹងគ្នា។ ទោះជា ប្ដីប្រពន្ធ រស់នៅបែកគ្នាក៏ដោយ ក៏ប្ដីប្រពន្ធ ត្រូវមានអាហារកាតព្វកិច្ច រវាងសហព័ទ្ធដែរ។ មានន័យថា សហព័ទ្ធម្ខាង អាចទាមទារ រួមទាំង សោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់កូន ដែលរស់នៅជាមួយខ្លួន ពីសហព័ទ្ធម្ខាងទៀតបានដែរ។

ក្នុងករណីដែលសហាពទ្ធ័ណាមួយ មិនអនុវត្តកាតព្វកិច្ចនៃសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍សហាពទ្ធ័ម្ខាងទៀតអាចដាក់ពាក្យសុំទៅតុលាការឲ្យសម្រេចអំពីសោហ៊ុយចំណាយនេះបាន ក្នុងនីតិវិធីរឿងក្តីដែលមិនមែន ជាបណ្តឹង ។

### ៣.២.ទំនាក់ទំនងរវាងការទទួលខុសត្រូវសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍នឹងរឿងក្តីសុំលែងលះ

សហាពទ្ធ័ ត្រូវបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកបន្ទុកនៃសោហ៊ុយចំណាយ ក្នុងពេលអាពាហ៍ពិពាហ៍ រហូតដល់ពេលដែល ប្តីប្រពន្ធ បានលែងលះគ្នាដាច់ស្រេច មិនថាឡើយសូម្បីតែនីតិវិធីលែងលះ កំពុងតែអនុវត្ត។ នៅក្នុងករណីដែលតុលាការ ច្រានចោលនូវការទាមទារលែងលះរបស់សហាព័ទ្ធ នោះបន្ទុកនៃការទទួលខុសត្រូវ សោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍ នៅតែបន្តដដែលសម្រាប់សហាព័ទ្ធ ។

នៅពេលដែលការសុំលែងលះ បានសម្រេចរួចរាល់ហើយ ករណីយកិច្ចទទួលខុសត្រូវនូវចំណែកបន្ទុកនៃ សោហ៊ុយអាពាហ៍ពិពាហ៍ ក៏ត្រូវអស់ពីពេលនោះដែរ ប៉ុន្តែ មាត្រា ៧៦ (អាហារកិច្ចនៅក្រោយការលែងលះ) នៃ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ គឺត្រូវបានរក្សាទុក ទោះជានៅក្រោយក្រមរដ្ឋប្បវេណីថ្មី ត្រូវបានអនុវត្ត ដោយ ផ្អែកទៅលើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

### ៣.៣ វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍មានបីវិធីដូចខាងក្រោមៈ

**ក.** ត្រូវគណនាទៅតាមចំណូលមូលដ្ឋាន (x) របស់អ្នកមានសិទ្ធិ (ច្រើនតែប្រពន្ធ) និងចំណូលមូលដ្ឋាន (Y) របស់អ្នកមានករណីកិច្ច (ច្រើនតែប្តី)។

**ខ.** ត្រូវគណនាសោហ៊ុយអាពាហ៍ពិពាហ៍ (Z) ដែលត្រូវចែកទៅឲ្យខាងគ្រួសារអ្នកមានសិទ្ធ ។

$$Z=(X+Y) \times Z=(X+Y) \times \frac{\text{សូចនាយករណ៍នៃសោហ៊ុយសម្រាប់ជីវភាពគ្រួសារអ្នកមានសិទ្ធិ} \\ \text{(អ្នកមានករណីកិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច )}}{\text{សូចនាយករណ៍នៃសោហ៊ុយសម្រាប់ជីវភាពទាំងសងខាង} \\ \text{( អ្នកមានករណីយកិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច )}}$$

**គ.** ត្រូវគណនាទឹកប្រាក់ ដែលអ្នកមានករណីយកិច្ចត្រូវទទួលបន្ទុក (ទឹកប្រាក់នៃចំណែកបន្ទុកនៃសោហ៊ុយ អាពាហ៍ពិពាហ៍) ពីទឹកប្រាក់ដែលបានគណនានៅចំណុច "ខ"

ទឹកប្រាក់នៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ = Z - Y

## ៩. អនីតិសង្វាស

### សេចក្តីផ្តើម

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ គឺជាកាលបរិច្ឆេទនៃការអនុវត្តច្បាប់ចំនួន០៤ រួមគ្នាមានក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលជាសេចក្តីត្រូវការចាំបាច់សំរាប់ប្រើប្រាស់នៅប្រទេសកម្ពុជា។

នៅក្នុងជំពូកទី៣ នៃគន្ថីទី៧ បានកំណត់ល័ក្ខខ័ណ្ឌអាពាហ៍ពិពាហ៍ ដែលនាំឲ្យមានអានុភាពគឺត្រូវបំពេញនីតិវិធីមួយចំនួនដើម្បីអាពាហ៍ពិពាហ៍មានសុពលភាពស្របតាមច្បាប់។ ក្រៅពីក្រមរដ្ឋប្បវេណី មានអនុក្រិត្យស្តីពីអត្រានុកូលដ្ឋាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ដែលជាការបំពេញបន្ថែមដោយទម្រង់ សៀវភៅអត្រានុកូលដ្ឋាន ដើម្បីកត់ត្រាអំពីស្ថានភាពគតិយុត្តដែលចងភ្ជាប់ទៅ បុគ្គលក៏មានកំណត់ពីការចុះបញ្ជីអាពាហ៍ពិពាហ៍ផងដែរ។

ទោះបីជាមានទំនើបកម្មច្បាប់សំរាប់ប្រើប្រាស់យ៉ាងណាក៏ដោយ ក្នុងបរិបទសង្គម នៃការលូតលាស់របស់មនុស្ស ផ្នត់គំនិតប្រជាពលរដ្ឋដែលបានអោយតម្លៃលើទំនាក់ទំនងអាពាហ៍ពិពាហ៍តាមប្រពៃណី និងកង្វះការយល់ដឹងអំពីច្បាប់ផងនោះ មានបុរសនារី គូស្រករភាគច្រើនដែលមិនបានអើពើ ឬ មិនបានធ្វើនីត្យានុកូលកម្មនៃអាពាហ៍ពិពាហ៍របស់ខ្លួននោះទេ។ ក្នុងទិដ្ឋភាពសង្គមជាក់ស្តែងឃើញថា ការរួមរស់ជីវិតដៃគូរស្នេហាមានលក្ខណៈខុសៗគ្នា។ គូស្រករខ្លះរួមរស់ជាមួយគ្នាដើម្បីក្តីសប្បាយជាបណ្តោះអាសន្ន ខ្លះរួមរស់ក្រោមដំបូលតែមួយជាគ្រួសារដោយបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវ រីឯខ្លះទៀត មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ។ ហេតុនេះអ្នកច្បាប់មួយចំនួនធំបានហៅស្ថានភាពនេះជារួមថាជា អនីតិសង្វាស ។ ប៉ុន្តែពាក្យអនីតិសង្វាសនេះ គ្មានវត្តមាននៅក្នុងបញ្ញត្តិច្បាប់ណាមួយនោះទេ ហើយគ្មានការឲ្យនិយមន័យជាក់លាក់ផងដែរ។

ក្នុងស្ថានភាពទូទៅដែលយើងហៅថា អនីតិសង្វាស នេះឲ្យនៅក្រៅច្បាប់ បានចោទបញ្ហាជាច្រើនទាំងក្នុងស្ថានភាពសង្គមជាក់ស្តែង និង វិស័យនីតិគ្រួសារ។

តើអនីតិសង្វាសមានន័យយ៉ាងដូចម្តេច? តើកត្តាអ្វីខ្លះដែលនាំឲ្យកើតមានអនីតិសង្វាស? តើភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ជាមួយអនីតិសង្វាស និង ភាពខុសគ្នារវាងអនីតិសង្វាស នឹងកំជាប់ពាក្យយ៉ាងណាខ្លះ? តើមានគុណសម្បត្តិ ឬ គុណវិបត្តិអ្វីខ្លះ? តើត្រូវប្រើប្រាស់ច្បាប់យ៉ាងដូចម្តេច ដើម្បីការពារដល់អ្នករងគ្រោះ នៃអនីតិសង្វាស?

## ៤.១. អ្វីទៅជាអនីតិសង្វាស?

អនីតិសង្វាស គឺជាទំនាក់ទំនងរវាងបុរស និង ស្ត្រី ដែលរស់នៅជាមួយគ្នាដោយមានឆន្ទៈថានឹង ក្លាយជាប្តីប្រពន្ធនឹងគ្នា ហើយត្រូវបានសង្គមចាត់ទុកថាជាប្តីប្រពន្ធដែលបានរៀបការជាមួយគ្នា។ ប៉ុន្តែពួកគេមិនបានបង្កើតអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ដោយសារខ្វះល័ក្ខខ័ណ្ឌច្បាប់ដែលត្រូវបំពេញនៃការរៀបអាពាហ៍ពិពាហ៍។

ជាក់ស្តែងពួកគេបានរៀបអាពាហ៍ពិពាហ៍ ទៅតាមប្រពៃណី ទំនៀមទំលាប់ និងបានរួមរស់ជាប្តីប្រពន្ធក្រោមដំបូលតែមួយ។

### ក.ភាពខុសគ្នារវាងអាពាហ៍ត្រឹមត្រូវ និង អនីតិសង្វាស

អាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់ ត្រូវបានបង្កើតឡើងនៅពេលដែលល័ក្ខខ័ណ្ឌទាំងបួនបានបំពេញមានដូចជា ***ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍*** និង ***ការចុះបញ្ជី*** តាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី។ ដោយឡែក ប្តីប្រពន្ធដែលរស់នៅជាអនីតិសង្វាសជន ជាធម្មតាមិនបានបំពេញល័ក្ខខ័ណ្ឌទាំងបួនខាងលើនោះឡើយ។

អនីតិសង្វាស មិនត្រូវបានទទួលស្គាល់ជាសហព័ទ្ធ ឬ ប្តីប្រពន្ធស្របច្បាប់ ប៉ុន្តែពួកគេបានរស់នៅជាមួយគ្នា មានជីវភាពរួមគ្នា ដូចប្តីប្រពន្ធ និង មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

ជាទូទៅ ពួកគេរស់នៅជាមួយគ្នាដោយមិនបានជូនដំណឹងដល់អាជ្ញាធរអំពីទំនាក់ទំនងរបស់ពួកគេឡើយ។ ខ្លះទៀតបានផ្តល់ដំណឹងនៅពេលដែលខ្លួនមានកូន មានចៅ ឬ ចំណងញាតិជាដើម ដូចការចុះសៀវភៅស្នាក់នៅ ចុះសៀវភៅគ្រួសារ ឬ សំបុត្រកំណើតផ្សេងៗ។

### ខ.ភាពខុសគ្នារវាងកំជាប់ពាក្យ និង អនីតិសង្វាស

កំជាប់ពាក្យ គឺជាការបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍នៅពេលអនាគត ដោយធ្វើពិធីកំជាប់ពាក្យ (មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀតគេមិនតម្រូវឲ្យមានការរៀបចំពិធីដើម្បីបង្កើតអនីតិសង្វាសឡើយ រីឯឆន្ទៈរបស់ប្តីប្រពន្ធអនីតិសង្វាស គឺ ***ពួកគេជាប្តីប្រពន្ធរួចទៅហើយ*** ដែលចំនុចនេះខុសពីឆន្ទៈរបស់ភាគីនៃកំជាប់ពាក្យដែលថា ***ពួកយើងនឹងរៀបការនៅពេលអនាគតខាងមុខនេះ*** ។ ប៉ុន្តែពេលខ្លះ វាមានការលំបាកក្នុងការបែងចែកអត្ថន័យនៃចំណុចទាំងពីរនេះ។

## ៤.២. មូលហេតុនាំអោយកើតមានអនីតិសង្វាស

- ភាគីនៃអនីតិសង្វាស ជាអនីតិជន

- ភាគីខ្វះការអប់រំ និង យល់ដឹងផ្នែកច្បាប់
- ភាគីរងនៅសម្ពាធបែងចែកវណ្ណៈគ្រួសារ ពីអាណាព្យាបាលមិនព្រមឲ្យមានអាពាហ៍ពិពាហ៍កើតឡើង។
- ភាគីនៃអនីតិសង្វាស គិតថានីតិវិធីរៀបអាពាហ៍ពិពាហ៍តាមច្បាប់មានលក្ខណៈស្មុគស្មាញចំណាយពេលវេលា និង ថវិការច្រើន។
- ភាគីអនីតិសង្វាសយល់ថា ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមានសារៈសំខាន់ជាង។
- ភាគីម្ខាងនៃអនីតិសង្វាស ត្រូវបានច្បាប់ហាមឃាត់មិនអោយចុះសំបុត្រអាពាហ៍ពិពាហ៍។
- ភាគីមានស្ថានភាពផ្លូវចិត្ត (មិនចង់មានចំណងផ្លូវច្បាប់ ខ្លាចបាត់បង់ត្រកូល)

### ៤.៣. ការបង្កើតអនីតិសង្វាស

ដើម្បីបង្កើតអនីតិសង្វាស ភាគីទាំងសងខាងត្រូវមានឆន្ទៈថា ពួកគេជាប្តីប្រពន្ធនឹងគ្នា ដោយសាមគ្គីភាពទាំងផ្នែកសេដ្ឋកិច្ច ផ្នែកផ្លូវកាយ ផ្លូវចិត្ត អាកប្បកិរិយា ព្រមទាំងឥរិយាបថខាងក្រៅដូចប្តីប្រពន្ធទូទៅផងដែរ។ ប៉ុន្តែមិនតម្រូវឲ្យរៀបចំជាពិធីអ្វីឡើយ។ ដូច្នេះជាទូទៅមិនមានភាពច្បាស់លាស់ថា តើពេលណាអនីតិសង្វាសបានចាប់ផ្តើម និង ពេលណាបានបញ្ចប់នោះទេ។ ដើម្បីកំណត់ពីអំឡុងពេលនៃអនីតិសង្វាស តុលាការត្រូវពិចារណាទៅលើអង្គហេតុតាមករណីនីមួយៗ។

### ៤.៤. ការអនុវត្តមាត្រាស្រដៀងស្តីពីប្តីប្រពន្ធអនីតិសង្វាសនៅក្នុងក្រមរដ្ឋប្បវេណី (អានុភាពនៃអនីតិសង្វាស)

#### ៤.៤.១. លក្ខណៈទូទៅ

ជាក់ស្តែងអនីតិសង្វាសមិនត្រូវបានទទួលស្គាល់ដោយច្បាប់នោះទេ។ ប៉ុន្តែច្បាប់ក៏មិនអាចបោះបង់អនីតសង្វាសចោល ដោយមិនពិចារណាដល់ផលប៉ះពាល់ចំពោះបុគ្គលដែលទន់ខ្សោយរងគ្រោះក្នុងជីវិតប្តីប្រពន្ធអនីតិសង្វាសបានឡើយ។ ហេតុនេះច្បាប់ត្រូវមានកិច្ចការពារដល់ទំនាក់ទំនងប្តីប្រពន្ធដែលគ្មានចំណងអាពាហ៍ពិពាហ៍ ដោយអនុវត្តនូវបទបញ្ញត្តិទាំងឡាយណាដែលមានលក្ខណៈប្រហាក់ប្រហែល តែត្រូវមានល័ក្ខខ័ណ្ឌពីរ ដែលអនីតិសង្វាសត្រូវបំពេញដូចជាៈ

- ល័ក្ខខ័ណ្ឌផ្នែកឆន្ទៈ ៖ គឺបុគ្គលអនីតិសង្វាសត្រូវមានឆន្ទៈដូចប្តីប្រពន្ធ(ឆន្ទៈសហព័ទ្ធ)ពិតៗ។
- កត្តាខាងក្រៅ ៖ ការរស់នៅដូចប្តីប្រពន្ធស្របច្បាប់ គឺមានជីវភាពរួមគ្នា ទាំងផ្លូវចិត្តផ្លូវកាយ រស់ក្រោមដំបូលផ្ទះតែមួយ។

ដោយសារតែអនីតិសង្វាសគឺជាអាពាហ៍ពីពាហ៍មិនស្របច្បាប់ នៅក្នុងក្រមរដ្ឋប្បវេណីមិនមានចែងអំពីអាពាហ៍ពិពាហ៍អនីតិសង្វាសនេះទេ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីការពារដល់ប្តី

ប្រពន្ធអនីតិសង្វាស យើងអាចយកមាត្រាពាក់ព័ន្ធខ្លះដែលស្តីពីអាពាហ៍ពិពាហ៍ស្របច្បាប់នៃក្រម រដ្ឋប្បវេណីមកអនុវត្តបាន។

មិនមានវិធានណាចែងចំពោះការជ្រើសរើសមាត្រាដែលអាចយកមកអនុវត្តនោះទេ ពីព្រោះវាអាស្រ័យទៅលើការបកស្រាយទាំងស្រុង។ ថ្វីត្បិតតែមាត្រានៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន មិនដូចគ្នានឹងមាត្រានៃក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាក៏ដោយ នៅក្នុងប្រទេសជប៉ុន ជាទូទៅគេបកស្រាយដូចខាងក្រោមនេះ។ ជាទូទៅមាត្រាស្តីពីទំនាក់ទំនងផ្ទៃក្នុងរបស់ប្តីប្រពន្ធ អាចយកមកអនុវត្តបាន។ ផ្ទុយទៅវិញ មិនគួរយកមាត្រាដែលពាក់ព័ន្ធនឹងតតិយជនមកអនុវត្តនោះឡើយ។

ការបកស្រាយនៅប្រទេសកម្ពុជា ត្រូវផ្អែកទៅតាមការអនុវត្តនៅក្នុងប្រទេសកម្ពុជា។

**៩.៤.២. មាត្រាពាក់ព័ន្ធដែលអាចយកមកអនុវត្តបាន**

**ក. ករណីយកិច្ចរួមរស់នឹងគ្នា និង សហការគ្នា និង សង្គ្រោះគ្នាទៅវិញទៅមក**

ប្តីប្រពន្ធអនីតិសង្វាស ត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ និង សង្គ្រោះគ្នាទៅវិញទៅមក(មាត្រា៩៦៦) នៃក្រមរដ្ឋប្បវេណី)។ ដូចនេះប្រសិនបើភាគីណាបំពាននឹងករណីយកិច្ចនេះភាគីនោះ ត្រូវទទួលខុសត្រូវលើសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលនោះ (មាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណី)។

**ខ. សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម**

ប្តីប្រពន្ធអនីតិសង្វាស មានភាពស្មើគ្នាក្នុងការប្រកបរបរការងារ ឬ ចូលរួមក្នុងសកម្មភាពសង្គម ដូចប្តីប្រពន្ធស្របច្បាប់ (មាត្រា៩៦៧ នៃក្រមរដ្ឋប្បវេណី)។

**គ. ករណីយកិច្ចចែករំលែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍**

ប្តីប្រពន្ធអនីតិសង្វាស ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលបានចំណាយសម្រាប់អាពាហ៍ពិពាហ៍(មាត្រា៩៧១ នៃក្រមរដ្ឋប្បវេណី)។

**ឃ. ប្រព័ន្ធនៃទ្រព្យសម្បត្តិដោយឡែក ទ្រព្យសម្បត្តិរួម និងការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ**

នៅពេលដែលអនីតិសង្វាសត្រូវបានរំលាយ ទ្រព្យសម្បត្តិដែលកើតមានឡើងក្នុងអំឡុងពេលអនីតិសង្វាស ត្រូវធ្វើការបែងចែក(មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ មាត្រាដែលស្តីអំពីប្រព័ន្ធនៃទ្រព្យសម្បត្តិដោយឡែក និង ទ្រពសម្បត្តិរួមក៏ត្រូវយកមកអនុវត្តផងដែរ ពីព្រោះថាប្រព័ន្ធនៃ

ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម គឺជាមូលដ្ឋាននៃការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ(មាត្រា៩៧២ និង មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី)។

**ង. ការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្តីប្រពន្ធ**

ប្រសិនបើ មាត្រានៃទ្រព្យសម្បត្តិរួម (មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី) ត្រូវបានយកមកអនុវត្តក្នុងអនីតិសង្វាស នោះមាត្រាស្តីពីការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្តីប្រពន្ធ(មាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី) ក៏អាចយកមកអនុវត្តបានផងដែរ ដោយសារតែប្រព័ន្ធទាំងពីរមានទំនាក់ទំនងនឹងគ្នាយ៉ាងខ្លាំង។ គោលគំនិតគឺៈ *ប្រសិនបើទ្រព្យសម្បត្តិដែលត្រូវបានទិញ ក្លាយជាទ្រព្យរួមនោះ កាតព្វកិច្ចនៃការបង់សោហ៊ុយលើការទិញទ្រព្យសម្បត្តិនោះ គួរតែជាការទទួលខុសត្រូវដោយសាមគ្គីភាពផងដែរ*។

**ច. មាត្រាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងប្រព័ន្ធទ្រព្យសម្បត្តិរួម**

ក្រមរដ្ឋប្បវេណីចែងនូវមាត្រាស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែងទ្រព្យសម្បត្តិរួម (មាត្រា៩៧៤ មាត្រា៩៧៦ និង មាត្រា៩៧៧ នៃក្រមរដ្ឋប្បវេណី)។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនមិនមានមាត្រាដូចនឹងមាត្រាខាងលើនេះទេ។ ដូច្នេះ តើផ្នែកមួយណាដែលគួរយកមកអនុវត្ត និង មិនគួរយកមកអនុវត្ត គឺត្រូវផ្អែកទៅលើការអនុវត្តនៅក្នុងប្រទេសកម្ពុជា។

**៩.៩.៣. មាត្រាដែលមិនត្រូវយកមកអនុវត្ត**

**ក. ការសន្មតបិតុភាព និង អំណាចមេបា**

កូនរបស់ប្តីប្រពន្ធអនីតិសង្វាស មិនត្រូវបានសន្មតថាជាកូនរបស់បុរសដែលជាប្តីនោះទេ (មាត្រា៩៨៨ នៃក្រមរដ្ឋប្បវេណីមិនត្រូវបានយកមកអនុវត្តឡើយ)។

ដើម្បីបង្កើតទំនាក់ទំនងរវាងឪពុក និង កូន គឺចាំបាច់ត្រូវមានការទទួលស្គាល់(មាត្រា៩៩៣ នៃក្រមរដ្ឋប្បវេណី)។

ក្នុងករណីដែលប្តីប្រពន្ធអនីតិសង្វាសមានកូន ហើយឪពុកបានទទួលស្គាល់កូននោះក៏ដោយ ក៏អំណាចមេបាមិនត្រូវបានប្រើប្រាស់ដោយសហការគ្នានោះទេ (មាត្រា១០៣៦ នៃក្រមរដ្ឋប្បវេណី មិនត្រូវបានយកមកអនុវត្តឡើយ)។ ជាគោលការណ៍អំណាចមេបាត្រូវប្រើប្រាស់ដោយម្តាយ (មាត្រា១០៣៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ឪពុកអាចប្រើប្រាស់បានលុះត្រាតែ មានការពិភាក្សា ឬ មានដីកាសម្រេចរបស់តុលាការដែលបានកំណត់យកឪពុកនោះជាអ្នកមានអំណាចមេបាតែប៉ុណ្ណោះ (មាត្រា១០៣៨ កថាខណ្ឌទី២ និង ទី៣ នៃក្រមរដ្ឋប្បវេណី។

### ខ. អត្តាធីនភាពនៃកូនដែលជាអនីតិជន

អត្តាធីនភាព មិនកើតឡើងចំពោះការបង្កើតអនីតិសង្វាសនោះទេ (មាត្រា២១ កថាខណ្ឌទី២ មិនត្រូវបានយកមកអនុវត្តឡើយ)។

### គ. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្រមរដ្ឋប្បវេណីចែងអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ(មាត្រា៩៦៩ និង មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណី)។ កិច្ចសន្យានេះមានលក្ខណៈពិសេស ពីព្រោះអានុភាពនៃកិច្ចសន្យានេះអាចយកមកតតាំងជាមួយតតិយជនបាន (មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណី)។ ដើម្បីអោយកិច្ចសន្យាមានអានុភាពពិសេសនេះ ត្រូវបំពេញតាមល័ក្ខខ័ណ្ឌដូចតទៅៈ

១/ គូភាគី ត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា

២/ កិច្ចសន្យានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ

៣/ កិច្ចសន្យាត្រូវចុះបញ្ជី។

ប្តីប្រពន្ធអនីតិសង្វាស មិនអាចចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានចែងក្នុងក្រមរដ្ឋប្បវេណីបានទេ ដោយសារតែប្តីប្រពន្ធអនីតិសង្វាស មិនបានបំពេញល័ក្ខខ័ណ្ឌទី១ឡើយ។ ប្តីប្រពន្ធអនីតិសង្វាសអាចធ្វើកិច្ចសន្យាចំពោះទ្រព្យសម្បត្តិរបស់ពួកគេបាន ប៉ុន្តែកិច្ចសន្យានេះមិនមែនជាកិច្ចសន្យាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឡើយ។

ពួកគេអាចចុះបញ្ជីទ្រព្យសម្បត្តិនេះ នៅសារការីអាស្រ័យលើខ្លឹមសារជាលក្ខណៈឯកជន (មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី)។

### គ. សន្តតិកម្ម

ប្តីប្រពន្ធអនីតិសង្វាស មិនអាចទទួលសន្តតិកម្មពីគ្នាបានឡើយ (មាត្រាស្តីពីសន្តតិកម្ម មិនត្រូវអនុវត្តឡើយ)។ពីព្រោះអាពាហ៍ពិពាហ៍របស់ពួកគេមិនស្របតាមបញ្ញត្តិនៃអាពាហ៍ពិពាហ៍។ ប៉ុន្តែអាចអនុវត្តបានលើជនដែលមាននិស្ស័យពិសេស តាមមាត្រា១២៩៩ នៃក្រមរដ្ឋប្បវេណី។

## ៤.៤.៤. ការរំលាយអនីតិសង្វាស

អនីតិសង្វាស ត្រូវរំលាយក្រោយពីភាគីបានព្រមព្រៀងបញ្ចប់ទំនាក់ទំនងក្នុងការរស់នៅជាប្តីប្រពន្ធនោះ។ លើសពីនេះទៀត ទោះបីជា ភាគីទាំងសងខាងមិនបានយល់ព្រមក៏ដោយ ប្រសិនបើភាគីម្ខាងបានបញ្ចប់ទំនាក់ទំនាងដោយឯកតោភាគី នោះអនីតិសង្វាសនឹងត្រូវរំលាយ។ មូលហេតុ

គឺ ដោយសារតែល័ក្ខខ័ណ្ឌនៅក្នុងបង្កើតអនីតិសង្វាស គឺជាឆន្ទៈ និងស្ថានភាពខាងក្រៅរបស់ភាគីអនីតិសង្វាសត្រូវបានរលត់។ នៅក្នុតការរំលាយអនីតិសង្វាស មិនត្រូវតម្រូវឲ្យមានមូលហេតុនៃការរំលាយ អន្តរាគមន៍ពីតុលាការនោះទេ។ តាមន័យនេះយើងអាចនិយាយបានថាមាត្រានៃក្រមរដ្ឋប្បវេណីដែលចែងអំពីល័ក្ខខ័ណ្ឌ និង នីតិវិធីនៃការលែងលះ (មាត្រា៩៧៨ និង ៩៧៩ នៃក្រមរដ្ឋប្បវេណី) មិនត្រូវបានយកមកអនុវត្តនោះទេ។

ប្រសិនបើពិចារណាចំពោះករណីដែលភាគីម្ខាងចាកចេញពីភាគីម្ខាងទៀតដោយហេតុផលសមរម្យណាមួយនោះ វានឹងពិតជាគួរអោយអាណិតណាស់ចំពោះភាគីដែលត្រូវបានគេបោះបង់អនីតិសង្វាស នៅតែត្រូវបានរំលាយ ទោះបីស្ថិតក្នុងករណីបែបនេះក៏ដោយ។ ភាគីដែលត្រូវបានគេបោះបង់នោះ អាចទទួលបានការការពារតាមរយៈសំណងជម្ងឺចិត្តដោយផ្អែកលើអំពើអនីត្យានុកូល (មាត្រា៧៩៣ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើ ប្តីប្រពន្ធអនីតិសង្វាសដាក់ពាក្យបណ្តឹង ឬ ពាក្យសុំលែងលះ តុលាការត្រូវលើកចោលពាក្យបណ្តឹង ឬ ពាក្យសុំនោះ ពីព្រោះថាមិនមានផលប្រយោជន៍នៃបណ្តឹងឡើយ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាមានគ្រួសារជាច្រើនរស់នៅជាអនីតិសង្វាស ហើយពួកគេត្រូវការការបញ្ជាក់ពីតុលាការទៅលើការរំលាយអនីតិសង្វាសរបស់ពួកគេ ដើម្បីបំពេញតាមភាពចាំបាច់នៃសង្គម និងភាពចាំបាច់ជាក់ស្តែង ជាពិសេសដើម្បីរៀបអាពាហ៍ពិពាហ៍ម្តងទៀត។ ដូច្នេះ គឺផ្អែកទៅតាមការអនុវត្តនៅក្នុងសង្គមកម្ពុជា។ ប៉ុន្តែមានគំនិតមួយដែលអាចជួយដល់ភាគីទាំងនោះបាន ប្រសិនបើមានការដាក់ពាក្យសុំ ឬ បណ្តឹងលែងលះ ចៅក្រមត្រូវលើកចោលពាក្យបណ្តឹង ឬ ពាក្យសុំនោះ ប៉ុន្តែចៅក្រមអាចលើកឡើងអំពីអង្គហេតុនៃការរំលាយអនីតិសង្វាស និងរៀបរាប់ពីសិទ្ធិរបស់ភាគីនីមួយៗនៅក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីទៅក្នុងសំអាងហេតុនៃដីកាសម្រេច ឬ សាលក្រមរបស់តុលាការ។

ដោយឡែកអនីតិសង្វាសក៏អាចត្រូវបានបញ្ចប់ក្នុងករណីខ្លះដូចជា៖ ភាគីបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់ ការប្រកាសបាត់ខ្លួន ភាគីអនីតិសង្វាសណាមួយទទួលមរណភាពជាដើម។

# ផ្នែកទី ៥
# អាហារកាតព្វកិច្ច

## ១. សេចក្តីផ្តើម

នៅពេលដែលបុគ្គលម្នាក់ មិនមានសមត្ថភាពអាចទ្រទ្រង់ចិញ្ចឹមជីវិតខ្លួនឯងបាន បុគ្គលនោះត្រូវការជំនួយសង្គ្រោះពីអ្នកដទៃ ដើម្បីតម្រូវចាំបាច់ក្នុងជីវភាពរស់នៅ។ រដ្ឋ មានកាតព្វកិច្ចជួយសង្គ្រោះជនក្រីក្រ ក្នុងនាមជាការឧបត្ថម្ភសង្គមកិច្ច ហៅថា អាហារកាតព្វកិច្ចសាធារណៈ។ យ៉ាងណាមិញក្នុងជីវភាពរស់នៅសព្វថ្ងៃ បុគ្គលនីមួយៗមានទំនាក់ទំនងគ្នារវាងញាតិ ដែលតែងមានការផ្គត់ផ្គង់ និងជួយសង្គ្រោះគ្នាទៅវិញទៅមក តាមទំនៀមទំលាប់ កតញ្ញូតាធម៌ និងមនោសញ្ចេតនាជាដើម។ ការផ្គត់ផ្គង់បែបនេះ ជាការផ្គត់ផ្គង់លក្ខណៈឯកជនក្នុងទំនាក់ទំនងញាតិ ដែលត្រូវបានហៅថា អាហារកាតព្វកិច្ចឯកជនតាមក្រមរដ្ឋប្បវេណី។ ច្បាប់តម្រូវឲ្យជនដែលមានលទ្ធភាព ត្រូវមានកាតព្វកិច្ចក្នុងការជួយផ្គត់ផ្គង់ដល់ញាតិ ដែលស្ថិតក្នុងស្ថានភាពក្រីក្រលំបាក ដើម្បីអាចទ្រទ្រង់ជីវភាពរស់នៅបាន។ អាហារកាតព្វកិច្ចឯកជន មានបីប្រភេទ គឺអាហារកាតព្វកិច្ចក្នុងទំនាក់ទំនងរវាងឪពុកម្តាយ និងកូនជាអនីតិជន អាហារកាតព្វកិច្ចក្នុងទំនាក់ទំនងសហព័ទ្ធ និងអាហារកាតព្វកិច្ច ក្នុងទំនាក់ទំនងញាតិ។

ករណីយកិច្ចផ្គត់ផ្គង់ពីឪពុកម្តាយ ចំពោះកូនជាអនីតិជន គឺជាអានុភាពនៃអំណាចមេបា ដែលអ្នកមានអំណាចមេបា មានករណីយកិច្ចជាមូលដ្ឋាន ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ដូចមានចែងក្នុងមាត្រា១០៣៤ នៃក្រមរដ្ឋប្បវេណី។ រីឯករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច រវាងសហព័ទ្ធ កើតចេញពីអានុភាពនៃចំណងអាពាហ៍ពិពាហ៍ ដែលសហព័ទ្ធមានករណីយកិច្ចសហការ និងសង្គ្រោះគ្នាទៅវិញទៅមក ដូចមានចែងក្នុងមាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី។ ដោយឡែកចំពោះអាហារកាតព្វកិច្ចក្នុងទំនាក់ទំនងញាតិ គឺជាករណីយកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច ដែលកើតចេញពីទំនាក់ទំនងញាតិក្នុងទំហំដែលច្បាប់កំណត់ដូចមានចែងចាប់ពីមាត្រា១១៤០ ដល់មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណី។

យ៉ាងណាមិញនៅក្នុងខ្លឹមសារនៃអត្ថបទនេះ ផ្តោតសំខាន់តែចំពោះអាហារកាតព្វកិច្ចដែលកើតចេញពីទំនាក់ទំនងញាតិប៉ុណ្ណោះ។ ហេតុដូច្នេះ ថាតើអ្វីជាអាហារកាតព្វកិច្ច? តើជនណាខ្លះដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច? ហើយជនណាខ្លះ មានកាតព្វកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច? តើអាហារកាតព្វកិច្ចត្រូវផ្តល់ក្នុងកម្រិតណា ដោយរបៀបណា និងត្រូវគណនាយ៉ាងដូចម្តេច? ហើយករណីដែលជនមានករណីយកិច្ចមិនផ្តល់អាហារកាតព្វកិច្ចនេះ តើអាចនឹងទទួលទណ្ឌកម្មអ្វីខ្លះ?

## ២.សញ្ញាណនៃអាហារកាតព្វកិច្ច

### ២.១ អាហារកាតព្វកិច្ច

សំដៅទៅលើ កាតព្វកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។ អាហារកាតព្វកិច្ច សំដៅដល់ជំនួយហិរញ្ញវត្ថុ ឬសម្ភារៈផ្សេងៗ ដែលត្រូវផ្តល់ដោយជនត្រូវផ្តល់អាហារកាតព្វកិច្ច (ហៅថា **ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច)** ដល់បុគ្គលជាញាតិ (ហៅថា **ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច**) ដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន ហើយបុគ្គលនោះមានសិទ្ធិទទួលការផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមល័ក្ខខ័ណ្ឌកំណត់។

អាហារកាតព្វកិច្ច ត្រូវផ្តល់ឲ្យដោយជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ដល់ញាតិរបស់ខ្លួន ដែលគ្មានលទ្ធភាព ឬធនធានគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការមូលដ្ឋានចាំបាច់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដូចជាម្ហូបអាហារ សំលៀកបំពាក់ ទីជំរក សុខុមាសភាព និងការអប់រំជាមូលដ្ឋាន ជាដើម។

ឧទាហរណ៍: កូនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកម្តាយ ដែលចាស់ជរាដូចជាម្ហូបអាហារ សំលៀកបំពាក់ ការស្នាក់នៅ និងមើលថែសុខភាពជាដើម។

**២.២. ល័ក្ខខ័ណ្ឌនៃការអនុវត្តការផ្គត់ផ្គង់អាហារកាតព្វកិច្ច** : មានពីរសំខាន់គឺ

- **ទី១**: ជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ច ត្រូវស្ថិតក្នុងស្ថានភាពក្រីក្រ លំបាក ហើយខ្លួនគ្មានលទ្ធភាព អាចផ្គត់ផ្គង់ជីវភាពខ្លួនឯងបានទាំងស្រុង ឬមួយផ្នែក ដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬសមត្ថភាពនៃការធ្វើការងារដោយខ្លួនឯង។ និងត្រូវមានបន្ទុកបង្ហាញភស្តុតាងពីអលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅខ្លួនឯង។
- **ទី២**: ជនដែលមានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវមានលទ្ធភាព ឬ មធ្យោបាយហិរញ្ញវត្ថុ អាចផ្តល់ជំនួយសង្គ្រោះបាន ។

**២.៣. ចរិកលក្ខណៈនៃអាហារកាតព្វកិច្ច**

- ជាសិទ្ធិផ្តាច់មុខផ្ទាល់របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច (មាត្រា ១១៩៤ នៃក្រមរដ្ឋប្បវេណី)

- ការផ្តត់ផ្គង់អាហារកាតព្វកិច្ចត្រូវផ្អែកលើគោលការណ៍នៃការពិភាក្សាគ្នាទៅវិញទៅមក (មាត្រា១១៩១ ១១៩២ និង១១៩៣ នៃក្រមរដ្ឋប្បវេណី)

- ទំហំ ឬកម្រិតនៃការផ្គត់ផ្គង់ អាចត្រូវបានប្រែប្រួល ឬផ្លាស់ប្តូរ ឬលុបចោល តាមការព្រមព្រៀង ឬតាមសេចក្តីសម្រេចរបស់តុលាការ ដោយអាស្រ័យទៅលើធនធានរបស់ជនមានករណីយកិច្ច ឬ តម្រូវការចាំបាច់របស់ជនមានសិទ្ធិទទួល (មាត្រា១១៩៣ នៃក្រមរដ្ឋប្បវេណី)

- អាហារកាតព្វកិច្ច មិនអាចជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬជំនួញផ្សេងៗទៀតបានឡើយ (មាត្រា ១១៩៤ នៃក្រមរដ្ឋប្បវេណី) ឬ សូម្បីតែធ្វើអនុប្បទានទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចផ្សេងទៀត ឬជនដែលមានប្រយោជន៍ផ្សេងទៀតបានទេ

- អាហារកាតព្វកិច្ចមានអានុភាពឆ្ពោះទៅអនាគត មិនអាចទាមទារអាហារកាតព្វកិច្ច ដែលកើតមានក្នុងអតីតកាលបានទេ

- អាហារកាតព្វកិច្ច មិនអាចត្រូវបានរឹបអូស (មាត្រា ៣៨២ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី)

- មិនអាចធ្វើឧបាទេសកម្មបាន (មាត្រា ៤២២ ក្រមរដ្ឋប្បវេណី)

- មិនអាចធ្វើសន្តតិកម្មបន្ត (មាត្រា ១១៩៧ ក្រមរដ្ឋប្បវេណី)

- លំដាប់របស់អ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ចមិនត្រូវបានកំណត់ទេ ប៉ុន្តែមានកំណត់លំដាប់អ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា ១១៩០ នៃក្រមរដ្ឋប្បវេណី)

## ៣.ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច

ជនដែលមិនអាចទ្រទ្រង់ជីវភាពក្នុងកម្រិតអប្បបរមា ហើយមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីញាតិរបស់ខ្លួន ហៅថា **ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច**។

តាមក្រមរដ្ឋប្បវេណី ពុំមានចែងឲ្យបានច្បាស់អំពីជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចទេ ដោយមានចែងតែអំពីជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចប៉ុណ្ណោះ ហេតុដូច្នេះថាតើអ្នកណាជាជនដែលមានសិទ្ធិទទួលការផ្គត់ផ្គង់អាហារកាតព្វកិច្ច។ ចំណុចនេះគេអាចធ្វើ

ការបេកស្រាយ ដោយទាញចេញពីជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមមាត្រា ១១៩០ នៃក្រមរដ្ឋប្បវេណី ដើម្បីកំណត់រកជន ដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចបាន គឺសំដៅទៅលើសមាជិកគ្រួសារ ឬ ជនដែលមានទំនាក់ទំនងញាតិនឹងគ្នាដែលគ្មានលទ្ធភាពឬ ធនធានគ្រប់គ្រាន់ ហើយដែលមានតម្រូវការមូលដ្ឋានចាំបាច់ដែលខានមិនបានសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ដូចជាអាហារ សំលៀកបំពាក់ ទីជំរក សុខភាព និងការអប់រំជាមូលដ្ឋាន ជាដើម។ ជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ច ត្រូវមានលក្ខណៈស្របគ្នានឹងជនដែលមានករណីយកិច្ចដែរ មានន័យថា ត្រូវតែជាញាតិរស់នៅជាមួយនឹងជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ជាញាតិលោហិតខ្សែផ្ទាល់ ជាបងប្អូនបង្កើត (មាត្រា១១៩០ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី) ប៉ុន្តែជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចនេះមិនត្រូវបានកំណត់លំដាប់ដូចជនដែលមានករណីយកិច្ចទេ។ លើសពីនេះ ញាតិថ្នាក់ទីបី ក៏អាចមានសិទ្ធិទាមទារអាហារកាតព្វកិច្ចបានដែរ ក្នុងករណីដែលជននោះ ពុំមានជនដែលមានករណីយកិច្ចដូចរៀបរាប់ខាងលើទេ (មាត្រា១១៩០ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ : លោក A គឺជាជនក្រីក្រ ចាស់ជរា គ្មានកូន ហើយគាត់រស់នៅជាមួយក្មួយប្រុសបង្កើត ហើយមានប្អូនប្រុសបង្កើតម្នាក់រស់នៅឆ្ងាយពីគាត់ ប៉ុន្តែមានជីវភាពធូរធា គាត់អាចទាមទារឲ្យក្មួយគាត់ជាញាតិដែលរស់នៅជាមួយគ្នា ឬប្អូនប្រុសរបស់គាត់ផ្គត់ផ្គង់អាហារកាតព្វកិច្ចឲ្យគាត់បាន។ ករណីនេះក្មួយប្រុស និងប្អូនប្រុសរបស់លោក A ត្រូវពិភាក្សាគ្នាកំណត់ជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់លោក A បើពិភាក្សាមិនបានត្រូវដាក់ពាក្យសុំទៅតុលាការពិចារណា និងសម្រេច។

ដោយឡែក ក្នុងករណីជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មានពីរ ឬច្រើននាក់ ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវផ្គង់ផ្គង់ដល់ជនទាំងអស់ដែលមានសិទ្ធិទាមទារនោះ ប៉ុន្តែបញ្ហាចោទឡើងថា ក្នុងករណីដែលជនដែលមានករណីយកិច្ចផ្គត់ផ្គង់គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ ទៅជនទាំងអស់នោះ តើត្រូវធ្វើយ៉ាងដូចម្ដេច?

ករណីខាងលើនេះតាមក្រមរដ្ឋប្បវេណី មាត្រា១១៩១ កថាខណ្ឌទី៣បានតម្រូវឲ្យមានការពិភាក្សារវាងភាគីដែលពាក់ព័ន្ធដើម្បីសម្រេចស្របតាមគោលការណ៍ពិភាក្សាគ្នាទៅវិញទៅមក លុះត្រាតែមិនអាចពិភាក្សាបាន ទើបត្រូវសុំទៅតុលាការដើម្បីកំណត់ជនដែលមានសិទ្ធិទទួលការទាមទារជាក់លាក់ ដោយពិចារណាលើទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ទំនាក់ទំនងបុគ្គលរបស់ភាគី និងស្ថានភាពផ្សេងទៀតជាដើម។

## ៣.១ សិទ្ធិទាមទារអាហារកាតព្វកិច្ច

សិទ្ធិទាមទារអាហារកាតព្វកិច្ចគឺជាសិទ្ធិទាមទារការផ្គត់ផ្គង់តម្រូវការជីវភាពចាំបាច់ របស់ជនដែលត្រូវទទួលអាហារកាតព្វកិច្ច ពីជនដែលមានករណីយកិច្ចផ្គត់ផ្គង់។ សិទ្ធិនេះ មានភាពផ្តាច់មុខ និងជាសិទ្ធិនៃបុគ្គលផ្ទាល់ខ្លួន ដែលមិនអាចយកមកធ្វើជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគ ឬជំនួញផ្សេងៗទៀត ជាមួយតតិយជនបានឡើយ (មាត្រា១១៩៤ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះ សិទ្ធិនេះមិនអាចត្រូវរឹបអូស (មាត្រា៣៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មិនអាចធ្វើឧបាទេសកម្ម (មាត្រា៤២២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) មិនអាចធ្វើសន្តិកម្មបន្តបាន (មាត្រា១១៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

បុគ្គលគ្រប់រូបមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីជនណាម្នាក់បាន លុះត្រាតែបំពេញនូវល័ក្ខខ័ណ្ឌពីរ គឺទី១ ស្ថិតក្នុងទំនាក់ទំនងញាតិ ដូចមានកំណត់ក្នុងមាត្រា១១៩០ នៃក្រមរដ្ឋប្បវេណី និងទី២ ត្រូវមានភស្តុតាងបញ្ជាក់អំពីអលទ្ធភាពក្នុងការទ្រទ្រង់ជីវភាព ជាពិសេសអលទ្ធភាពក្នុងការបំពេញតម្រូវការចាំបាច់អប្បបរមាក្នុងជីវភាពរបស់ខ្លួន បើពុំដូច្នេះទេ មិនមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីជនមានករណីយកិច្ចបានទេ។

ដោយឡែក ចំពោះញាតិពន្ធ ទោះបីជាសហព័ទ្ធម្ខាង បានទទួលមរណភាព ដែលនាំឲ្យអាពាហ៍ពិពាហ៍ត្រូវរលាយក៏ដោយ ក៏ទំនាក់ទំនងញាតិពន្ធ មិនត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិទេ (មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណី) ហេតុដូច្នេះការផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវយកមកអនុវត្តដូចគ្នាសម្រាប់សហព័ទ្ធដែលនៅរស់ និងញាតិរបស់សហព័ទ្ធដែលបានស្លាប់ (មាត្រា១១៩០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ (មាត្រា៩៨១កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) តើជននោះនៅតែមានករណីយកិច្ចផ្គត់ផ្គង់ញាតិរបស់សហព័ទ្ធដែលស្លាប់ ឬទេ? ថាតើការបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិនេះ ធ្វើឡើងតាមវិធីបែបណា? តាមផ្លូវតុលាការ ឬក្រៅផ្លូវតុលាការ?

ករណីនេះអាចបកស្រាយថា មិនមានកាតព្វកិច្ចទេ ព្រោះទំនាក់ទំនងញាតិត្រូវបានបញ្ចប់ ហេតុដូច្នេះសហព័ទ្ធដែលនៅរស់ មិនមានកាតព្វកិច្ចចំពោះជនដែលមិនមែនជាញាតិទេ ប៉ុន្តែផ្ទុយមកវិញបើធ្វើការបកស្រាយថា មិនមានកាតព្វកិច្ចដោយសារទំនាក់ទំនងញាតិត្រូវបានរលត់នោះ ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំង ដល់គោលបំណងបញ្ញត្តិអាហារកាតព្វកិច្ចសម្រាប់ជន ដែលមិនមានលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពខ្លួនឯង ហើយអាចឲ្យសហព័ទ្ធដែលនៅរស់ មានចេតនាទុច្ចរិត

គេចវេសពីកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ច ចំពោះញាតិរបស់សហព័ទ្ធដែលស្លាប់ ដោយធ្វើការបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិ។

### ៣.២ ការទាមទារអាហារកាតព្វកិច្ចរបស់អតីតសហព័ទ្ធ

យ៉ាងណាមិញ ក្នុងករណីដែលចំណងអាពាហ៍ពិពាហ៍ត្រូវបញ្ចប់ ដោយសារការលែងលះគ្នា ករណីយកិច្ចនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច និងករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក ត្រូវបានបញ្ចប់ ដោយសារចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្តាច់ ពីព្រោះការលែងលះនាំឲ្យផ្តាច់ទំនាក់ទំនងញាតិរវាងភាគីទាំងសងខាង (មាត្រា៩៩១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ហេតុដូច្នេះអតីតសហព័ទ្ធ ឬអតីតញាតិពន្ធទាំងនោះ មិនមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីអតីតសហព័ទ្ធម្ខាងទៀតទេ។ ប៉ុន្តែក្នុងក្រមព្រហ្មទណ្ឌ បានបញ្ញត្តថា ការមិនផ្តល់កាតព្វកិច្ចចំពោះអតីតសហព័ទ្ធ តាមសេចក្តីសម្រេចរបស់តុលាការ គឺជាបទល្មើសមជ្ឈិម ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣២៤ នៃក្រមព្រហ្មទណ្ឌ។ មាត្រានេះហាក់មានន័យថា អតីតសហព័ទ្ធមានសិទ្ធិប្តឹងទៅតុលាការទាមទារឲ្យអតីតសហព័ទ្ធម្ខាងទៀត ផ្តល់អាហារកាតព្វកិច្ចមកដល់ខ្លួនបាន ទោះបីចំណងអាពាហ៍ពិពាហ៍ត្រូវបានរលាយក៏ដោយ។ ជាចំណោទបញ្ហាថាតើតុលាការដែលទទួលបណ្តឹងទាមទារអាហារកាតព្វកិច្ចនោះ ត្រូវសម្រេចអំពីការផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់អតីតសហព័ទ្ធ ផ្អែកលើច្បាប់សារធាតុអ្វី?

**ចំណោទបញ្ហាផ្សេងទៀតចំពោះសិទ្ធិទាមទារអាហារកាតព្វកិច្ច :**

១.ក្នុងអំឡុងពេលផ្គត់ផ្គង់អាហារកាតព្វកិច្ច ជនដែលមានសិទ្ធិបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែនៅតែមិនអាចទ្រទ្រង់ជីវភាពដោយខ្លួនឯងបាន រួមទាំងសហព័ទ្ធខ្លួនផង តើជននោះ និងសហព័ទ្ធនៅតែមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីជនដែលមានករណីយកិច្ច ដែរ ឬទេ?

២. ក្នុងករណីដែលជនដែលមានករណីយកិច្ច បានរៀបអាពាហ៍ពិពាហ៍ និងមានកូនត្រូវទទួលបន្ទុក តើជននោះនៅតែមានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដល់ញាតិដែលមិនអាចទ្រទ្រង់ជីវភាពរបស់ខ្លួនបាន ឬទេ?

### ៤. ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច

ជនដែលត្រូវផ្តល់អាហារកាតព្វកិច្ច ដល់ញាតិដែលមិនអាចទ្រទ្រង់ជីវភាពបាន ហៅថា **ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច**។ ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវធ្វើការផ្គត់ផ្គង់ហិរញ្ញវត្ថុ ឬសម្ភារៈផ្សេងទៀត តាមមធ្យោបាយណាមួយសមស្រប ទៅឲ្យជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ក្នុងករណីជននោះអលទ្ធភាព មិនអាចចិញ្ចឹមខ្លួនឯងបាន សម្រាប់

តម្រូវការជីវភាពរស់នៅអប្បបរមា។ ទោះយ៉ាងណាក៏ដោយ មិនមែនមានន័យថា គ្រប់ទំនាក់ទំនងញាតិទាំងអស់ សុទ្ធតែផ្តល់ករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចនោះទេ។ ជាទូទៅញាតិដែលរស់នៅជាមួយគ្នា (លំដាប់ទីមួយ) ញាតិលោហិតខ្សែផ្ទាល់ (លំដាប់ទីពីរ) និងបងប្អូនបង្កើត (លំដាប់ទីបី) របស់ជនដែលត្រូវទទួលអាហារកាតព្វកិច្ច គឺជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។ នៅក្នុងករណីខ្លះ តុលាការមានសិទ្ធិក្នុងការតែងតាំងជនផ្សេងទៀត ជាជនដែលមានករណីយកិច្ចត្រូវផ្គង់ផ្គង់អាហារកាតព្វកិច្ចបាន ដរាបណាជនដទៃនោះមានទំនាក់ទំនងយ៉ាងហោចណាស់ស្ថិតក្នុងទំហំញាតិក្នុងថ្នាក់ទីបី ជាមួយនឹងជនដែលត្រូវទទួលអាហារកាតព្វកិច្ច (មាត្រា ១១៩០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានពីរប្រភេទ គឺ :

**ទី១ : ជនមានករណីយកិច្ចតាមច្បាប់កំណត់ មានលំដាប់ខាងក្រោម :**

- **លំដាប់ទី១ :** ញាតិដែលរស់នៅជាមួយគ្នា (មាត្រា១១៩០ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណី)
- **លំដាប់ទី២** : ញាតិលោហិតខ្សែផ្ទាល់ (មាត្រា១១៩០ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)
- **លំដាប់ទី៣** : បងប្អូនបង្កើត (មាត្រា១១៩០ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណី)

ឧទាហរណ៍ : លោក A ជាជនក្រីក្រ ចាស់ជរា មិនអាចចិញ្ចឹមជីវិតខ្លួនបាន ហើយសព្វថ្ងៃរស់នៅជាមួយក្មួយស្រីបង្កើតម្នាក់ លោក A មានកូនប្រុស៣នាក់ រស់នៅទីក្រុង និងមានប្អូនប្រុសបង្កើតម្នាក់រស់នៅប្រទេសបារាំង។ ករណីនេះលោក A ជាជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច ហើយក្មួយស្រីបង្កើត កូនប្រុសទាំង៣នាក់ និងប្អូនប្រុសបង្កើតរបស់លោក A គឺជាជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយក្មួយស្រី ស្ថិតក្នុងលំដាប់ទី១ កូនប្រុសស្ថិតក្នុងលំដាប់ទី២ និងប្អូនប្រុសស្ថិតក្នុងលំដាប់ទី៣។ ជាបឋមលោក A ត្រូវផ្គត់ផ្គង់ដោយញាតិក្នុងលំដាប់ទី១ ដែលរស់នៅជាមួយគ្នា ប៉ុន្តែករណីនេះជនមានករណីយកិច្ចទាំងអស់ខាងលើ អាចធ្វើការពិភាក្សាគ្នាកំណត់យកជនដែលមានករណីយកិច្ចជាក់លាក់ក្នុងការផ្គត់ផ្គង់លោក A បាន បើពុំដូច្នេះទេ ត្រូវប្តឹងទៅតុលាការសម្រេចអាស្រ័យលើធនធាន អាយុ ទំនាក់ទំនង និងស្ថានភាពផ្សេងទៀតរបស់ជនមានករណីយកិច្ចនីមួយៗ។

ជាបញ្ហាចោទឡើងថា តើជនដែលមានលំដាប់មានករណីយកិច្ចនីមួយៗអាចធ្វើការបដិសេធមិនផ្តល់អាហារកាតព្វកិច្ចដល់ជនមានសិទ្ធិទទួល ដោយអះអាងពីលំដាប់ករណីយកិច្ចរបស់ខ្លួន និងស្ថានភាពផ្សេងៗទៀតបានដែរ ឬទេ?

**ទី២ : ជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្តីសម្រេចរបស់តុលាការៈ**

ជនមានករណីយកិច្ចផ្គត់ផ្គង់តាមសេចក្តីសម្រេចរបស់តុលាការមានពីរ គឺ ញាតិក្នុងថ្នាក់ទី៣ (មាត្រា១១៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ក្នុងករណីមានស្ថានភាពពិសេសណាមួយ និងសហព័ទ្ធដែលនៅរស់ ឬញាតិរបស់សហព័ទ្ធដែលស្លាប់ ក្នុងករណីដែលអាពាហ៍ពិពាហ៍បានរលាយដោយមរណភាពរបស់សហព័ទ្ធម្ខាង (មាត្រា១១៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ លោក A រស់នៅតែម្នាក់ឯង ពុំមានកូន ហើយបងប្អូនរបស់លោក A បានស្លាប់អស់ លោក A នៅសល់តែក្មួយប្រុសម្នាក់មានជីវភាពធូរធារ ត្រូវជាកូនរបស់បងប្រុសបង្កើតខ្លួន ហើយលោក A ពុំមានសមត្ថភាពក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួនបានទេ ។ ករណីនេះលោក A អាចដាក់ពាក្យសុំទៅតុលាការទាមទារឲ្យក្មួយប្រុស ជាញាតិក្នុងថ្នាក់ទី៣ ផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ខ្លួនបាន ។

យ៉ាងណាមិញ ប្រសិនបើមានបុគ្គលតែម្នាក់ ដែលត្រូវមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច បុគ្គលនោះនឹងត្រូវក្លាយជាជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ប៉ុន្តែបើមានបុគ្គលពីរនាក់ ឬច្រើននាក់ តើបុគ្គលណាម្នាក់ ដែលជាជនមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចនោះ? យោងតាមមាត្រា ១១៤១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី គេត្រូវកំណត់រកជនដែលមានករណីយកិច្ចត្រូវផ្តល់អាហារកាតព្វកិច្ចម្នាក់គត់ តាមរយៈការពិភាក្សាព្រមព្រៀងគ្នា។ ប្រសិនបើគ្មានការយល់ព្រម ឬការពិភាក្សាមិនបានសម្រេចបាន តុលាការ គឺជាអ្នកកំណត់ជនដែលត្រូវមានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចនេះ (មាត្រា១១៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

**ការកំណត់ជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកិច្ច តាមរយៈការពិភាក្សា :**

ជាទូទៅ ជនមានករណីយកិច្ចលំដាប់ទី១ គួរតែក្លាយជាជន ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកិច្ច ។ ប្រសិនបើ មានជនមានករណីយកិច្ច លំដាប់ទី១ ចាប់ពី២នាក់ ឬច្រើននាក់ ពួកគេត្រូវធ្វើការពិភាក្សា ហើយត្រូវកំណត់ថានរណាម្នាក់ ត្រូវក្លាយជាអ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ច។ ពួកគេអាចកំណត់បានថា បុគ្គលតែម្នាក់ ជាជនត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចទាំងស្រុង ឬកំណត់យកបុគ្គល ២ នាក់ ឬច្រើននាក់ ជាជនត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដោយសហការគ្នា។

ប្រសិនបើគ្មានជនមានករណីយកិច្ចលំដាប់ទី១នោះទេ ជនមានករណីយកិច្ចលំដាប់ទី២ ត្រូវក្លាយជាជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។ ប្រសិនបើជនករណីយកិច្ចមានច្រើននាក់ ពួកគេត្រូវពិភាក្សាគ្នាកំណត់រកមនុស្សតែម្នាក់ ដែលនឹងត្រូវក្លាយជាជនត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។

ប្រសិនបើគ្មានជនករណីយកិច្ចលំដាប់ទី១ និង ទី២ទេ ជនករណីយកិច្ចលំដាប់ទី៣ ត្រូវក្លាយជាជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ ដូចគ្នានេះដែរ កាលណាជនករណីយកិច្ច លំដាប់ទី៣ មានច្រើននាក់ បុគ្គលទាំងនោះ ត្រូវពិភាក្សាគ្នាកំណត់រកបុគ្គលណាម្នាក់ ដើម្បីធ្វើជាជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

យ៉ាងណាមិញ ការពិភាក្សាគ្នាក្នុងការកំណត់ជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចនេះ មិនកម្រិតតែទៅលើជនដែលស្ថិតក្នុងលំដាប់ដូចគ្នានោះទេ ពោលគឺ ក្នុងករណីដែល ជនមានករណីយកិច្ចលំដាប់ទី១ ពុំមានលទ្ធភាពហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ នោះជនមានករណីយកិច្ចលំដាប់ទី១ អាចពិភាក្សាជាមួយជនមានករណីយកិច្ចលំដាប់ទី២ និង ទី៣ ដើម្បីសម្រេចកំណត់ឲ្យជនណាម្នាក់ ជាជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចវិញ។

**ការកំណត់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ :**

ប្រសិនបើជនករណីយកិច្ចមានច្រើននាក់ ហើយពួកគេមិនអាចព្រមព្រៀងលើការកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបានទេនោះ ពួកគេអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីទាមទារការកំណត់រកជនណាម្នាក់ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង និងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុចទី៦០) ។ តុលាការត្រូវពិចារណាលើចំណុចដូចជា លទ្ធភាពទ្រព្យសម្បត្តិ អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ទំនាក់ទំនងរវាងភាគីទាំងពីរ ហើយគ្រប់ស្ថានភាពផ្សេងៗទៀតទាំងអស់ ដើម្បីសម្រេចកំណត់ជនម្នាក់ ឬច្រើននាក់ ឲ្យធ្វើជាជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា១១៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។

ក្រៅពីនេះ ការទាមទារការផ្គត់ផ្គង់អាហារកាតព្វកិច្ច ពីញាតិក្នុងថ្នាក់ទីបី ឬការទាមទារអាហារកាតព្វកិច្ចក្នុងករណីទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវរលាយដោយការមរណភាពក្តី ក៏ត្រូវដាក់ពាក្យសុំទៅតុលាការ តាមមាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី មិនមែនជាបណ្តឹង និងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុចទី៦០ ផងដែរ ។

## ៥. កម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច

### ៥.១ ការពិភាក្សារវាងជនមានករណីយកិច្ចផ្គត់ផ្គង់ និងជនមានសិទ្ធិទាមទារ

កម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវកំណត់តាមការពិភាក្សារបស់ភាគី ក្នុងករណីខ្លះ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចរស់នៅជាមួយជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ឯករណីខ្លះទៀតគេអាចរស់នៅដាច់ដោយឡែកពីគ្នា ដោយជនដែលមានករណីយកិច្ច ត្រូវផ្តល់អាហារកាតព្វកិច្ចជាលុយកាក់ ឬគ្រឿងឧបភោគបរិភោគ សំលៀកបំពាក់ជាដើម។

ជាធម្មតាជនដែលមានតម្រូវការ តែងតែចង់បានការផ្គត់ផ្គង់ចំនួនច្រើន រីឯជនដែលមានករណីយកិច្ច ចង់ផ្តល់ការផ្គត់ផ្គង់ក្នុងទំហំតិចតួច ប៉ុន្តែជាគោលការណ៍កម្រិតនៃការផ្គត់ផ្គង់ត្រូវបំពេញនូវភាពចាំបាច់តាមស្តង់ដារអប្បបរមា នៃតម្រូវការចាំបាច់របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ក្នុងកម្រិតត្រឹមអាចទ្រទ្រង់ជីវភាពរស់នៅជាមូលដ្ឋានប្រចាំថ្ងៃតែប៉ុណ្ណោះ។ ដូច្នេះ ទោះបីជនមានករណីយកិច្ច មានចំណូលច្រើនយ៉ាងណាក៏ដោយ ក៏ជនទទួលអាហារកាតព្វកិច្ច មិនអាចទាមទារការផ្គត់ផ្គង់អាហារកាតព្វកិច្ច ឲ្យច្រើនជាងភាពចាំបាច់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅជាអប្បបរមានោះទេ លើកលែងជនមានករណីយកិច្ចផ្តល់ឲ្យដោយស្ម័គ្រចិត្តពោលគឺ ផ្គត់ផ្គង់អាហារកាតព្វកិច្ច ដើម្បីធានាកម្រិតស្តង់ដារជីវភាពអប្បបរមា។ ប៉ុន្តែជាបញ្ហាកើតឡើងត្រង់ថាតើស្តង់ដារជីវភាពរស់នៅកម្រិតអប្បបរមា ត្រូវវាយតម្លៃផ្អែកលើមូលដ្ឋានអ្វី? នេះជាភាពលំបាកមួយរបស់តុលាការ ក៏ដូចជាការឈានដល់ការព្រមព្រៀងរបស់ភាគី ក្នុងការកំណត់កម្រិតអាហារកាតព្វកិច្ចអប្បបរមា។ ដូច្នេះតុលាការគប្បីមានយុទ្ធសាស្ត្រក្នុងការកំណត់ជាមូលដ្ឋាន វាយតម្លៃកម្រិតជីវភាពអប្បបរមា នៅក្នុងបរិបទប្រទេសកម្ពុជា។

កម្រិតជីវភាពអប្បបរមា អាចត្រូវបានកំណត់អាស្រ័យទៅលើតម្រូវការមូលដ្ឋាន ដែលរួមមាន អាហារ ទីជម្រក សុខភាព សម្លៀកបំពាក់ និងការសិក្សាអប់រំមូលដ្ឋានជាដើម ដោយតុលាការអាចធ្វើការពិចារណាដោយផ្អែកលើតម្រូវការចាំបាច់នេះ ជាមូលដ្ឋានកំណត់ទំហំនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន។

ផ្ទុយទៅវិញ ក្នុងករណីដែលភាគីទាំងពីរមិនអាចពិភាក្សាព្រមព្រៀងគ្នា ក្នុងការសម្រេចអំពីរបៀប និងកម្រិតនៃអាហារកាតព្វកិច្ច ដែលត្រូវផ្គត់ផ្គង់ ភាគីណាមួយអាចដាក់ពាក្យសុំទៅតុលាការដើម្បីឲ្យតុលាការចេញសេចក្តីសម្រេចកំណត់អំពីកម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា១១៩២ នៃក្រមរដ្ឋប្បវេណី) ដោយតុលាការពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ ក្នុង

ជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់។ ការដាក់ពាក្យសុំទៅតុលាការ គឺធ្វើតាមមាត្រា៣ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុចទី៦០ ។

## ៥.២ ការកែប្រែ ផ្លាស់ប្តូរ ឬលុបចោលការផ្គត់ផ្គង់អាហារកាតព្វកិច្ច

ការកំណត់កម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច អាចត្រូវបានផ្លាស់ប្តូរ ឬលុបចោលដោយការពិភាក្សា ឬតាមសេចក្តីសម្រេចរបស់តុលាការ ដោយពិចារណាលើការផ្លាស់ប្តូរស្ថានភាពរបស់ភាគី (តាមមាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍: ជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច មានសមត្ថភាពចិញ្ចឹមជីវិតខ្លួនឯងបាន ឬជនមានករណីយកិច្ចផ្គត់ផ្គង់ជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដោយមិនអាចធ្វើការផ្គត់ផ្គង់អាហារកាតព្វកិច្ចក្នុងកម្រិតណាមួយដូចមុនជាដើម។

## ៥.៣ ការបញ្ចប់ការផ្គត់ផ្គង់អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច បញ្ចប់តាមការពិភាក្សាព្រមព្រៀងរបស់ភាគី ។ ក្រៅពីនេះអាហារកាតព្វកិច្ចបញ្ចប់ នៅពេលដែលជនមានសិទ្ធិទាមទារអាហារកាតព្វកិច្ច បានទទួលមរណភាព ពីព្រោះសិទ្ធិទាមទារអាហារកាតព្វកិច្ចត្រូវបានរលត់ ដោយហេតុថាសិទ្ធិនេះជាសិទ្ធិផ្តាច់មុខភ្ជាប់ជាមួយនឹងជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ជាចំណោទបញ្ហា ក្នុងករណីដែលអ្នកមានសិទ្ធិមានជម្ងឺហើយជំពាក់ថ្លៃព្យាបាលជម្ងឺ ថាតើថ្លៃចំណាយទូទាត់ថ្លៃព្យាបាលនេះជាបន្ទុករបស់អ្នកមានករណីយកិច្ចឬទេ?

ម្យ៉ាងវិញទៀត តើមរណភាពរបស់ជនមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច អាចនាំឲ្យករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចនោះបញ្ចប់ ឬទេ? តើសន្តតិជននៃជនមានករណីយកិច្ចនោះត្រូវបន្តករណីយកិច្ចនោះ ឬទេ? ដោយសារតែ ករណីយកិច្ចក្នុងការផ្តល់អាហារកាតព្វកិច្ច មានភាពផ្តាច់មុខចំពោះមតកជន សន្តតិជនមិនត្រូវទទួលបន្តនូវកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ចឡើយ (មាត្រា១១៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងករណីនេះ ត្រូវធ្វើការកំណត់រកអ្នកមានករណីយកិច្ចផ្តល់អាហារកតព្វកិច្ច ដោយយោងតាមមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី។

ការបញ្ចប់អាហារកាតព្វកិច្ច ក៏អាចបញ្ចប់តាមការលុបចោលរបស់តុលាការ ដោយមូលហេតុផ្លាស់ប្តូរស្ថានភាពរបស់ភាគីណាមួយផងដែរ។

**៦. ការគណនារកចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច**

**៦.១ មូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច**

A= (សោហ៊ុយចំណាយចាំបាច់សម្រាប់ការរស់នៅជាអប្បបរមារបស់ជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច) – (ប្រាក់ចំណូលរបស់ជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច)

B= (ប្រាក់ចំណូលរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច) – (សោហ៊ុយចំណាយលើការរស់នៅតាមដូនតារបស់ជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច)

ចំនួនអាហារកាតព្វកិច្ច ដែលត្រូវផ្តល់ឲ្យ = A ឬ B យកមួយណាដែលមានចំនួនតិចជាង

**<u>ឧទាហរណ៍ជាសម្មតិកម្មទី១ :</u>**

X គ្មានប្រាក់ចំណូល ហើយត្រូវការប្រាក់ចំនួន ១២០ដុល្លារ/ខែ ដើម្បីផ្គត់ផ្គង់ការរស់នៅជាអប្បបរមារបស់ខ្លួន។ Y គឺជាបងប្រុសរបស់ X និងជាជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។ Y មានប្រាក់ចំណូល ៨០០ដុល្លារ/ខែ។ Y ត្រូវការប្រាក់ចំនួន ៥០០ដុល្លារ/ខែ ដើម្បីចិញ្ចឹមជីវភាពរស់នៅបច្ចុប្បន្នរបស់ខ្លួន។

នាំឲ្យតាម A= ១២០ដុល្លារ និង B= ៣០០ដុល្លារ ។ ដូច្នេះ Y ត្រូវផ្តល់ប្រាក់ ១២០ ដុល្លារ/ខែ ទៅឲ្យ X ។

**<u>ឧទាហរណ៍ជាសម្មតិកម្មទី២ :</u>**

X មានប្រាក់ចំណូលចំនួន ៦០ដុល្លារ/ខែ ហើយត្រូវការប្រាក់ចំនួន ១៥០ដុល្លារ/ខែ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅជាអប្បបរមារបស់ខ្លួន។ Y ជាបងប្រុសរបស់ X និងជាជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។ Y មានប្រាក់ចំណូល ៥០០ដុល្លារ/ខែ។ Y ត្រូវការប្រាក់ចំនួន ៤៥០ ដុល្លារ/ខែ ដើម្បីចិញ្ចឹមជីវភាពរស់នៅបច្ចុប្បន្នរបស់ខ្លួន។

នាំឲ្យ A= ៩០ដុល្លារ និង B= ៥០ដុល្លារ ។ ដូច្នេះ Y ត្រូវផ្តល់ប្រាក់ ៥០ដុល្លារ/ខែ ទៅឲ្យ X ។

## ៧. ទណ្ឌកម្មនៃការមិនផ្តត់ផ្គង់អាហារកាតព្វកិច្ច

ការផ្តត់ផ្គង់អាហារកាតព្វកិច្ច គឺជាកាតព្វកិច្ចដែលច្បាប់កំណត់ ចំពោះជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់ ចំពោះជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ប៉ុន្តែច្បាប់កំណត់ករណីយកិច្ចនេះដោយផ្អែកជាសំខាន់លើគោលការណ៍នៃការស្ម័គ្រចិត្តផ្តត់ផ្គង់ និងការពិភាក្សាគ្នាទៅវិញទៅមករវាងជនមានករណីយកិច្ច និងជនមានសិទ្ធិទាមទារ។ លុះត្រាតែការពិភាក្សាមិនបានសម្រេច ឬមិនជនមានករណីយកិច្ចមិនគោរពតាមលទ្ធផលនៃកិច្ចពិភាក្សាក្នុងការផ្តត់ផ្គង់កាតព្វកិច្ច ទើបជនពាក់ព័ន្ធទាំងឡាយ ជាពិសេសជនដែលមានសិទ្ធិទាមទារធ្វើការដាក់ពាក្យសុំទៅតុលាការចេញសេចក្តីសម្រេចដែលមានលក្ខណៈចាប់បង្ខំ។

ទណ្ឌកម្មនៃការមិនផ្តត់ផ្គង់អាហារកាតព្វកិច្ច អាចមានពីរករណី គឺការចាប់បង្ខំដោយអំណាចតុលាការឲ្យផ្តត់ផ្គង់កាតព្វកិច្ច (មាត្រា១១៩១ ១១៩២ នៃក្រមរដ្ឋប្បវេណី និងមាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី មិនមែនជាបណ្តឹង និងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុចទី៦០) និងបទល្មើសព្រហ្មទណ្ឌ ដែលកើតចេញពីការមិនគោរពសេចក្តីសម្រេចរបស់តុលាការ ឲ្យផ្តត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា៣២៤ នៃក្រមព្រហ្មទណ្ឌ)។

ប៉ុន្តែជាបញ្ហានៅត្រង់ថា តើការមិនគោរពកាតព្វកិច្ចក្នុងការផ្តត់ផ្គង់អាហារកាតព្វកិច្ច តាមសេចក្តីសម្រេចរបស់តុលាការ ត្រូវក្លាយជាទណ្ឌកម្មព្រហ្មទណ្ឌដោយស្វ័យប្រវត្តិឬទេ? ពោលគឺ តើគេអាចបកស្រាយថា សិទ្ធិទាមទារអាហារកាតព្វកិច្ច នឹងក្លាយជាសិទ្ធិលើបំណុល ហើយបំពានសិទ្ធិលើបំណុល គ្រាន់តែជាទណ្ឌកម្មរដ្ឋប្បវេណី ដែលសេចក្តីសម្រេចរបស់តុលាការ នឹងក្លាយជាលិខិតអនុវត្ត ដែលជាកម្មវត្ថុក្នុងការអនុវត្តដោយបង្ខំ បានដែរ ឬទេ?

# ជំពូកទី ៩
# សន្តតិកម្ម
# ផ្នែកទី ១
# មតកសាសន៍

## ១. អត្ថន័យ និង លក្ខណៈនៃមតកសាសន៍

### ១.១. និយមន័យ

មតកសាសន៍ គឺជាការការបង្ហាញឆន្ទៈជាឯកតោភាគីមួយរបស់ម្ចាស់បណ្តាំ ដែលខ្លួនមានការព្រួយបារម្ភពីបញ្ហាពិសេសដែលទាក់ទងនឹងទ្រព្យរបស់ខ្លួន ឬ ឋានៈរបស់បុគ្គលណាម្នាក់ ដើម្បីបង្កើតនូវអានុភាពមួយ នៅពេលដែលខ្លួនទទួលមរណភាព ហើយមតកសាសន៍នេះត្រូវបង្កើតឡើង ដោយផ្អែកលើទម្រង់ជាក់លាក់ណាមួយ។

មនុស្សយើងអាចចាត់ចែងដោយសេរីនូវទ្រព្យសម្បត្តិរបស់ខ្លួនបាន តាមរយៈមតកសាសន៍ (សេរីភាពនៃមតកសាសន៍)។ នេះគឺជាការពង្រីកគោលការណ៍ស្វ័យភាពរបស់បុគ្គលឯកជន (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី) ក្រោយពេលមរណភាព។

### ១.២. លក្ខណៈនៃមតកសាសន៍

**- សកម្មភាពឯកតោភាគីតាមច្បាប់**

មតកសាសន៍ គឺជាសកម្មភាពឯកតោភាគី ដោយគ្មានភាគីម្ខាងទៀត។ មិនចាំបាច់មានការទទួល ឬ យល់ព្រមពីភាគីម្ខាងទៀតទេ។

**- អានុភាពនៃមតកសាសន៍កើតមាននៅពេលម្ចាស់បណ្តាំទទួលមរណភាព (កថាខណ្ឌទី ១ នៃមាត្រា ១១៩៤ នៃក្រមរដ្ឋប្បវេណី )**

នៅពេលដែលម្ចាស់បណ្តាំនៅរស់ មតកសាសន៍ពុំមានអានុភាពនោះទេ ដូច្នេះហើយ ម្ចាស់បណ្តាំមានសិទ្ធិសេរីភាពក្នុងការលុបចោលនូវការបង្ហាញឆន្ទៈតាមរយៈមតកសាសន៍នៅពេលណាក៏បានដែរ (មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណី)។

**- មតកសាសន៍គឺជាសកម្មភាពមួយដែលត្រូវធ្វើឡើងតាមរយៈទម្រង់ (កថាខណ្ឌទី ១ នៃ មាត្រា ១១៧០ នៃក្រមរដ្ឋប្បវេណី)**

ដើម្បីធ្វើឲ្យម្ចាស់បណ្តាំបង្ហាញឆន្ទៈដោយមានការពិចារណាហ្មត់ចត់ ហើយដើម្បីការពារកុំឲ្យមានការក្លែងបន្លំ ឬ កែប្រែមតកសាសន៍ វាចាំបាច់ណាស់ក្នុងការធ្វើមតកសាសន៍ ទៅតាមទម្រង់

ដែលបានកំណត់ជាក់លាក់។ ប្រសិនបើមតកសាសន៍មិនអនុលោមតាមទម្រង់នៃក្រមរដ្ឋប្បវេណីទេនោះ វាត្រូវចាត់ទុកជា មោឃៈ (មាត្រា ១១៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

**- ចំណុចផ្សេងៗដែលអាចធ្វើតាមមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់**

វាមានសារៈសំខាន់ណាស់ ក្នុងការកំណត់ចំណុចដែលអាចធ្វើតាមមតកសាសន៍ដោយសារតែមតកសាសន៍ ត្រូវបានបង្កើតឡើងដោយមិនមានការព្រមព្រៀងពីភាគីពាក់ព័ន្ធឡើយ។ ដូច្នេះហើយ ចំណុចដែលត្រូវកំណត់ក្នុងមតកសាសន៍ ត្រូវបានដាក់កម្រិតដោយច្បាប់។

ក្នុងករណីមួយចំនួន ម្ចាស់បណ្តាំបានសរសេររៀបរាប់ពីចំណុចខ្លះដែលមិនមានចែងនៅក្នុងច្បាប់នោះទេ មានដូចជា "សន្តតិជនត្រូវមានការពិភាក្សាគ្នាដោយស្មោះត្រង់" ឬ "សន្តតិជនត្រូវរក្សាទំនាក់ទំនងជាមួយគ្នាជារៀងដរាប" ជាអាទិ៍។ ចំណុចទាំងនោះគ្មានអានុភាពផ្លូវច្បាប់ទេ បើទោះបីជាសន្តតិជនត្រូវគោរពតាមក៏ដោយ (មាត្រា ១១៨៧ នៃក្រមរដ្ឋប្បវេណី)។

**- ការបង្កើតមតកសាសន៍មានភាពផ្តាច់មុខ និង ជាសកម្មភាពផ្ទាល់ខ្លួនរបស់ម្ចាស់បណ្តាំ**

មតកសាសន៍ត្រូវបានទទួលស្គាល់ជាអានុភាពផ្លូវច្បាប់ ដោយមានការគោរពនូវឆន្ទៈពិត និងចុងក្រោយរបស់ម្ចាស់បណ្តាំ។ ដូច្នេះហើយ ការបង្កើតមតកសាសន៍មិនអាចធ្វើដោយភ្នាក់ងារបានឡើយ។ ទោះបីជាជនដែលជាជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរដោយមិនចាំបាច់មានការយល់ព្រមពីនរណាម្នាក់ (មាត្រា ១១៦៨ កថាខណ្ឌទី ១ និង មាត្រា ១១៦៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ក្រៅពីនេះ អ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអាណាព្យាបាល ឬ ឪពុកម្តាយ មិនអាចធ្វើមតកសាសន៍ជំនួសឲ្យជនស្ថិតក្រោមអាណាព្យាបាល ឬ កូនដែលជាអនីតិជនបានទេ។

## ២. សមត្ថភាពក្នុងការធ្វើមតកសាសន៍

មតកសាសន៍ គឺជារបបមួយដែលបង្កើតឡើង ដើម្បីគោរពឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។

**- ម្ចាស់បណ្តាំត្រូវមានសមត្ថភាពធ្វើមតកសាសន៍**

ម្ចាស់បណ្តាំត្រូវមានសមត្ថភាពធ្វើមតកសាសន៍ នៅពេលធ្វើមតកសាសន៍នោះ (មាត្រា ១១៦៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ នៅពេលធ្វើមតកសាសន៍ ប្រសិនបើម្ចាស់បណ្តាំខ្វះសមត្ថភាពដោយសារការស្រវឹង ឬ មានជម្ងឺខួរក្បាលជាដើមនោះ មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ។

ម៉្យាងវិញទៀត ម្ចាស់បណ្តាំត្រូវមានសមត្ថភាពនៅពេលធ្វើមតកសាសន៍តែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ទោះបីជាម្ចាស់បណ្តាំបាត់បង់សមត្ថភាពនេះក្រោយពេលធ្វើមតកសាសន៍ក៏ដោយ ក៏មតកសាសន៍នៅតែមានសុពលភាពដែរ។

**-ជាគោលការណ៍ នីតិជនអាចធ្វើមតកសាសន៍បាន**

សូម្បីតែជនដែលស្ថិតនៅក្រោមអាណាព្យាបាល ឬ ជនស្ថិតក្រោមហិតូបត្ថម្ភ ក៏អាចធ្វើ

មតកសាសន៍ដោយខ្លួនឯងបានដែរ ដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាល ឬ ហិតូបត្ថមក: ហើយមតក សាសន៍ទាំងនោះមិនអាចលុបចោលបានទេ (មាត្រា ១១៦៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ទោះជាយ៉ាងនេះក្ដី ពួកគេត្រូវមានសមត្ថភាពធ្វើមតកសាសន៍នោះផង ដែរ។

អ្វីដែលស្មុគស្មាញនោះគឺ ករណីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ តែងតែខ្វះសមត្ថភាពក្នុងការធ្វើមតកសាសន៍ (មើលមាត្រា ១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចមានសមត្ថភាពធ្វើមតកសាសន៍នៅពេលខ្លះដែរ ដោយសារតែស្ថានភាពខួរក្បាលរបស់ជននោះ អាចនឹងប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាន តែនៅពេលដែលជននោះជាសះស្បើយមួយរយៈឡើងវិញជាបណ្ដោះអាសន្ននូវសមត្ថភាពប៉ុណ្ណោះ។ ក្រោយធ្វើមតកសាសន៍ ជននោះអាចបាត់បង់សមត្ថភាពក្នុងពេលឆាប់ៗម្តងទៀត។ ប៉ុន្តែ វាមិនមានផលប៉ះពាល់ដល់សុពលភាពរបស់មតកសាសន៍នោះទេ។ នៅក្នុងការបង្ហាញភស្តុតាងអំពីការសះស្បើយមួយរយៈនូវសមត្ថភាពជាបណ្ដោះអាសន្ននោះ នៅពេលធ្វើមតកសាសន៍ គួរតែមានវត្តមានវេជ្ជបណ្ឌិត ២ ឬ ច្រើននាក់ ហើយវេជ្ជបណ្ឌិត ត្រូវសសេរបញ្ជាក់បន្ថែមលើមតកសាសន៍នោះ (មាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណី)។

**- ជាគោលការណ៍ អនីតិជនមិនអាចធ្វើមតកសាសន៍បានទេ**

អនីតិជនមិនអាចធ្វើមតកសាសន៍បានទេ លុះត្រាតែជននោះទទួលបានអត្តាធីនភាព (មាត្រា ១១៦៨ កថាខណ្ឌទី ១ និង មាត្រា ២១ នៃក្រមរដ្ឋប្បវេណី)។

**- បន្ទុកភស្តុតាង**

ក្រោយម្ចាស់បណ្ដាំទទួលមរណភាព បុគ្គលដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ អាចមានការឈ្លោះប្រកែកគ្នាលើបញ្ហាសុពលភាពនៃមតកសាសន៍ ដោយផ្អែកលើហេតុផលថា ម្ចាស់បណ្ដាំខ្វះសមត្ថភាពធ្វើមតកសាសន៍។ ក្នុងករណីដូចខាងលើ ភាគីដែលអះអាងដូចនេះ ត្រូវបញ្ជាក់ភស្តុតាងទៅលើហេតុនៃកង្វះសមត្ថភាពនោះ (មាត្រា ១១៦៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ទោះជាយ៉ាងនេះក្ដី ប្រសិនបើម្ចាស់បណ្ដាំស្ថិតនៅក្រោមអាណាព្យាបាលទូទៅនៅពេលធ្វើមតកសាសន៍ បុគ្គលដែលអះអាងពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ ត្រូវធ្វើការបញ្ជាក់ភស្តុតាង (មាត្រា ១១៦៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

## ៣. វិធីធ្វើមតកសាសន៍

### ៣.១. គោលគំនិត

មតកសាសន៍ដែលពុំបានធ្វើឡើងតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ (មាត្រា ១១៧០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ពេលដែលម្ចាស់បណ្តាំបានទទួលមរណភាពមតកសាសន៍នឹងមានអានុភាព។ ដូចនេះ មិនមានឱកាសសម្រាប់សួរពីឆន្ទៈពិត ឬ ប្រឆាំងចំពោះម្ចាស់បណ្តាំបាននោះទេ។ ក៏មានករណីខ្លះ តតិយជនអាចបង្កើតមតកសាសន៍ក្លែងក្លាយបានផងដែរ ឬ ខ្លឹមសារពិតរបស់មតកសាសន៍ត្រូវបានតតិយជននោះកែប្រែផងដែរ។

ដូច្នេះហើយ ដើម្បីធ្វើឲ្យឆន្ទៈរបស់ម្ចាស់បណ្តាំមានភាពច្បាស់លាស់ និងដើម្បីការពារមិនឲ្យមានអ្នកក្លែងបន្លំ ឬ កែប្រែមតកសាសន៍ ក្រមរដ្ឋប្បវេណីបានចែងយ៉ាងលំអិតអំពីទម្រង់មតកសាសន៍ ហើយប្រសិនបើ មិនអនុវត្តតាមទម្រង់នោះទេ មតកសាសន៍នោះនឹងត្រូវចាត់ទុកជាមោឃៈ។

### ៣.២. ប្រភេទនៃទម្រង់មតកសាសន៍

#### វិធីធម្មតា

ជាគោលការណ៍ មតកសាសន៍ត្រូវធ្វើទៅតាមវិធីធម្មតា។ មតកសាសន៍តាមវិធីធម្មតា អាចធ្វើបានគ្រប់ពេល គ្រប់កាលៈទេសៈស្ថានភាព។ មាន ៣ ទម្រង់៖

១. មតកសាសន៍ ដោយលិខិតយថាភូត (មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី)

២. មតកសាសន៍ ដោយលិខិតឯកជន (មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណី)

៣. មតកសាសន៍ ដោយលិខិតសំងាត់ (មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណី)

#### វិធីពិសេស

ក្នុងករណីលើកលែង មតកសាសន៍អាចធ្វើបានតាមវិធីពិសេស។ មតកសាសន៍តាមវិធីពិសេស ត្រូវបានធ្វើតែក្នុងស្ថានភាពពិសេស ដូចជា ម្ចាស់បណ្តាំកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ម្ចាស់បណ្តាំជាប់ពន្ធនាគារ ជាដើម។ យើងត្រូវចំណាំថា ទោះបីជាស្ថិតក្នុងស្ថានភាពពិសេសបែបនោះក៏ដោយ ម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ តាមវិធីធម្មតាបានដែរ។ ក្នុងស្ថានភាពពិសេសនោះ វាជាជម្រើសរបស់ម្ចាស់បណ្តាំ ចំពោះការធ្វើដោយវិធីធម្មតា ឬ វិធីពិសេស។

-មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា ១១៧៧ នៃក្រមរដ្ឋប្បវេណី)

-មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង (មាត្រា ១១៧៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)

-មតកសាសន៍របស់ជនដែលនៅលើនាវា ឬ យន្តហោះ (មាត្រា ១១៧៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)

### ៣.២.១. វិធីធម្មតា

### ៣.២.១.១. មតកសាសន៍ដោយលិខិតយថាភូត (មាត្រា ១១៧៣)

ម្ចាស់បណ្តាំ ត្រូវពន្យល់ផ្ទាល់មាត់អំពីឆន្ទៈនៃមតកសាសន៍ចំពោះសារការី ហើយត្រូវមានវត្តមានរបស់សាក្សី យ៉ាងតិចពីរនាក់ ហើយសារការី ត្រូវសរសេរអំពីខ្លឹមសារនៃមតកសាសន៍នោះជាលាយលក្ខណ៍អក្សរ និងត្រូវអានឲ្យម្ចាស់បណ្តាំស្តាប់។ បន្ទាប់មក ម្ចាស់បណ្តាំ សាក្សី និងសារការី ត្រូវចុះហត្ថលេខា ជាអាទិ៍ ទៅលើលិខិតនោះ។

ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា (ប្រើដៃជាសញ្ញា) ដោយមានអ្នកបកប្រែ ឬ ត្រូវសរសេរទៅកាន់សារការី (មាត្រា ១១៧៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើម្ចាស់បណ្តាំមិនអាចស្តាប់បាន គេត្រូវប្រើភាសាសញ្ញា ដោយមានអ្នកបកប្រែជំនួសឲ្យការអានរបស់សារការីនូវចំណុចដែលសរសេរនោះ (មាត្រា ១១៧៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលអនុលោមទៅតាមមាត្រា ១១៧៩ សារការីត្រូវសរសេរការពិតនៅក្នុងលិខិតយថាភូត (មាត្រា ១១៧៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។

**គុណប្រយោជន៍ ៖**

- ខ្លឹមសារនៃមតកសាសន៍មានភាពច្បាស់លាស់ ព្រោះតែសារការីសរសេរនៅលើមតកសាន៍នោះ
- មតកសាសន៍មានភាពជាផ្លូវការ ដោយសារសារការីជួយបង្កើតមតកសាសន៍នោះ
- ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មានភាពជឿជាក់ និងទុកចិត្តលើមតកសាន៍ ពីព្រោះសារការីចូលរួមក្នុងនីតិវិធីនៃការធ្វើមតកសាសន៍ ហើយជាអ្នករក្សាទុកមតកសាសន៍នោះ
- អ្នកមិនចេះអក្សរក៏អាចធ្វើមតកសាសន៍បានដែរ ពីព្រោះសារការី គឺជាអ្នកសរសេរខ្លឹមសាររបស់ មតកសាសន៍
- មតកសាសន៍មិនត្រូវបានក្លែងបន្លំ ឬ ផ្លាស់ប្តូរ ឬ បាត់បង់ ពីព្រោះសារការីជាអ្នករក្សាទុកមតកសាសន៍
- មុនពេលអនុវត្តន៍មតកសាសន៍មិនចាំបាច់មាននីតិវិធីពិនិត្យបញ្ជាក់ទេ

**គុណវិបត្តិ ៖**

- ម្ចាស់បណ្តាំត្រូវស្នើសុំឲ្យសារការីជួយ

- សារការី និង សាក្សីដឹងខ្លឹមសារក្នុងមតកសាសន៍

**៣.២.១.២. មតកសាសន៍ដោយលិខិតឯកជន (មាត្រា ១១៧៤)**

នេះគឺជាវិធីធ្វើមតកសាសន៍ ដែលម្ចាស់បណ្តាំត្រូវសរសេរអំពីខ្លឹមសារទាំងមូលនៃមតកសាសន៍ ហើយ ចុះថ្ងៃខែឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនឯង។ ករណីមានការបន្ថែម ឬការលុប ឬការកែប្រែផ្សេងទៀត ម្ចាស់បណ្តាំត្រូវសរសេរបន្ថែមនូវហេតុនេះ ព្រមទាំងចុះហត្ថលេខាផង។

**គុណប្រយោជន៍៖**

-ម្ចាស់បណ្តាំ អាចធ្វើតែឯងបាន ដោយមិនចាំបាច់មានអន្តរាគមន៍ពីសារការី ឬ វត្តមានរបស់សាក្សី

-មិនអស់សោហ៊ុយ

- អាចរក្សាការសំងាត់នៃខ្លឹមសារនៃមតកសាសន៍

**គុណវិបត្តិ ៖**

- មតកសាសន៍នឹងត្រូវមោឃៈដោយសារកំហុសនៃទម្រង់ ដោយសារតែ មានការទាមទារឲ្យគោរពទម្រង់តឹងរឹង ហើយសារការីមិនបានចូលរួមជួយ។

- ប្រសិនបើ ម្ចាស់បណ្តាំមិនចេះសរសេរអក្សរទេ គាត់មិនអាចធ្វើមតកសាសន៍បានទេ ព្រោះខ្លឹមសារនៃមតកសាសន៍មិនអាចសរសេរដោយអ្នកផ្សេងនោះទេ ហើយម្ចាស់បណ្តាំក៏មិនត្រូវបានអនុញ្ញាតឲ្យប្រើ

កុំព្យូទ័រសម្រាប់ធ្វើមតកសាសន៍ផងដែរ (មាត្រា ១១៧៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)

- អាចបាត់ ឬ អាចមានការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ ព្រោះម្ចាស់បណ្តាំជាអ្នករក្សាមតកសាសន៍

- ចាំបាច់ត្រូវមានការពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍ (មាត្រា ១២១៣ កថាខណ្ឌទី ១)

**៣.២.១.៣. មតកសាសន៍ដោយលិខិតសំងាត់ (មាត្រា ១១៧៥)**

មតកសាសន៍ដោយលិខិតសំងាត់ ជាវិធីមួយដែលសារការីបញ្ជាក់ថាមានមតកសាសន៍ ប៉ុន្តែ អ្វីៗក្នុងមតកសាសន៍នោះ ត្រូវបានរក្សាការសម្ងាត់។ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាក្នុងលិខិតដោយខ្លួនឯងផ្ទាល់។ ប៉ុន្តែ ម្ចាស់បណ្តាំត្រូវសុំឲ្យអ្នកណាម្នាក់ សរសេរខ្លឹមសារលើមតកសាសន៍ ឬ អាចប្រើកុំព្យូទ័របាន។ ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ព្រមទាំងសរសេរសញ្ញាលើមាត់ស្រោមនោះ ដើម្បីឲ្យដឹងនៅពេលគេបើកស្រោម ហើយត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និង សាក្សីពីរនាក់ ដោយថ្លែងការណ៍ថា នេះគឺជាមតកសាសន៍ ជាអាទិ៍។ ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា ឬ ត្រូវសរសេរ (មាត្រា ១១៧៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ សារការី ម្ចាស់បណ្តាំ និង សាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ។

ម្យ៉ាងទៀត ទោះបីជាមិនស្របនឹងល័ក្ខខ័ណ្ឌនៃមតកសាសន៍ដោយលិខិតសំងាត់ក៏ដោយ ក៏អាចមានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ ដរាបណាមតកសាសន៍នោះអនុលោមតាមមាត្រា ១១៧៥ (មាត្រា ១១៧១ នៃក្រមរដ្ឋប្បវេណី)។

**គុណប្រយោជន៍៖**

- ទោះបីជាមិនចេះសរសេរអក្សរ ក៏អាចធ្វើបានដែរ ព្រោះគាត់អាចស្នើរឲ្យអ្នកណាម្នាក់សរសេរខ្លឹមសារ ឬ ប្រើកុំព្យូទ័រ។
- អាចការពារការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ ឬ ផ្លាស់ប្តូរ ព្រោះមតកសាសន៍ត្រូវបានរក្សាក្នុងស្រោមសំបុត្របិទជិត។
- អាចរក្សាការសំងាត់អំពីខ្លឹមសារនៃមតកសាសន៍បាន ព្រោះមតកសាសន៍ត្រូវបានរក្សាក្នុងស្រោមសំបុត្របិទជិត។

**គុណវិបត្តិ៖**

- ចាំបាច់មានអន្តរាគមន៍ពីសារការី
- ចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ពេលអនុវត្តមតកសាសន៍ (មាត្រា ១២១៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)

| | មតកសាសន៍ដោយលិខិតយថាភូត | មតកសាសន៍ដោយលិខិត ឯកជន | មតកសាសន៍ដោយលិខិត សំងាត់ |
|---|---|---|---|
| អ្នកសរសេរ | សារការី | ម្ចាស់បណ្តាំ | អ្នកណាក៏បានដែរ |
| សាក្សី | សាក្សីយ៉ាងតិច ពីរនាក់ | គ្មាន | សាក្សីយ៉ាងតិច ពីរនាក់<br>សារការី |
| ហត្ថលេខា | ម្ចាស់បណ្តាំ<br>សារការី<br>សាក្សី | ម្ចាស់បណ្តាំ | ម្ចាស់បណ្តាំ<br>សារការី<br>សាក្សី |
| ពិនិត្យបញ្ជាក់ | មិនចាំបាច់ | ចាំបាច់ | ចាំបាច់ |

**៣.២.២. វិធីពិសេស**

**៣.២.២.១ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ( មាត្រា ១១៧៧ )**

ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត អាចធ្វើមតកសាសន៍តាមវិធីធម្មតាបាន។ ប៉ុន្តែ ជននោះគ្មានសមត្ថភាពសរសេរខ្លឹមសារដោយខ្លួនឯងបានទេ ឬ គ្មានពេលស្នើរឲ្យសារការី

ជួយបាន។ ក្នុងការការពារជនបែបនេះ ក្រមរដ្ឋប្បវេណីបានកំណត់វិធីពិសេសនៃមតកសាសន៍។ សរុបមក ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត អាចធ្វើមតកសាសន៍តាមធម្មតាបាន ឬ តាមវិធីពិសេសក៏បាន។ ប្រសិនបើគាត់ចង់ប្រើវិធីនេះ គាត់ត្រូវប្រកាសឆន្ទៈមតកសាសន៍យ៉ាងហោចណាស់ឲ្យសាក្សីម្នាក់ក្នុងចំណោម ៣នាក់បានដឹង។

ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា ឬ ត្រូវសរសេរ (មាត្រា ១១៧៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ សាក្សីដែលដឹងឮ ត្រូវសរសេរខ្លឹមសារនៃមតកសាសន៍។ បន្ទាប់ពីបានបញ្ជាក់ខ្លឹមសារនៃមតកសាសន៍នោះហើយ សាក្សីម្នាក់ៗ ត្រូវចុះហត្ថលេខាលើលិខិតនោះ។

ក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ត្រូវមានការបញ្ជាក់ពីតុលាការ (មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធផ្នែកទី៥ លេខ ៣)។ ហើយ ក្នុងករណីដែលតុលាការទទួលស្គាល់ថា ខ្លឹមសារនោះគឺជាឆន្ទៈពិតរបស់ម្ចាស់បណ្តាំ ពេលនោះមតកសាសន៍ នឹងមានសុពលភាព។

### ៣.២.២.២ មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ (មាត្រា ១១៧៨)

តាមច្បាប់ ជនដែលត្រូវជាប់ឃុំឃាំងដោយសាលក្រមរបស់តុលាការ ឬ ដោយបញ្ជារដ្ឋបាល អាចធ្វើមតកសាសន៍តាមវិធីធម្មតាបាន។ តាមនីតិវិធីច្បាប់ ជនដែលនៅលើនាវា ឬ នៅក្នុងយន្តហោះអាចធ្វើមតកសាសន៍ដោយវិធីធម្មតាបាន។ ទោះជាយ៉ាងនេះក៏ដោយ ពួកគេមិនអាចធ្វើមតកសាសន៍តាមលិខិតយថាភូត ឬ តាមលិខិតសំងាត់បានទេ ព្រោះពួកគេគ្មានសិទ្ធិរកជំនួយពីសារការីបានឡើយ។ លើសពីនេះ ប្រសិនបើពួកគេ មិនចេះអក្សរ ឬមានជម្ងឺ មិនអាចសរសេរលិខិតបាន ពួកគេមិនអាចធ្វើមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនបាននោះទេ។ ក្នុងករណីនេះ ពួកគេគ្មានផ្លូវអាចធ្វើមតកសាសន៍បានឡើយ។ ដូចនេះ ក្រមរដ្ឋប្បវេណីផ្តល់នូវវិធីពិសេសនៃមតកសាសន៍។ នីតិវិធីនៃករណីនេះ គឺប្រហាក់ប្រហែលនឹងមតកសាសន៍ដោយលិខិតយថាភូតដែរ គឺនគរបាល ឬ នាវិក ម្ចាស់យន្តហោះ ជាដើម នឹងដើរតួនាទីដូចជាសារការីដែរ។

មតកសាសន៍ ដោយផ្អែកលើមាត្រានេះ គ្រាន់តែជាមតកសាសន៍ដែលធ្វើឡើងជាបណ្តោះអាសន្នប៉ុណ្ណោះ ដូច្នេះមតកសាសន៍នេះ នឹងបាត់បង់នូវអានុភាព ប្រសិនបើម្ចាស់បណ្តាំអាចរស់នៅរយៈពេល ៦ ខែ ក្រោយពេលចេញពីកន្លែងឃុំឃាំង ឬ ក្រោយពេលចុះពីនាវា ឬ យន្តហោះ ជាអាទិ៍ (មាត្រា ១១៧៨ កថាខណ្ឌទី ៥ នៃក្រមរដ្ឋប្បវេណី)។

### ៣.២.៣. មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ

ជាគោលការណ៍ មតកសាសន៍ដែលធ្វើមិនត្រូវតាមទម្រង់ណាមួយក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព

លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលធ្វើដោយម្ចាស់បណ្តាំដូចគ្នា។ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំណាដែលមានខ្លឹមសារផ្ទុយគ្នា នឹងត្រូវចាត់ទុកជាមោឃៈទៅតាមកម្រិតនៃភាពផ្ទុយគ្នានោះ (មាត្រា ១១៧០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើមានតែមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំមួយទេ មតកសាសន៍នោះមានសុពលភាពពេញលេញ។ ប្រសិនបើមានមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំពីរ អានុភាពនឹងត្រូវដូចខាងក្រោម៖

ឧទាហរណ៍ មានមតកសាសន៍២ ។ មតកសាសន៍ A ថា "ឲ្យដីទៅប្រពន្ធ X។ ឲ្យឡានទៅកូន Y។" ដោយឡែក មតកសាសន៍ B ថា "ឲ្យឡាន និង ដីទៅប្រពន្ធ X។"

**-មតកសាសន៍ទាំងពីរគ្មានការចុះថ្ងៃខែឆ្នាំ**

ដីត្រូវប្រគល់ឲ្យទៅ X ពីព្រោះគ្មានការផ្ទុយគ្នារវាងមតកសាសន៍ទេ នៅចំណុចនេះ។ មួយវិញទៀត មតកសាសន៍ទាំងពីរ គ្មានអានុភាព លើចំណុចដែលថាឲ្យឡានទៅ X ឬ Y ពីព្រោះមតកសាសន៍ទាំងពីរផ្ទុយគ្នា។

**-មតកសាសន៍ A មានចុះថ្ងៃខែឆ្នាំ ប៉ុន្តែ មតកសាសន៍ B គ្មានចុះថ្ងៃខែឆ្នាំ**

ដីត្រូវប្រគល់ឲ្យទៅ X ហើយ ឡានត្រូវប្រគល់ឲ្យ Y ពីព្រោះមតកសាសន៍ A មានសុពលភាពពេញលេញ។

**-មតកសាសន៍ទាំងពីរមានចុះថ្ងៃខែឆ្នាំ ហើយមតកសាសន៍ A បានធ្វើតាមក្រោយ**

ដីត្រូវប្រគល់ឲ្យទៅ X ហើយ ឡានត្រូវប្រគល់ឲ្យ Y ពីព្រោះមតកសាសន៍ A មានសុពលភាពពេញលេញ។ ក្នុងករណីនេះ "ឡានត្រូវប្រគល់ឲ្យ Y" នៅក្នុងមតកសាសន៍ B ត្រូវចាត់ទុកថាមានចុះថ្ងៃខែឆ្នាំ (មាត្រា ១១៨៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

### ៣.២.៤. មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស

ជនជាតិខ្មែររស់នៅបរទេស ត្រូវធ្វើមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួន។ ប្រសិនបើគាត់ចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតសម្ងាត់ គាត់ត្រូវស្នើរទៅកុងស៊ុលកម្ពុជានៃប្រទេសដែលគាត់រស់នៅ ដើរតួនាទីជាសារការី (មាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណី)។

## ៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

មានតែចំណុចដែលច្បាប់បានកំណត់ទេ ដែលអាចសរសេរក្នុងមតកសាសន៍បាន។ ម្ចាស់បណ្តាំ ចង់សរសេរអ្វីៗក្រៅពីចំណុចទាំងនេះក៏បានដែរ ក៏ប៉ុន្តែពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។

**- ទាក់ទងនឹងសន្តតិកម្ម**

**ក.** ការផ្តាច់មតិកពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន និង ការលុបចោលនូវការផ្តាច់មតិកពីសន្តតិជន (មាត្រា ១១៥១, មាត្រា ១១៥៤ នៃក្រមរដ្ឋប្បវេណី)

**ខ**. ការកំណត់ចំណែកមតិក (មាត្រា ១១៨២ នៃក្រមរដ្ឋប្បវេណី)

**គ**. ការកំណត់នូវវិធីបែងចែកមតិក (មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណី)

**ឃ**. ការហាមឃាត់នូវការបែងចែកមតិក (មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណី)

**ង**. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១១៨៦នៃក្រមរដ្ឋប្បវេណី)

**- ទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិ**

**ក**. អច្ច័យទានសកល អច្ច័យទានពិសេស (មាត្រា ១១៨៤ នៃក្រមរដ្ឋប្បវេណី)

**ខ**.ការវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ (មាត្រា ១១៣ នៃក្រមរដ្ឋប្បវេណី)

**- ទំនាក់ទំនងនឹងឋានៈបុគ្គល**

**ក**. ការទទួលស្គាល់កូន (មាត្រា ៩៩៧ នៃក្រមរដ្ឋប្បវេណី)

**ខ**. ការកំណត់អ្នកអាណាព្យាបាលនៃអនីតិជន (មាត្រា ១០៦៨ នៃក្រមរដ្ឋប្បវេណី)

### ៥. ការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំ អាចលុបចោលមតកសាសន៍នៅពេលណាក៏បាន។ ប៉ុន្តែ មតកសាសន៍នឹងមានអានុភាព នៅក្រោយពេលម្ចាស់បណ្តាំបានទទួលមរណភាព។ នៅពេលមានវិវាទ ម្ចាស់បណ្តាំបានទទួលមរណភាពបាត់ទៅហើយ ដូច្នេះមិនអាចដឹងថាម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ឬក៏អត់នោះទេ។ ដូច្នេះ ដើម្បីដោះស្រាយវិវាទដូចនេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តនូវវិធានទាក់ទងនឹងវិធីនៃការលុបចោលមតកសាសន៍។ ការលុបចោលមតកសាសន៍ ត្រូវធ្វើដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី (មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណី)។

នៅពេលដែលមតកសាសន៍ត្រូវបានលុបចោល នឹងត្រូវចាត់ទុកថាគ្មានមតកសាសន៍នោះតាំងពីដំបូង។

<u>ការលុបចោលមតកសាសន៍ អាចបែងចែកជាពីរប្រភេទ៖</u>

- ការលុបចោលដោយមតកសាសន៍ (មាត្រា ១១៨៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)

-ការលុបចោលដែលច្បាប់បានកំណត់ (ក្នុងករណីដែលបានប្រព្រឹត្តអំពើកំណត់មួយចំនួនដែលផ្ទុយនឹង មតកសាសន៍មុន = ការលុបចោលដែលច្បាប់កំណត់) (មាត្រា ១១៨៩ កថាខណ្ឌទី ២ មាត្រា ១១៩០ មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី)។

### ៥.១ ការលុបចោលដោយមតកសាសន៍ ( មាត្រា ១១៨៩ កថាខណ្ឌទី ១)

ក្នុងករណីដែលបានធ្វើមតកសាសន៍ជាថ្មី ដែលមានខ្លឹមសារថា **"លុបចោលមតកសាសន៍ដែលបានធ្វើ នៅថ្ងៃទី ០ ខែ ០ ឆ្នាំ ០"** គឺជាការលុបចោលដោយមតកសាសន៍។

មតកសាសន៍ដែលលុបចោលមតកសាសន៍ មិនមានទម្រង់ដូចនឹង មតកសាសន៍ដែលត្រូវបានលុបចោលនោះទេ។ ឧទាហរណ៍ ម្ចាស់បណ្តាំធ្វើមតកសាសន៍ទី ២ ដោយលិខិតផ្ទាល់ខ្លួន ដើម្បីលុបចោលមតកសាសន៍ទី ១ ដែលធ្វើដោយលិខិតយថាភូត។

មតកសាសន៍ទី ២ ដែលលុបចោលមតកសាសន៍ទី ១ ក៏ជាមតកសាសន៍ដែរ។ ដូច្នេះ មតកសាសន៍ទី ២ ត្រូវអនុវត្តតាមទម្រង់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី។ លើសពីនេះទៀត ម្ចាស់បណ្តាំក៏អាចលុបចោលមតកសាសន៍ទី ២ បានផងដែរ។ ប្រសិនបើមតកសាសន៍ទី ២ ត្រូវបានលុបចោល នឹងត្រូវចាត់ទុកថាគ្មានមតកសាសន៍ទី ២ តាំងពីដំបូង។ ដូច្នេះ មានគំនិតមួយលើកឡើងថា ដោយសារយើងចាត់ទុកថាគ្មានមតកសាសន៍ទី ២ តាំងពីដំបូង យើងត្រូវគិតថាមតកសាសន៍ទី ១ មានអានុភាពតាំងពីដំបូងមករហូតដល់ឥឡូវ មានន័យថា មតកសាសន៍ទី ១ នឹងមានអានុភាពឡើងវិញ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវគិតពីឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។ យើងមិនត្រឹមតែគិតអំពីខ្លឹមសារនៃមតកសាសន៍ទាំងពីរនោះទេ ប៉ុន្តែយើងក៏ត្រូវគិតពីវិធីនៃការលុបចោលនៃមតកសាសន៍ទី ២ (ការលុបចោលដោយមតកសាសន៍ទី ៣ ការលុបចោលដោយបំផ្លាញមតកសាសន៍ទី ២ ការលុបចោលដោយការបោះបង់កម្មវត្ថុនៃមតកសាសន៍) និង ហេតុផលពីក្រោយការលុបចោលមតកសាសន៍ទី ២ ដោយម្ចាស់បណ្តាំ។ម្យ៉ាងទៀត យើងត្រូវព្យាយាមបកស្រាយ ថាតើឆន្ទៈពិតរបស់ម្ចាស់បណ្តាំ ចង់ឲ្យមតកសាសន៍ទី ១ មានអានុភាពឡើងវិញ ឬយ៉ាងណា។

### ៥.២. ការលុបចោលដែលច្បាប់កំណត់

ក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើសកម្មភាពផ្ទុយនឹងមតកសាសន៍មុន ករណីនោះត្រូវបានចាត់ទុកថា បានលុបចោលដោយស្វ័យប្រវត្តិនូវមតកសាសន៍មុន។

<u>ក្នុងករណីដែលមតកសាសន៍ក្រោយមានភាពផ្ទុយនឹងមតកសាសន៍មុន (មាត្រា ១១៨៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)</u>

ក្នុងករណីដែលមតកសាសន៍មុន និង មតកសាសន៍ក្រោយមានភាពផ្ទុយគ្នា ទោះជាមិនបានបង្ហាញឆន្ទៈលុបចោលមតកសាសន៍ក៏ដោយ ក៏ត្រូវចាត់ទុកថា បានលុបចោលនូវភាគដែលមានភាពផ្ទុយនោះ ក្នុងមតកសាសន៍មុន។

<u>ឧទាហរណ៍ ដូចករណីខាងក្រោមនេះ</u>

មតកសាសន៍មុន ៖ "ឲ្យ A ទទួលដោយសន្តតិកម្ម នូវទ្រព្យសម្បត្តិទាំងអស់ (ដី ប្រាក់បញ្ញើនៅធនាគារ ទ្រព្យផ្សេងទៀត)"

មតកសាសន៍ក្រោយ ៖ "ឲ្យ A ទទួលដោយសន្តតិកម្មនូវដីទាំងអស់ ឲ្យ B ទទួលសន្តតិកម្មនូវប្រាក់បញ្ញើ នៅធនាគារទាំងអស់ ឲ្យ C ទទួលដោយសន្តតិកម្មនូវទ្រព្យក្រៅពីនេះ" ។

ក្នុងករណីនេះ ត្រូវចាត់ទុកថា "ឲ្យ A ទទួលដោយសន្តតិកម្មនូវប្រាក់បញ្ញើធនាគារ និង ទ្រព្យផ្សេងទៀត" ក្នុងមតកសាសន៍មុន ត្រូវបានលុបចោល។

<u>ស្តីពីវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើ សកម្មភាពផ្សេងទៀត (មាត្រា ១១៩០ នៃក្រមរដ្ឋប្បវេណី)</u>

ស្តីពីវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើ សកម្មភាពផ្សេងទៀត ត្រូវបានចាត់ទុកថា ស្តីពីភាគដែលផ្ទុយនឹងមតកសាសន៍ ត្រូវបានលុបចោល។

ឧទាហរណ៍ ម្ចាស់បណ្តាំបានសរសេរក្នុងមតកសាសន៍ថា "ឲ្យ A ធ្វើសន្តតិកម្មដី B" ក៏ប៉ុន្តែ បើសិនជាម្ចាស់បណ្តាំបានលក់ដីនោះបាត់ទៅពេលគាត់នៅរស់ ត្រូវចាត់ទុកថា គាត់បានលុប ចោលនូវមតកសាសន៍នោះ។

<u>ការបំផ្លាញចោលនូវមតកសាសន៍ ជាអាទិ៍ (មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី)</u>

ប្រសិនបើ ម្ចាស់បណ្តាំបានបំផ្លាញចោលច្បាប់ដើមនៃមតកសាសន៍ ឬ វត្ថុដែលជាកម្មវត្ថុនៃ មតកសាសន៍នោះ**ដោយចេតនា** ត្រូវចាត់ទុកថាម្ចាស់បណ្តាំ បានលុបចោលនូវផ្នែកដែលត្រូវបាន បំផ្លាញនោះ។ មួយវិញទៀត ប្រសិនបើតតិយជនបានបំផ្លាញមតកសាសន៍ មតកសាសន៍នោះ នៅ តែមានសុពលភាព។ លើសពីនេះទៀត កាលណាម្ចាស់បណ្តាំបានបំផ្លាញមតកសាសន៍ដោយ កំហុស មតកសាសន៍នោះក៏នៅតែមានសុពលភាពដដែល។ ដូច្នេះ បើសិនជាតតិយជន ឬ ម្ចាស់ បណ្តាំហែកចោល ឬ ដុតចោលមតកសាសន៍ដោយកំហុស មតកសាសន៍នោះនៅតែមានសុពល ភាពដដែល។ ប៉ុន្តែ បើសិនជា គេមិនអាចអានមតកសាសន៍ដែលត្រូវហែក ឬ ដុតចោលនោះបានទេ គឺគ្មានវិធីណាទេ គឺត្រូវចាត់ទុកថាគ្មានសុពលភាព។

ក្នុងករណីដែលមតកសាសន៍ធ្វើដោយលិខិតយថាភូត សារការីរក្សានឹងរក្សាទុកនូវច្បាប់ ដើម ហើយម្ចាស់បណ្តាំរក្សាទុកតែមតកសាសន៍ដែលបានថតចម្លងប៉ុណ្ណោះ។ ដូច្នេះ ការលុប ចោលដោយការបំផ្លាញមតកសាសន៍នឹងមិនអាចកើតមានឡើងនោះទេ។ ទោះបីជាម្ចាស់បណ្តាំ បំផ្លាញមតកសាសន៍ដែលបានថតចម្លងក៏ដោយ ក៏មិនអាចចាត់ទុកជាការលុបចោលមតកសាសន៍ បានឡើយ។

### ៥.៣. ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ

ក្រមរដ្ឋប្បវេណីចែងអំពី ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុង ការបង្ហាញឆន្ទៈ យោងតាមមាត្រា ៣៥៦ និង មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី។ ពីព្រោះមតក សាសន៍ គឺជាសកម្មភាព ឯកតោគី ហើយមតកសាសន៍អាចត្រូវបានលុបចោលដោយផ្អែកលើវិការៈ ក្នុងការបង្ហាញឆន្ទៈបានផងដែរ (មាត្រាទាំងនោះមិនត្រឹមតែអនុវត្តលើកិច្ចសន្យានោះទេ ប៉ុន្តែ មាត្រាទាំងនេះក៏អនុវត្តលើសកម្មភាពឯកតោភាគីផងដែរ ។ សូមមើល មាត្រា ៣១២ កថាខណ្ឌទី

២ នៃក្រមរដ្ឋប្បវេណី)។ ការលុបចោលមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ និង ការលុបចោលមតកសាសន៍ដោយយោងតាមមាត្រា ១១៨៨ និង មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី មានលក្ខណៈដូចគ្នា ប៉ុន្តែខុសគ្នាត្រង់៖

-ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ តម្រូវឲ្យមានអង្គហេតុច្បាស់លាស់ ដូចជា កំហុស ការឆបោក ឬ ការបង្ខិតបង្ខំ ជាដើម។ ម្យ៉ាងវិញទៀត ការលុបចោលមតកសាសន៍យោងតាមមាត្រា ១១៨៨ និង មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យមានអង្គហេតុណាមួយទេ គ្រាន់តែឲ្យមានទម្រង់ជាក់ច្បាស់ទៅបានហើយ។

-សិទ្ធិក្នុងការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ អាចអនុវត្តដោយ សន្តតិជនបាន (មាត្រា ៣៥៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ មួយវិញទៀត ការលុបចោលមតកសាសន៍ យោងតាមមាត្រា ១១៨៨ និង មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើដោយម្ចាស់បណ្តាំដោយផ្ទាល់។

## ៦. អានុភាពនៃមតកសាសន៍

### ៦.១. អានុភាពនៃមតកសាសន៍

មតកសាសន៍ ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព (មាត្រា ១១៩៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលមតកសាសន៍ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះ ត្រូវបានបំពេញ នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាពចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ (មាត្រា ១១៩៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ ក្នុងករណីដែលឪពុក បានធ្វើអច្ច័យទានដីដែលមានភ្ជាប់នឹងអាគារ ទៅឲ្យកូនស្រីរបស់គាត់ ដោយមានល័ក្ខខ័ណ្ឌថា "ក្រោយពេលកូនស្រីបានរៀបអាពាហ៍ពិពាហ៍" ។ ប្រសិនបើកូនស្រីមិន ទាន់រៀបការ ពេលម្ចាស់បណ្តាំទទួលមរណៈភាព មតកសាសន៍នោះគ្មានអានុភាពពេលម្ចាស់បណ្តាំទទួលមរណៈភាពទេ ប៉ុន្តែ វានឹងមានអានុភាពនៅពេលកូនស្រីរៀបអាពាហ៍ពិពាហ៍។

### ៦.២. មោឃភាព និង ការលុបចោលនូវមតកសាសន៍

ក្នុងករណីដែលមតកសាសន៍ត្រូវបានធ្វើមិនត្រឹមត្រូវនឹងទម្រង់ (មាត្រា ១១៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី) (មាត្រា ១១៦៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ឬ ក្នុងករណីដែលម្ចាស់បណ្តាំ ពុំមានសមត្ថភាពនាពេលធ្វើមតកសាសន៍ (មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី) ឬ ក្នុងករណី

ដែលខ្លឹមសារនៃមតកសាសន៍នោះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ មតកសាសន៍នោះនឹងគ្មានសុពលភាពទេ។

មតកសាសន៍អាចត្រូវលុបចោលដោយម្ចាស់បណ្តាំ បើយោងតាមមាត្រា ១១៨៨ និង មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណី។ លើសពីនេះទៀត មតកសាសន៍អាចត្រូវលុបចោលដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ (កំហុស ការឆបោក ឬ ការបង្ខិតបង្ខំ ជាដើម) ដោយម្ចាស់បណ្តាំ ឬ សន្តតិជនរបស់ម្ចាស់បណ្តាំ។ ក្នុងករណីដូចនេះ មតកសាសន៍នឹងបាត់បង់អានុភាព។

## ៧. អច្ច័យទាន

### ៧.១. លក្ខណៈទូទៅ

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំបានធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍។ អ្នកទទួលអច្ច័យទាន គេហៅថា "អច្ច័យលាភី" ។

អច្ច័យទាន គឺជារបបមួយប្រហាក់ប្រហែលនឹងប្រទានកម្មដែរ ក៏ប៉ុន្តែអច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ដូច្នេះ ខុសគ្នានឹងប្រទានកម្មដែលជាការផ្ទេរទ្រព្យសម្បត្តិ តាមរយៈកិច្ចសន្យា។

អច្ច័យទានមានអានុភាពនៅពេលម្ចាស់បណ្តាំទទួលមរណភាព (មាត្រា ១១៩៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

អច្ច័យទាន មានពីរប្រភេទ គឺ ៖

- អច្ច័យទាន ដែលជាប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគដោយកំណត់ទៅតាមភាគ (អច្ច័យទានសកល) ឧទាហរណ៍ "ឲ្យ ១ភាគ៣ នៃមតិកទៅលោក X"
- អច្ច័យទាន ដែលជាប្រទានកម្មនូវទ្រព្យសម្បត្តិពិសេស (អច្ច័យទានពិសេស) ឧទាហរណ៍ "ឲ្យឡានខ្ញុំទៅ លោក X"

អ្នកទទួលអច្ច័យទានសកល (=អច្ច័យលាភីសាកល) មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន (មាត្រា ១២១២ នៃក្រមរដ្ឋប្បវេណី)។

### ៧.២. អច្ច័យលាភី

ប្រសិនបើអច្ច័យលាភីបានទទួលមរណភាពនៅមុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យទានពុំបង្កើតអានុភាពឡើយ។ លើសពីនេះទៀត អច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះ ត្រូវបានបំពេញនៅក្រោយពេលអច្ច័យលាភីបានទទួលមរណភាព អច្ច័យទានពុំបង្កើតអានុភាពឡើយ (មាត្រា ១២០០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដូចនោះ កម្មវត្ថុនៃអច្ច័យទាន នឹងក្លាយជាកម្មសិទ្ធរបស់សន្តតិជន (មាត្រា ១១៩៨ នៃក្រមរដ្ឋប្បវេណី)។

ប៉ុន្តែ ម្ចាស់បណ្តាំអាចធ្វើឲ្យអច្ច័យទានមានអានុភាពឡើងវិញ ទោះបីជា អច្ច័យលាភីបានស្លាប់ហើយក៏ដោយ (មាត្រា ១២០០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ម្ចាស់បណ្តាំបានសរសេរក្នុងមតកសាសន៍ថា "ខ្ញុំ ឲ្យឡានទៅលោក X ជាអច្ច័យទាន។ អច្ច័យទាននេះនឹងមិនបាត់បង់អានុភាពឡើយ ទោះបីជាលោក X ស្លាប់មុនខ្ញុំក៏ដោយ" ។ ករណីនេះ លោក X បានស្លាប់មុនម្ចាស់បណ្តាំ សន្តតិជនរបស់លោក X នឹងទទួលបានឡានជាអច្ច័យទាន។

ចំពោះទារកដែលនៅក្នុងគភ៌ នៅពេលម្ចាស់បណ្តាំទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន (មាត្រា ៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ កាលណាទារកក្នុងផ្ទៃនោះកើតមក នឹងត្រូវមានសិទ្ធិទទួលបានអច្ច័យទាននោះ។

## ៧.៣. ការបោះបង់ ឬ ការទទួលស្គាល់នូវអច្ច័យទាន

អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ដូច្នេះ ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព ដោយគ្មានពាក់ព័ន្ធនឹងឆន្ទៈរបស់អច្ច័យលាភីទេ។ ក៏ប៉ុន្តែ មិនអាចបង្ខំអច្ច័យលាភីបានទេ ម្ល៉ោះហើយ អច្ច័យលាភីអាចបោះបង់ អច្ច័យទានបាន (មាត្រា ១២០១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ការបោះបង់អច្ច័យទានមានអានុភាពប្រតិសកម្ម (មាត្រា ១២០១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ប្រសិនបើអច្ច័យលាភីបោះបង់អច្ច័យទាន កម្មវត្ថុនៃអច្ច័យទាន នឹងត្រូវចាត់ទុកជាផ្នែកនៃមតិកតាំងពីដំបូង។

<u>ការបោះបង់អច្ច័យទានពិសេស</u>

មិនមានបទបញ្ញត្តិណាចែងនៅក្នុងក្រមរដ្ឋប្បវេណី អំពីការបោះបង់អច្ច័យទានពិសេសនោះទេ។ ដូច្នេះ អច្ច័យលាភីត្រូវបង្ហាញឆន្ទៈនៃការបោះបង់អច្ច័យទានទៅឲ្យបុគ្គលទទួលខុសត្រូវលើអច្ច័យទាន (ឧទាហរណ៍ សន្តតិជន អច្ច័យលាភីសកល នីតិបុគ្គលមតិក) ដោយវិធី ណាមួយ ដូចជាការប្រាប់ដោយផ្ទាល់មាត់ ផ្ញើរសំបុត្រ ឬ អ៊ីម៉េល ជាអាទិ៍។

គ្មានពេលកំណត់សម្រាប់ការបោះបង់ទេ។ ប៉ុន្តែ កាលណាអច្ច័យលាភីបានទទួលអច្ច័យទានហើយ ខ្លួនមិនអាចបោះបង់អច្ច័យទានបាននោះទេ (មើលមាត្រា ១២០៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ការទទួលយកអច្ច័យទាន អាចធ្វើទៅបានដោយការបង្ហាញឆន្ទៈដល់បុគ្គលទទួលខុសត្រូវលើអច្ច័យទាន ដោយ អច្ច័យលាភី។ ឬ ប្រសិនបើ អច្ច័យលាភីបានទទួលកម្មវត្ថុនៃអច្ច័យទានដោយមិនមានការប្រកែក គឺ អាចចាត់ទុកថាជាការទទួលអច្ច័យទាននោះ។

លើសពីនេះទៀត បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬ បុគ្គលដែលមានទំនាក់ទំនងជាមួយផលប្រយោជន៍ (ឧទាហរណ៍ ម្ចាស់បំណុលរបស់បុគ្គលដែលមានករណីយកិច្ច

ពាក់ព័ន្ធនឹងអច្ច័យទាន) អាចធ្វើការដោស់តឿនពីការទទួលយក ឬ ការលុបចោលកិច្ចសន្យាក្នុងកំឡុងពេលសមរម្យមួយ ទៅកាន់អច្ច័យលាភី។ ប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាននៅក្នុងអំឡុងពេលកំណត់នោះទេ ត្រូវចាត់ទុកថាអច្ច័យលាភីបានទទួលអច្ច័យទាននោះ (មាត្រា ១២០២ នៃក្រមរដ្ឋប្បវេណី)។

<u>ការបោះបង់អច្ច័យទានសកល</u>

ចំពោះការបោះបង់ចោលអច្ច័យទានសកល គឺត្រូវធ្វើឲ្យមានអានុភាពដោយអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម (មាត្រា ១២០១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ ការបោះបង់ត្រូវធ្វើឡើង រយៈពេល ៣ខែ ក្រោយពេលអច្ច័យលាភីបានដឹងពីការធ្វើអច្ច័យទានសកល (មាត្រា ១២៤៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះទៀត ការបោះបង់ត្រូវធ្វើដោយការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ (មាត្រា ១២៦០ មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ១៩)។

## ៧.៤. អច្ច័យទានដែលភ្ជាប់បន្ទុក

### ៧.៤.១. ការទទួលខុសត្រូវរបស់អច្ច័យលាភី (មាត្រា ១២១១)

អច្ច័យទានដែលភ្ជាប់បន្ទុក គឺជាអច្ច័យទាន ដែលតម្រូវឲ្យអច្ច័យលាភីទទួលបន្ទុកនូវករណីយកិច្ចកំណត់មួយ ចំនួន។

ឧទាហរណ៍ ម្ចាស់បណ្តាំ A បានទុកមតកសាសន៍មួយ ដែលមានខ្លឹមសារថា "ធ្វើអច្ច័យទានដីទៅឲ្យ B។ ក៏ ប៉ុន្តែ B ត្រូវបង់ ១០០០ ដុល្លារ ទៅអោយ C"។

អច្ច័យលាភី ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ច ត្រឹមកំរិតដែលមិនលើសពីតំលៃនៃវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន។

ឧទាហរណ៍ ក្នុងករណីខាងលើនេះ ប្រសិនជាដីនោះ មានតំលៃ ៨០០ដុល្លារ B អាចបង់ ៨០០ ដុល្លារទៅ C ហើយគាត់អាចធ្វើលទ្ធកម្មដីនោះបាន។

### ៧.៤.២. ករណីតម្លៃនៃកម្មវត្ថុត្រូវបានកាត់បន្ថយ

កាលណាតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកត្រូវបានកាត់បន្ថយ ដោយសំអាងលើការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ការទាមទារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងអច្ច័យលាភី នឹងរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគថយចុះនោះ បើសិនជាម្ចាស់បណ្តាំបានបង្ហាញឆន្ទៈខុសគ្នា នៅក្នុងមតកសាសន៍ត្រូវអនុលោមតាមឆន្ទៈនោះ (មាត្រា ១២១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ ម្ចាស់បណ្តាំ A បានរក្សាទុកមតកសាសន៍ដែលមានខ្លឹមសារថា "ប្រគល់អច្ច័យទានដីឲ្យ B។ ប៉ុន្តែ B ត្រូវសងទៅ C ១០០០$។" តម្លៃដីនោះគឺ ២០០០$ ប៉ុន្តែ B សងតែ ១០០០$ ទៅឲ្យសន្តតិជន ដោយសារតែការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ក្នុងករណីនេះ ដោយសារតែតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកត្រូវបានកាត់បន្ថយចំនួន ៥០% បន្ទុកក៏ត្រូវកាត់បន្ថយ ៥០% ដែរ។ ដូច្នេះ B ត្រូវសងទៅ C តែ ៥០០$ ប៉ុណ្ណោះ។

មួយវិញទៀត ប្រសិនបើ ម្ចាស់បណ្តាំសរសេរក្នុងមតកសាសន៍ថា "បើទោះជាតម្លៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក ត្រូវបានកាត់បន្ថយដោយសារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយ បន្ទុកក៏មិនត្រូវកាត់បន្ថយដែរ។ មតកសាសន៍នេះនឹងបង្កើតអានុភាព ហើយB ត្រូវបង់ ១០០០$ ទៅ C។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវធ្វើការកត់សម្គាល់ថា ទោះបីជាក្នុងករណីនេះក៏ដោយ ក៏ត្រូវអនុលោមតាម មាត្រា ១២១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីដែរ។ ដូច្នេះហើយ ប្រសិនបើ B បង់ ១៥០០$ ឲ្យទៅសន្តតិជនដោយសារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយ ក៏តម្លៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកមានតម្លៃត្រឹមតែ ៥០០$ ប៉ុណ្ណោះ។ ដូចនេះ B ត្រូវបង់ ៥០០$ ទៅឲ្យ C។

### ៧.៤.៣. ករណីអច្ច័យលាភីមិនបានអនុវត្តករណីយកិច្ច

សន្តតិជន ឬ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវមាន ២ ជម្រើស៖

១. ពួកគេអាចដាក់បណ្តឹងទាមទារការអនុវត្តករណីយកិច្ច ពីអច្ច័យលាភី

២. ពួកគេអាចលុបចោលកិច្ចសន្យាអច្ច័យទានដោយផ្អែកលើ មាត្រា ១១៩៣ នៃក្រមរដ្ឋប្បវេណី។

*ទោះបីជាអច្ច័យលាភីមិនបានអនុវត្តករណីយកិច្ចក៏ដោយ ក៏សន្តតិជនមិនអាចរំលាយអច្ច័យទានដោយផ្អែកលើមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីបានដែរ ពីព្រោះ អច្ច័យទានមិនមែនជាកិច្ចសន្យានោះទេ។

## ៨. ការអនុវត្តមតកសាសន៍

### ៨.១ អត្ថន័យនៃការអនុវត្តមតកសាសន៍

ការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ ដើម្បីសម្រេចនូវខ្លឹមសារនៃមតកសាសន៍នោះ ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះ បានកើតឡើង។

អានុភាពនៃមតកសាសន៍ កើតឡើងដោយគ្មាននីតិវិធីច្បាស់លាស់នោះទេ។ ឧទាហរណ៍ នៅពេលដែលមតកសាសន៍បានកំណត់ចំណែកមតិកសម្រាប់សន្តតិជននីមួយៗ មតិកនោះក្លាយជាកម្មសិទ្ធរបស់សន្តតិជននោះដោយស្វ័យប្រវត្តិតាមរយៈចំណែកដែលត្រូវបានកំណត់នោះ។ ឬក៏អច្ច័យលាភីមានសិទ្ធិទទួលបាននូវកម្មវត្ថុនៃអច្ច័យទាននោះ។ ក៏ប៉ុន្តែ ដើម្បីបំពេញនូវអានុភាពនោះ

ចាំបាច់ត្រូវមាននីតិវិធីច្បាស់លាស់ ។ ឧទាហរណ៍ ត្រូវផ្ទេរការកាន់កាប់ទ្រព្យជាកម្មវត្ថុនៃសន្តតិកម្ម ត្រូវដកលុយពីធនាគារ ត្រូវផ្ទេរការចុះបញ្ជីកម្មសិទ្ធអចលនវត្ថុ ជាដើម។ ដូច្នេះ ក្រមរដ្ឋប្បវេណី មានបញ្ញត្តិដែលចែងអំពី នីតិវិធីនៃការអនុវត្តមតកសាសន៍។

### ៨.២. ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍ (មាត្រា ១២១៣)

ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវធ្វើការពិនិត្យបញ្ជាក់ រួមទាំងមតកសាសន៍ដោយវិធីពិសេស (មាត្រា ១២១៣ កថាខណ្ឌ ទី ២ នៃក្រមរដ្ឋប្បវេណី)។ ជាពិសេស ត្រូវកត់សម្គាល់ថា មតកសាសន៍ដោយជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ត្រូវបានបញ្ជាក់ដោយតុលាការរួចហើយ (មាត្រា ១១៧៧ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ នៅតែតម្រូវឲ្យមានការពិនិត្យបញ្ជាក់។

#### ៨.២.១. គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍

គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ គឺជាការរក្សាទុកនូវភស្តុតាង។ តាមរយៈការពិនិត្យបញ្ជាក់ តុលាការបានកត់ត្រាទុកនូវស្ថានភាពខាងក្រៅនៃមតកសាសន៍ ចៀសវាងការក្លែងបន្លំ ឬការផ្លាស់ប្តូរ។ ដូច្នេះ តុលាការនឹងកត់ត្រាទុកនូវមតកសាសន៍ដោយការថតចម្លង ការថតយករូបភាព និង ពណ៌នាស្ថានភាពខាងក្រៅនៃមតកសាសន៍ដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត តុលាការនឹងមិនវិនិច្ឆ័យសុពលភាពរបស់មតកសាសន៍នោះទេ។ ប្រសិនបើមានបុគ្គលណាម្នាក់ចង់លើកមតិប្រឆាំងលើសុពលភាពនៃមតកសាសន៍ បុគ្គលនោះត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ។ ការបញ្ជាក់នូវសុពលភាពនៃមតកសាសន៍ មិនមែនជាគោលបំណងនៃការពិនិត្យបញ្ជាក់នោះទេ។

#### ៨.២.២. នីតិវិធីសំខាន់ដែលត្រូវគោរពតាមមុនពេលឡើងតុលាការ

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ក្រោយពីបានដឹងពីការចាប់ផ្តើមសន្តតិកម្ម ត្រូវបង្ហាញឯកសារមតកសាសន៍ទៅកាន់តុលាការ ដោយគ្មានការយឺតយ៉ាវ ហើយតុលាការត្រូវពិនិត្យបញ្ជាក់។ ករណីគ្មានអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ គេត្រូវធ្វើដូចខាងលើដែរ ក្រោយពេលសន្តតិជន ឬ ជនពាក់ព័ន្ធនឹងផលប្រយោជន៍ បានរកឃើញលិខិតមតកសាសន៍នោះ (មាត្រា ១២១៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើសន្តតិជនបានរកឃើញមតកសាសន៍ដែលរហែក ហើយពួកគេគិតថាមតកសាសន៍នោះត្រូវបានលុបចោល ពួកគេនៅតែត្រូវប្រគល់មតកសាសន៍នោះទៅឲ្យតុលាការដើម្បីពិនិត្យបញ្ជាក់ ពីព្រោះតុលាការគឺជាអ្នកកំណត់ចុងក្រោយថា មតកសាសន៍នោះត្រូវបានលុបចោល ឬក៏អត់។

ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា គេមិនត្រូវបើកមតកសាសន៍នោះទេ។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា សន្តតិជន ឬ ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវប្រគល់លិខិតមតកសាសន៍នោះទៅកាន់តុលាការ ដោយមិនត្រូវបើកមើលឡើយ។ ជាធម្មតា មតកសាសន៍ដែលបិទដោយប្រថាប់ត្រា គឺជាមតកសាសន៍ដោយលិខិតសម្ងាត់។ ប៉ុន្តែ ម្ចាស់បណ្តាំក៏អាចបិទប្រថាប់ត្រានូវមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនបានផងដែរ។ ករណីនេះ គេមិនត្រូវបើកមើលមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនដែលបានបិទប្រថាប់ត្រានោះទេ។

ជនដែលបានបើកលិខិតមតកសាសន៍ដោយមិនបានធ្វើការពិនិត្យបញ្ជាក់ ត្រូវពិន័យជាប្រាក់ មិនលើសពី ១ លានរៀល (មាត្រា ១២១៣ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែទោះបីជាមតកសាសន៍នោះត្រូវបានបើកមើលនៅក្រៅតុលាការក៏ដោយ មតកសាសន៍នោះក៏នៅតែមានសុពលភាពដដែល (មាត្រា ១២១៣ កថាខណ្ឌទី ៥ នៃក្រមរដ្ឋប្បវេណី)។

### ៨.២.៣. នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ

#### ៨.២.៣.១. សមត្ថកិច្ច

សាលាដំបូង គឺជាកន្លែងមានសមត្ថកិច្ចការចាប់ផ្តើមសន្តតិកម្ម (មាត្រា ៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៥)។ កន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាស័យដ្ឋានរបស់មតកជននៅពេលទទួលមរណភាព (មាត្រា ១១៩៦ នៃក្រមរដ្ឋប្បវេណី)។

#### ៨.២.៣.២. ការកោះហៅសន្តតិជន ជាអាទិ៍

ជាទូទៅ សន្តតិជនជាអ្នកដាក់ពាក្យសុំស្នើឲ្យមានការពិនិត្យបញ្ជាក់។ យោងតាមក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យមានវត្តមានរបស់សន្តតិជន ឬ អច្ច័យលាភីក្នុងការពិនិត្យបញ្ជាក់នោះទេ។ ប៉ុន្តែតុលាការគួរតែអនុញ្ញាតឲ្យសន្តតិជន ឬ អច្ច័យលាភី មានឱកាសចូលរួមនីតិវិធីពិនិត្យបញ្ជាក់នោះ។ ដូច្នេះតុលាការត្រូវកំណត់ពេលវេលាសម្រាប់ការពិនិត្យបញ្ជាក់ ហើយកោះហៅសន្តតិជន ឬ អច្ច័យលាភីដែលតុលាការបានស្គាល់នោះ។

ជាពិសេស ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា មតកសាសន៍នោះនឹងត្រូវបើកនៅក្នុងតុលាការដោយមានវត្តមានរបស់ សន្តតិជន ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ពួកគេ (មាត្រា ១២១៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ កាលណាមតកសាសន៍បិទដោយប្រថាប់ត្រា តុលាការត្រូវកោះហៅសន្តតិជន និង អច្ច័យលាភីដែលតុលាការបានស្គាល់ (ប៉ុន្តែ ជាធម្មតាតុលាការមិនស្គាល់អច្ច័យលាភីទេ ពីព្រោះមតកសាសន៍ត្រូវបានបិទដោយ

ប្រថាប់ត្រាបាត់ទៅហើយ)។ ទោះបីជាយ៉ាងនេះ ក៏ដោយ ក្នុងករណីមតកសាសន៍បិទដោយប្រថាប់ត្រា មិនមែនមានន័យថា គ្រប់សន្តតិជនទាំងអស់ត្រូវមានវត្តមាននោះទេ។

ការបើកមតកសាសន៍អាចប្រព្រឹត្តទៅបាននៅអំឡុងពេលពាក់កណ្តាលនៃនីតិវិធីពិនិត្យបញ្ជាក់បាន។

### ៨.២.៣.៣. កាលបរិច្ឆេទនៃការពិនិត្យបញ្ជាក់

តុលាការត្រូវពិនិត្យមតកសាសន៍។ ទោះបីជាមតកសាសន៍នោះហាក់ដូចជាគ្មានសុពលភាព ឬ ត្រូវបានលុបចោលក្តី ក៏តុលាការត្រូវតែធ្វើការពិនិត្យបញ្ជាក់ដែរ។ តុលាការគប្បីកត់ត្រាចំណុចដូចខាងក្រោមៈ

-បុគ្គលដែលបានស្នើសុំការពិនិត្យបញ្ជាក់

-កាលបរិច្ឆេទការពិនិត្យបញ្ជាក់

-បុគ្គលដែលមានវត្តមាននៅពេលធ្វើនីតិវិធីការពិនិត្យបញ្ជាក់

-ស្ថានភាពខាងក្រៅនៃមតកសាសន៍ ដូចជា ចំនួនទំព័រ ប្រភេទ និង គុណភាពក្រដាស ប្រភេទប៊ិច ហត្ថលេខា និង កាលបរិច្ឆេទនៅក្នុងមតកសាសន៍ ជាដើម។

-ថតរូបភាព និង ថតចម្លងមតកសាសន៍នោះ

## ៨.៣. អ្នកប្រតិបត្តិមតកសាសន៍

### ៨.៣.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

មតកជនអាចជ្រើសតាំង ឬ ប្រគល់អាណត្តិឲ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់បានតាមរយៈមតកសាសន៍ (មាត្រា ១១៨៦ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ប្រសិនបើមតកសាសន៍បានបញ្ញត្តអំពីការជ្រើសតាំង ឬ ប្រគល់អាណត្តិឲ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនត្រូវផ្តល់ដំណឹងទៅបុគ្គលដែលត្រូវបានជ្រើសតាំង ឬ តតិយជននោះ ឲ្យបានឆាប់រហ័សបំផុត។

ប្រសិនបើមតកសាសន៍មិនបានបញ្ញត្តដូចខាងលើនោះទេ សន្តតិជនត្រូវស្នើសុំទៅតុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍។ ប៉ុន្តែ គេមិនចាំបាច់ធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍គ្រប់ពេលនោះទេ។ ប្រសិនបើ សន្តតិជនទាំងអស់យល់ព្រមអនុវត្តមតកសាសន៍ដោយខ្លួនឯង នោះពួកគេអាចធ្វើដូចនេះបាន។ ករណីនេះ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍មិនមានភាពចាំបាច់នោះទេ។

ទោះជាយ៉ាងនេះក៏ដោយ ចំពោះការទទួលស្គាល់កូនតាមរយៈមតកសាសន៍ (មាត្រា ៩៩៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ការផ្តាច់មតិកដោយមតកសាសន៍ (មាត្រា ១១៥២ នៃក្រមរដ្ឋប្បវេណី)

ការលុបចោលការផ្ដាច់មតិកដោយមតកសាសន៍ (មាត្រា ១១៥៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី) អ្នកប្រតិបត្តិមតកសាសន៍ត្រូវអនុវត្តតាមនីតិវិធីណាមួយ។ ដូច្នេះហើយ ប្រសិនបើមតកសាសន៍មានរាប់បញ្ចូលបញ្ហាទាំងនេះ សន្តតិជនត្រូវស្នើសុំទៅតុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១២១៨ នៃក្រមរដ្ឋប្បវេណី)។

### ៨.៣.២. ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

**-ករណីការតែងតាំងអ្នកប្រតិបត្តិមតកសាសន៍តាមរយៈមតកសាសន៍**

ជនដែលត្រូវបានតែងតាំង មិនត្រូវបានបង្ខំឲ្យកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍នោះទេ។ ប៉ុន្តែ កាលណាជននោះយល់ព្រមកាន់មុខងារនោះហើយ ជននោះត្រូវអនុវត្តមុខងារនោះភ្លាម (មាត្រា ១២១៥ នៃក្រមរដ្ឋប្បវេណី)។ គ្មានបញ្ញត្តិដែលចែងអំពីវិធីក្នុងការទទួលយកការកាន់មុខងារនោះទេ ប៉ុន្តែ ជាធម្មតាអ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការទទួលយកមុខងារនេះ តាមរយៈការបង្ហាញឆន្ទៈទៅកាន់សន្តតិជន។

ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនបានបង្ហាញឆន្ទៈឲ្យបានច្បាស់លាស់នោះទេ សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចកំណត់រយៈពេលសមរម្យណាមួយ ហើយធ្វើការដាស់តឿនទៅជនដែលត្រូវបានតែងតាំងជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទាមទារឲ្យជននោះផ្ដល់ចម្លើយជាក់លាក់មួយថាតើគាត់យល់ព្រមកាន់មុខងារនោះ ឬមួយយ៉ាងណា? ប្រសិនបើ ជននោះមិនបានផ្ដល់ចម្លើយជាក់លាក់មួយក្នុងរយៈពេលកំណត់សមរម្យនោះទេ គេត្រូវចាត់ទុកថាជននោះបានលាឈប់ពីមុខងារនេះ (មាត្រា ១២១៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើជនដែលត្រូវបានតែងតាំងនោះ មិនព្រមកាន់មុខងារ សន្តតិជនត្រូវពិចារណាថាតើពួកគេ ត្រូវអនុវត្តមតកសាសន៍ដោយខ្លួនឯង ឬ ស្នើរសុំឲ្យតុលាការតែងតាំងអ្នកប្រតិបត្តិមតកសាសន៍។

**-ករណីប្រគល់អណត្តិឲ្យតតិយជនដើម្បីកំណត់អ្នកប្រតិបត្តិមតកសាសន៍**

ជនដែលទទួលអាណត្តិក្នុងមតកសាសន៍ដើម្បីកំណត់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបង្កើតអានុភាពនូវនៃការកំណត់នោះ និង ជូនដំណឹងនោះទៅឲ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ។ បើជនដែលទទួលអាណត្តិមានបំណងលាឈប់ពីអាណត្តិនេះ ជននោះត្រូវជូនដំណឹងទៅសន្តតិជនដោយគ្មានភាពយឺតយ៉ាវ (មាត្រា ១២១៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើ ជនដែលទទួលអាណត្តិដើម្បីកំណត់អ្នកប្រតិបត្តិមតកសាសន៍ មិនបានបង្កើតអានុភាពនៃការកំណត់ភ្លាមៗនោះទេ សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចជូនដំណឹង ក្នុងរយៈពេលកំណត់សមរម្យណាមួយទៅជនដែលត្រូវទទួលអាណត្តិជាអ្នកប្រតិបត្តិមតកសាសន៍ ហើយទាមទារឲ្យមានការកំណត់ជ្រើសតាំងនោះ។ ករណីនេះ បើសិនជាតតិយជនមិន

បានតែងតាំងអ្នកប្រតិបត្តិមតកសាសន៍ ក្នុង រយៈពេលកំណត់សមរម្យណាមួយទេនោះ ជននោះនឹងត្រូវចាត់ទុកថាបានលាឈប់ពីអាណត្តិ (មាត្រា ១២១៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

**-ករណីការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយសេចក្ដីសម្រេចរបស់តុលាការ**

តុលាការអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ ទៅតាមការស្នើសុំរបស់សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ (មាត្រា ១២១៨ នៃក្រមរដ្ឋប្បវេណី មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៦)។

## ៨.៣.៣. ការដាក់កម្រិតលើការទទួលស្គាល់ជនប្រតិបត្តិមតកសាសន៍

ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនក្ស័យធន មិនអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានទេ (មាត្រា ១២១៧ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ជានីតិបុគ្គល ការរំលាយនីតិបុគ្គល ឬ អ្នករួមបញ្ចូលនីតិបុគ្គល នឹងមិនទទួលស្គាល់ថានីតិបុគ្គលនោះជាអ្នកប្រតិបត្តិមតកសាសន៍ឡើយ (មាត្រា ១២២៩ មាត្រា ៦៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត ជាគោលការណ៍ បុគ្គលណាក៏អាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ ដូចជា មិត្តភក្ដិរបស់មតកជន សាច់ញាតិរបស់មតកជន ឬ មេធាវី ជាដើម។ លើសពីនេះទៀត នីតិបុគ្គល សន្តតិជនម្នាក់ក្នុងចំណោមសន្តតិជនទាំងអស់ ឬ អច្ច័យលាភី ក៏អាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ។

## ៨.៣.៤. មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ (មាត្រា ១២២០ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើ ការធ្វើការងារនោះត្រូវចំណាយអស់សោហ៊ុយណាមួយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រើប្រាស់មតិកចំពោះសោយហ៊ុយនោះ(មាត្រា ១២២៨ នៃក្រមរដ្ឋប្បវេណី)។ ការចំណាយរួមមាន ការផ្ដល់កម្រៃឲ្យអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១២២៦ នៃក្រមរដ្ឋប្បវេណី)។

បន្ថែមពីនេះទៀត មាត្រា ១២២៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីកិច្ចសន្យាអាណត្តិ ហេតុដូច្នេះ ៖

-អ្នកប្រតិបត្តិមតកសាសន៍ត្រូវចាត់ចែងកិច្ចការអាណត្តិដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុច្ចរិត (មាត្រា ៦៤០ នៃក្រមរដ្ឋប្បវេណី)។

-អ្នកប្រតិបត្តិមតកសាសន៍ត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ហើយត្រូវរាយការណ៍អំពីហេតុនោះ ទៅកាន់សន្តតិជនដោយគ្មានភាពយឺតយ៉ាវ ក្រោយពេលបញ្ចប់អាណត្តិ (មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណី)។

-ប្រសិនបើ បានទទួលប្រាក់ ឬ វត្ថុផ្សេងៗ ពីការចាត់ចែងកិច្ចការអាណត្តិ អ្នកប្រតិបត្តិមតកសាសន៍បានត្រូវប្រគល់ផលទាំងនោះទៅឲ្យសន្តតិជន (មាត្រា ៦៤២ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនអាចបំពេញនូវកាតព្វកិច្ចខ្លួនបាននោះទេ ត្រូវទទួលខុសត្រូវលើសំណងការខូចខាត (មាត្រា ៦៤៣ នៃក្រមរដ្ឋប្បវេណី)។

### ៨.៣.៤.១ ការចាប់ផ្ដើមបំពេញមុខងារ

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះ ទៅឲ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ (មាត្រា ១២១៩ នៃក្រមរដ្ឋប្បវេណី)។ សន្តតិជនមានសិទ្ធិចូលរួម នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន (មាត្រា ១២១៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ណាមួយនោះ ការរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ គឺមានភាពចាំបាច់ចំពោះតែទ្រព្យសម្បត្តិជាក់លាក់នោះប៉ុណ្ណោះ (មាត្រា ១២២២ នៃក្រមរដ្ឋប្បវេណី)។

### ៨.៣.៤.២ ការអនុវត្តមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និង កាតព្វកិច្ចធ្វើសកម្មភាពអ្វីៗទាំងអស់ដែលចាំបាច់សំរាប់អនុវត្តមតកសាសន៍។

-មតកសាសន៍អាចមានចែងអំពីការផ្ទេរទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ ជាអច្ច័យទាន ឬ អំពីការកំណត់វិធីសាស្ត្របែងចែកទ្រព្យសម្បត្តិ។ អ្នកប្រតិបត្តិមតកសាសន៍អាចផ្ទេរទ្រព្យសម្បត្តិ អាចចាត់នីតិវិធីនៃការផ្ទេរសិទ្ធិចុះបញ្ជីអចលនវត្ថុ ឬ អាចដកលុយពីគណនីធនាគារ ជាដើម ដើម្បីអនុវត្តការផ្ទេរនេះ។

-ប្រសិនបើមតកសាសន៍មានចែងពីការទទួលស្គាល់កូន អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យបណ្ដឹងទៅមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៩៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

-ប្រសិនបើមតកសាសន៍មានចែងពីការផ្ដាច់មតិក ឬ ការលុបចោលការផ្ដាច់មតិក អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការ (មាត្រា ១១៥២ មាត្រា ១១៥៤ កថាខណ្ឌទី ១ មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ២)។

#### ៨.៣.៤.៣. ការកម្រិតនូវសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់សន្តតិជន

ទ្រព្យសម្បត្តិ ត្រូវធ្លាក់ទៅលើសន្តតិជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម (មាត្រា ១១៤៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ប្រសិនបើ សន្តតិជនបានចាត់ចែងទ្រព្យសម្បត្តិ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ នោះអ្នកប្រតិបត្តិមតកសាសន៍នឹងមិនអាចបំពេញមុខងាររបស់ខ្លួនបានឡើយ។ ដូច្នេះ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជន ពុំមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិនោះទេ (មាត្រា ១២២១ នៃក្រមរដ្ឋប្បវេណី)។ ការចាត់ចែងរបស់សន្តតិជន ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនេះ នឹងមិនមានអានុភាពនោះទេ។

#### ៨.៣.៤.៤. ឋានៈ សិទ្ធិជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បន្ត ការផ្តល់កម្រៃ ជាអាទិ៍

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ហើយសកម្មភាពនោះនឹងបង្កើតអានុភាពដោយផ្ទាល់ចំពោះសន្តតិជន (មាត្រា ១២២៣ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ A ជាមតកជន ហើយ B ជាអ្នកប្រតិបត្តិមតកសាសន៍។ B ត្រូវប្រើឈ្មោះថា "B ជាអ្នកប្រតិបត្តិមតកសាសន៍របស់ A" នៅពេលដែល B ទៅដកលុយពីគណនីធនាគាររបស់ A។

ក្រៅពីនេះ មានបញ្ញត្តិដូចតទៅ ៖

- សិទ្ធិជ្រើសតាំងបន្ត (សិទ្ធិអំណាចរបស់អ្នកប្រតិបត្តិមតកសាសន៍ ក្នុងការអោយតតិយជនបំពេញភារកិច្ចនោះ) (មាត្រា ១២២៤ នៃក្រមរដ្ឋប្បវេណី)
- ករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ កាតព្វកិច្ចនឹងត្រូវកំណត់ទៅតាមមតិភាគច្រើន (មាត្រា ១២២៥ នៃក្រមរដ្ឋប្បវេណី)
- កម្រៃ (មាត្រា ១២២៦ នៃក្រមរដ្ឋប្បវេណី មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៨)

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន។ ប្រសិនបើមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការអាចកំណត់ចំនួនទឹកប្រាក់ដែលខ្លួនយល់ឃើញថា សមរម្យក្នុងការផ្តល់ជាកម្រៃ ដោយផ្អែកតាមស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងៗទៀត ទៅតាមការស្នើសុំរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ។

- អ្នកប្រតិបត្តិមតកសាសន៍ មិនអនុញ្ញាតឲ្យលាលែងពីការងារនោះទេ បើសិនគ្មានហេតុផលសមរម្យ និង ការអនុញ្ញាតពីតុលាការ (មាត្រា ១២២៧ កថាខណ្ឌទី ១ មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៨)។
- ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍ធ្វេសប្រហែសក្នុងការងារ ឬ មានហេតុផលសមរម្យណាមួយនោះ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចស្នើរឲ្យតុលាការធ្វើការដកចេញអ្នកប្រតិបត្តិមតកសាសន៍

នោះ (មាត្រា ១២២៧ កថាខណ្ឌទី ២ មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៨)។

- សោហ៊ុយដែលត្រូវប្រើប្រាស់ក្នុងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក (មាត្រា ១២២៨ នៃក្រមរដ្ឋប្បវេណី)។

-ការអនុវត្តបញ្ញត្តិស្តីពីអាណត្តិបើមានការចាំបាច់ (មាត្រា ១២២៩ នៃក្រមរដ្ឋប្បវេណី)

បញ្ញត្តិស្តីពីអាណត្តិនឹងត្រូវអនុវត្តបើមានការចាំបាច់ ពីព្រោះមានភាពស្រដៀងគ្នានៃឋានៈនីត្យានុកូល

# ផ្នែកទី២

# ការបែងចែកមត៌ក

## ៩. ការបែងចែកមតិក

ក្រមរដ្ឋប្បវេណីចែងអំពីវិធានក្នុងការគណនាចំនួននៃចំណែកមតិក ដែលសន្តតិជនគ្រប់រូបមានសិទ្ធិទទួលបាន។ ដូចនេះហើយ ប្រសិនបើមតិកនោះ គឺមានតែសាច់ប្រាក់ការបែងចែកមតិកឲ្យមានភាពស្មើគ្នា គឺមានភាពងាយស្រួល។ ប៉ុន្តែជាទូទៅ មតិករួមមានទ្រព្យសម្បត្តិផ្សេងៗដូចជាចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល។ នៅពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនមិនត្រឹមតែត្រូវកំណត់ចំនួនចំណែកមតិកដែលនឹងត្រូវបែងចែកសម្រាប់សន្តតិជនម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវកំណត់ថា សន្តិជនរូបណានឹងត្រូវទទួលមតិកមួយណាផងដែរ។ ដូច្នេះហើយសន្តតិជនត្រូវកំណត់នូវរបៀបនៃការបែងចែកមតិក។ ចំណុចនេះមានភាពស្រដៀងគ្នាទៅនឹងការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធក្នុងករណីលែងលះផងដែរ។ ការបែងចែកមតិក ជាទូទៅត្រូវធ្វើតាមរយៈការពិភាក្សារវាងសហសន្តតិជន (មាត្រា ១២៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើពួកគេមិនអាចឈានដល់កិច្ចព្រមព្រៀង ឬការពិភាក្សាមិនបានសម្រេច សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនឹងធ្វើការការបែងចែកទ្រព្យសម្បត្តិតាមរយៈដីកាសម្រេច (មាត្រា ១២៧០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងឧបសម្ព័ន្ធផ្នែកទី៥ លេខ១៧)។

### ៩.១. ករណីមានភាពចាំបាច់ក្នុងការបែងចែកមតិក

ចូរគិតអំពីករណីមួយដែលមតកជនបានធ្វើមតកសាសន៍មួយ ហើយមតកសាសន៍នោះបានរៀបរាប់ពីមតិកគ្រប់ប្រភេទ និងរៀបរាប់ពីបុគ្គលដែលត្រូវទទួលបានមតិកនិមួយៗយ៉ាងលម្អិតផងដែរ។ ក្នុងករណីនេះ មតិកទាំងអស់នឹងត្រូវបែងចែកទៅតាមខ្លឹមសារនៃមតកសាសន៍នោះក្រោយការស្លាប់របស់មតកជន (មាត្រា ១១៩៤ និងមាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ គេមិនចាំបាច់ធ្វើការបែងចែកមតិកឡើយ។

ផ្ទុយទៅវិញគេចាំបាច់ត្រូវធ្វើការបែងចែកមតិកក្នុងករណីដូចខាងក្រោមនេះ៖

<u>ក. ករណីគ្មានមតកសាសន៍</u>

ប្រសិនបើគ្មានមតកសាសន៍ទេ សន្តតិជនត្រូវធ្វើការបែងចែកគ្រប់មត៌កទាំងអស់តាមបញ្ញត្តិ ស្ដីពីសន្តតិកម្មតាមច្បាប់ ។

**ខ.** ករណីមានមតកសាសន៍ ប៉ុន្តែមតកសាសន៍នោះមិនបានកំណត់របៀបក្នុងការបែងចែក

ក្នុងករណីខ្លះ មតកសាសន៍បានកំណត់ចំនួននៃចំណែកមត៌ក ប៉ុន្តែមិនបានកំណត់របៀបក្នុងការបែងចែកមត៌កនោះឡើយ។

ជាឧទាហរណ៍៖ មានសន្តតិជន A B និង C ចំណែកឯមត៌ករួមមាន ដី ឡាន និងលុយ ហើយមតកសាសន៍កំនត់ថា A ត្រូវទទួលបាន ៣ភាគ៦ B ត្រូវទទួលបាន ២ភាគ៦ និង C ត្រូវទទួលបាន ១ភាគ៦។ ក្នុងករណីនេះ A B និង C ត្រូវបែងចែកមត៌កតាមរយៈចំណែកមត៌កដែលត្រូវបានកំណត់នៅក្នុងមតកសាសន៍។ ប៉ុន្តែ មតកសាសន៍នោះមិនបានបញ្ជាក់ថា អ្នកណាត្រូវទទួលបានដី អ្នកណាត្រូវទទួលបានឡាន និងអ្នកណាត្រូវទទួលបានលុយនោះទេ។ ដូចនេះហើយពួកគេត្រូវធ្វើបំណែងចែកមត៌កតាមរយៈការពិភាក្សាគ្នា ឬតាមសេចក្ដីសម្រេចរបស់តុលាការ។

**គ.** ករណីមានមតកសាសន៍ ហើយមតកសាសន៍នោះបានកំណត់របៀបក្នុងការបែងចែកមត៌ក ប៉ុន្តែមិនបានរៀបរាប់អំពីទ្រព្យដែលនឹងត្រូវបែងចែកមួយចំនួន

ឧទាហរណ៍៖ មានសន្តតិជន A B និង C។ មត៌ករួមមាន ដី ឡាន និង លុយ។ មតកសាសន៍បានកំណត់ថា A B និង C ត្រូវទទួលបានមត៌កស្មើៗគ្នា ដោយ A ត្រូវទទួលបានដី។ ក្នុងករណីនេះមានភាពមិនច្បាស់លាស់ថា តើអ្នកណាត្រូវទទួលបានឡាន និងលុយ? ដូច្នេះ ពួកគេចាំបាច់ត្រូវធ្វើការបែងចែកមត៌កដើម្បីកំណត់ពីរបៀបក្នុងការបែងចែកឡាន និងលុយតាមរយៈការពិភាក្សា ឬដោយសេចក្ដីសម្រេចរបស់តុលាការ។

### ៩.២. ការគ្រប់គ្រងមត៌កមុននឹងធ្វើការបែងចែក

មត៌ក ត្រូវស្ថិតនៅក្រោមកម្មសិទ្ធអវិភាគរបស់សហសន្តតិជន រហូតដល់ការបែងចែកត្រូវបានប្រព្រឹត្ត (មាត្រា ១១៩៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងកំឡុងពេលនេះ សន្តតិជនដែលកាន់កាប់មត៌កនៅពេលមតកជនទទួលមរណៈភាព ត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះរហូតដល់ពេលធ្វើការបែងចែកមត៌ក (មាត្រា ១២៦២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះទៀត សន្តតិជនត្រូវគ្រប់គ្រងមត៌កនេះប្រកបដោយការប្រុងប្រយ័ត្នឲ្យដូចគ្នានឹងទ្រព្យសម្បត្តិរបស់ខ្លួនផងដែរ (មាត្រា ១២៦២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងអំឡុងពេលនេះ សោហ៊ុយចំណាយដែលទាក់ទងទៅនឹងមត៌កត្រូវជាបន្ទុកនៃមត៌កនោះ ប៉ុន្តែសោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន ត្រូវជាបន្ទុករបស់សន្តតិជននោះ (មាត្រា ១២៦៥ នៃក្រមរដ្ឋប្បវេណី)។

**ផលដែលកើតមកពីការបែងចែកមតិក**

ដោយសារតែការបែងចែកមតិកអាចនឹងត្រូវធ្វើឡើង យ៉ាងហោចណាស់រយៈពេល១ខែ ក្រោយការចាប់ផ្ដើមសន្តតិកម្ម (មាត្រា ១២៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ដូច្នេះមតិកនឹងស្ថិតក្រោមកម្មសិទ្ធអវិភាគក្នុងរយៈពេលលើសពី១ខែ។ ក្នុងអំឡុងពេលនោះ ផលធម្មជាតិ ឬស៊ីវិលអាចនឹងកើតចេញមកពីការបែងចែកមតិកដូចជា ការប្រាក់ដែលបានពីការដាក់ប្រាក់នៅធនាគារ ចំណូលបានពីការជួលផ្ទះ ឬផលស្រូវជាដើម។ ផលទាំងនេះ សុទ្ធតែជាកម្មវត្ថុនៃមតិក (មាត្រា ១២៧២ នៃក្រមរដ្ឋប្បវេណី)។

**៩.៣. របៀបនៃការបែងចែកមតិក**

របៀបនៃការបែងចែកមតិក ត្រូវបានចែកចេញជាបីគឺៈ

**ក.** <u>ការបែងចែកវត្ថុជាក់ស្ដែង</u>

ការបែងចែកវត្ថុជាក់ស្ដែង គឺជាវិធីនៃការបែងចែកវត្ថុដោយផ្ទាល់តែម្ដង។

ឧទាហរណ៍៖ មានសន្តតិជន A B និង C ។ មតិករួមមាន ដី ឡាន និងប្រាក់ចំនួន ១៣.០០០ ដុល្លារ។ ក្នុងករណីនេះ ប្រសិនបើការបែងចែកមតិកដោយឲ្យ A ទទួលបានដី B ទទួលបានឡាន និងប្រាក់ ៣.០០០ដុល្លារ ហើយ C ទទួលបានប្រាក់ ១០.០០០ដុល្លារ នោះការបែងចែកនេះហៅថាការបែងចែកវត្ថុជាក់ស្ដែង។

**ខ.** <u>ការបែងចែកក្រោមល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួល</u>

ការបែងចែកក្រោមល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួល គឺជាវិធីនៃការបែងចែកមតិកដោយអនុញ្ញាតឲ្យសន្តតិជនណាម្នាក់ទទួលយកនូវមតិកទាំងមូល ដោយស្ថិតក្នុងល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួលក្នុងចំនួនសមរម្យទៅឲ្យសន្តតិជនផ្សេងទៀត ឲ្យត្រូវនឹងចំណែកមតិកដែលសន្តតិជននិមួយៗត្រូវទទួលបាន (មាត្រា ១២៦៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ មានសន្តតិជន A B និង C។ ដីគឺជាមតិកតែមួយគត់។ ក្នុងករណីនេះ ប្រសិនបើការបែងចែកមតិកដោយឲ្យ A ទទួលបាននូវដីទាំងមូល នោះ A ត្រូវបង់ប្រាក់ ៥.០០០ដុល្លារទៅ B និង ៥.០០០ដុល្លារទៀតទៅ C។ ករណីនេះ គេហៅថាការបែងចែកក្រោមល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួល។

**គ.** <u>ការបែងចែកប្រាក់ដែលបានមកពីការលក់ (មាត្រា១២៧១ នៃក្រមរដ្ឋប្បវេណី)</u>

ការបែងចែកប្រាក់ដែលបានមកពីការលក់ គឺជារបៀបនៃការបែងចែកមតិកតាមរយៈការលៃទុកប្រាក់ដែលបានមកពីការលក់ដោយការដេញថ្លៃជាសាធារណៈសម្រាប់ផ្តល់ឲ្យសន្តតិជន។

ឧទាហរណ៍៖ មានសន្តតិជន A B និង C។ ដីជាមតិកតែមួយគត់។ ក្នុងករណីនេះកាលណាតុលាការបានចេញដីកសម្រេចដែលមានខ្លឹមសារថា "ត្រូវលក់អចលនទ្រព្យដោយការដេញថ្លៃជាសាធារណៈ ហើយប្រាក់ដែលនៅសល់ពីការលក់ក្រោយពីកាត់សោហ៊ុយចំណាយលើការដេញថ្លៃត្រូវចែកទៅឲ្យ AB និង C ស្មើៗគ្នា"។ នេះហៅថាការបែងចែកប្រាក់ដែលបានមកពីការលក់។

## ៩.៤. វត្ថុសម្រាប់ជំនឿសាសនា ចេតិយ និងចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន

ទ្រព្យទាំងនេះ មិនមែនជាកម្មវត្ថុនៃការបែងចែកមតិកនោះទេ។ សន្តតិកម្មនៃទ្រព្យទាំងនេះត្រូវអនុលោមតាមមាត្រា ១១៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

## ៩.៥. កាតព្វកិច្ច

ក្នុងករណីដែលមតកជនមានកាតព្វកិច្ចណាមួយ សន្តតិជនត្រូវទទួលសន្តតិកម្មនូវកាតព្វកិច្ចនោះ (មាត្រា ១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ កាតព្វកិច្ចត្រូវបានផ្ទេរតាមរយៈការបែងចែកមតិកតាមច្បាប់ ហើយជាគោលការណ៍ការបែងចែកកាតព្វកិច្ចនេះ មិនអាចធ្វើការផ្លាស់ប្តូរតាមរយៈមតកសាសន៍ ការពិភាក្សារវាងសន្តតិជន ឬសេចក្តីសម្រេចរបស់តុលាការបាននោះទេ។ ដូច្នេះប្រសិនបើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមតិក ដោយពិចារណាលើការណ៍ថាខ្លួនត្រូវសងកាតព្វកិច្ចនោះ និងមិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ (មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណី)។ ការបែងចែកកាតព្វកិច្ចអាចផ្លាស់ប្តូរទៅបាន លុះត្រាតែម្ចាស់បំណុលមានការយល់ព្រមតែប៉ុណ្ណោះ។ តុលាការមិនត្រូវបែងចែកកាតព្វកិច្ចនោះទេនៅពេលអនុវត្តការបែងចែកមតិកទេ។

ឧទាហរណ៍៖ មានសន្តតិជន A និង B។ ការបែងចែកមតិកតាមច្បាប់ ពួកគេនឹងទទួលបានចំណែកស្មើគ្នា។ ទ្រព្យដែលនឹងត្រូវធ្វើការបែងចែកមានតែដីប៉ុណ្ណោះ ហើយមតកជនមានកាតព្វកិច្ចចំពោះ X ចំនួន ៥.០០០ដុល្លារ។ A និង B ព្រមព្រៀងគ្នាថា A ត្រូវទទួលដីហើយទទួលបន្ទុកកាតព្វកិច្ចទាំងអស់ចំណែក B រួចខ្លួន។ ក្នុងករណីនេះ X អាចទាមទារឲ្យ A និង B សងកាតព្វកិច្ចទាំងពីរនាក់បាន ដោយមិនគិតពីការព្រមព្រៀងរបស់ពួកគេទេ លើកលែងតែ X បានយល់ព្រមតែប៉ុណ្ណោះ។ ករណីនេះ កាលណា X ទាមទារសំណងពី B នោះ B ត្រូវសងប្រាក់ចំនួន ២.៥០០ដុល្លារទៅ X។ B ក៏អាចទាមទារសំណងពី A បានដែរដោយផ្អែកតាមការព្រមព្រៀងរបស់ពួកគេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ការព្រមព្រៀងនេះគ្មានអានុភាពចំពោះ X ទេ ពីព្រោះ X មិនមែនជាគូភាគីនៃការព្រមព្រៀងនោះឡើយ។

## ៩.៦. ចំនុចគួរពិចារណា

ក្នុងការពិភាក្សាបែងចែកមតិក ឬការបែងចែកដោយតុលាការ គប្បីធ្វើការពិចារណាលើមាត្រា ១២៦៧ ១២៦៨ ១២៦៩ និង ១២៧០ នៃក្រមរដ្ឋប្បវេណី ដោយមិនគិតអំពីថា តើការបែងចែកមតិក ត្រូវបានធ្វើឡើងដោយការពិភាក្សា ឬសេចក្តីសម្រេចរបស់តុលាការនោះទេ។ នៅក្នុងករណីដែល ធ្វើការបែងចែកដោយការពិភាក្សា ទោះបីជាគូភាគីមិនបានធ្វើគោរពតាមបញ្ញត្តិនេះក៏ដោយ ក៏មិន មានបញ្ហាធ្ងន់ធ្ងរណាមួយកើតឡើងដែរ ដោយសារតែគ្រប់ភាគីទាំងអស់បានយល់ព្រមលើការបែង ចែកនេះរួចទៅហើយ។ ម្យ៉ាងវិញទៀត នៅពេលដែលតុលាការចេញសេចក្តីសម្រេចបែងចែកមតិក តុលាការត្រូវពិចារណាឲ្យបានល្អិតល្អន់ចំពោះបញ្ញត្តិមានចែងខាងលើដូចជា ប្រភេទ លក្ខណៈនៃ វត្ថុ ឬសិទ្ធិដែលមានក្នុងមតិក អាយុ មុខរបរ ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ជីវភាព របស់សហសន្តតិជន និមួយៗ ទំនៀមទំលាប់ក្នុងតំបន់ និងមតិលើសពីពាក់កណ្តាល។

## ៩.៧. ទម្រង់នៃការបែងចែកមតិកតាមការព្រមព្រៀង

ពុំមានល័ក្ខខ័ណ្ឌណា ដែលតម្រូវឲ្យមានទម្រង់សម្រាប់ការព្រមព្រៀងទៅលើបែងចែកមតិក នោះទេ។ ជាទូទៅ ការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ ត្រូវធ្វើឡើងដោយមានចុះហត្ថលេខា និង ស្នាមម្រាមដៃរបស់សន្តតិជនទាំងអស់។ ប៉ុន្តែប្រសិនបើផ្អែកតាមច្បាប់ ទោះបីជាការព្រមព្រៀង ធ្វើ ឡើងដោយផ្ទាល់មាត់ក៏ដោយ ក៏មានអានុភាពដែរ។

មួយវិញទៀត ប្រសិនបើច្បាប់ ឬបទដ្ឋានគតិយុត្ត ទាមទារឲ្យមានទម្រង់ជាក់លាក់សម្រាប់ ផ្ទេរសិទ្ធិលើវត្ថុ នោះការបែងចែកមតិកត្រូវអនុលោមតាមទម្រង់ដែលចាំបាច់នោះ (មាត្រា ១២៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ដើម្បីចុះបញ្ជីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុផ្អែកលើការបែងចែកមតិក ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឲ្យមានឯកសារជាលាយល័ក្ខណ៍អក្សរ និងលិខិតយថាភូតដែលចេញ ដោយអាជ្ញាធរមានសមត្ថកិច្ច។ ជាងនេះទៅទៀត ដើម្បីធ្វើឲ្យល្អឥតខ្ចោះនូវការបែងចែកសិទ្ធិលើ បំណុលក្នុងករណីដែលការបែងចែកខុសពីចំណែកមតិកដែលកំណត់ដោយច្បាប់ ការបែងចែក បែបនេះត្រូវជូនដំណឹងទៅកូនបំណុលឲ្យបានដឹង (មាត្រា ១២៧៥ នៃក្រមរដ្ឋប្បវេណី)។

# ផ្នែកទី៣

# ភាគបម្រុង

របបភាគបម្រុង គឺជារបបដែលធានាឲ្យបាននូវចំណែកមតិករបស់សន្តតិជន ដើម្បីការពារផលប្រយោជន៍របស់សន្តតិជននោះ។ របបភាគបម្រុងក៏មានមុខងារ ក្នុងការសម្របសម្រួលរវាងសន្តតិកម្មតាមមតកសាសន៍ និង សន្តតិកម្មតាមច្បាប់ផងដែរ ពីព្រោះថា សន្តតិកម្មដែលបំពានភាគបម្រុងនឹងបាត់បង់អានុភាពដោយសាររបបភាគបម្រុងនេះ។

ការរារាំងមិនឲ្យអ្នកដែលមានសិទ្ធិលើភាគបម្រុងទទួលបាននូវភាគបម្រុង អាចធ្វើទៅបានលុះត្រាតែមានការផ្តាច់មតិក។ ការផ្តាច់មតិកអាចធ្វើឡើងតាមវិធីពីរយ៉ាងគឺតាមរយៈការដាក់ពាក្យសុំផ្តាច់

មតិកទៅតុលាការ ដោយមតកជនកាលនៅរស់ ឬ ការធ្វើមតកសាសន៍ដើម្បីផ្តាច់មតិក (មាត្រា ១១៥១ និង មាត្រា ១១៥២ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើតុលាការចេញដីកាសម្រេចផ្តាច់មតិក នោះជនដែលត្រូវផ្តាច់មតិក មិនត្រូវចាត់ទុកថាជាសន្តតិជនទេ ដូច្នេះជននេះក៏មិនអាចមានសិទ្ធិលើភាគបម្រុងដែរ។ ក្នុងស្ថានភាពនេះ អាចនឹងមានសន្តតិកម្មជំនួស តាមមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី ហើយសន្តតិជនជំនួសនឹងក្លាយជាជនដែលមានសិទ្ធិលើភាគបម្រុង។

## ១. អ្នកមានសិទ្ធិលើភាគបម្រុង និង ចំណែកនៃភាគបម្រុង

យោងតាមមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី អ្នកមានសិទ្ធិលើភាគបម្រុងរួមមាន បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ ហេតុនេះ បងប្អូនបង្កើតរបស់មតកជនពុំមែនជាអ្នកមានសិទ្ធិលើភាគបម្រុងទេ ទោះបីជាបងប្អូនបង្កើតគឺជាសន្តតិជនក៏ដោយ។

ចំណែកនៃភាគបម្រុង គឺមួយភាគពីរនៃទ្រព្យសម្បត្តិរបស់មតកជន ក៏ប៉ុន្តែ ប្រសិនបើមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូនជីតា ចំណែកនៃភាគបម្រុង គឺមួយភាគបីនៃទ្រព្យសម្បត្តិរបស់មតកជន។ នៅក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានភាគបម្រុងតាមសមាមាត្រនៃចំណែកមតិក **(មាត្រា ១២៣០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)**។ ដូច្នេះ ប្រសិនបើមតកជនមានកូនច្រើននាក់ ចំណែកនៃភាគបម្រុងរបស់កូនម្នាក់ៗ ត្រូវស្មើគ្នា។ ក្នុងករណីដែលមតកជនមានសហព័ទ្ធម្នាក់ និងកូន នោះសហព័ទ្ធ និងកូនត្រូវមានចំណែកនៃភាគបម្រុងស្មើៗគ្នា។ ប្រសិនបើមតកជនមានសហព័ទ្ធម្នាក់ និង ឪពុកម្តាយ នោះ

ចំណែកនៃភាគបម្រុងរបស់សហព័ទ្ធគឺ មួយភាគបី ចំណែកឪពុកម្ដាយវិញ គឺមានចំណែកពីរភាគបី ក៏ប៉ុន្តែ ប្រសិនបើមានឪពុក ឬ ម្ដាយតែម្នាក់ នោះចំណែកនៃភាគបម្រុងរបស់សហព័ទ្ធ គឺមួយភាគពីរ ហើយចំណែកភាគបម្រុងរបស់ឪពុក ឬ ម្ដាយ ក៏មួយភាគពីរដែរ។ ចំពោះករណីដែលមតកជនបន្សល់ទុកនូវសហព័ទ្ធម្នាក់ និង ជីដូនជីតា នោះចំណែកនៃភាគបម្រុងរបស់សហព័ទ្ធ គឺមួយភាគពីរ ហើយចំណែកភាគបម្រុងរបស់ជីដូនជីតាក៏មួយភាគពីរដែរ បើទោះបីជាជីដូនជីតាមានចំនួនប៉ុន្មាននាក់ក៏ដោយ។

**ឧទាហរណ៍ ៖** ប្រសិនបើមតកជនមានសន្តតិជនជាប្រពន្ធម្នាក់ និង កូនចំនួនពីរនាក់ នោះភាគបម្រុងរបស់សន្តតិជនទាំងអស់គឺមួយភាគពីរនៃទ្រព្យសម្បត្តិរបស់មតកជន។ សម្រាប់សន្តតិជនម្នាក់ៗ គឺមានចំណែកភាគបម្រុងស្មើគ្នា។ ហេតុនេះសរុបមក ចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ គឺ ១/២ x ១/៣=១/៦ នៃទ្រព្យសម្បត្តិរបស់មតកជន។

## ២. ការគណនារកចំណែកនៃភាគបម្រុង

នៅក្នុងការគណនារកចំណែកនៃភាគបម្រុងរបស់អ្នកមានសិទ្ធិលើភាគបម្រុង មាត្រា ១២៣១ នៃក្រមរដ្ឋប្បវេណីបានចែងពីទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង ដោយត្រូវរួមបញ្ចូលនូវតម្លៃទ្រព្យសម្បត្តិមួយចំនួនទៀត ក្រៅពីទ្រព្យសម្បត្តិដែលមតកជនបន្សល់ទុកនៅពេលចាប់ផ្ដើមសន្តតិកម្ម។ ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនាភាគបម្រុងរួមមាន ៖ ទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្ម បូកជាមួយនឹងតម្លៃនៃផលប្រយោជន៍ពិសេស និងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់នៅមាត្រា ១២៣២ ហើយត្រូវដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ។

ផ្អែកតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី តម្លៃនៃផលប្រយោជន៍ពិសេសដែលត្រូវយកមកបូកបញ្ចូល គឺសំដៅទៅលើតម្លៃនៃប្រទានកម្មដែលសន្តតិជនបានទទួលនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ។ ចំពោះប្រទានកម្មដែលកំណត់នៅមាត្រា ១២៣២ នៃក្រមរដ្ឋប្បវេណី សំដៅទៅលើប្រទានកម្មដែលបានធ្វើចំពោះបុគ្គលក្រៅពីសន្តតិជន ហើយជាប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ ជាប្រទានកម្មដែលបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាលឲ្យខូចខាតធ្ងន់ធ្ងរដល់អ្នកមានសិទ្ធិលើភាគបម្រុង។ ស្របតាមមាត្រា ១២៣២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ក៏ត្រូវចាត់ទុកថាជាប្រទានកម្ម តាមន័យនៃបញ្ញត្តិនេះដែរ។

**ឧទាហរណ៍ ៖** ទ្រព្យសម្បត្តិសកម្មរបស់មតកជនដែលមាននាពេលចាប់ផ្តើមសន្តតិកម្មមានចំនួន **$៨០,០០០** បំណុលមានចំនួន **$៣០,០០០** ដុល្លារ ផលប្រយោជន៍ពិសេសដែលសន្តតិជនបានទទួលមានចំនួន **$៥០,០០០**។ ដូច្នេះ ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងគឺ៖ **$៨០,០០០ + $៥០,០០០ - $៣០,០០០ = $១០០,០០០** ។

តាមឧទាហរណ៍ខាងលើឃើញថា យើងចាំបាច់ត្រូវវាយតម្លៃទ្រព្យសម្បត្តិទាំងឡាយរបស់មតកជន ដើម្បីអាចគណនារកភាគបម្រុងរបស់សន្តតិជន។ ប៉ុន្តែ ក្រមរដ្ឋប្បវេណី មិនបានចែងដោយលម្អិតអំពីវិធីក្នុងការវាយតម្លៃនោះទេ។ ទោះបីជាយ៉ាងណា ក្នុងការវាយតម្លៃអំពីទ្រព្យសម្បត្តិខាងលើ ត្រូវពិចារណាលើចំណុចដូចខាងក្រោម៖

**- តម្លៃនៃទ្រព្យសម្បត្តិរូបវន្ត មានដូចជា ដី ឡាន គ្រឿងអលង្ការ ជាអាទិ៍៖**

ត្រូវគិតអំពីតម្លៃលើទីផ្សារ នៅពេលចាប់ផ្តើមសន្តតិកម្ម។

**- តម្លៃនៃប្រទានកម្មជាទឹកប្រាក់៖**

ប្រសិនបើមតកជនបានធ្វើប្រទានកម្មកាលនៅរស់ជាមូលដ្ឋាន ត្រូវកំណត់ចំនួនដែលផ្តល់ឲ្យជាប្រទានកម្មនោះ ជាតម្លៃនៃប្រទានកម្ម។ ឧទាហរណ៍ ប្រសិនបើមតកជនធ្វើប្រទានកម្មជាទឹកប្រាក់ចំនួន $១,០០០ នោះតម្លៃនៃប្រទានកម្មក៏ស្មើនឹង $១,០០០ ដែរ។ ផ្ទុយទៅវិញ ប្រសិនបើធ្វើប្រទានកម្មក្នុងរយៈពេលយូរ មុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃទឹកប្រាក់នោះអាចនឹងមានភាពខុសគ្នា។ ឧទាហរណ៍ កាលពី១៥ឆ្នាំមុនពេលចាប់ផ្តើមសន្តតិកម្ម មតកជនបានធ្វើប្រទានកម្មជាទឹកប្រាក់ចំនួន $១,០០០។ ក្នុងអំឡុងពេល១៥ឆ្នាំនោះ តម្លៃរបស់ប្រាក់អាចនឹងធ្លាក់ចុះ ដោយសារអតិផរណា ហើយចំនួនប្រាក់ $១,០០០ អាចស្មើនឹង $១,៥០០ នៅពេលចាប់ផ្តើមសន្តតិកម្ម។ ក្នុងករណីនេះ ត្រូវកំណត់ចំនួន $១,៥០០ ជាតម្លៃនៃប្រទានកម្ម។

**- តម្លៃនៃសិទ្ធិលើបំណុលនៃការទាមទារប្រាក់៖**

ជាមូលដ្ឋាន ចំនួនប្រាក់ដែលជាកម្មវត្ថុនៃសិទ្ធិលើបំណុល ត្រូវតែជាតម្លៃមួយដែលស្របទៅតាមបទដ្ឋានត្រឹមត្រូវមួយ។ ឧទាហរណ៍ តម្លៃនៃការទាមទារប្រាក់ចំនួន ១០០០$ ត្រូវមានតម្លៃស្មើនឹង ១០០០$។ ទោះជាយ៉ាងនេះក្តី គួរតែពិចារណាអំពីហានិភ័យនៃភាពមិនអាចសងបំណុលបានផងដែរ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលគ្មានសមត្ថភាពសងបំណុល សិទ្ធិលើបំណុលក៏គ្មានតម្លៃដែរ។ ដូច្នេះ ក្នុងករណីខ្លះ តម្លៃនៃសិទ្ធិលើបំណុល១០០០$ នោះ អាចកំណត់ឲ្យមានតម្លៃតិចជាង ១០០០$ បាន។

**- តម្លៃនៃសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់៖**

ជាធម្មតា តម្លៃនៃសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ មានតម្លៃតិចជាងតម្លៃនៃសិទ្ធិមិនភ្ជាប់នឹងលក្ខណ្ឌ។ ឧទាហរណ៍៖ លោក A មានសិទ្ធិលើបំណុលដែលមានខ្លឹមសារថា "លោក B ត្រូវបង់លុយ ១០០០$ ឲ្យទៅលោក A"។ ជាទូទៅ សិទ្ធិលើបំណុលនេះ ត្រូវកំណត់ឲ្យមានតម្លៃស្មើនឹង ១០០០$។ ម្យ៉ាងវិញទៀត លោក C មានសិទ្ធិលើបំណុលដែលមានខ្លឹមសារថា "លោក D ត្រូវបង់លុយ ១០០០$ ទៅឲ្យលោក C ប្រសិនបើលោក C រៀបការនៅឆ្នាំ ២០១៨"។ ជាធម្មតា ត្រូវកំណត់សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌនេះ ឲ្យមានតម្លៃតិចជាង ១០០០$ ដោយសារតែយើងមិនដឹងថា លោក C នឹងរៀបការនៅឆ្នាំ ២០១៨ ឬក៏អត់នោះទេ។

លើសពីនេះទៀត មានការពិបាកក្នុងការវាយតម្លៃសិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់។ ឧទាហរណ៍៖ លោក A មានសិទ្ធិលើបំណុលដែលមានខ្លឹមសារថា "លោក B ត្រូវបង់លុយ ១០០$ ទៅឲ្យ លោក A រៀងរាល់ចុងខែរហូតដល់លោក B ស្លាប់" ។ ក្នុងករណីបែបនេះ គឺមានការពិបាកក្នុងការកំណត់តម្លៃរបស់សិទ្ធិលើបំណុលនេះ ពីព្រោះយើងមិនអាចដឹងបានថានៅពេលណាដែលលោក B នឹងស្លាប់បាត់បង់ជីវិតនោះទេ។ ដូច្នេះហើយ តម្លៃនៃសិទ្ធិទាំងអស់នេះ ត្រូវកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ (មាត្រា១២៣១ កថាខណ្ឌទី១ នៃក្រម
រដ្ឋប្បវេណី និង មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៩)។

## ៣. ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាវិធានការមួយដើម្បីស្តារផលប្រយោជន៍របស់សន្តតិជនដែលមានសិទ្ធិលើភាគបម្រុង ឲ្យទទួលបាននូវសិទ្ធិរបស់ខ្លួនតាមកំណត់ច្បាប់។ ក្រមរដ្ឋប្បវេណី បានចែងពីការកំណត់ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឲ្យកាត់បន្ថយបាន ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយ និង លំដាប់នៃការកាត់បន្ថយ។

### ក. ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវបានចែងនៅមាត្រា ១២៣៤ នៃក្រមរដ្ឋប្បវេណីដែលមានបញ្ញត្តិដូចតទៅ ៖

*ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបាន ដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួនផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម។*

ដូច្នេះ ត្រូវគណនាដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទឹកប្រាក់នៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលតាមរយៈសន្តតិកម្ម ជាមួយនឹងចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងនោះ បានទទួលបន្ទុកដោយសន្តតិកម្ម។

**របៀបនៃការគណនាមានដូចតទៅ ៖**

(ចំនួននៃភាគបម្រុង) – (ចំនួនសរុបនៃទឹកប្រាក់នៃទ្រព្យសម្បត្តិ ដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម) – (ចំនួននៃផលប្រយោជន៍ពិសេសដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម) + (ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងនោះ បានទទួលបន្ទុកដោយសន្តតិកម្ម)។

**ឧទាហរណ៍ ៖** លោក A មានភាគបម្រុងចំនួន ៣០០០$។ ប៉ុន្តែជាក់ស្តែង លោក A បានទទួលប្រាក់ ១០០០$ ពីសន្តតិកម្ម ហើយមិនទទួលបានផលប្រយោជន៍ពិសេសនោះទេ។ លើសពីនេះទៀត លោក A បានទទួលកាតព្វកិច្ចពីសន្តតិកម្មចំនួន ៥០០$។ ក្នុងករណីនេះ ចំនួនទឹកប្រាក់ដែលលោក A អាចទាមទារឲ្យកាត់បន្ថយ ពីព្រោះតែសិទ្ធិលើភាគបម្រុងរបស់គាត់ត្រូវគេបំពាននោះគឺ ២៥០០$ ពីព្រោះ ៣០០០$ - ១០០០$ - 0$ + ៥០០$ = ២៥០០$។

**ឧទាហរណ៍ ៖** ប្រសិនបើលោក **ក** ស្លាប់ដោយបន្សល់ទ្រព្យសម្បត្តិចំនួន ១១០ តែលោក **ក** បានធ្វើមតកសាសន៍កំណត់យកលោក **ខ** ជាកូនច្បងរបស់គាត់ឲ្យធ្វើជាអច្ច័យលាភីសកល។ ម្យ៉ាងទៀត នៅពេលដែលលោក **ក** នៅរស់ លោកបានធ្វើប្រទានកម្មឲ្យកូនឈ្មោះ **គ** និង ឈ្មោះ **ឃ** ក្នុងម្នាក់ៗចំនួន ២០។ ក្រៅពីនេះ លោក **ក** នៅជំពាក់បំណុលគេចំនួន ៦០។ ហេតុនេះ ដើម្បីគណនារកភាគបម្រុងរបស់សន្តតិជន គឺត្រូវយក ១១០ ដែលជាទ្រព្យសម្បត្តិមាននាពេលចាប់ផ្តើមសន្តតិកម្ម បូកនឹង ២០ (ផលប្រយោជន៍ពិសេស) បូកនឹង ២០ (ផលប្រយោជន៍ពិសេស) ដក ៦០ (កាតព្វកិច្ច) ស្មើនឹង ៩០ ចែកនឹង ២ (ចំនួនភាគបម្រុង ក្នុងករណីអ្នកដែលមានសិទ្ធិលើភាគបម្រុង

ជាបច្ឆាញាតិផ្ទាល់) ស្មើនឹង ៤៥។ ដូច្នេះ ភាគបម្រុងរបស់សន្តតិជនរបស់លោក **ត** មានចំនួន ៤៥ សម្រាប់កូនទាំងបីនាក់។ ដើម្បីគណនារកចំណែកភាគបម្រុងសម្រាប់កូនម្នាក់ៗ ត្រូវយក ៤៥ ចែកនឹង ៣ (ចំនួនសន្តតិជន) ស្មើនឹង ១៥។ តាមសម្មតិកម្មខាងលើ សន្តតិជនម្នាក់ៗត្រូវទទួលបន្ទុកលើបំណុលចំនួន ២០។

ដើម្បីគណនារកចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវគណនាដូចខាងក្រោម ចំពោះសន្តតិជនម្នាក់ៗ ៖

-ចំពោះសន្តតិជនឈ្មោះ **ខ** ត្រូវយក ១៥ (ចំណែកភាគបម្រុង) ដក ១១០ (ទ្រព្យសម្បត្តិដែលទទួលបានដោយសន្តតិកម្ម ពីព្រោះថា **ខ** គឺជាអច្ច័យលាភីសកល) បូក ២០ (បំណុលដែលលោក **ខ** ត្រូវទទួលបន្ទុក)។ ជាលទ្ធផលឃើញថា លោក **ខ** បានទទួលលើសពីចំណែកនៃភាគបម្រុងទៅទៀត ។ ដូច្នេះ លោក **ខ** ពុំមានសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទេ។

-ចំពោះសន្តតិជនឈ្មោះ **គ** ត្រូវយក ១៥ (ចំណែកភាគបម្រុង) ដក ២០ (ផលប្រយោជន៍ពិសេស) បូកនឹង ២០ (បំណុល) ស្មើនឹង ១៥។ ហេតុនេះ លោក **គ** មានសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងចំនួន ១៥។

-ចំពោះសន្តតិជនឈ្មោះ **ឃ** ក៏ដូចទៅនឹងករណីរបស់លោក **គ** ដែរ។ លោក **ឃ** មានសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងចំនួន ១៥។

ហេតុនេះ លោក **គ** និង លោក **ឃ** មានសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មានន័យថា មានសិទ្ធិទាមទារឲ្យគេប្រគល់ឲ្យខ្លួនក្នុងម្នាក់ៗចំនួន ១៥។

### ខ. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយ

មាត្រា ១២៣៣ នៃក្រមរដ្ឋប្បវេណីបានចែងថា *អច្ច័យទាន ការកំណត់ចំណែកមតិកតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង។ ប៉ុន្តែក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមតិក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ។*

ហេតុនេះ ឃើញថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយមាន ៖

-អច្ច័យទាន ៖ ប្រសិនបើជាអច្ច័យទានភ្ជាប់បន្ទុក តម្លៃនៃកម្មវត្ថុនៃការកាត់បន្ថយ គឺត្រូវដក តម្លៃនៃបន្ទុកចេញសិន **(មាត្រា ១២៤១)**។

-ការកំណត់ចំណែកមតិកតាមមតកសាសន៍

-ការទទួលផលប្រយោជន៍ពិសេស

-ប្រទានកម្ម ៖ ប្រសិនបើជាប្រទានកម្មភ្ជាប់បន្ទុក តម្លៃនៃកម្មវត្ថុនៃការកាត់បន្ថយ គឺត្រូវដក តម្លៃនៃបន្ទុកចេញសិន **(មាត្រា ១២៤១)**។ តាមមាត្រា ១២៤២ នៃក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជា ប្រទានកម្មដែលជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ ក្នុងករណីដែលកិច្ចសន្យាបានធ្វើដោយយក តម្លៃថ្នូរមិនត្រឹមត្រូវ ហើយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិ លើភាគបម្រុង។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុងទាមទារឲ្យធ្វើការកាត់បន្ថយ ត្រូវសង តម្លៃថ្នូរនោះវិញ ។ ឧទាហរណ៍ថាបើមតកជនបានលក់ទ្រព្យសម្បត្តិក្នុងតម្លៃទាបជាតម្លៃធម្មតា អាច ចាត់ទុកថាជាកិច្ចសន្យាដែលយកតម្លៃថ្នូរមិនត្រឹមត្រូវ តាមមាត្រា ១២៤២ នៃក្រមរដ្ឋប្បវេណី។

រួមមក ប្រសិនបើមានការបំពានលើភាគបម្រុងតាមរយៈសកម្មភាពទាំងអស់ខាងលើនេះ របបភាគ
បម្រុងនឹងធានាលើភាគបម្រុង ដោយបដិសេធលើអានុភាពនៃសកម្មភាពទាំងនេះ។ ប៉ុន្តែថ្វីត្បិតតែ មានការបំពានភាគបម្រុងក៏ដោយ ក៏សកម្មភាពទាំងនេះនៅតែមានសុពលភាពដដែល។ ដូច្នេះ ប្រសិនបើអ្នកមានសិទ្ធិលើភាគបម្រុងទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង សកម្មភាពទាំង នោះត្រូវបាត់បង់អានុភាព តាមកម្រិតនៃការបំពានលើភាគបម្រុងនោះ។ ម្យ៉ាងវិញទៀត ប្រសិនបើ សិទ្ធិលើបំណុលឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាលនៃការរំលត់ (មាត្រា១២៤៥ នៃក្រមរដ្ឋប្ប-វេណី) ឬ ការបោះបង់ភាគបម្រុង (មាត្រា១២៤៦ នៃក្រមរដ្ឋវេណី) សកម្មភាពទាំងនោះមិនមែនជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទៀតទេ។

ជាក់ស្តែងនៅក្នុងឧទាហរណ៍នៃសន្តតិកម្មរបស់លោក **ឥ** ខាងលើ បង្ហាញឲ្យឃើញថា មានតែអច្ច័យទានដែលមតកជនប្រគល់ទៅឲ្យ **ខ** ប៉ុណ្ណោះដែលអាចជាកម្មវត្ថុនៃការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់លោក **គ** និង លោក **ឃ** បាន។ អច្ច័យទាននោះមានតម្លៃ ១១០ ប៉ុន្តែ ដោយហេតុថា លោក **ខ** ក៏ជាសន្តតិជនមានសិទ្ធិលើភាគបម្រុងដែរ ហេតុនេះ មានតែផ្នែកដែល លើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ដែលជាកម្មវត្ថុនៃការកាត់

បន្ថយ។ ដូច្នេះ ផ្នែកដែលលើសពីចំនួនភាគបម្រុងដែលលោក ខ បានទទួល គឺត្រូវយក ១៥ (ចំនួនភាគបម្រុង) ដក ១១០ (ទ្រព្យសម្បត្តិដែលទទួលបានដោយសន្តតិកម្ម) បូកនឹង ២០ (បំណុល) ស្មើនឹង ៧៥។ ហេតុនេះ កម្មវត្ថុ ដែលអាចយកមកធ្វើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺមានចំនួនត្រឹមតែ ៧៥ ប៉ុណ្ណោះ។

ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវធ្វើឡើងតាមរយៈការប្រកាសឆន្ទៈរបស់អ្នកមានសិទ្ធិលើភាគបម្រុង ទៅកាន់អ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក)។ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងត្រូវមានអានុភាព នៅពេលដែលការប្រកាសឆន្ទៈបែបនេះ ត្រូវបានធ្វើឡើងនៅខាងក្រៅតុលាការ។ អ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុងវិញ។ ប្រសិនបើអ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ស្ម័គ្រចិត្តប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុងវិញនោះ ករណីនេះមិនចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៅតុលាការឡើយ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មិនព្រមអនុវត្តកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុងវិញទេនោះ អ្នកមានសិទ្ធិលើភាគបម្រុងមានសិទ្ធិដាក់ពាក្យបណ្ដឹងទៅតុលាការបាន។ នៅក្នុងពាក្យបណ្ដឹងនេះ ការទាមទារដែលធ្វើដោយអ្នកមានសិទ្ធិលើភាគបម្រុង មានដូចជា ការផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការកាត់បន្ថយ ឬ ការចុះបញ្ជីការផ្ទេរកម្មសិទ្ធលើវត្ថុដែលជាកម្មវត្ថុនៃការកាត់បន្ថយ (ដី) ឬ ការបង់ប្រាក់មួយចំនួន ជាអាទិ៍។

ប្រសិនបើអ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មិនប្រគល់វត្ថុដែលជាកម្មវត្ថុវិញនោះ គាត់អាចបង់ប្រាក់ជាជំនួសបាន។ អ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បី
បង្គ្រប់ភាគបម្រុងអាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃវត្ថុដែលជាកម្មវត្ថុ ទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុង តាមកម្រិតដែលត្រូវទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង **(មាត្រា១២៨៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)**។ សូមចំណាំថា ការអនុវត្តកាតព្វកិច្ចដោយការបង់តាមតម្លៃ ឬ ការប្រគល់វត្ថុដែលជាកម្មវត្ថុ គឺស្ថិតនៅលើជម្រើសរបស់អ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង។ ដូច្នេះហើយ ប្រសិនបើអ្នកមានសិទ្ធិលើភាគបម្រុងទាមទារការបង់តម្លៃជំនួសការប្រគល់វត្ថុដែលជាកម្មវត្ថុនោះ អ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នៅតែអាចជ្រើសរើសប្រគល់វត្ថុដែលជាកម្មវត្ថុទៅវិញបាន។

បញ្ហាមួយទៀតអាចចោទឡើង ក្នុងករណីដែលអ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង បានលក់វត្ថុដែលជាកម្មវត្ថុឲ្យទៅតតិយជន។ ដូច្នេះ តើអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារយកវត្ថុដែលជាកម្មវត្ថុនោះពីតតិយជនវិញបានដែរ ឬទេ? ដើម្បីដោះស្រាយចំណោទនេះ មាត្រា ១២៥៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីចែងថា បើសហសន្តតិជន អច្ច័យលាភី ឬ បដិគាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មទៅឲ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃដែលបានចាត់ចែងនោះ ទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុង។ ក៏ប៉ុន្តែប្រសិនបើអនុប្បទានិកបានដឹងថា នឹងបណ្តាលឲ្យមានការខូចខាតលើអ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារការកាត់បន្ថយចំពោះអនុប្បទានិកបានដែរ។ ដូច្នេះ ក្នុងករណីបែបនេះ អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារយកវត្ថុដែលជាកម្មវត្ថុនៃការកាត់បន្ថយ ពីតតិយជនបានដែរ កាលបើមានភស្តុតាងបញ្ជាក់ថា តតិយជន (អនុប្បទានិក) បានដឹងថា អនុប្បទានដែលបានធ្វើចំពោះរូបខ្លួននឹងបណ្តាលឲ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។

**ឧទាហរណ៍ ៖** លោក **ឥ** បានទទួលប្រទានកម្មពីមតកជននូវផ្ទះមួយខ្នង ហើយផ្ទះនេះក្លាយជាកម្មវត្ថុនៃកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង តែផ្ទះនេះត្រូវបានផ្ទេរពីលោក **ឥ** ទៅឲ្យអ្នកដទៃ ក្នុងតម្លៃ ២០០០។ ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយគឺ ២៥០០។ ហេតុនេះ អ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឲ្យកាត់បន្ថយត្រឹមតែតម្លៃ ២០០០ ដែលជាតម្លៃនៅពេលចាត់ចែងប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើតម្លៃនៃផ្ទះកើនរហូតដល់ ៥០០០ ហើយមានភស្តុតាងបញ្ជាក់ថា អនុប្បទានិកបានដឹងថា ការធ្វើអនុប្បទាន នេះនឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង អ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារ ៥០០ ដែលនៅខ្វះពីអនុប្បទានិកបាន។

ក្រៅពីទ្រព្យសម្បត្តិ ឬប្រាក់សំណង អ្នកមានសិទ្ធិលើភាគបម្រុងមានសិទ្ធិទាមទារនូវផលដែលកើតឡើងពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងនោះ ក្រោយពីថ្ងៃដែលបានទាមទារឲ្យធ្វើកាត់បន្ថយ។

**ឧទាហរណ៍ ៖** ជនដែលត្រូវទទួលការកាត់បន្ថយ ត្រូវសងផ្ទះមកឲ្យអ្នកមានសិទ្ធិលើភាគបម្រុង តែផ្ទះនេះបានជួលឲ្យគេក្នុងតម្លៃមួយខែ ៥០០ ដុល្លារ។ នៅថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៥ អ្នកមានសិទ្ធិលើភាគបម្រុងបានទាមទារឲ្យធ្វើការកាត់បន្ថយ មានន័យថា ទាមទារឲ្យប្រគល់ផ្ទះដែលមានតម្លៃ ២០,០០០ ដុល្លារ មកឲ្យខ្លួនវិញ ដើម្បីបង្គ្រប់ភាគបម្រុង។ ដូច្នេះ ជនដែលត្រូវទទួលការកាត់បន្ថយ ត្រូវប្រគល់ផ្ទះ និងប្រាក់ថ្លៃឈ្នួលផ្ទះដែលបានទទួល ចាប់ពីថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៥ មកឲ្យអ្នកមានសិទ្ធិលើភាគបម្រុង។

ប្រសិនបើជនដែលត្រូវទទួលការកាត់បន្ថយអសាធនីយ៍ មានន័យថា ពុំមានទ្រព្យសម្បត្តិដើម្បីសងទៅអ្នកមានសិទ្ធិលើភាគបម្រុង គឺអ្នកមានសិទ្ធិលើភាគបម្រុងជាអ្នកទទួលរងនូវការខាតបង់នេះ ដោយពុំអាចទាមទារពីនរណាផ្សេងទៀតបានឡើយ **(មាត្រា ១២៤០ នៃក្រមរដ្ឋប្បវេណី)**។

## គ. លំដាប់នៃការកាត់បន្ថយ

លំដាប់នៃការកាត់បន្ថយត្រូវបានចែងនៅមាត្រា ១២៣៦ រហូតដល់មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណី។ មាត្រា ១២៣៦ នៃក្រមរដ្ឋប្បវេណី ចែងថា ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមតិកដែលបានកំណត់តាមមតកសាសន៍ជាមុនទេ។ ចំណែកមាត្រា ១២៣៧ នៃក្រមរដ្ឋប្បវេណីកំណត់ថា *ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមតិកដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន។ អច្ច័យទានត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ។ បញ្ញត្តិនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមតិកដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិ ដែលមានកំណត់តែមួយចំណុច ឬ ច្រើនចំណុច។ ប៉ុន្តែអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ក្នុងករណីដែលចំណែកមតិកដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ។ ចំណែកមតិកតាមមតកសាសន៍ដែលបានកំណត់ជាភាគនៃមតិក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោយធ្វើការផ្លាស់ប្តូរភាគនោះ។ ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ។*

មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណីចែងថា *ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់។ បើបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេសលើសពី ២០ ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។*

រួមសេចក្តីមក លំដាប់នៃការកាត់បន្ថយមានដូចតទៅ ៖

**ទី ១៖** អច្ច័យទានសម្រាប់សន្តតិជន និង ការកំណត់ចំណែកមតិក **(មាត្រា១២៣៦ មាត្រា ១២៣៧កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)**។ ប្រសិនបើមាន ២ ឬ ច្រើន ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ទៅតាមសមាមាត្រនៃតម្លៃរបស់វត្ថុដែលជាកម្មវត្ថុនោះ។ "តម្លៃនៃវត្ថុដែលជាកម្មវត្ថុ" មានន័យថា យកតម្លៃរបស់វត្ថុដែលជាកម្មវត្ថុ ដកនឹងចំនួនភាគបម្រុងដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ (មាត្រា១២៣៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ចំនួននៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមានចំនួន ១០,០០០$ ។ មានអច្ច័យទាន ២ ដែលត្រូវយកមកកាត់បន្ថយ គឺ ឡាន និង ដី។ តម្លៃរបស់ឡានគឺ ១០,០០០$ រីឯ តម្លៃដីគឺ ៤០,០០០$។ ក្នុងករណីនេះ ត្រូវកាត់បន្ថយ ២០០០$ ពីតម្លៃឡាន និង ៨០០០$ ទៀតពីតម្លៃដីដើម្បីបង្គ្រប់ភាគបម្រុង។

**ទី ២៖** អច្ច័យទានដែលបានប្រគល់ឲ្យបុគ្គលផ្សេងក្រៅពីសន្តតិជន **(មាត្រា១២៣៦ មាត្រា ១២៣៧កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)**។ ប្រសិនបើមានអច្ច័យទាន ២ ឬ ច្រើន ត្រូវកាត់បន្ថយទៅតាម
សមាមាត្រនៃតម្លៃរបស់វត្ថុដែលជាកម្មវត្ថុ **(មាត្រា១២៣៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)**។

**ទី ៣៖** ប្រទានកម្ម និង ផលប្រយោជន៍ពិសេស **(មាត្រា១២៣៦ នៃក្រមរដ្ឋប្បវេណី)**។ ប្រសិនបើមានប្រទានកម្ម ឬ ផលប្រយោជន៍ពិសេស ២ ឬ ច្រើន ត្រូវកាត់បន្ថយប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ ជាមុន **(មាត្រា១២៣៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)** ។ ប្រសិនបើប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសបានធ្វើលើសពី ២០ ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយ ដើម្បី បង្គ្រប់ភាគបម្រុងបាន។ ប្រសិនបើប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសបានធ្វើក្នុងពេលតែមួយ ហើយមានច្រើន ត្រូវកាត់បន្ថយតាមសមាមាត្រ។

**ករណីសិក្សា**

**ករណីសិក្សាទី ១ ៖**

○ សន្តតិជនគឺ លោក A លោក B និងលោក C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់)។

○ មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។

○ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយកន្លែងដែលមានតម្លៃ ១៥០,០០០$ ទៅឲ្យ លោក A (នេះត្រូវជាផលប្រយោជន៍ពិសេស) ។

○ មតកជនពុំបានបន្សល់ទុកនូវមតិកនោះទេ ទាំងទ្រព្យសកម្ម និង ទ្រព្យអកម្ម។

○ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០ លោក B បានជូនដំណឹងទៅ លោក A ពីឆន្ទៈរបស់ខ្លួនក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ប៉ុន្តែ លោក A មិនសហការជាមួយលោក B ក្នុងការចុះបញ្ជីផ្ទេរដីនោះទេ។ ដូច្នេះ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ លោក B បានដាក់ពាក្យបណ្ដឹងទាមទារឲ្យចុះបញ្ជីផ្ទេរដីជាសហកម្មសិទ្ធិ ចំពោះលោក A។

○ លោក C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដីចំពោះលោក A តាំងពីពេលនៅរស់ដែរ តែលោក C មិនបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះទេ។

ផ្អែកតាមសម្មតិកម្មខាងលើ **ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងតាមមាត្រា ១២៣១ នៃក្រមរដ្ឋប្បវេណី** មានដូចតទៅ ៖

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មតាមមាត្រា១២៣២ នៃក្រមរដ្ឋប្បវេណី – បំណុល

**= 0 + 150,000 + 0 – 0**

**= 150,000**

**ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់លោក B :**

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង (មាត្រា១២៣០ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី) × សមាមាត្រនៃចំណែកមតិក

**= 150,000 × 1/2 × 1/3**

**= 25,000**

**ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង (មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណី)៖**

ចំនួនទឹកប្រាក់នៃភាគបម្រុង – ចំនួនទឹកប្រាក់សរុប ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម – ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

= 25,000 - 0 - 0 + 0

តាមការគណនាខាងលើនេះបង្ហាញឲ្យឃើញថា ទឹកប្រាក់ចំនួន ២៥,០០០$ ដែលលោក A បានទទួលតាមរយៈប្រទានកម្មដីពីមតកជននោះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់នៃភាគបម្រុង។

→25,000 / 150,000 = 1/6 គឺជាចំណែកដែលត្រូវធ្លាក់ទៅលើ B

ហេតុដូច្នេះ សេចក្តីសម្រេចបញ្ចប់នៃសាលក្រមមានខ្លឹមសារដូចតទៅ ៖

"ចុងចម្លើយ A ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរសហកម្មសិទ្ធិនៃចំណែក1/6 នៃដី ដែលបានរៀបរាប់នៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឲ្យដើមចោទ B ដោយមូលហេតុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០"។

ក្នុងករណីខាងលើ ប្រសិនបើលោក A បង់តម្លៃដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ទៅឲ្យលោក B នោះ លោក A នឹងរួចខ្លួនពីកាតព្វកិច្ចនៃការសង **(មាត្រា១២៥៤ នៃក្រមរដ្ឋប្បវេណី)**។ ដូច្នេះហើយ ការសន្និដ្ឋានតម្លៃដី គឺនៅតែមានតម្លៃ ១៥០,០០០$។ ប្រសិនបើលោក A ពិតជាបានបង់លុយចំនួន ២៥,០០០$ ទៅឲ្យលោក B មុនថ្ងៃចុងក្រោយនៃការទាញហេតុផលដោយផ្ទាល់មាត់មែននោះ តុលាការនឹងលើកចោលការទាមទាររបស់លោក B ។

**ករណីសិក្សាទី ២ ៖**

○ សន្តតិជនគឺលោក A លោក B និងលោក C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់)។

○ មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។

○ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយកន្លែងដែលមានតម្លៃ ១៥០,០០០$ ទៅឲ្យលោក A (នេះត្រូវជាផលប្រយោជន៍ពិសេស)។

○ ទ្រព្យសម្បត្តិសន្តតិកម្មរបស់មតកជនគឺមាន ៦០,០០០$ ជាសាច់ប្រាក់។ លោក A លោក B និងលោក C បានព្រមព្រៀងក្នុងការបែងចែកប្រាក់នោះថា ៣០,០០០$ ត្រូវឲ្យទៅលោក B ហើយ ៣០,០០០$ ទៀតឲ្យទៅលោក C។

○ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១០ លោក B បានជូនដំណឹងទៅលោក A ពីឆន្ទៈរបស់ខ្លួនក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់លោក B។ ប៉ុន្តែ លោក A មិនសហការជាមួយលោក B ក្នុងការផ្ទេរការចុះបញ្ជីដីនោះទេ។ ដូច្នេះ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ លោក B បានដាក់ពាក្យបណ្ដឹងទាមទារឲ្យធ្វើការចុះបញ្ជីផ្ទេរចំណែកសហកម្មសិទ្ធិលើដីនោះ ចំពោះលោក A។

○ លោក C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដីចំពោះ លោក A តាំងពីមុនមតកជនទទួលមរណភាព តែលោក C មិនបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះទេ។

**ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា (មាត្រា១២៣ នៃក្រមរដ្ឋប្បវេណី)៖**

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មពេលនៅរស់ (មាត្រា១២៣២ នៃក្រមរដ្ឋប្បវេណី) − បំណុល

**= 60,000 + 150,000 + 0 − 0**

**= 210,000**

**ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់លោក B៖**

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង (មាត្រា១២៣០ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី) × សមាមាត្រនៃចំណែកមតិក (មាត្រា១២៣០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)

**= 210,000 × 1/2 × 1/3**

**= 35,000**

**ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង (មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណី)៖**

ចំនួនទឹកប្រាក់នៃភាគបម្រុង − ចំនួនទឹកប្រាក់សរុប ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម − ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

**= 35,000 - 30,000 - 0 + 0**

= 5,000

តាមការគណនាខាងលើនេះ ទឹកប្រាក់ចំនួន ៥០០០$ ដែលលោក A បានទទួលតាមរយៈប្រទានកម្មដីពីមតកជននោះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ដោយសារតម្លៃនៃដី មានចំនួន ១៥០,០០០$៖

→ **5,000 / 150,000 = 1/30** គឺជាចំណែកដែលត្រូវធ្លាក់ទៅលើលោក B

ហេតុដូច្នេះ សេចក្តីសម្រេចបញ្ចប់នៃសាលក្រមមានខ្លឹមសារដូចតទៅ ៖

"ចុងចម្លើយ A ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរសហកម្មសិទ្ធិនៃចំណែក១/៣០នៃដី ដែលបានរៀបរាប់នៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឲ្យដើមចោទ B ដោយមូលហេតុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០"។

**ករណីសិក្សាទី ៣ ៖**

○ សន្តតិជនគឺលោក A លោក B និងលោក C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់)។

○ មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។

○ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ មតកជនបានធ្វើប្រទានកម្មដីមួយកន្លែងដែលមានតម្លៃ ៣០០០$ ទៅឲ្យលោក A (នេះត្រូវជាផលប្រយោជន៍ពិសេស)។

○ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយកន្លែងដែលមានតម្លៃ ១៥០,០០០$ ទៅឲ្យលោក A (នេះត្រូវជាផលប្រយោជន៍ពិសេស)។

○ ទ្រព្យសម្បត្តិដែលមាននាពេលចាប់ផ្តើមសន្តតិកម្មរបស់មតកជនគឺមាន ៦០,០០០$ ជាសាច់ប្រាក់។ លោក A លោក B និងលោក C បានព្រមព្រៀងក្នុងការបែងចែកប្រាក់ដូចតទៅ ៣០,០០០$ ត្រូវឲ្យទៅលោក B ហើយ ៣០,០០០$ ទៀតឲ្យទៅលោក C។

○ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០ លោក B បានជូនដំណឹងទៅលោក A ពីឆន្ទៈខ្លួនក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់លោក B។ ប៉ុន្តែលោក A មិនសហការជាមួយលោក B ក្នុងការចុះបញ្ជីផ្ទេរចំណែកនៃដីនោះទេ។ ដូច្នេះ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១០ លោក B បានដាក់ពាក្យបណ្តឹងទាមទារឲ្យ ចុះបញ្ជីផ្ទេរចំណែកនៃសហកម្មសិទ្ធិលើដីនោះ ចំពោះលោក A។

○ លោក C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដីចំពោះលោក A តាំងពីមុនមតកជនស្លាប់ដែរ តែលោក C មិនបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះទេ។

**ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា (មាត្រា១២៣១ នៃក្រមរដ្ឋប្បវេណី)៖**

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មពេលនៅរស់ (មាត្រា១២៣២ នៃក្រមរដ្ឋប្បវេណី) – បំណុល

**= 60,000 + (3,000 + 150,000) + 0 – 0**

**= 240,000**

**ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់លោក B៖**

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង (មាត្រា១២៣០ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី) × សមាមាត្រនៃចំណែកមតិក (មាត្រា១២៣០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)

**= 240,000 × 1/2 × 1/3**

**= 40,000**

**ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង (មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណី)៖**

ចំនួនទឹកប្រាក់នៃភាគបម្រុង – ចំនួនទឹកប្រាក់សរុប ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម – ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

**= 40,000 - 30,000 - 0 + 0**

**= 10,000**

តាមការគណនាខាងលើ ទឹកប្រាក់ចំនួន ១៥០,០០០$ ដែលលោក A បានទទួលតាមរយៈប្រទានកម្មដីពីមតកជននោះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់នៃភាគបម្រុង (យោងតាម

មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណី ការកាត់បន្ថយដើម្បីបង្គ្រប់ត្រូវចាប់ផ្តើមពីប្រទានកម្មដែលបានធ្វើក្រោយគេ ហេតុនេះហើយ អានុភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់នេះ មិនមានឥទ្ធិពលដល់ប្រទានកម្មដីជាសាច់ប្រាក់ ៣០០០$ទេ)។

→**10,000 / 150,000 = 1/15** គឺជាចំណែកដែលត្រូវធ្លាក់ទៅលើលោក B

ដូច្នេះ សេចក្តីសម្រេចបញ្ចប់នៃសាលក្រមមានខ្លឹមសារដូចតទៅ ៖

"ចុងចម្លើយ A ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរសហកម្មសិទ្ធិនៃចំណែក 1/15 នៃដី ដែលបានរៀបរាប់នៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឲ្យដើមចោទ B ដោយមូលហេតុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០"។

## ៤. ការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

តាមមាត្រា ១២៤៥ នៃក្រមរដ្ឋប្បវេណី សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឲ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។

អ្នកមានសិទ្ធិលើភាគបម្រុង ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនៅក្នុងអំឡុងពេលណាមួយដូចខាងលើ។ សូមចំណាំថា សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ អាចអនុវត្តខាងក្រៅតុលាការបាន។ ដូច្នេះហើយ អ្វីដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវធ្វើក្នុងអំឡុងពេលខាងលើគឺ ត្រូវជូនដំណឹងទៅអ្នកមានកាតព្វកិច្ចនៃការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អំពីឆន្ទៈរបស់ខ្លួនក្នុងការអនុវត្តសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោយវិធីណាមួយ ហើយមិនចាំបាច់ដាក់ពាក្យបណ្តឹងនៅក្នុងអំឡុងពេលនោះឡើយ។

ម្យ៉ាងវិញទៀត ប្រសិនបើមានការបោះបង់ភាគបម្រុង សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏មិនមានអត្ថិភាពដែរ។ មាត្រា ១២៤៦ នៃក្រមរដ្ឋប្បវេណីចែងថា *ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ។*

# ផ្នែកទី៤

# ការយល់ព្រមទាំងស្រុង ការបោះបង់ និង ការយល់ព្រមដោយមានកម្រិត

## ១. លក្ខណៈទូទៅ

នៅពេលមតកជនទទួលមរណភាព សន្តតិជនជាអ្នកស្នងនូវសិទ្ធិ និង បំណុលទាំងអស់ដែលជាកម្មសិទ្ធរបស់មតកជន (មាត្រា១១៩៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ប្រសិនបើមានបំណុលច្រើនលើសលុបនោះ ប្រហែលជាអយុត្តិធម៌ណាស់ក្នុងការបង្ខំឲ្យសន្តតិជនទទួលបន្ទុកបំណុលទាំងនោះ។ ជាធម្មតា សន្តតិជនចង់ទទួលសន្តតិកម្ម ប្រសិនបើសិទ្ធិមានច្រើនជាងបំណុល ហើយសន្តតិជនចង់ទទួលសន្តតិកម្មដោយមានកម្រិត ករណីដែលមិនច្បាស់ថាបំណុលមានចំនួនប៉ុន្មាន និង ចង់បោះបង់សន្តតិកម្ម ប្រសិនបើបំណុលមានច្រើនជាងសិទ្ធិ ។ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីបានផ្តល់នូវ ជម្រើស **៣**យ៉ាងដល់សន្តតិជនៈ

**- ការយល់ព្រមទាំងស្រុង**

**-ការបោះបង់**

**-ការយល់ព្រមដោយមានកម្រិត**

## ២. ការយល់ព្រមទាំងស្រុង

ប្រសិនបើសន្តតិជនមិនបង្កើតអានុភាពនៃការបោះបង់ ឬ ការយល់ព្រមដោយមានកម្រិតទេនោះ ត្រូវចាត់ទុកថាសន្តតិជននោះបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង ក្រោយពេលមតកជនបានទទួលមរណភាព ចាប់តាំងពីពេលដែលបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម (មាត្រា១២៥៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះទៀត នៅក្នុងអំឡុងពេល ៣ខែ ប្រសិនបើ សន្តតិជនបានចាត់ចែងភាគណាមួយនៃមតិកនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង (មាត្រា១២៥៥ ចំណុច ក នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ទោះបីជានៅក្រោយពេលសន្តតិជនបង្កើតអានុភាពនៃការបោះបង់សន្តតិកម្មក៏ដោយ ប្រសិនបើសន្តតិជនលាក់ ឬ ប្រើប្រាស់មតិកមួយភាគនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង (មាត្រា១២៥៥ ចំណុច គ នៃក្រមរដ្ឋប្បវេណី)។ មាត្រា១២៥៥ ចំណុច ក ចំណុច ខ និង ចំណុច គនៃក្រមរដ្ឋប្បវេណី ហៅថា "**ការយល់ព្រមទាំងស្រុងតាមច្បាប់**" ។ ប្រសិនបើសន្តតិជនបានយល់ព្រមទាំងស្រុង សន្តតិជននោះត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជន (មាត្រា១២៥៤នៃក្រមរដ្ឋប្បវេណី)។ដូច្នេះប្រសិនបើសន្តតិជនបាន

បង្កើតអានុភាពលើការយល់ព្រមទាំងស្រុងមិនថាបំណុលមានចំនួនប៉ុន្មាននោះទេក៏សន្តតិជនត្រូវទទួលកាតព្វកិច្ចសងបំណុលទាំងអស់នោះដែរ។

***ប្រសិនបើ សន្តតិជនសងបំណុលដោយការប្រើប្រាស់មតិក**

ប្រសិនបើសន្តតិជនមានបំណាងចង់បោះបង់សន្តតិកម្ម គាត់មិនត្រូវសងបំណុលដោយប្រើប្រាស់មតិកនោះទេ។ ប្រសិនបើគាត់ធ្វើបែបនេះ ត្រូវចាត់ទុកថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្ម (មាត្រា១២៥៥ ចំណុច ក)។

ទោះជាយ៉ាងនេះក្តី អាចនឹងមានករណីដូចខាងក្រោមនេះ៖

សន្តតិជនម្នាក់គិតថានឹងយល់ព្រមទាំងស្រុងលើសន្តតិកម្ម ដូច្នេះហើយ គាត់បានសងបំណុលដោយប្រើប្រាស់មតិក។ ប៉ុន្តែក្រោយមក គាត់បានដឹងច្បាស់ថាចំនួនបំណុលមានច្រើនលើសពីការស្មាន ហើយគាត់បានប្តូរចិត្តចង់បោះបង់សន្តតិកម្មនោះវិញ។ នៅក្នុងករណីនេះ ទោះបីជាសន្តតិជនបានប្រើប្រាស់មតិកដើម្បីសងបំណុលក៏ដោយ គាត់មិនត្រូវបានចាត់ទុកថាបានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះទេ។ មូលហេតុ គឺដោយសារតែ មាត្រា១២៥៥ ចំណុច ក មិនយកមកអនុវត្តក្នុង មាត្រា១២៥១ កថាខណ្ឌទី២ ឡើយ។

## ៣.ការបោះបង់សន្តតិកម្ម

### ៣.១. គោលបំណង

នៅពេលចាប់ផ្តើមសន្តតិកម្មសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិនិងករណីយកិច្ចទាំងអស់របស់មតកជន (មាត្រា១១៨៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ទោះជាយ៉ាងនេះក៏ដោយ វាមិនត្រឹមត្រូវនោះទេនៅក្នុងការបង្ខំឲ្យសន្តតិជនទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ច ប្រសិនបើសន្តតិជននោះមិនចង់បានអ្វីសោះពីមតកជន។ ជាពិសេស ប្រសិនបើ មតកជនមានកាតព្វកិច្ចច្រើន ការបង្ខំឲ្យសន្តតិជនទទួលបន្ទុកបំណុលនោះជារឿងដែលមិនសមរម្យឡើយ។ ដូចនេះ ក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យសន្តតិជន អាចធ្វើការបោះបង់សន្តតិកម្មបាន។ ប្រសិនបើសន្តតិជនបោះបង់សន្តតិកម្ម គាត់នឹងមិនទទួលបានអ្វីទាំងអស់។

ជាធម្មតា សន្តតិជនបោះបង់សន្តតិកម្មក្នុងករណីនៅពេលដែលមានបំណុលច្រើនជាងសិទ្ធិ។ ប៉ុន្តែ ទោះបីជាគ្មានបំណុលក៏ដោយ ក៏សន្តតិជននៅតែអាចបោះបង់សន្តតិកម្មបានដែរ។ ឧទាហរណ៍ សន្តតិជនម្នាក់ដែលចង់ឲ្យសន្តតិជនម្នាក់ទៀតទទួលបានមតិកទាំងអស់ អាចធ្វើការបោះបង់សន្តតិកម្មបាន ដើម្បីគោរពដល់សិទ្ធិរបស់សន្តតិជនម្នាក់ទៀតនោះ ដូចជា បងប្រុសច្បង។

### ៣.២. របៀបនៃការបោះបង់សន្តតិកម្ម

#### ៣.២.១. ការដាក់ពាក្យសុំ

សន្តតិជនត្រូវដាក់ពាក្យសុំបោះបង់សន្តតិកម្មទៅកាន់តុលាការ ដើម្បីបង្កើតអានុភាពនៃការបោះបង់សន្តតិកម្ម (មាត្រា១២៦០ នៃក្រមរដ្ឋប្បវេណី)។ តុលាការដែលមានសមត្ថកិច្ចគឺជាតុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម (មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនិងឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៨)។

ការដាក់ពាក្យសុំបោះបង់សន្តតិកម្ម ត្រូវធ្វើឡើងដោយសន្តតិជនម្នាក់ៗ។ ដូចនេះ អ្នកដាក់ពាក្យមិនចាំបាច់ដាក់ពាក្យសុំជាមួយសន្តតិជនដទៃ ឬ មិនចាំបាច់មានការយល់ព្រមពីសន្តតិជនដទៃនោះឡើយ។ លើសពីនេះទៀត ថ្វីត្បិតតែសន្តតិជនម្នាក់បានធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្មក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែអាចធ្វើការបោះបង់សន្តតិកម្មបានដែរ។

#### ៣.២.២. ករណីដែលសន្តតិជនជាអនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើ សន្តតិជនជាអនីតិជនឬជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបាននោះទេ លើកលែងតែជាអនីតិជនដែលបានទទួលអត្តាធីនភាពតែប៉ុណ្ណោះ។ ថ្វីត្បិតតែសន្តតិជននោះ បានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អាណាព្យាបាលរបស់អនីតិជន ឬ អាណាព្យាបាលទូទៅ) ក៏ដោយ ក៏សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបានដែរ។ ដើម្បីឲ្យសន្តតិជននោះអាចបោះបង់សន្តតិកម្មបាន អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវដាក់ពាក្យសុំ (មាត្រា១៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ប្រសិនបើ បានតែងតាំងអ្នកត្រួតពិនិត្យសម្រាប់អាណាព្យាបាលទូទៅ ឬ អាណាព្យាបាលរបស់អនីតិជន នោះអាណាព្យាបាលទូទៅ ឬ អាណាព្យាបាលរបស់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យនោះជាមុនសិន (មាត្រា១០៩០ និង មាត្រា១១២៦ នៃក្រមរដ្ឋប្បវេណី)។

*ជម្លោះផលប្រយោជន៍

ក្នុងករណីខ្លះ អ្នកតំណាងដែលច្បាប់បានកំណត់ ក៏អាចជាសន្តតិជនផងដែរ។ ឧទាហរណ៍ដូចជា៖X ជាប្តី Y ជាប្រពន្ធ និង Z ជាកូនដែលជាអនីតិជន។ នៅពេលដែល Xទទួលមរណភាពនោះ Y និង Z នឹងក្លាយជាសន្តតិជន ហើយ Yគឺជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ Z។ ក្នុងឧទាហរណ៍ផ្សេងទៀត៖X គឺជាឪពុក មានកូន Y និង Zដែលជាមនុស្សពេញវ័យ។ពីព្រោះតែZ ខ្វះសមត្ថភាពក្នុងការយល់ពីអត្ថន័យនៃអំពើរបស់ខ្លួនដែលច្បាប់បានកំណត់ នោះY ត្រូវតែងតាំងឲ្យធ្វើជាអាណាព្យាបាលទូទៅរបស់ Z។ ក្នុងករណីនេះ នៅពេលដែល Xទទួលមរណភាពទាំង Y និង

Z នឹងក្លាយជាសន្តតិជន ហើយ Y គឺជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ Z។

ក្នុងករណីខាងលើ ប្រសិនបើ Y យល់ព្រមទាំងស្រុងលើសន្តតិកម្មរបស់ខ្លួន ស្របពេលដែលបោះបង់សន្តតិកម្មរបស់ Z ក្នុងនាមជា Z នោះភាគនៃសន្តតិកម្មរបស់Y នឹងកើនឡើង មានន័យថា ផលប្រយោជន៍របស់ Y និង Z កំពុងតែមានជម្លោះ។ ដូច្នេះហើយ ក្នុងករណីដូចនេះ អ្នកតំណាងពិសេសនឹងត្រូវតែងតាំងដើម្បីដាក់ពាក្យសុំបោះបង់សន្តតិកម្មរបស់ Z (មាត្រា១០៦៥ និង ១០២២ នៃក្រមរដ្ឋប្បវេណី)។

### ៣.២.៣. ករណីដែលសន្តតិជនជាជនដែលស្ថិតក្រោមហិតូបត្ថម្ភ

សន្តតិជនអាចដាក់ពាក្យសុំដោយខ្លួនឯងបាន ប៉ុន្តែត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ (មាត្រា៣០ ចំណុច គ និង ង នៃក្រមរដ្ឋប្បវេណី និង មាត្រា១៧ កថាខណ្ឌទី ៥ និង ៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ មួយវិញទៀត ហិតូបត្ថម្ភកៈមិនអាចដាក់ពាក្យសុំក្នុងនាមជាជននៅក្រោមហិតូបត្ថម្ភនោះទេ ដោយសារតែហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។

## ៣.៣. ការដាក់កម្រិតរយៈពេលដាក់ពាក្យសុំ

### ៣.៣.១. វិធានទូទៅ

ប្រសិនបើសន្តតិជនចង់បោះបង់សន្តតិកម្ម គាត់ត្រូវដាក់ពាក្យសុំបោះបង់ទៅកាន់តុលាការក្នុងអំឡុងពេល ៣ខែ ក្រោយពីបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម។ អំឡុងពេល ៣ខែនេះ ហៅថា **"អំឡុងពេលគិតពិចារណា"** ។ ពីព្រោះតែសន្តតិជនម្នាក់ៗបានដឹងអំពីការចាប់ផ្តើមសន្តតិកម្មនៅពេលខុសៗគ្នា ដូចនេះអំឡុងពេលសម្រាប់គិតពិចារណា ក៏ត្រូវគណនាសម្រាប់សន្តតិជនម្នាក់ៗដោយអំឡុងពេលខុសៗគ្នាផងដែរ។ ដូច្នេះទោះបីជារយៈពេលសម្រាប់គិតពិចារណារបស់សន្តតិជនខ្លះបានចប់ក៏ដោយ ក៏សន្តតិជនផ្សេងទៀត នៅតែអាចបោះបង់ចោលសន្តតិកម្មបានផងដែរ។

នៅក្នុងអំឡុងពេលគិតពិចារណា សន្តតិជនត្រូវស្រាវជ្រាវពី សិទ្ធិ និង កាតព្វកិច្ចហើយត្រូវសម្រេច ថាតើត្រូវបោះបង់សន្តតិកម្ម ត្រូវយល់ព្រមដោយមានកម្រិត ឬ ត្រូវយល់ព្រមទាំងស្រុង? ប្រសិនបើគាត់មិនបានដាក់ពាក្យសុំបោះបង់ ឬ យល់ព្រមដោយកម្រិតទេនោះ ត្រូវចាត់ទុកថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះ (មាត្រា១២៥៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ស្តីពីការយល់ព្រមទាំងស្រុងតាមច្បាប់)។

### ៣.៣.២. ករណីសន្តតិជនទទួលមរណភាពដោយមិនបានយល់ព្រម ឬ បោះបង់

ប្រសិនបើសន្តតិជនទទួលមរណភាព ដោយមិនបានធ្វើការយល់ព្រម ឬ បោះបង់នោះ អំឡុងពេលគិតពិចារណាត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជននៃសន្តតិជនដែលបានទទួលមរណភាពនោះ បានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម (មាត្រា១២៤៩ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖A ជាមតកជន B ជាសន្តតិជន និងCជាកូនរបស់ B។Aបានទទួលមរណភាពនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦។ B បានទទួលមរណភាពនៅ ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៦ ដោយមិនបានយល់ព្រម ឬ បោះបង់សន្តតិកម្មឡើយ។ C បានដឹងពីការស្លាប់របស់ B នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦។ ក្នុងករណីនេះ អំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពី A ត្រូវគណនាចាប់ពី ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ តទៅ (មាត្រា១២៤៩ នៃក្រមរដ្ឋប្បវេណី)។ អំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពីB ត្រូវគណនាពី ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៦ ដូចគ្នា (មាត្រា១២៤៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ C អាចគិតពិចារណាថា ត្រូវបោះបង់ ឬ ក៏អត់ រហូតដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៦។ ប្រសិនបើ C បោះបង់សន្តតិកម្មពី B នោះ C មិនចាំបាច់ពិចារណាលើសន្តតិកម្មពី A ឡើយ។ ផ្ទុយទៅវិញ ប្រសិនបើ C យល់ព្រមសន្តតិកម្មពី B នោះ C ត្រូវពិចារណាបន្ថែម ថាតើត្រូវបោះបង់ ឬ យល់ព្រមទទួលសន្តតិកម្មពី A។

### ៣.៣.៣. ករណីដែលសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ បានចាប់ផ្តើម (មាត្រា១២៥០ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើ សន្តតិជនដែលជាអនីតិជន គ្មានទាំងអ្នកមានអំណាចមេបា ឬ អាណាព្យាបាលទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីក្រោយពេលដែលបានតែងតាំងអាណាព្យាបាលសម្រាប់អនីតិជន។

### ៣.៣.៤. ករណីដែលសន្តតិជនមិនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ច

ក្នុងករណីដែលមតកជនមានកាតព្វកិច្ចច្រើនលើសលប់ ដែលមិនអាចយកសិទ្ធិទៅសងឲ្យគ្រប់ចំនួនបានទេនោះ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច តាមស្ថានភាពនៃជីវភាពរបស់មតកជន ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់មតកជន និង ស្ថានភាពផ្សេងៗទៀតទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជន បានដឹងពីអត្ថិភាពនៃកាតព្វកិច្ចនោះ (មាត្រា១២៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ ប្រសិនបើសន្តតិ

ជនបានចាត់ចែងទ្រព្យដែលជាមតិកណាមួយ ដើម្បីសងកាតព្វកិច្ចរបស់មតកជន នៅមុនពេលដែលខ្លួនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ចដែលបានរៀបរាប់ខាងលើ មាត្រា១២៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ មានន័យថា សន្តតិជននៅតែអាចបោះបង់សន្តតិកម្មបានជានិច្ច។

### ៣.៣.៥. ការពន្យារពេលគិតពិចារណា

ក្នុងករណីដែលមានសិទ្ធិ ឬ កាតព្វកិច្ចច្រើន អំឡុងពេល ៣ខែ ប្រហែលជាមិនគ្រប់គ្រាន់សម្រាប់កំណត់ថាត្រូវបោះបង់សន្តតិកម្ម ឬ អត់នោះទេ។ ករណីនេះ សន្តតិជនអាចដាក់ពាក្យសុំពន្យារពេលបាន (មាត្រា១២៨៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី និង មាត្រា៣នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនិង ឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១១)។ពាក្យសុំពន្យារអំឡុងពេលគិតពិចារណាត្រូវដាក់ទៅតុលាការនៅក្នុងអំឡុងពេលគិតពិចារណានោះ។ ប្រសិនបើតុលាការទទួលបានពាក្យសុំនោះ តុលាការត្រូវពិចារណាលើចំណុចដូចជា ចំនួន និង ប្រភេទនៃមតិក និង កាតព្វកិច្ច ទីកន្លែងចាប់ផ្តើមសន្តតិកម្ម ទីកន្លែងដែលសហសន្តតិជនរស់នៅ ជាដើម។ ប្រសិនបើតុលាការយល់ថាគួរផ្តល់ឲ្យការពន្យារ តុលាការត្រូវចេញដីកាសម្រេចពន្យារអំឡុងពេលគិតពិចារណា។

បញ្ហាស្ថិតត្រង់ថា ប្រសិនបើការពន្យារអំឡុងពេលនោះនៅតែមិនគ្រប់គ្រាន់ តើសន្តតិជនអាចដាក់ពាក្យសុំពន្យារលើកទី២ បានដែរឬទេ? សន្តតិជន អាចដាក់ពាក្យសុំជាលើកទី២បាន ពីព្រោះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពេលវេលានៃការពន្យារនោះឡើយ។ ពាក្យសុំទី២ នោះ ត្រូវដាក់នៅក្នុងអំឡុងពេលដែលបានពន្យារដោយដីកាសម្រេចនៃពាក្យសុំទី១។

## ៣.៤. អានុភាព

### ៣.៤.១. ដីកាសម្រេច

ប្រសិនបើ តុលាការគិតថាពាក្យសុំបោះបង់សន្តតិកម្មមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចដើម្បីទទួលយកពាក្យសុំបោះបង់សន្តតិកម្ម ។

តុលាការត្រូវពិនិត្យថា អ្នកដែលបានដាក់ពាក្យសុំ គឺជាសន្តតិជនពិតប្រាកដដែរឬទេ តើបានដាក់ពាក្យសុំក្នុងអំឡុងពេលគិតពិចារណដែរឬទេ តើអ្នកដាក់ពាក្យសុំពិតជាមានបំណងចង់បោះបង់សន្តតិកម្មដែរឬទេ ថាតើមានមូលហេតុសម្រាប់ការយល់ព្រមទាំងស្រុងតាមច្បាប់ដែរឬទេ? (មាត្រា១២៥៥ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត មូលហេតុត្រឹមត្រូវ ឬ ភាពចាំបាច់ក្នុងការបោះបង់ មិនមែនជាល័ក្ខខ័ណ្ឌក្នុងការបោះបង់សន្តតិកម្មនោះទេ។ ដូចនេះ តុលាការមិនត្រូវលើកចោលពាក្យសុំនោះឡើយ ទោះបីជាគ្មានមូលហេតុ ឬភាពចាំបាច់នៃការបោះបង់ក៏ដោយ។

ច្បាប់មិនតម្រូវឲ្យតុលាការ ដឹងឮពីគំនិតរបស់អ្នកដាក់ពាក្យសុំនោះទេ។ ប៉ុន្តែ ដើម្បីជាការអនុវត្តដ៏ល្អនោះ តុលាការគួរពិនិត្យលើអ្នកដាក់ពាក្យសុំដោយផ្ទាល់ ឬ យ៉ាងហោចណាស់ ពិនិត្យតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការបញ្ជាក់ថាជា ឆន្ទៈពិតរបស់អ្នកដាក់ពាក្យសុំ។

**៣.៤.២. អានុភាពនៃការបោះបង់សន្តតិកម្ម**

**-អានុភាពចំពោះសន្តតិជនដែលបានបោះបង់សន្តតិកម្ម**

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា១២៦១ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូង ។

**-អានុភាពចំពោះសហសន្តតិជនផ្សេងទៀត**

ចំនួនមតិកដែលសហសន្តតិជនអាចទទួលបានអាចនឹងមានការកើនឡើង ពីព្រោះចំនួននៃសន្តតិជននឹងត្រូវបានកាត់បន្ថយដោយសារតែការបោះបង់ចោលសន្តតិកម្មរបស់សន្តតិជនណាម្នាក់។ ប្រសិនបើ សន្តតិជនទាំងអស់បោះបង់សន្តតិកម្ម សន្តតិជនដែលស្ថិតនៅលំដាប់បន្ទាប់ ត្រូវទទួលសិទ្ធិ និង ទទួលបន្ទុកកាតព្វកិច្ច (ស្តីពី លំដាប់នៃសន្តតិកម្ម មើល មាត្រា១១៥៦ មាត្រា១១៥៩ និង មាត្រា ១១៦០ នៃក្រមរដ្ឋប្បវេណី)។

**-ការបោះបង់សន្តតិកម្ម និង សន្តតិកម្មជំនួស**

ទោះបីជា សន្តតិជនបានបោះបង់សន្តតិកម្មក៏ដោយ សន្តតិកម្មជំនួសនឹងមិនកើតឡើងនោះទេ (មាត្រា១១៥៧ នៃក្រមរដ្ឋប្បវេណី មិនបានចែងអំពីករណីបោះបង់សន្តតិកម្មឡើយ)។ ដូច្នេះហើយ ញាតិលោហិតខ្សែផ្ទាល់នៃសន្តតិជនដែលបានបោះបង់សន្តតិកម្ម មិនអាចទទួលមតិកតាមរយៈសន្តតិកម្មជំនួសបានឡើយ។

**៣.៥. ការបោះបង់ និង ការគ្រប់គ្រងមតិក**

ជាធម្មតា នៅពេលចាប់ផ្តើមសន្តតិកម្ម មតិកគឺស្ថិតនៅក្រោមកម្មសិទ្ធិរបស់សន្តតិជន។ សន្តតិជនទាំងនោះត្រូវរក្សាទុក និង គ្រប់គ្រងមតិកដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ (មាត្រា១២៦២ កថាខណ្ឌទី១ និង កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ការរក្សាទុក និង គ្រប់គ្រងមតិកដោយប្រុងប្រយ័ត្នដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួននោះត្រូវបន្តរហូតដល់បុគ្គលដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមតិកនោះបាន (មាត្រា១២៦២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើសន្តតិជន ចំណាយសោហ៊ុយក្នុងការរក្សាការពារមត៌ក សោហ៊ុយទាំងនោះត្រូវចំណាយចេញពីទ្រព្យសម្បត្តិ (មាត្រា១២៦៥ នៃក្រមរដ្ឋប្បវេណី)។

## ៤. ការយល់ព្រមដោយមានកម្រិត

### ៤.១. គោលបំណង

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ (មាត្រា១២៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ នេះហៅថា ការយល់ព្រមដោយមានកម្រិត។

ប្រសិនបើមានភាពច្បាស់លាស់ថា មានកាតព្វកិច្ចច្រើនជាងទ្រព្យសម្បត្តិ សន្តតិជនអាចធ្វើការសម្រេចចិត្តដើម្បីបោះបង់សន្តតិកម្មបាន។ ប៉ុន្តែ ក៏អាចមានករណីដែលមិនដឹងច្បាស់ពីចំនួននៃកាតព្វកិច្ចផងដែរ។ ក្នុងករណីដូចនេះ សន្តតិជនអាចនឹងចង់ដឹងថា តើចំនួនកាតព្វកិច្ចមានលើសសិទ្ធិដែរឬទេ? ប្រសិនបើ សន្តតិជនយល់ព្រមដោយមានកម្រិតនឹងត្រូវសងបំណុលនោះដោយប្រើប្រាស់មត៌ក។ ក្រោយពីការសង ប្រសិនបើមាននៅសល់ទ្រព្យសម្បត្តិ សន្តតិជនអាចទទួលយកទ្រព្យសម្បត្តិនោះបាន។ ផ្ទុយទៅវិញ ប្រសិនបើមាននៅសល់បំណុលក្រោយពីការសង សន្តតិជនគ្មានកាតព្វកិច្ចសងបំណុលនោះឡើយ។

### ៤.២. វិធីក្នុងការយល់ព្រមដោយមានកម្រិត

#### ៤.២.១. ការដាក់ពាក្យសុំ

នៅក្នុងការបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិត រួមជាមួយបញ្ជីសារពើភ័ណ្ឌទៅកាន់តុលាការ (មាត្រា១២៥៧ នៃក្រមរដ្ឋប្បវេណី)។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម (មាត្រា៣នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនិង ឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៣)។

សហសន្តតិជនត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិត ដោយរួមគ្នាទាំងអស់ (មាត្រា១២៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ប្រសិនបើសន្តតិជនម្នាក់សុខចិត្តយល់ព្រមទាំងស្រុង ហើយមិនយល់ព្រមសហការដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតទេនោះ សន្តតិជនដទៃទៀតមិនអាចយល់ព្រមដោយកម្រិតលើសន្តតិកម្មនោះបានឡើយ។ ម្យ៉ាងវិញទៀត ទោះបីជា សន្តតិជនម្នាក់បានបោះបង់សន្តតិកម្មក៏ដោយ ក៏សន្តតិជនដទៃនៅតែអាចយល់ព្រមដោយកម្រិតបានដែរ ដោយសារតែបុគ្គលដែលបានបោះបង់នោះ ត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណី)។

#### ៩.២.២. ករណីដែលសន្តតិជនជាអនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ

ខ្លឹមសារដូចដែលបានរៀបរាប់នៅក្នុងចំណុចការបោះបង់សន្តតិកម្មខាងលើ អាចយកមកអនុវត្តបាន។

#### ៩.២.៣. ករណីដែលសន្តតិជនជាជនស្ថិតក្រោមហិត្វបត្ថម្ភ

ខ្លឹមសារដូចដែលបានរៀបរាប់នៅក្នុងចំណុចការបោះបង់សន្តតិកម្មខាងលើ អាចយកមកអនុវត្តបាន។

### ៩.៣. ការកំណត់ពេលវេលានៃការដាក់ពាក្យសុំ

ជាទូទៅ ខ្លឹមសារដូចដែលបានរៀបរាប់នៅក្នុងចំណុចការបោះបង់សន្តតិកម្មខាងលើ អាចយកមកអនុវត្តបាន។ ប៉ុន្តែខាងក្រោមនេះជាបញ្ហាមួយៈ

| |
|---|
| ករណីសិក្សាៈ Xបានទទួលមរណភាពហើយមានសន្តតិជនពីរនាក់គឺA និង B។ A បានដឹងពីការស្លាប់របស់ X នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦។ នៅក្នុងអំឡុងពេលគិតពិចារណា A មិនបានដាក់ពាក្យសុំបោះបង់សន្តតិកម្ម ឬ ពាក្យសុំយល់ព្រមដោយកម្រិតឡើយ។ ក្រោយមក នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ B បានដឹងពីការស្លាប់របស់ X។ ឥឡូវនេះ B ចង់ដាក់ពាក្យសុំយល់ព្រមដោយកម្រិត។ ដោយសារតែ ការដាក់ពាក្យសុំយល់ព្រមដោយកម្រិត ត្រូវធ្វើឡើងរួមគ្នាពីគ្រប់សន្តតិជនទាំងអស់ B ក៏បានសុំ A ឲ្យដាក់ពាក្យសុំជាមួយគ្នា ហើយ A ក៏បានយល់ព្រម។ ប៉ុន្តែ អំឡុងពេលគិតពិចារណារបស់ A បានហួសពេលបាត់ទៅហើយ។ ក្នុងករណីនេះ តើ A និង B អាចរួមគ្នាដាក់ពាក្យសុំយល់ព្រមដោយកម្រិតបានដែរ ឬទេ? |

### ៩.៤. អានុភាព

#### ៩.៤.១. ដីកាសម្រេច

ប្រសិនបើ តុលាការគិតថាពាក្យសុំអំពីការយល់ព្រមដោយមានកម្រិត មានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចដើម្បីទទួលយកពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតនោះ។ ប្រសិនបើ មានសន្តតិជន ២ ឬ ច្រើននាក់ តុលាការត្រូវតែងតាំងអ្នកគ្រប់គ្រងរក្សាមតិក (មាត្រា ១២៨៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ចំពោះដីកាសម្រេច ខ្លឹមសារដូចដែលបានរៀបរាប់នៅក្នុងចំណុចការបោះបង់សន្តតិកម្មខាងលើអាចយកមកអនុវត្តបាន។

### ៩.៤.២. អានុភាពនៃការយល់ព្រមដោយមានកម្រិត

- ការជម្រះបញ្ជីមតិក

ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយមានកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ (មាត្រា១២៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ជារួម មតិកត្រូវបែងចែកឲ្យដាច់ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន។ កាតព្វកិច្ច និង អច្ច័យទាននឹងត្រូវដកចេញពីមតិកតែប៉ុណ្ណោះ ដោយផ្អែកតាមមាត្រា១២៨០ ដល់ ១២៨៩ នៃក្រមរដ្ឋប្បវេណី។ ក្រោយពីបានសងបំណុល និងធ្វើអច្ច័យទានគ្រប់អស់ហើយ ប្រសិនបើ ទ្រព្យសម្បត្តិមាននៅសល់ សន្តតិជនអាចទទួលបានទ្រព្យសម្បត្តិនោះ។ ផ្ទុយទៅវិញ ប្រសិនបើមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់សងកាតព្វកិច្ច និងធ្វើអច្ច័យទានទេនោះ ម្ចាស់បំណុល និង អច្ច័យលាភី មិនអាចទទួលបានការសងដ៏ពេញលេញមួយបានឡើយ។

*ប្រសិនបើម្ចាស់បំណុល (ដើមចោទ) បានដាក់ពាក្យបណ្តឹងចំពោះសន្តតិជន (ចុងចម្លើយ) ដែលបានយល់ព្រមដោយមានកម្រិត ហើយម្ចាស់បំណុលជាអ្នកឈ្នះ សាលក្រមត្រូវបញ្ជាក់ឲ្យច្បាស់ថា ចុងចម្លើយត្រូវទទួលបន្ទុកកាតព្វកិច្ចត្រឹមកម្រិតនៃមតិកដែលខ្លួនទទួលបានតែប៉ុណ្ណោះ។ ឧទាហរណ៍៖ នៅក្នុងសេចក្តីសម្រេចបញ្ចប់ ៖ “ចុងចម្លើយត្រូវបង់ប្រាក់ចំនួន ១០០០$ ទៅឲ្យដើមចោទ **តាមកម្រិតនៃទ្រព្យសម្បត្តិដែលចុងចម្លើយទទួលបន្តពីលោក X។**”

-ការទទួលខុសត្រូវរបស់សន្តតិជនដែលបានបំពានលើការយល់ព្រមដោយមានកម្រិត

ក្រោយពីបានបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត ប្រសិនបើ សន្តតិជនមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគទៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បានចាត់ចែងភាគណាមួយនៃទ្រព្យសម្បត្តិ ឬ លាក់ ឬ ប្រើប្រាស់ភាគណាមួយនៃទ្រព្យសម្បត្តិជាលក្ខណៈឯកជន នោះសន្តតិជនរូបនោះនឹងត្រូវចាត់ទុកថាបានយល់ព្រមទាំងស្រុង។ នៅក្នុងករណីនេះ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសន្តតិជននោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលពុំអាចទទួលការសងដោយមតិកបាន (មាត្រា១២៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

# ផ្នែកទី៥
# អវត្តមាននៃសន្តតិជន

## ១. គោលគំនិតទូទៅ

នៅពេលដែលមនុស្សម្នាក់ទទួលមរណភាព ទ្រព្យសម្បត្តិរបស់គាត់នឹងត្រូវបានទទួលបន្តដោយសន្តតិជន។ ប្រសិនបើមានសន្តតិជន ប៉ុន្តែ ពួកគេបានបាត់ខ្លួន នោះការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់បុគ្គលដែលអវត្តមាន (មាត្រា៣៧ ក្រមរដ្ឋប្បវេណី) និង ការប្រកាសការបាត់ខ្លួន (មាត្រា៥១ ក្រមរដ្ឋប្បវេណី) ត្រូវយកមកប្រើប្រាស់។

មួយវិញទៀត ក៏អាចមានករណីដែលមិនមានភាពច្បាស់លាស់ ថាតើមានសន្តតិជន ឬក៏អត់ផងដែរ។ ក្នុងករណីដូចនេះ ចាំបាច់ត្រូវមាននីតិវិធីក្នុងការស្វែងរកសន្តតិជន។ ប្រសិនបើរកមិនឃើញសន្តតិជនទេនោះ ទ្រព្យសម្បត្តិដែលនៅសល់ ត្រូវប្រគល់ឲ្យជនដែលមាននិស្ស័យពិសេសជាមួយនឹងមតកជន ឬ ធ្លាក់ទៅជាទ្រព្យរដ្ឋ( មើលមាត្រា១២៩០-១៣០០ ក្រមរដ្ឋប្បវេណី)។

## ២. លំហូរនៃនិតិវិធី


មតកជនទទួលមរណភាព
ការចាត់តាំងអ្នកចាត់ចែងគ្រប់គ្រង (មាត្រា១២៩១)
ការជូនដំណឹងជាសាធារណៈលើកទី ១ (មាត្រា១២៩១-២)
យ៉ាងហោចណាស់ ២ខែ (មាត្រា១២៩៦-១)
ការជូនដំណឹងជាសាធារណៈលើកទី ២ (មាត្រា១២៩៦-១)
យ៉ាងហោចណាស់ ២ខែ (មាត្រា១២៩៦-១)
ការដកចេញពីការជម្រះ (១២៩៦-២ និង ១២៨៨)
ការចាប់ផ្ដើមការជម្រះនៃមតិក (មាត្រា១២៩៦-២ និង ១២៨៣ ដល់ ១២៨៦)
ការជូនដំណឹងជាសាធារណៈលើកទី ៣ (មាត្រា១២៩៧)
យ៉ាងហោចណាស់ ៦ខែ (មាត្រា១២៩៧-១)
ការរលត់នៃសិទ្ធិ (មាត្រា១២៩៨)
អំឡុងពេល ៣ខែ (មាត្រា ១២៩៩-២)
ពាក្យសុំនៃការចែកទ្រព្យទៅឲ្យជនដែលមាននិស្ស័យពិសេស (មាត្រា ១២៩៩-២)
ការជម្រះត្រូវបញ្ចប់ មុនពេលធ្លាក់ទៅជាទ្រព្យរដ្ឋ
ការចែកទ្រព្យទៅឲ្យជនដែលមាននិស្ស័យពិសេស (មាត្រា ១២៩៩-២)
ទ្រព្យដែលនៅសល់ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ (មាត្រា ១៣០០)

### ៣. នីតិវិធី

### ៣.១. មរណភាពនៃមតកជន

- ប្រសិនបើគ្មានភាពច្បាស់លាស់ថាមានសន្តតិជនទេ មតិកនឹងត្រូវក្លាយជានីតិបុគ្គលមតិកដោយស្វ័យប្រវត្តិ (មាត្រា១២៩០ ក្រមរដ្ឋប្បវេណី)។ ទោះបីជាមតិកមានចំនួនតិចតួចក៏ដោយ ក៏នីតិបុគ្គលមតិកនឹងត្រូវបង្កើតឡើងដោយស្វ័យប្រវត្តិ។

- ដើម្បីបង្កើតនីតិបុគ្គលមតិក មិនតម្រូវឲ្យមាននីតិវិធីឡើយ។ ដូច្នេះ ទោះបីជាគ្មាននរណាម្នាក់ដាក់ពាក្យសុំតែងតាំងអ្នកគ្រប់គ្រងក៏ដោយ (មាត្រា១២៩១ ក្រមរដ្ឋប្បវេណី) ក៏នីតិបុគ្គលមតិកត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិដែរ។ ប៉ុន្តែ ប្រសិនបើគ្មានអ្នកគ្រប់គ្រង នោះក៏គ្មានការចាប់ផ្តើមនៃនីតិវិធីដែរ។

- "**ភាពមិនច្បាស់លាស់ថាមានសន្តតិជន**" រួមមាន៖

- ច្បាស់ថាមិនមានសន្តតិជន
- មានសន្តតិជនដែរ ប៉ុន្តែពួកគេទាំងអស់បានបោះបង់ចោលសន្តតិកម្ម (មាត្រា ១២៦១ ក្រមរដ្ឋប្បវេណី)
- មានសន្តតិជនដែរ ប៉ុន្តែពួកគេគឺជាអភ័ព្វបុគ្គល (មាត្រា១១៥០ ក្រមរដ្ឋប្បវេណី) ឬ ជាជនដែលត្រូវបានផ្តាច់មតិក (មាត្រា១១៥១ ក្រមរដ្ឋប្បវេណី)។

### ៣.២. ការតែងតាំងអ្នកគ្រប់គ្រង (មាត្រា១២៩១ កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី និង មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធផ្នែក៥ ចំណុច៦០)

- តុលាការត្រូវតែងតាំងអ្នកគ្រប់គ្រងទៅតាមពាក្យសុំ។ ប្រសិនបើគ្មានអ្នកណាម្នាក់បានដាក់ពាក្យសុំទេ នោះមិនត្រូវតែងតាំងអ្នកគ្រប់គ្រងឡើយ។ ក្នុងករណីនេះ គឺមាននីតិបុគ្គលមតិកតែគ្មាននីតិវិធីឡើយ។ ប្រសិនបើមានមតិកច្រើនសន្ធឹកសន្ធាប់ ដូចជា អចលនវត្ថុ ជាដើមនោះ មេឃុំ ឬ ចៅសង្កាត់ ឬ ព្រះរាជអាជ្ញា ត្រូវធ្វើជាអ្នកដាក់ពាក្យសុំនោះ។

- មានករណីជាច្រើនដែលម្ចាស់បំណុលរបស់មតកជន អច្ច័យលាភី ឬ ជនដែលមាននិស្ស័យពិសេស (មាត្រា១២៩៩ ក្រមរដ្ឋប្បវេណី) ធ្វើការដាក់ពាក្យសុំក្នុងការតែងតាំងអ្នកគ្រប់គ្រង។ បុគ្គលទាំងនេះគឺជា "**បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍**" (មាត្រា១២៩១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី) ដោយសារតែ ពួកគេត្រូវមានសិទ្ធិទទួលបានមតិកមួយផ្នែក។

## ៣.៣. ការជូនដំណឹងលើកទី ១ ដោយតុលាការ៖ ការជូនដំណឹងជាសាធារណៈនៃការតែងតាំងអ្នកគ្រប់គ្រង (មាត្រា១២៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)

- ការជូនដំណឹងជាសាធារណៈ ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តធម៌ ( មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

## ៣.៤. ការជូនដំណឹងលើកទី ២ ដោយអ្នកគ្រប់គ្រង៖ ការជូនដំណឹងជាសាធារណៈសម្រាប់ការបង្ហាញការទាមទារ (មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)

- ការជូនដំណឹងជាសាធារណៈ ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តធម៌ (មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

- ការជូនដំណឹងជាសាធារណៈត្រូវ៖

- បញ្ជាក់នូវអំឡុងពេលជាក់លាក់ដែលមិនត្រូវតិចជាង ២ខែ (មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)
- បង្ហាញថា គ្រប់សន្តតិជន និង អច្ច័យលាភីទាំងអស់ត្រូវបង្ហាញពីការទាមទាររបស់ពួកគេ នៅក្នុងអំឡុងពេលកំណត់ខាងលើ (មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)
- សរសេរថា ម្ចាស់បំណុលរបស់សន្តតិជនដែលមិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើទេនោះ ការទាមទារនោះនឹងត្រូវដកចេញពីការជម្រះ (មាត្រា១២៩៦ កថាខណ្ឌទី១ និងមាត្រា១២៨១ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណី)។

## ៣.៥. ការដកចេញពីការជម្រះ (មាត្រា១២៩៦ កថាខណ្ឌទី១ និង មាត្រា១២៨៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)

- ម្ចាស់បំណុល និង អច្ច័យលាភី ដែលមិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើ នឹងត្រូវដកចេញពីការជម្រះ។ ម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ អាចអនុវត្តសិទ្ធិរបស់ពួកគេ លុះត្រាតែមានសល់ទ្រព្យសម្បត្តិក្រោយពីការជម្រះ។

- ថ្វីត្បិតតែ ម្ចាស់បំណុល និង អច្ច័យលាភី មិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើក៏ដោយ ប្រសិនបើអ្នកគ្រប់គ្រងស្គាល់ពួកគេ ពួកគេនឹងមានសិទ្ធិទទួលបានការសងតាមរយៈការជម្រះ។

- ថ្វីត្បិតតែ ម្ចាស់បំណុលមិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើក៏ដោយ ក៏សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ មិនត្រូវបានរលត់ឡើយ (មាត្រា១២៨៨ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ម្ចាស់បំណុលទាំងនោះអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនតាមរយៈការជម្រះបាន។

### ៣.៦. ការជម្រះ

- "**ការជម្រះ**" មានន័យថា អ្នកគ្រប់គ្រងធ្វើការសងបំណុល និង អច្ច័យទានដោយយកចេញពីមតិក។

- ជាធម្មតា ការជម្រះចាប់ផ្ដើមនៅពេលដែលអំឡុងពេលជាក់លាក់ (យ៉ាងហោចណាស់ ២ ខែ) បានកន្លងផុត ក្រោយពីការជូនដំណឹងជាសាធារណៈលើកទី២ (មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ នៅមុនអំឡុងពេលជាក់លាក់នោះ អ្នកគ្រប់គ្រងអាចបដិសេធការសងចំពោះម្ចាស់បំណុល និង អច្ច័យលាភីបាន (មាត្រា១២៩៦ កថាខណ្ឌទី២ និង មាត្រា១២៨២ នៃក្រមរដ្ឋប្បវេណី)។ សូម្បីតែ ក្នុងអំឡុងពេលកំណត់ជាក់លាក់នោះក៏ដោយ ក៏អ្នកគ្រប់គ្រងអាចសងទៅម្ចាស់បំណុល និង អច្ច័យលាភីបានដែរ។ ក្នុងករណីនេះ ប្រសិនបើមិនអាចសងទៅម្ចាស់បំណុល និង អច្ច័យលាភីដទៃទៀតបានទេនោះ អ្នកគ្រប់គ្រងត្រូវមានករណីយកិច្ចសងសំណងខូចខាត (មាត្រា១២៩៦ កថាខណ្ឌទី១ និង មាត្រា១២៨៧ នៃក្រមរដ្ឋប្បវេណី)។

- ចំពោះវិធីក្នុងការសង សូមមើលបញ្ញត្តិ និង សេចក្ដីពន្យល់នៃមាត្រា១២៨៣-១២៨៨ នៃក្រមរដ្ឋប្បវេណី។

### ៣.៧. ការជូនដំណឹងលើកទី ៣ ដោយតុលាការ៖ ការជូនដំណឹងជាសាធារណៈសម្រាប់ការស្វែងរកសន្តតិជន (មាត្រា១២៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)

- ប្រសិនបើ ក្រោយពីពេលដែលអំឡុងពេលដែលបានកំណត់ជាក់លាក់នៃការជូនដំណឹងលើកទី២នោះហួសកំណត់ ហើយនៅតែមិនអាចរកឃើញអត្ថិភាពនៃសន្តតិជនទៀតនោះ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈលើកទី៣ តាមពាក្យសុំពីសំណាក់អ្នកគ្រប់គ្រង ឬ ព្រះរាជអាជ្ញា។ ប៉ុន្តែ ដោយសារតែគោលបំណងនៃការជូនដំណឹងនេះ គឺដើម្បីផ្ដល់ឲ្យនូវទ្រព្យសម្បត្តិដែលនៅសល់ទៅឲ្យសន្តតិជន ដូច្នេះ ប្រសិនបើប៉ាន់ប្រមាណឃើញថា គ្មានសេសសល់មតិកទេ មិនទាមទារឲ្យ អ្នកគ្រប់គ្រង និង តំណាងអយ្យការធ្វើពាក្យសុំឡើយ។

- ការជូនដំណឹងជាសាធារណៈ ត្រូវធ្វើឡើងដោយការបិទប្រកាសរបស់តុលាការ និង ចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ (មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

- ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឲ្យច្បាស់ពីអំឡុងពេលជាក់លាក់មួយដែលមិនឲ្យតិចជាង ៦ខែ ហើយត្រូវសរសេរថា ប្រសិនបើមានសន្តតិជន ពួកគេត្រូវប្រកាសដោយខ្លួនឯងថាជាសន្តតិជននៅក្នុងអំឡុងពេលខាងលើ។

**៣.៨. ការរលត់សិទ្ធិ (មាត្រា១២៩៨)**

- ប្រសិនបើគ្មានសន្តតិជនណាបង្ហាញខ្លួនក្នុងអំឡុងពេលខាងលើនេះទេ សន្តតិជនទាំងអស់នឹងបាត់បង់សិទ្ធិរបស់ខ្លួន។ លើសពីនេះទៀត ម្ចាស់បំណុល និង អច្ច័យលាភីទាំងអស់ដែលអ្នកគ្រប់គ្រងស្គាល់នឹងបាត់បង់សិទ្ធិដូចគ្នា។ ពួកគេ មិនអាចអនុវត្តសិទ្ធិរបស់ពួកគេបានឡើយ ទោះបីជានៅសល់នូវមតិកក្រោយពីការជម្រះក៏ដោយ។

- ប្រសិនបើ សន្តតិជនបង្ហាញខ្លួនក្រោយការរលត់នៃសិទ្ធិនៃមាត្រា១២៩៨ នៃក្រមរដ្ឋប្បវេណី សន្តតិជនរូបនោះមិនមានសិទ្ធិទទួលបាននូវផ្នែកណាមួយនៃមតិកឡើយ។ ទោះបីជាមានការបង្ហាញខ្លួនរបស់សន្តតិជននោះក៏ដោយ ក៏នីតិវិធីនៃនីតិបុគ្គលមតិកនៅតែបន្តដែរ។

**៣.៩. ការចែកមតិកទៅឲ្យជនដែលមាននិស្ស័យពិសេស (មាត្រា១២៩៩ នៃក្រមរដ្ឋប្បវេណី មាត្រា ៣ នៃច្បាប់ស្តីពីរៀងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធផ្នែក៥ ចំណុច២៥)**

- ផ្អែកតាមមាត្រា១២៩៨ នៃក្រមរដ្ឋប្បវេណី នៅក្នុងករណីខ្លះ ក៏អាចមានមតិកដែលនៅសល់ក្រោយពីការរលត់សិទ្ធផងដែរ។ ក្នុងករណីដូចនេះ ជនដែលមាននិស្ស័យពិសេសអាចដាក់ពាក្យសុំបែងចែកមតិកទៅឲ្យជនដែលមាននិស្ស័យពិសេសបាន។ ប្រសិនបើ តុលាការពិចារណាឃើញថា សមហេតុផល នោះតុលាការអាចចេញដីកាសម្រេចប្រគល់ឲ្យនូវផ្នែកនៃមតិកដែលនៅសល់ទៅជនដែលមាននិស្ស័យពិសេស។

- ថ្វីត្បិតតែ ជនដែលមាននិស្ស័យពិសេស គឺជាសាច់ញាតិរបស់មតកជនក៏ដោយ ក៏ទំនាក់ទំនងញាតិ ឬញាតិពន្ធមិនមានភាពចាំបាច់អ្វីដែរ។ នៅក្នុងករណីខ្លះ មិត្តភក្តិរបស់មតកជន ឬមណ្ឌលមើលថែចាស់ជរាដែលមើលថែមតកជនបានជិតដល់ ក៏អាចក្លាយជាជនដែលមាននិស្ស័យពិសេសបានដែរ។

-ឧទាហរណ៍នៃជនដែលរួមរស់ជីវភាពជាមួយនឹងមតកជន៖

- ប្តីប្រពន្ធអនីតិសង្វាស
- ក្មួយប្រុស ក្មួយស្រី និង ពូ មីង ដែលរស់នៅជាមួយគ្នាដូចជាឪពុកម្តាយ និង កូន
- កូនចុង ឬ ឪពុកម្តាយចុង។

- ឧទាហរណ៍នៃជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន៖

- មេផ្ទះ គិលានុបដ្ឋាយិកា បងប្អូនសាច់ឆ្ងាយ ឬ អ្នកធ្វើការងារសង្គម ជាដើម។ ក្នុងករណីដែលពួកគេទទួលបានការបង់ប្រាក់ នោះនឹងមានការលំបាកនៅក្នុងការកំណត់ថាពួកគេជាជនដែលមាននិស្ស័យពិសេសនេះ។ ប៉ុន្តែ ប្រសិនបើពួកគេខំប្រឹងប្រែងធ្វើការងារយ៉ាងនឿយហត់ជាងបងប្អូនធម្មតាធ្វើទៀតនោះ ពួកគេអាចសក្តិសមនឹងត្រូវបានចាត់ទុកជាជនដែលមាននិស្ស័យពិសេស។

- នៅពេលកំណត់ ថាតើត្រូវផ្តល់មតិកមួយផ្នែកទៅឲ្យបុគ្គលនោះ ឬក៏អត់ តុលាការត្រូវគិតពិចារណាលើអង្គហេតុផ្សេងៗ ដូចជា៖

- តើបុគ្គលនោះ គឺជាសាច់ញាតិរបស់មតកជនដែរ ឬទេ?
- តើបុគ្គលនោះ បាននឹងកំពុងរស់នៅជាមួយមតកជនដែរ ឬទេ?
- តើបុគ្គលនោះ បានទៅសួរសុខទុក្ខមតកជននៅឯមន្ទីរពេទ្យប៉ុន្មានដងដែរ?
- តើបុគ្គលនោះ បានផ្តល់ការមើលថែទាំប្រភេទណាដល់មតកជន?
- តើជំនួយហិរញ្ញវត្ថុប្រភេទណាដែលបុគ្គលនោះ បានផ្តល់ទៅឲ្យមតកជន ដូចជា សោហ៊ុយចំណាយប្រចាំថ្ងៃ ថ្លៃថ្នាំពេទ្យ សោហ៊ុយលើបុណ្យសព?
- តើបុគ្គលនោះ បានជួយដល់មតកជនក្នុងភាពដំណើរការសំខាន់ចាំបាច់ ដូចជា ការដាក់ពាក្យចូលមណ្ឌលមើលថែចាស់ជរា ការដាក់ពាក្យសុំទទួលការព្យាបាលក្នុងមន្ទីរពេទ្យ ឬ ការដាក់ពាក្យសុំទទួលជំនួយហិរញ្ញវត្ថុសាធារណៈ និង ការរៀបចំពិធីបុណ្យសព ជាដើម?
- តើអ្វីជាឆន្ទៈរបស់មតកជន?។

***ចំណុចសម្រាប់ពិចារណា**

- ប្រសិនបើគ្មានមតិកគ្រប់គ្រាន់សម្រាប់សងទៅលើការចំណាយ ដើម្បីដំណើរការចំពោះនីតិវិធីនៃនីតិបុគ្គលមតិក តើតុលាការអាចច្រានចោលពាក្យសុំតែងតាំងអ្នកគ្រប់គ្រងបានដែរ ឬទេ?

- ប្រសិនបើ ចំនួនមតិកបានអស់ក្នុងពេលដែលនីតិវិធីកំពុងតែដំណើរការ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

- តើអ្នកគ្រប់គ្រងដែលត្រូវបានតែងតាំងនោះ អាចលាលែងពីការងារបានដែរ ឬទេ?

- តើតុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងនោះបានដែរ ឬទេ?

- តើអ្នកគ្រប់គ្រងនោះអាចទទួលបានប្រាក់កម្រៃ នៅពេលណា និងដោយរបៀបណាដែរ (មាត្រា ១២៩៣ ក្រមរដ្ឋប្បវេណី)?

-ឧទាហរណ៍៖ X និង Y ជាសហកម្មសិទ្ធិករទៅលើដី L មួយដោយមានចំណែកស្មើគ្នា។ X បានទទួលមរណភាពដោយគ្មានសន្តតិជនទេ។ តើចំណែកលើដី L របស់ X ត្រូវក្លាយជាកម្មសិទ្ធិរបស់ Y ដែរ ឬទេ? ឬ តើចំណែកនោះត្រូវក្លាយជានីតិបុគ្គលមតិក? ប្រសិនបើ អ្នកបកស្រាយថា ត្រូវបង្កើតនីតិបុគ្គលមតិក នៅពេលដែលនីតិវិធីមានដំណើរការ ហើយមាននៅសល់ចំណែករបស់ X លើដី L ក្រោយការជម្រះ តើចំណែករបស់ X ត្រូវក្លាយជាកម្មសិទ្ធិរបស់ Y មែនដែរ ឬទេ (មាត្រា២១០ ក្រមរដ្ឋប្បវេណី)? ឬ តើវាត្រូវប្រគល់ឲ្យទៅជនដែលមាននិស្ស័យពិសេស ឬមួយយ៉ាងណា (មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណី)?

# ជំពូក ១០
# ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
# និង
# ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

## ១. ទំនាក់ទំនងជាមួយនឹងក្រមនីតិវិធីរដ្ឋប្បវេណី

### ក. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

គឺជាច្បាប់ពិសេសមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ដូច្នេះហើយ ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវអនុវត្តចំពោះរឿងក្តីនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល លើកលែងតែច្បាប់នេះមានចែងខុសពីក្រមនីតិវិធីរដ្ឋប្បវេណីតែប៉ុណ្ណោះ។

### ខ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

គឺជាច្បាប់ដាច់ដោយឡែកពីក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះហើយ ក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវអនុវត្តចំពោះរឿងក្តីនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឡើយ លើកលែងតែច្បាប់នេះមានបញ្ញត្តិពីការអនុវត្តដូចគ្នាចំពោះក្រមនីតិវិធីរដ្ឋប្បវេណីតែប៉ុណ្ណោះ។



មាត្រាខ្លះនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវអនុវត្តដូចគ្នាចំពោះរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមានចែងដូចគ្នានោះ (ឧទាហរណ៍៖ មាត្រា៣ កថាខណ្ឌទី៣ មាត្រា១៩ កថាខណ្ឌទី១ មាត្រា២២ កថាខណ្ឌទី១ និងទី៥ មាត្រា២៩ កថាខណ្ឌទី៣ មាត្រា៣៩ មាត្រា៩២ មាត្រា៩៣ កថាខណ្ឌទី៨ មាត្រា៩៤ កថាខណ្ឌទី៥ និងទី៦ មាត្រា៩៥ កថាខណ្ឌទី៥)។

## ២. វិសាលភាពនៃការអនុវត្ត

### ក. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវអនុវត្តចំពោះករណីដែលមានចែងក្នុងមាត្រា៣ នៃច្បាប់នេះ។

*តើអ្វីជា "បណ្តឹងដែលមានគោលបំណងបង្កើត ឬ បញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងបុគ្គលផ្សេងៗ" (មាត្រា៣ ចំណុច ញ) នៃច្បាប់នេះ ? ដោយសារតែក្នុងក្រមរដ្ឋប្បវេណីមិនមានចែងពីបណ្តឹងប្រភេទនេះឡើយ ដូច្នេះតើបណ្តឹងប្រភេទនេះត្រូវអនុញ្ញាតឲ្យមានការអនុវត្ត ឬអត់នោះ គឺអាស្រ័យលើការបកស្រាយចំពោះផលប្រយោជន៍នៃបណ្តឹង (មាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ។

- បណ្តឹងបញ្ជាក់ពីនត្ថិភាពនៃអនីតិសង្វាស?
- បណ្តឹងបញ្ជាក់ពីអត្ថិភាពនៃទំនាក់ទំនងសុំកូន?
- បណ្តឹងបញ្ជាក់ពីអត្ថិភាពនៃភាពជាបងប្អូន?

### ខ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវអនុវត្តចំពោះករណីដែលមានចែងក្នុងមាត្រា៣ នៃច្បាប់នេះ និងក្នុងតារាងឧបសម្ព័ន្ធ។

*តើច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អាចអនុវត្តចំពោះរឿងក្តីដែលមិនមានសរសេរក្នុងតារាងឧបសម្ព័ន្ធបានដែរឬទេ? ឧទាហរណ៍៖ មាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ចែងថាតុលាការត្រូវកំណត់រកបុគ្គលដែលមានអំណាចមេបា នៅក្រោយការរំលាយនៃសុំកូនធម្មតា។ ទោះជាយ៉ាងនេះក្តី តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមិនមានសរសេរខ្លឹមសារនៃមាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឡើយ។ តើអាចអនុញ្ញាតឲ្យយកតារាងឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី ១០ (សមត្ថកិច្ចទៅលើពាក្យសុំនៃមាត្រា ១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ទៅធ្វើការអនុវត្តស្រដៀងចំពោះពាក្យសុំនៅ

ក្នុងមាត្រា១០២៨ កថាខណ្ឌទី៤ ដោយសារតែពាក្យសុំក្នុងមាត្រា១០២៨ កថាខណ្ឌទី៤នេះ គឺជាគំនិតជាមូលដ្ឋាននៃពាក្យសុំក្នុងមាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីបានដែរឬទេ?

## ៣. ការប្រៀបធៀបរវាង ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

### ៣.១. តើអនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅអាចធ្វើសកម្មភាពបណ្តឹងបានដែរឬទេ?

#### ក. ក្រមនីតិវិធីរដ្ឋប្បវេណី

អនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពបណ្តឹងបានដោយខ្លួនឯងទេ ហើយត្រូវតំណាងដោយអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែក្នុងករណីដែលអនីតិជនអាចធ្វើសកម្មភាពនោះដោយឯករាជ្យបាន (ឧទាហរណ៍ដូចជា អនីតិជនដែលទទួលអត្តាធីនភាព ផ្អែកលើមាត្រា២១ នៃក្រមរដ្ឋប្បវេណី) អនីតិជននោះអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន (មាត្រា៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីផ្សេងទៀត ប្រសិនបើបុគ្គលដែលខ្វះសមត្ថភាពក្នុងការយល់ដឹងពីលទ្ធផលផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួននោះ បុគ្គលនោះមិនត្រូវធ្វើសកម្មភាពបណ្តឹងឡើយ (មាត្រា៣២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា១៤ នៃក្រមរដ្ឋប្បវេណី)។

#### ខ. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

អនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន (មាត្រា៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដកចេញនូវការអនុវត្តមាត្រា១៨ និង មាត្រា២៦ នៃក្រមរដ្ឋប្បវេណី និង មាត្រា៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីផ្សេងទៀត ប្រសិនបើ បុគ្គលដែលខ្វះសមត្ថភាពក្នុងការយល់ដឹងពីលទ្ធផលផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួននោះ បុគ្គលនោះមិនត្រូវធ្វើសកម្មភាពបណ្តឹងឡើយ (មាត្រា៣២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា១៤ នៃក្រមរដ្ឋប្បវេណី)។

#### គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

អនីតិជន ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពបណ្តឹងបានដោយខ្លួនឯងទេ ហើយត្រូវតំណាងដោយអ្នកតំណាងដែលច្បាប់បានកំណត់(មាត្រា១៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ប៉ុន្តែក្នុងករណីដែលអនីតិជនអាចធ្វើសកម្មភាពនោះដោយឯករាជ្យបាន (ឧទារហណ៍ដូចជា អនីតិជនដែលទទួលអត្តាធីនភាព

ផ្អែកលើមាត្រា២១ នៃក្រមរដ្ឋប្បវេណី) ឬអនីតិជននោះធ្វើសកម្មភាពទាក់ទងនឹងឋានៈរបស់ខ្លួន អនីតិជននោះអាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបាន (មាត្រា១៧ កថាខណ្ឌទី២ ចំណុចក និង ខនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។ ក្នុងករណីផ្សេងទៀត ប្រសិនបើ បុគ្គលដែលខ្វះសមត្ថភាពក្នុងការយល់ដឹងពីលទ្ធផលផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន បុគ្គលនោះ មិនត្រូវធ្វើសកម្មភាពបណ្ដឹងឡើយ (មាត្រា១៧ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង និង មាត្រា១៤ នៃក្រមរដ្ឋប្បវេណី)។

## ៣.២. ការច្រានចោលនូវមធ្យោបាយតទល់ និងការពារខ្លួនសម្រាប់ការដាក់ទៅតុលាការយឺតយ៉ាវ

### ក. ក្រមនីតិវិធីរដ្ឋប្បវេណី

តុលាការអាចច្រានចោលមធ្យោបាយតទល់ និងការពារខ្លួនក្នុងហេតុផលនៃការដាក់មក តុលាការយឺតយ៉ាវបាន (មាត្រា៩៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### ខ.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

តុលាការមិនត្រូវច្រានចោលមធ្យោបាយតទល់ និង ការពារខ្លួនក្នុងហេតុផលនៃការដាក់មក តុលាការយឺតយ៉ាវឡើយ (មាត្រា១៣ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈ បុគ្គល ដកចេញនូវការអនុវត្តមាត្រា៩៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### គ. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

តុលាការមិនត្រូវច្រានចោលមធ្យោបាយតទល់ និងការពារខ្លួនក្នុងហេតុផលនៃការដាក់មក តុលាការយឺតយ៉ាវឡើយ (ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មិនមានមាត្រា ដូចនេះឡើយ ហើយមាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវបានចាត់ទុកថាជាមាត្រាដែល អនុវត្តដូចគ្នានោះទេ នៅក្នុងច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

## ៣.៣. តើតុលាការអាចចេញសាលក្រម ឬដីកាសម្រេចរបស់ខ្លួន ដោយផ្អែកលើអង្គហេតុណាដែល មិនបានសុំពីសំណាក់ភាគីណាមួយបានដែរឬទេ?

### ក. ក្រមនីតិវិធីរដ្ឋប្បវេណី

តុលាការ<u>**មិនអាច**</u>ចេញសាលក្រម ឬដីកាសម្រេចរបស់ខ្លួន ទៅលើអង្គហេតុណាដែលមិន បានសុំពីសំណាក់ភាគីណាមួយបានឡើយ (មាត្រា១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "អង្គហេតុ" ដែលបានលើកឡើងនៅទីនេះមានន័យថា "អង្គហេតុចម្បង" (អាចហៅថា "អង្គហេតុ ផ្ទាល់" ) ហើយមិនរាប់បញ្ចូល "អង្គហេតុប្រយោល" ឡើយ។ ដូច្នេះហើយ តុលាការ<u>**អាចចេញ**</u> សាលក្រមរបស់ខ្លួនទៅលើ<u>**អង្គហេតុប្រយោល**</u>ដែលមិនបានសុំដោយភាគីណាមួយបាន។ សូម

មើលសេចក្ដីពន្យល់ពីក្រមនីតិវិធីរដ្ឋប្បវេណី (នីតិវិធីបណ្ដឹង) គន្ថីទី៣ ជំពូក២ ផ្នែកទី៣ កថាភាគ២ ចំណុចទី១។

**ខ.ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល**

តុលាការ<u>អាច</u>ចេញសាលក្រម ឬសាលដីការបស់ខ្លួន ទៅលើអង្គហេតុណាដែលមិនបានសុំពីសំណាក់ភាគីណាមួយបាន។ ក្នុងករណីនេះ តុលាការត្រូវស្ដាប់ពីទស្សនៈរបស់ភាគីទាក់ទងនឹងអង្គហេតុដូចនេះ (មាត្រា១៩ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

**គ. ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង**

តុលាការ<u>អាច</u>ចេញដីកាសម្រេចរបស់ខ្លួន ដោយផ្អែកលើអង្គហេតុណាដែលមិនបានសុំដោយអ្នកដាក់ពាក្យ ឬ ភាគីម្ខាងទៀតបាន។ ក្នុងករណីនេះ តុលាការត្រូវខិតខំស្ដាប់នូវទស្សនៈរបស់ភាគីទាក់ទងនឹងបណ្ដឹងដូចនេះ (មាត្រា២៧ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

## ៣.៤. ការត្រួតពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់តុលាការ

**ក. ក្រមនីតិវិធីរដ្ឋប្បវេណី**

ប្រសិនបើយល់ឃើញថាមានភាពចាំបាច់ តុលាការ<u>អាច</u>ធ្វើការត្រួតពិនិត្យទៅលើភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន (មាត្រា១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ.ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល**

ប្រសិនបើយល់ឃើញថាមានភាពចាំបាច់ តុលាការ<u>អាច</u>ធ្វើការត្រួតពិនិត្យទៅលើភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន (មាត្រា១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**គ. ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង**

ប្រសិនបើយល់ឃើញថាមានភាពចាំបាច់ តុលាការ<u>ត្រូវ</u>ធ្វើការត្រួតពិនិត្យទៅលើភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន (មាត្រា២៧ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

## ៣.៥. តើតុលាការត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ដែរឬទេ?

**ក. ក្រមនីតិវិធីរដ្ឋប្បវេណី**

តុលាការត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ (មាត្រា១១៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយការធ្វើនេះ ត្រូវបើកចំហជាសាធារណៈ (មាត្រា១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ.នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល**

តុលាការត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ (មាត្រា១១៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) តែការធ្វើនេះមិនចាំបាច់បើកចំហជាសាធារណៈនោះទេ (មាត្រា១៦ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

**គ. ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង**

តុលាការមិនចាំបាច់ធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់នោះទេ (មាត្រា២៨ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

## ៣.៦. ការផ្សះផ្សារលើបណ្ដឹង ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារ

**ក. ក្រមនីតិវិធីរដ្ឋប្បវេណី**

ភាគីអាចបញ្ចប់នីតិវិធីដោយការផ្សះផ្សារលើបណ្ដឹង(មាត្រា២២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារ (មាត្រា២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ.នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល**

ភាគីមិនអាចបញ្ចប់នីតិវិធីដោយការផ្សះផ្សារលើបណ្ដឹង ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារបានឡើយ (មាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដកចេញនូវការអនុវត្តមាត្រា២២០ និង ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**គ. ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង**

ភាគីមិនអាចបញ្ចប់នីតិវិធីដោយការផ្សះផ្សារលើបណ្ដឹង ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារបានឡើយ (ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងមិនមានមាត្រាដែលពាក់ព័ន្ធនឹងការផ្សះផ្សារលើបណ្ដឹង ការបោះបង់ ឬ ការទទួលស្គាល់ការទាមទារនោះទេ)។

## ៤. ករណីសិក្សា

### ៤.១. ការលែងលះ

<u>ករណីទី១</u>៖ X ជាប្ដី Y ជាប្រពន្ធ។ X និង Y បានព្រមព្រៀងលែងលះគ្នា និង ព្រមព្រៀងពីវិធីបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ (មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែមិនអាចព្រមព្រៀងថា អ្នកណាត្រូវមានអំណាចមេបាក្រោយការលែងលះ។ តើពួកគេត្រូវដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង (មាត្រា៩៧៩នៃក្រមរដ្ឋប្បវេណី) ឬ ត្រូវដាក់ពាក្យប្ដឹងលែងលះ (មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី)?

*ចំណុចសម្រាប់ពិចារណា៖*

-ក្នុងករណីបណ្ដឹងលែងលះ តុលាការត្រូវកំណត់រកអ្នកណាម្នាក់ដែលជាអ្នកមានអំណាចមេបា (មាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)

- ក្នុងករណីពាក្យសុំលែងលះដោយការព្រមព្រៀង គឺគ្មានមាត្រាណាមួយនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលអនុញ្ញាតឲ្យតុលាការធ្វើការកំណត់ជនដែលមានអំណាចមេបាឡើយ។

- ប្រសិនបើ គូភាគីបានព្រមព្រៀងលែងលះគ្នា ហើយបានដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង ប៉ុន្តែគូភាគីមិនយល់ព្រម ថាតើអ្នកណាម្នាក់ជាអ្នកត្រូវមានអំណាចមេបាក្រោយការលែងលះនោះ តើតុលាការត្រូវច្រានចោលពាក្យសុំនោះ ឬមួយយ៉ាងណា?

<u>ករណីទី២</u>៖ X ជាប្ដី Y ជាប្រពន្ធ។ X និង Y បានព្រមព្រៀងលែងលះគ្នា និងព្រមថាអ្នកណាជាអ្នកមានអំណាចមេបាក្រោយការលែងលះ ប៉ុន្តែមិនបានព្រមព្រៀងលើវិធីបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ (មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី) លើការបង់ប្រាក់សោហ៊ុយថែទាំកូន និង លើរបៀបចូលជួបប្រាស្រ័យជាមួយកូនទេ (មាត្រា១០៤០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ តើពួកគេត្រូវដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង (មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី) ឬ ត្រូវដាក់ពាក្យប្ដឹងលែងលះ (មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី)?

*ចំណុចសម្រាប់ពិចារណា៖*

- ប្រសិនបើ គូភាគីបានព្រមព្រៀងលើការលែងលះ និង ព្រមលើការកំណត់អ្នកដែលមានអំណាចមេបាក្រោយការលែងលះ តុលាការអាចចេញដីកាសម្រេចលែងលះដោយការព្រមព្រៀង។

- ចំពោះការបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ ការបង់ប្រាក់សោហ៊ុយថែទាំកូន និង របៀបចូលជួបប្រាស្រ័យជាមួយកូន គូភាគីអាចដាក់ពាក្យសុំមួយដាច់ដោយឡែកពីពាក្យសុំលែងលះ (មើលតារាងឧបសម្ព័ន្ធ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

<u>ករណីទី៣</u>៖ X ជាប្ដី Y ជាប្រពន្ធ។ X បានដាក់បណ្ដឹងលែងលះ (មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងអំឡុងពេលនៃនីតិវិធី X និង Y បានព្រមព្រៀងលើចំណុចទាំងអស់រួមមាន ការលែងលះ អំណាចមេបា ការបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ ការបង់ប្រាក់សោហ៊ុយថែទាំកូន និង របៀបចូលជួបប្រាស្រ័យជាមួយកូន។ តើតុលាការត្រូវធ្វើយ៉ាងដូចម្ដេច?

*ចំណុចសម្រាប់ពិចារណា៖*

- នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនមានចែងពីការព្រមព្រៀងផ្សះផ្សារ ឬការទាមទារឲ្យទទួលស្គាល់ឡើយ (មាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

- តុលាការមិនមានការពាក់ព័ន្ធនឹងការព្រមព្រៀងរបស់គូភាគីឡើយ ប៉ុន្តែ តុលាការអាចធ្វើការគិតពិចារណាទៅលើការព្រមព្រៀងនោះបាន។

<u>ករណីទី៤</u>៖ X ជាប្តី Y ជាប្រពន្ធ។ X បានដាក់បណ្តឹងលែងលះ (មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ Y បានបាត់ខ្លួន។ តើតុលាការត្រូវដំណើរការនីតិវិធីយ៉ាងដូចម្តេច?

-ប្រសិនបើមិនដឹងពីកន្លែងស្នាក់នៅរបស់ចុងចម្លើយទេ ក្រលាបញ្ជីអាចបញ្ជូនពាក្យបណ្តឹង និងដីកាកោះហៅ តាមរយៈការផ្សាយជាសាធារណៈបាន (មាត្រា២៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- យោងតាមមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីអវត្តមានរបស់ចុងចម្លើយ តុលាការអាចចាត់ទុកថា ចុងចម្លើយបានសារភាពអង្គហេតុដែលបានលើកឡើងដោយដើមបណ្តឹង ហើយអាចចេញសាលក្រមកំបាំងមុខបាន។ ប៉ុន្តែដោយសារតែ មាត្រា១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដកចេញនូវការអនុវត្តមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការមិនត្រូវចេញសាលក្រមកំបាំងមុខ ក្នុងករណីបណ្តឹងលែងលះឡើយ។ តុលាការត្រូវចេញសាលក្រមមួយដោយផ្អែកលើភស្តុតាងរបស់ដើមចោទ។

<u>ករណីទី៥</u>៖ X និង Y មានទំនាក់ទំនងជាប្តីប្រពន្ធអនីតិសង្វាស ប៉ុន្តែ X ចង់បញ្ចប់ទំនាក់ទំនងរវាងពួកគេ។ X បានដាក់ពាក្យប្តឹងសុំរំលាយអាពាហ៍ពិពាហ៍អនីតិសង្វាស។ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

*ចំណុចសម្រាប់ពិចារណា៖*

- អាពាហ៍ពិពាហ៍អនីតិសង្វាស ត្រូវបានរំលាយនៅពេលដែលទំនាក់ទំនងត្រូវបានបញ្ចប់ ដោយគ្មានការចូលរួមរបស់តុលាការ។ មិនមានភាពចាំបាច់នោះទេ ក្នុងការដាក់ពាក្យបណ្តឹងដើម្បីរំលាយអាពាហ៍ពិពាហ៍អនីតិសង្វាស។ ពាក្យបណ្តឹងដូចនេះ ខ្វះនូវផលប្រយោជន៍នៃបណ្តឹង (មើលមាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង គន្លឹះទី៣ ជំពូក១ កថាភាគទី៣ ផ្នែកទី២ ចំណុច១ នៃសេចក្តីពន្យល់ពីក្រមនីតិវិធីរដ្ឋប្បវេណី (នីតិវិធីនៃសាលក្រម)។

**៩.២. ការបែងចែកមត៌ក**

ករណីទី១៖ A បានទទួលមរណភាព X និង Y ជាសន្តតិជន។ X និង Y បានព្រមព្រៀងលើវិធីនៃការបែងចែកមត៌ក (មាត្រា១២៦៦ នៃក្រមរដ្ឋប្បវេណី) ហើយពួកគេបានបង្កើតកិច្ចព្រមព្រៀងជាលាយល័ក្ខអក្សរទៅលើរបៀបបែងចែកមត៌ក។ ប៉ុន្តែ X បានប្តូរគំនិត ហើយបានដាក់ពាក្យសុំបែងចែកមត៌កទៅកាន់តុលាការ។ Y បានស្នើឲ្យតុលាការច្រានចោលពាក្យសុំនោះ ពីព្រោះពួកគេបានព្រមព្រៀងលើវិធីបែងចែកមត៌កហើយ។ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

| |
|---|
| *ចំណុចសម្រាប់ពិចារណា៖*<br><br>- បើតាមទ្រឹស្តី នៅពេលដែលគ្រប់សន្តតិជនទាំងអស់បានព្រមព្រៀងបែងចែកមត៌ក មត៌កក៏ត្រូវបានបែងចែក ហើយតុលាការមិនអាចបែងចែកមត៌កបានទៀតទេ។<br><br>- មាត្រា១២៧០ នៃក្រមរដ្ឋប្បវេណីនិយាយថា "នៅពេលដែលសហសន្តតិជនមិនអាចឈានដល់កិច្ចព្រមព្រៀង ឬ មិនអាចពិភាក្សាបាន" សហសន្តតិជនអាចដាក់ពាក្យសុំបែងចែកបាន។ នេះមានន័យថា ប្រសិនបើសហសន្តតិជនអាចឈានដល់កិច្ចព្រមព្រៀងទៅលើវិធីក្នុងការបែងចែកមត៌ក ពួកគេមិនអាចដាក់ពាក្យសុំបែងចែកមត៌កបានទៀតនោះទេ។<br><br>- ប្រសិនបើ មានដីនៅក្នុងចំណោមមត៌កទាំងអស់ តើកិច្ចព្រមព្រៀងជាលាយល័ក្ខអក្សរចំពោះការបែងចែកមត៌កត្រូវធ្វើតាមរយៈលិខិតយថាភូត (មាត្រា៣៣៦ កថាខណ្ឌទី២ និង មាត្រា១២៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ឬមួយយ៉ាងណា? |

ករណីទី២៖ A បានទទួលមរណភាព X និង Y ជាសន្តតិជន។ ដោយសារតែ X និង Y មិនអាចឈានដល់កិច្ចព្រមព្រៀងទៅលើការបែងចែកទ្រព្យសម្បត្តិបាន X បានដាក់ពាក្យសុំបែងធ្វើការចែកមត៌ក (មាត្រា១២៧០ នៃក្រមរដ្ឋប្បវេណី) ទៅកាន់តុលាការ។ នៅអំឡុងពេលដំណើរការនីតិវិធី X និង Y បានព្រមព្រៀងលើរបៀបបែងចែកមត៌ក។ ប៉ុន្តែពួកគេមិនដកពាក្យសុំទេ ហើយបន្តទាមទារដីកាសម្រេចរបស់តុលាការទៀត។ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

| |
|---|
| *ចំណុចសម្រាប់ពិចារណា៖*<br><br>- សន្តតិជនទាំងអស់បានព្រមព្រៀងលើវិធីក្នុងការបែងចែកមត៌ក ប៉ុន្តែនៅតែទាមទារដីកាសម្រេចរបស់តុលាការក្នុងការបែងចែកមត៌ក។ តើកិច្ចព្រមព្រៀងនេះមានន័យដូចម្តេច? តើសន្តតិជនបានបែងចែកមត៌កតាមការព្រមព្រៀងដែរឬទេ? ឬ តើពួកគេគ្រាន់តែយល់ព្រមស្នើសុំតុលាការដើម្បីបែងចែកមត៌កតាមរយៈកិច្ចព្រមព្រៀង? |

ករណីទី៣៖ A បានទទួលមរណភាព X និង Y ជាសន្តតិជន។ មានមតកសាសន៍មួយមានខ្លឹមសារថា "X ត្រូវទទួលសន្តតិកម្មជាប្រាក់ Y ត្រូវទទួលសន្តតិកម្មជាដី។" ដោយសារតែ X ចង់បានដី X បានដាក់ពាក្យសុំបែងចែកមត៌កទៅកាន់តុលាការ ហើយទាមទារយកដី។ Y ស្នើសុំទៅតុលាការឲ្យច្រានចោលពាក្យសុំនោះ ពីព្រោះនៅក្នុងមតកសាសន៍ មានសរសេរយ៉ាងច្បាស់ថា Y ត្រូវទទួលបានដី។ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

*ចំណុចសម្រាប់ពិចារណា៖*

- នៅពេល A ទទួលមរណភាព មតកសាសន៍មានអានុភាព (មាត្រា១១៩៤ នៃក្រមរដ្ឋប្បវេណី)។ នៅពេលដែលមតកសាសន៍មានអានុភាព មត៌កនឹងក្លាយជាកម្មសិទ្ធិរបស់សន្តតិជនម្នាក់ៗដោយស្វ័យប្រវត្តិតាមរយៈមតកសាសន៍ (មាត្រា១១៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ប្រាក់បានក្លាយជាកម្មសិទ្ធិទាំងអស់របស់ X ហើយដីបានក្លាយជាកម្មសិទ្ធិរបស់ Y រួចទៅហើយ។ ពុំមានការបែងចែកមត៌កទៀតឡើយ។

ករណីទី៤៖ A បានទទួលមរណភាព X និង Y ជាសន្តតិជន។ មានមតកសាសន៍មួយមានខ្លឹមសារថា "X ត្រូវទទួលសន្តតិកម្មជាប្រាក់ Y ត្រូវទទួលសន្តតិកម្មជាដី។" ថ្វីត្បិតតែមានមតកសាសន៍ក៏ដោយ X និង Y បានយល់ព្រមថា X ត្រូវទទួលបានដី ហើយ Y ត្រូវទទួលបានប្រាក់ ហើយពួកគេបានធ្វើលិខិតយថាភូតមួយ។ ក្រោយមក X បានប្តូរគំនិត ហើយបានដាក់ពាក្យសុំបែងចែកមត៌កទៅកាន់តុលាការ និងទាមទារយកប្រាក់វិញ។ Y បានស្នើសុំទៅតុលាការឲ្យច្រានចោលពាក្យសុំនោះ ដោយសារតែពួកគេបានព្រមព្រៀងគ្នារួចហើយថា X ត្រូវទទួលបានដី ហើយ Y ត្រូវទទួលបានប្រាក់។ តើតុលាការត្រូវធ្វើយ៉ាងដូចម្តេច?

*ចំណុចសម្រាប់ពិចារណា៖*

-នៅពេល A ទទួលមរណភាព ប្រាក់ត្រូវក្លាយជាកម្មសិទ្ធិរបស់ X ហើយដីក្លាយជាកម្មសិទ្ធិរបស់ Y (មាត្រា១១៩៤ និង ១១៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ការបែងចែកមត៌កមិនអាចប្រព្រឹត្តិទៅបានទៀតឡើយ។ ប្រសិនបើ ក្រោយពី A បានទទួលមរណៈភាព X និង Y បានព្រមព្រៀងថា X ត្រូវទទួលបានដី ហើយ Y ត្រូវទទួលបានប្រាក់ នោះកិច្ចព្រមព្រៀងនេះគួរត្រូវបានបកស្រាយថាជាកិច្ចសន្យានៃការដូរវិញ (មាត្រា៥៦៦ នៃក្រមរដ្ឋប្បវេណី)។

### ៤.៣. ការរំលាយសុំកូនធម្មតា

ករណីទី១៖ X1 និង X2 ជាអ្នកសុំកូនធម្មតា។ Y1 និង Y2 គឺជាឪពុកម្តាយបង្កើត។ Z គឺជាកូនបង្កើតរបស់ Y1 និង Y2 ហើយជាកូនសុំរបស់ X1 និង X2។ ក្រោយពីសុំកូនធម្មតា Y1 និង Y2

ក៏បានលែងលះ។ X1 X2 និង Y1 បានយល់ព្រមរំលាយសុំកូនធម្មតានោះ ហើយ Y1 ចង់ក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ Z នៅក្រោយពេលរំលាយ។ ប៉ុន្តែ Y2 មិនយល់ព្រមឲ្យ Y1 ធ្វើជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ Z នៅក្រោយពេលរំលាយឡើយ។ ឥឡូវនេះ Z មានអាយុ ៨ឆ្នាំហើយ។ តើ X1 X2 និង Y1 ត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីរំលាយសុំកូនធម្មតានោះ?

*ចំណុចសម្រាប់ពិចារណា៖*

- ដោយសារតែកូនសុំគឺជាអនីតិជន នោះអ្នកសុំកូន និង ឪពុកម្ដាយបង្កើត ត្រូវយល់ព្រមចំពោះការរំលាយ ហើយដាក់ពាក្យសុំការរំលាយដោយការព្រមព្រៀង (មាត្រា១០២៨ កថាខណ្ឌទី១ និង ទី២ នៃក្រមរដ្ឋប្បវេណី មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និង តារាងឧបសម្ព័ន្ធផ្នែក៤ ចំណុចទី១០)។ លើសពីនេះទៀត ដោយសារតែឪពុកម្ដាយបង្កើតបានលែងលះគ្នា នោះត្រូវកំណត់ថា ម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវធ្វើជាអ្នកមានអំណាចមេបាចំពោះ Z ក្រោយការរំលាយនោះ (មាត្រា១០២៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ ដោយសារតែ Y1 និង Y2 មិនអាចព្រមព្រៀងលើការកំណត់អ្នកណាម្នាក់ជាអ្នកមានអំណាចមេបាទៅលើ Z ក្រោយការរំលាយ តុលាការត្រូវតែងតាំងបុគ្គលម្នាក់ ជាអ្នកដែលមានអំណាចមេបាលើ Z (មាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី)។

- មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និង តារាងឧបសម្ព័ន្ធ មិនបានសរសេរពីមាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឡើយ។ ប៉ុន្តែ ពាក្យសុំនៃមាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី មានភាពចាំបាច់មុនពាក្យសុំនៃមាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ នៅក្នុងតារាងឧបសម្ព័ន្ធផ្នែក៤ ចំណុចទី១០ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មានសរសេរពីមាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ តើតារាងឧបសម្ព័ន្ធផ្នែក៤ ចំណុចទី១០ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង អាចយកមកអនុវត្តស្រដៀងចំពោះមាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីបានដែរ ឬយ៉ាងណា?